សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មិថុនា ឆ្នាំ ២០១៦

# លីអាហូណា



**របៀបដែលឪពុកប្រទានពរដល់ជីវិតរបស់កូនៗខ្លួន ទំព័រ ៤, ១០**


អ្នកផ្សព្វផ្សាយសាសនានៅក្នុងប្រទេសជប៉ុន បីស្សពជាអធិបតី សាវកថ្មី ៖ អែលឌើរ ហ្គេរី អ៊ី ស្ទីវើនសុន ទំព័រ ១៤

របៀបដែលព្រះគម្ពីរមរមនស្ដារចក្ខុវិស័យខាងវិញ្ញាណឡើងវិញ ទំព័រ ២០

សំណួរចម្លើយទាំង ១៤ អំពីជីវិតបន្ទាប់ ទំព័រ ៣២



*« គេមិនដែលស្រេកឃ្លានទៀត ឯចំហាយក្ដៅឬព្រះអាទិត្យ នឹងមិនធ្វើទុក្ខគេ ដ្បិតព្រះដែលផ្ដល់សេចក្ដីមេត្តាដល់គេ ទ្រង់នឹងនាំគេទៅ អើទ្រង់នឹងដឹកដៃគេនាំទៅតាមទីមានក្បាលទឹក » ។*

នីហ្វៃទី ១ ២១:១០

# លីអាហូណា ខែ មិថុនា ឆ្នាំ ២០១៦



៤


## សារលិខិត

**៤ សារលិខិតគណៈប្រធានទីមួយ ៖ ព្រះវរបិតារបស់យើង អ្នកប្រៀនប្រដៅរបស់យើង**
ដោយ ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ

**៧ សារលិខិតបង្រៀនសួរសុខទុក្ខ ៖ ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ**

## អត្ថបទពិសេសៗ

**១៤ អែលឌើរ ហ្គែរី អ៊ី ស្ទីវ៉ែនសុន ៖ ដួងចិត្តដែលមានការយល់ដឹង**
ដោយ អែលឌើរ រ៉ូបឺត ឌី ហែល
*អែលឌើរ ស្ទីវ៉ែនសុន បម្រើដោយដួងចិត្តយល់ដឹងពីការបំផុសមកពីព្រះវិញ្ញាណ ពរជ័យនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ និង សមត្ថភាពរបស់សាសនាចក្រដើម្បីប្រទានពរដល់ជនទ័លក្រ ។*

**២០ ភ្នែករបស់មនុស្សខ្វាក់នឹងមើលឃើញ**
ដោយ អែលឌើរ លីន ជី រ៉ូប៊ីន
*ព្រះគម្ពីរមរមនជាសាក្សីផ្ទាល់ភ្នែកទីពីរអំពីព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អដ៏រុងរឿងរបស់ទ្រង់ ។*

**២៦ អព្ភូតហេតុទាំងប្រាំពីរនៅក្នុងដំណើរជីវិត**
ដោយ អ៊ីហ្វ្រែម ស្ម៊ីធ
*ដំណើរជីវិតរបស់ខ្ញុំ គឺចាប់ផ្ដើមពីក្មេងកំព្រាខ្សត់ខ្សោយ ទៅជាអ្នកផ្សព្វផ្សាយសាសនាចក្របម្រើព្រះអម្ចាស់ដែលជាអព្ភូតហេតុដ៏ធំពេកក្រៃ ។*

**២៨ *ចូរមកតាមខ្ញុំ* ៖ ការបង្រៀន មូលដ្ឋានគ្រឹះនៅក្នុងគេហដ្ឋាន**
ដោយ អាលីសា ស្ដានថុន និង ណាថាលី ខេមបែល
*គំនិតយោបល់សម្រាប់ការរៀនសូត្រ ជាក្រុមគ្រួសារ អំពីប្រធានបទយុវវ័យប្រចាំខែ ។*

**៣២ តើយើងដឹងអ្វីខ្លះអំពីជីវិតបន្ទាប់ពីសេចក្ដីស្លាប់ ?**
ដោយ ដេវីឌ អេ អេដវួដ
*យើងអាចជួយឆ្លើយនឹងសំណួរជាច្រើនអំពីជីវិតបន្ទាប់ពីសេចក្ដីស្លាប់ ដោយសារសេចក្ដីពិតដ៏ច្បាស់ និង ពិសេសៗនៃដំណឹងល្អដែលបានស្ដារឡើងវិញ ។*

**៣៦ ការដកបទពិសោធន៍នៃការផ្លាស់ប្ដូរដួងចិត្ត**
ដោយអែលឌើរ អែតវើត ឌូប
*នៅពេលកូនស្រីរបស់យើងធ្លាក់ខ្លួនឈឺ នោះខ្ញុំដឹងថាដួងចិត្តរបស់ខ្ញុំត្រូវតែផ្លាស់ប្ដូរឲ្យកាន់តែដូចការផ្លាស់ប្ដូររបស់អាលម៉ា ។*

## ផ្នែកនានា

**៨ អ្វីដែលយើងជឿ ៖ យើងជឿលើការធ្វើតាមព្យាការី**

**១០ គេហដ្ឋានរបស់យើង ក្រុមគ្រួសាររបស់យើង ៖ គំរូនៃសេចក្ដីស្រឡាញ់របស់ឪពុកខ្ញុំ**
ឈ្មោះត្រូវបានដកចេញ

**១២ តន្ត្រី ៖ សូមមករកទ្រង់**
ដោយ ជេអូឌ័រ អ៊ី យើធីស និង ហូហ្គ ដបិលយូ. ឌូហ្គល

**៤០ ការគិតពិចារណា ៖ ជយោ !**
ដោយ ជី ហ្វ្រេក ឃីសើរ

**៤១ ការបម្រើនៅក្នុងសាសនាចក្រ ៖ គ្មានរឿងបែបនោះកើតឡើងឡើយ !**
ដោយ ប្រេត ជេ ផតទើរ

**៤២ សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**៨០ លុះត្រាជួបទៀត ៖ មូលហេតុ និង របៀប ព្រមទាំងអ្វីដែលត្រូវថ្លែងទីបន្ទាល់**
ប្រធាន ស្ពែនសើរ ដបុលយូ ឃីមបឹល



**នៅលើក្របមុខ**
ខាងមុខ ៖ រូបថត ដោយ ខូឌី បែល ។ ខាងក្នុងក្របមុខ ៖ រូបថតដកស្រង់មកពី iStock/Thinkstock ។ ខាងក្នុងក្របខាងក្រោយ ៖ រូបថតដោយ លេសលី នីលស៊ុន ។

| ## យុវមជ្ឈិមវ័យ | ## យុវវ័យ | ## កុមារ |
|---|---|---|

## យុវមជ្ឈិមវ័យ





**៤៦ ការតស៊ូស៊ិតស្វាញ និង ភាពជាសិស្ស**
ដោយ អែលឌើរ ដាវីឌ ហ្វៃ អ៊ីវីនស៍
*យើងត្រូវមានការតស៊ូស៊ិតស្វាញ ដើម្បីក្លាយជាកូនសិស្សពិតរបស់ព្រះអង្គសង្គ្រោះ ហើយសម្រេចបាននូវគោលដៅល្អពិតៗ ដែលព្រះវរបិតាសួគ៌របស់យើងជ្រាបថា យើងត្រូវការសម្រេចឲ្យបានដើម្បីរៀបចំសម្រាប់ភាពអស់កល្បជានិច្ច ។*

**៥០ ជើងឯកនៃថ្ងៃឈប់សម្រាក**
ដោយ សាមែនថា ម៉ាក់ហ្វៃដយិន
*នោះជាជម្រើសរបស់យើង ៖ ថាតើយើងអាចលេងនៅថ្ងៃអាទិត្យ ហើយព្យាយាមក្លាយជាជើងឯកថ្នាក់ជាតិ ឬ យើងអាចបោះបង់ការប្រកួត ហើយរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។*


## យុវវ័យ


**៥២ ផ្នែកដ៏លំបាកបំផុត នៃការធ្វើជាអ្នកផ្សព្វផ្សាយសាសនា**
ដោយ វេនឌី អ៊ុលរីធ
*អ្នកបានអានព្រះគម្ពីរមរមន និង ប្រកាសដំណឹងល្អរបស់យើង ។ តើអ្នកដឹងពីរបៀបនិយាយជាមួយមនុស្សប្លែកមុខ និង ប្រឈមមុខនឹងការបដិសេធពីគេដែរឬទេ ? ចូរដុសខាត់ជំនាញមួយផ្សេងទៀតដែលអ្នកនឹងត្រូវការក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ។*

**៥៧ ទីកន្លែងរបស់យើង**

**៥៨ ចេញមកពីតំបន់បេសកកម្ម ៖ មនុស្សម្នាក់ដែលស្រេកអំពាវនាវ**
ដោយ ស្ទេផាន ឌូឌែល
*គាត់ហាក់បីដូចជាព្រួសរាយ ពិបាកនិយាយជាមួយ គួរឲ្យខ្លាច ។ ប៉ុន្តែគាត់ពិតជាមនុស្សម្នាក់ដែលត្រូវការចម្លើយអស់កល្បជាច្រើន ។*

**៦១ ចម្លើយមកពីថ្នាក់ដឹកនាំសាសនាចក្រ ៖ របៀបជួយអ្នកផ្សព្វផ្សាយសាសនា**
ដោយអែលឌើរ ដាវីឌ អេ បែដណា

**៦២ សំណួរ និង ចម្លើយ**
*ឪពុកម្ដាយរបស់ខ្ញុំប្រើពាក្យជេរ ស្ដាប់ចម្រៀងពុខ្លាំងៗ និង មើលកម្មវិធីទូរទស្សន៍ដែលមិនសមរម្យ ។ តើខ្ញុំអាចធ្វើអ្វីដើម្បីមានអារម្មណ៍ពីព្រះវិញ្ញាណនៅផ្ទះ ជាពិសេសនៅថ្ងៃអាទិត្យ ?*

**៦៤ របៀបធ្វើជាមិត្តភក្តិល្អ**
ដោយ ដេវីឌ ម៉ូរ៉ែល
*យើងទាំងអស់គ្នាចង់បានមិត្តភក្តិ ។ នេះគឺជាវិធីមួយចំនួនដើម្បីធ្វើជាមិត្តភក្តិល្អ និង មានភាពសាមគ្គីផងដែរ ។*


## កុមារ





**៦៦ កុមារដែលឈរយ៉ាងរឹងមាំ ៖ ការពារអ្វីដែលត្រឹមត្រូវ**
ដោយ អាស៊ី តាន

**៦៨ ដៃគូសិក្សារបស់យ័រដាន់**
ដោយ យើស៊ីន អ៊ីត
*យ័រដាន់ពុំដឹងថាត្រូវធ្វើអ្វីឡើយប្រសិនបើគ្មានដៃគូសិក្សាព្រះគម្ពីរមរមនរបស់គាត់នោះ ។ ប៉ុន្តែក្រោយមក គាត់មានគំនិតមួយ !*

**៧០ គ្រប់គ្រឿងសឹករបស់ព្រះ**
*តើមានកិច្ចការអ្វីខ្លះដែលអ្នកអាចធ្វើដើម្បីរក្សាវិញ្ញាណរបស់អ្នកឲ្យមានសុវត្ថិភាព និង រីករាយ ?*

**៧២ ចម្លើយមកពីសាវក ៖ តើយើងសន្យាអ្វីខ្លះនៅពេលធ្វើពិធីបុណ្យជ្រមុជទឹក ?**
ដោយ អែលឌើរ នែល អិល អាន់ឌើរសិន

**៧៣ ទំព័ររបស់យើង**

**៧៤ វិរៈបុរសក្នុងព្រះគម្ពីរមរមន ៖ អ័ប៊ីសជាអ្នកផ្សាយសាសនា**

**៧៥ ខ្ញុំអាចអានព្រះគម្ពីរមរមន**

**៧៦ រឿងចេញពីព្រះគម្ពីរមរមន ៖ អាលម៉ាបង្រៀនរបៀបអធិស្ឋាន**

**៧៩ ទំព័រផាត់ពណ៌ ៖ ខ្ញុំអាចមានគារវភាព**





*ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើអ្នកអាចអធិស្ឋាននៅកន្លែងណា ?*

**ខែ មិថុនា ឆ្នាំ ២០១៦ ភាគទី ៤០ លេខ ៦**
**លីអាហូណា ១៣២៨៤ 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេស្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អិម. រ័សុល បាឡឺដ, រ៉ូប៊ឺត ឌី ហេល, ជែហ្វ្រី អ័រ ហូឡិន, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវែនសុន, ឌែល ជី បេនឡាន់

**អ្នកកែសម្រួល ៖** យ៉ូសែប ដបុលយូ. ស៊ីតាទី
**ជំនួយការអ្នកកែសម្រួល ៖** ជេមស៍ ប៊ី ម៉ាទីណូ, ខារ៉ូ អេហ្វ ម៉ាកខន់ឃី
**អ្នកប្រឹក្សា ៖** ប្រេន ខេ អាស្តុន, បេនដល យេ ប៊ិនណ្ណិត, ក្រេក អេ ខារដុន, ឆារិល អេ អេសព្លិន, គ្រីស្តូហ្វែល ហ្គូលឌិន, ដូហ្គ្លាស ឌី ហូលមែស, ឡែរី អរ ឡរិន, ខារ៉ូល អិម ស្ទេហ្វិន

**នាយកគ្រប់គ្រង ៖** ភីធើរ អេហ្វ អ៊ីវ៉ាន
**នាយកគ្រប់គ្រងប្រតិបត្តិការ ៖** វិនសិន អេ វ៉ូន
**នាយកគ្រប់គ្រងទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយបិហ្គ
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន
**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ វ៉ាល ចនសុន
**ជំនួយការការគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ាយអិន ខា
**ជំនួយការបោះពុម្ព ៖** មេហ្គែន វើរហើរ
**និពន្ធ និងកែសម្រួលដោយ ៖** ប្រ៊ីតថានី ប៊ីតធី, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាថាយ ឌី ហ្វ៊ីតតុន, ឡារី ហូលើរ, ហ្គារេត អេច ហ្គាហ្វ, ឡាប៉ែន ផតទើរ ហ្គាន, ជីល ហាកឃីង, ឆាលឡុត ឡាកាបាល់, ម៉ៃឃល អរ ម៉ូរីស, សាលី ចនសុន អូដេឃីក, យ៉ូស្វេ ជេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី អាន សេលូ, ប៉ុល វ៉ាន់ឌិន បើហ្គ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កុត នូដសិន
**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ថែដ អ័រ ភីធើរសុន
**រចនាប្លង់ដោយ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, មែនឌី ប៊ិនថ័លី, ស៊ី ឃីមបឹល បុត, ថូម៉ាស ឆាល, ណាត ហ្គីនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រ៊ីន, ស្កុត អិម ម៉ូយ, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ នីកូល វ៉ែកឃិនហូស៍
**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលេត នេបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខន្នី ប៊ិរទូប ប្រ៊ីច, ជូលី ប៊ឺដេត, ខេទី ដានខាន, ប្រែអិន ដ័បុលយូ ជីជី, ដិន្នីស ខឺប៊ី, ជីន្នី ជេ នីលសុន, ហ្គែល ធេត វ៉ាហ្វធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** គ្រេហ្គ ខេ សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្ទីវិន អ័រ គ្រីស្ទានសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬសាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ *Liahona,* Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយគ្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុំណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2016 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
June 2016 Vol. 15 No. 3. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# យោបល់នានាសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ពីរ ។*



**« អ្វីដែលយើងជឿ »** ទំព័រ ៨ ៖ អត្ថបទនេះបង្រៀនថា « នៅពេលយើងគាំទ្រដល់ព្យាការី និង ពួកសាវក នោះយើងទទួលបានទីបន្ទាល់មួយអំពីពួកលោកថាជាអ្នកបម្រើរបស់ព្រះ » ។ អ្នកអាចបង្កើនទីបន្ទាល់របស់អ្នកអំពីព្យាការី ដោយការអាន និង ការស្ដាប់សុន្ទរកថាសន្និសីទទូទៅ ។ សូមគិតពីការអានសុន្ទរកថាថ្មីៗនេះរបស់ប្រធានម៉នសុនជាគ្រួសារ ហើយជ្រើសរើសយកការទូន្មានជាក់លាក់មួយរបស់លោក ដើម្បីរស់នៅតាមការទូន្មាននោះ ។ នៅពេលអ្នករស់នៅតាមអ្វីដែលព្យាការីបានស្នើសុំ សូមព្យាយាមសម្គាល់មើលថាតើអ្នកទទួលពរជ័យតាមរបៀបណា ។

**«*ចូរមកតាមខ្ញុំ* ៖ ការបង្រៀនពីមូលដ្ឋានគ្រឹះនៅគេហដ្ឋាន »** ទំព័រ ២៨ ៖ ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃីមបឹល ( ឆ្នាំ ១៨៩៥–១៩៨៥ ) បានបង្រៀនថា « ភាពជោគជ័យរបស់យើងម្នាក់ៗ និង សាសនាចក្រទាំងមូលនឹងត្រូវបានកំណត់យ៉ាងខ្លាំងទៅលើរបៀបដែលយើងផ្ដោតចិត្តទុកដាក់យ៉ាងស្មោះត្រង់លើការរស់ នៅតាមដំណឹងល្អនៅគេហដ្ឋាន » ។ សូមគិតពីការសិក្សាប្រធានបទមួយនៃ *ចូរមកតាមខ្ញុំ* ជាមួយគ្រួសាររយៈពេលមួយខែ ។ អ្នកអាចសិក្សាពីកត្តាចាំបាច់នានានៃប្រធានបទដែលអ្នកបានជ្រើសរើសរៀងរាល់សប្ដាហ៍ ដោយប្រើព្រះគម្ពីរ ឬ ជំនួយសិក្សាផ្សេងទៀតដូចជា *ប្រកាសដំណឹងល្អរបស់យើង* គេហទំព័រ LDS.org សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ និង *The Life of Christ Bible Videos* ( វីដេអូព្រះគម្ពីរប៊ីបអំពីជីវប្រវត្តិរបស់ព្រះគ្រីស្ទ )។ នៅក្នុងរាត្រីជួបជុំក្រុមគ្រួសាររៀងរាល់សប្ដាហ៍ អ្នកអាចចែកចាយពីអ្វីដែលអ្នកបានរៀន និង បានទទួលអារម្មណ៍ ។ សូមគិតពីការកត់ត្រាទុកនូវគំនិត និង ការបំផុសនានានៅក្នុងសៀវភៅកំណត់ហេតុសិក្សាមួយ ហើយចែកចាយអ្វីដែលអ្នកបានរៀនជាមួយមិត្តភក្ដិរបស់អ្នកតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ។

## មានធនធានជាច្រើនទៀតនៅលើអ៊ិនធើរណែត

*លីអាហូណា* និង ធនធានផ្សេងៗទៀតរបស់សាសនាចក្រ មានជាច្រើនភាសានៅលើគេហទំព័រ **languages.lds.org** ។ សូមមើលគេហទំព័រ **facebook.com/liahona.magazine** ( ដែលមានជាភាសាអង់គ្លេស ភាសាព័រទុយហ្គាល់ និង ភាសាអេស្ប៉ាញ ) ដើម្បីរកសារលិខិតដ៏បំផុសគំនិតនានា គំនិតសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ និង ឯកសារដែលអ្នកអាចចែកចាយជាមួយមិត្តភក្ដិ និង គ្រួសាររបស់អ្នក ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយគឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទនោះ ។*

***ការគោរពប្រតិបត្តិ,*** *៨, ២៨, ៧០*
***ការតស៊ូស៊ូទ្រាំ***
***ការតស៊ូស្វិតស្វាញ,*** *៤៦*
***ការបង្រៀន,*** *២៨, ៤៣*
***ការបន្ទាបខ្លួន,*** *៥២*
***ការបម្រើ,*** *៤១*
***ការប្រែចិត្តជឿ,*** *៣៦*
***ការអធិស្ឋាន,*** *១២, ៥៨, ៦១, ៦៦, ៧៦*
***កិច្ចការផ្សព្វផ្សាយសាសនា,*** *៥២, ៥៨, ៦១, ៧៤*
***កិច្ចការព្រះវិហារបរិសុទ្ធ,*** *៧*
***ក្រុមគ្រួសារ,*** *១០, ២៨, ៣៦, ៤៣, ៤៤, ៦២*
***ខ្លួនទីពឹងខ្លួន,*** *២៨*
***គារវភាព,*** *៧៩*
***គោលដៅ,*** *៤៦*
***ដង្វាយធួន,*** *៣៦*
***ថ្ងៃឈប់សម្រាក,*** *៤៥, ៥០, ៦២*
***ទីបន្ទាល់,*** *៨០*
***បព្វជិតភាពអើរ៉ុន,*** *៤១*
***ផែនការនៃសេចក្ដីសង្គ្រោះ,*** *៣២, ៥៨*
***ពិធីបរិសុទ្ធ,*** *៧, ២៨*
***ពិធីបុណ្យជ្រមុជទឹក,*** *៧២, ៧៣*
***ពិធីសាក្រាម៉ង់,*** *៤០*
***ព្យាការី,*** *៨, ៤២, ៤៤*
***ព្រះគម្ពីរប៊ីប,*** *២០*
***ព្រះគម្ពីរមរមន,*** *២០, ៥៧, ៦៨, ៧៤, ៧៥*
***ព្រះដ៏ជាព្រះវរបិតា,*** *៤*
***ព្រះយេស៊ូវគ្រីស្ទ,*** *១២, ២៨, ៤០*
***ព្រះវិហារបរិសុទ្ធ,*** *៤៤, ៧៣*
***ភាពជាសិស្ស,*** *៤៦*
***ភាពជាឪពុក,*** *៤, ១០*
***មិត្តភាព,*** *៦៤*
***យុវវ័យ,*** *៤១*
***សេចក្ដីជំនឿ,*** *៣៦, ៤៦, ៧៥*
***សេចក្ដីសញ្ញា,*** *៧, ២៨, ៧២*
***អព្ភូតហេតុ,*** *២៦*
***អាពាហ៍ពិពាហ៍,*** *២៨*
***ឥរិយាបថ,*** *៥២*



ដោយ ប្រធាន ឌៀថើរ
អេស្វ អុជដូហ្វ
ទីប្រឹក្សាទីពីរក្នុង
គណៈប្រធានទីមួយ

# ព្រះវរបិតារបស់យើង
## អ្នកប្រៀនប្រដៅរបស់យើង

តើអ្នកធ្លាប់បើកប្រអប់មួយ ហើយទាញយកសេចក្ដីណែនាំដំឡើងឧបករណ៍នោះ ហើយគិតថា « សេចក្ដីណែនាំនេះមើលមិនយល់ទាល់តែសោះ ? » ពេលខ្លះ ទោះបីជាយើងមានចេតនា និង មានទំនុកចិត្តក្នុងខ្លួនយ៉ាងល្អបំផុតក្ដី យើងបានដកផ្នែកមួយចេញមក ហើយសួរថា « តើផ្នែកនេះសម្រាប់ធ្វើអ្វី ? » ឬ « តើដាក់យ៉ាងដូចម្ដេចទើបត្រឹមត្រូវ ? »

យើងខកចិត្តខ្លាំងឡើងៗ នៅពេលយើងមើលប្រអប់នោះ ហើយឃើញថា មានក្រដាសព្រមានមួយដែលនិយាយថា « ការដំឡើងនេះតម្រូវឲ្យមនុស្ស—អាយុចាប់ពី៨ឆ្នាំឡើងទៅ » ។ ដោយសារយើងនៅតែគ្មានតម្រុយ នោះសេចក្ដីណែនាំនេះពុំបានបង្កើនទំនុកចិត្តរបស់យើង ឬ ការផ្ដល់តម្លៃដល់ខ្លួនឯងឡើយ ។

ពេលខ្លះយើងមានបទពិសោធន៍ស្រដៀងគ្នានេះជាមួយដំណឹងល្អ ។ នៅពេលយើងក្រឡេកមើលទៅផ្នែកមួយចំនួននៃដំណឹងល្អ យើងប្រហែលជាយកដៃអេះក្បាលខ្លួន ហើយឆ្ងល់ថាតើផ្នែកនោះសម្រាប់អ្វី ។ ឬ នៅពេលយើងពិនិត្យមើលផ្នែកផ្សេងទៀត យើងអាចដឹងថា ទោះបីជាបន្ទាប់ពីការខំព្យាយាមយល់ពេញលេញពីវាក្ដី យើងនៅតែពុំយល់ពីមូលហេតុដែលផ្នែកនោះត្រូវបានដាក់បញ្ចូលមកឡើយ ។

### ព្រះវរបិតាសួគ៌របស់យើងគឺជាអ្នកប្រៀនប្រដៅយើង

សំណាងល្អ ព្រះវរបិតាសួគ៌របស់យើងបានប្រទាននូវសេចក្ដីណែនាំដ៏អស្ចារ្យសម្រាប់ការរៀបចំជីវិតរបស់យើង ហើយអាចប្រែកាន់តែល្អបំផុត ។ សេចក្ដីណែនាំទាំងនោះដំណើរការទៅបានដោយគ្មានគិតពីអាយុ ឬ កាលៈទេសៈអ្វីឡើយ ។ ទ្រង់បានប្រទានដំណឹងល្អ និង សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដល់ពួកយើង ។ ទ្រង់បានប្រទានផែនការប្រោសលោះ ផែនការនៃសេចក្ដីសង្គ្រោះ ដែលជាផែនការនៃសុភមង្គល ។ ទ្រង់ពុំទុកយើងឲ្យនៅឯកោជាមួយនឹងភាពមិនប្រាកដប្រជា ឬ ឧបសគ្គនានានៃជីវិតនេះដោយមានបន្ទូលថា « ចូរឯងទៅចុះ ។ ចូរឲ្យមានសំណាងល្អ ។ ដោះស្រាយខ្លួនឯងចុះ » ។

ប្រសិនបើយើងគ្រាន់តែអត់ធ្មត់ ហើយមើលដោយមានចិត្តបន្ទាបខ្លួន ព្រមទាំងបើកគំនិត នោះយើងនឹងរកឃើញថាព្រះបានប្រទានឧបករណ៍ជាច្រើនដល់យើងដើម្បីយល់បានកាន់តែប្រសើរឡើង អំពីសេចក្ដីណែនាំដ៏ធំធេងរបស់ទ្រង់សម្រាប់សុភមង្គលរបស់យើងនៅក្នុងជីវិត ៖

- ទ្រង់បានប្រទានដល់យើងនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដែលពុំអាចកាត់ថ្លៃបាន ដែលមានសក្ដានុពលក្លាយជារបស់ផងយើង អ្នកណែនាំបង្រៀនពីសួគ៌នៅពេលយើងសិក្សាព្រះបន្ទូលរបស់ព្រះ ហើយព្យាយាមពាំនាំគំនិត និង ទង្វើនានារបស់យើងឲ្យស្របទៅនឹងព្រះបន្ទូលរបស់ទ្រង់ ។
- ទ្រង់បានប្រទានឱកាសនិយាយជាមួយទ្រង់២៤ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងមួយសប្ដាហ៍ តាមរយៈការអធិស្ឋានដោយសេចក្ដីជំនឿ និង ការទូលអង្វរដោយស្មោះសរ ។
- ទ្រង់បានប្រទានពួកសាវក និង ព្យាការីសម័យទំនើបនេះដល់ពួកយើង ដែលជាអ្នកបើកសម្ដែងនូវព្រះបន្ទូលរបស់ព្រះនៅក្នុងសម័យយើងនេះ ហើយមានសិទ្ធិអំណាចចងភ្ជាប់ ឬ ផ្សារភ្ជាប់នៅលើផែនដី និង លើឋានសួគ៌ ។
- ទ្រង់បានស្ដារសាសនាចក្ររបស់ទ្រង់ឡើងវិញ—ដែលជាអង្គការមួយនៃពួកអ្នកជឿ ដែលធ្វើការរួមគ្នាដើម្បីជួយគ្នាទៅវិញទៅមក នៅពេលពួកគេធ្វើការសម្រាប់សេចក្ដីសង្គ្រោះរបស់ខ្លួនដោយសេចក្ដីភ័យខ្លាច ញាប់ញ័រ និង ដោយគ្មានក្ដីអំណរ ។[1]
- ទ្រង់បានប្រទានព្រះគម្ពីរដ៏បរិសុទ្ធដល់យើង—ជាព្រះបន្ទូលរបស់ទ្រង់ដែលបានសរសេរទុកសម្រាប់យើង ។
- ទ្រង់បានប្រទានធនធានជាច្រើននៃបច្ចេកវិទ្យាសម័យទំនើបនេះ ដើម្បីជួយយើងនៅក្នុងដំណើរនៃភាពជាសិស្សនេះ ។ ធនធានដ៏អស្ចារ្យជាច្រើនទាំងនេះអាចស្វែងរកបាននៅក្នុងគេហទំព័រ LDS.org ។



ហេតុអ្វីព្រះវរបិតាសួគ៌ប្រទានជំនួយយ៉ាងច្រើនដល់យើង ? ដោយសារទ្រង់ស្រឡាញ់ពួកយើង ។ ហើយដោយសារដូចដែលទ្រង់បានមានព្រះបន្ទូលដោយព្រះអង្គទ្រង់ថា « នេះហើយជាកិច្ចការរបស់យើងនិងសិរីល្អរបស់យើង—គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ។[២]

និយាយម្យ៉ាងទៀតថាព្រះវរបិតាសួគ៌គឺជាព្រះរបស់យើង ហើយព្រះគឺជាអ្នកប្រៀនប្រដៅយើង ។

ព្រះវរបិតាគង់នៅស្ថានសួគ៌ជ្រាបពីសេចក្តីត្រូវការរបស់កូនចៅទ្រង់ជាងអ្នកណាៗទាំងអស់ ។ វាគឺជាកិច្ចការ និង ជាសិរីល្អរបស់ទ្រង់ ដើម្បីជួយយើងជានិច្ចដោយប្រទាននូវធនធានខាងសាច់ឈាម និង ខាងវិញ្ញាណដ៏អស្ចារ្យដល់ពួកយើង ដើម្បីជួយយើងនៅលើមាគ៌ាឆ្ពោះទៅកាន់ទ្រង់វិញ ។

### ឪពុកគ្រប់រូបគឺជាអ្នកប្រៀនប្រដៅ

នៅប្រទេសមួយចំនួនទៀតលើពិភពលោក ឪពុកត្រូវបានគោរពពីសមាជិកគ្រួសារ និង សង្គមនៅក្នុងខែមិថុនា ។ វាតែងតែល្អជានិច្ចដើម្បីគោរពឪពុកម្ដាយរបស់យើង ។ ឪពុកធ្វើកិច្ចការល្អជាច្រើនសម្រាប់គ្រួសារខ្លួន ហើយមានបុគ្គលិកលក្ខណៈគួរឲ្យកោតសរសើរជាច្រើន ។ តួនាទីសំខាន់បំផុតចំនួនពីរដែលឪពុកមាននៅក្នុងជីវិតរបស់កូនៗខ្លួននោះគឺធ្វើជាគំរូល្អ និង ជាអ្នកប្រៀនប្រដៅកូនដ៏ល្អម្នាក់ ។ ឪពុកធ្វើកិច្ចការនានាលើសពីការគ្រាន់តែប្រាប់ដល់កូនៗខ្លួនអំពីអ្វីដែលត្រឹមត្រូវ ឬ ខុសឆ្គងទៅទៀត ពួកគាត់ធ្វើកិច្ចការលើសពីការគ្រាន់តែបោះក្បួនសៀវភៅឲ្យកូន ហើយរំពឹងឲ្យពួកគេដោះស្រាយជីវិតដោយខ្លួនឯងទៅទៀត ។

ឪពុកប្រៀនប្រដៅកូនៗដ៏មានតម្លៃរបស់ខ្លួន ហើយបង្ហាញគំរូល្អរបស់ពួកគាត់តាមរយៈការរស់នៅដោយស្មោះត្រង់ក្នុងជីវិត ។ ឪពុកពុំចាកចេញពីកូនៗរបស់

**ការបង្រៀនចេញពីសារលិខិតនេះ**

អ្នកអាចចាប់ផ្ដើមដោយសួរដល់អស់អ្នកដែលអ្នកបង្រៀន ឲ្យគិតពីគ្រាមួយនៅពេលដែលព្រះវរបិតាសួគ៌បានប្រៀនប្រដៅពួកគេ ។ បន្ទាប់មក អ្នកអាចសុំឲ្យពួកគេគិតអំពីភាពស្រដៀងគ្នារវាងគ្រាទាំងនោះ ទៅនឹងគ្រាណាមួយ ដែលពួកគេមានអារម្មណ៍ថាឪពុករបស់ខ្លួន នៅលើផែនដីនេះបានប្រៀនប្រដៅពួកគេ ។ សូមអញ្ជើញពួកគេឲ្យសរសេរភាពស្រដៀងគ្នានោះនូវរបៀបដែលពួកគេត្រូវបានប្រៀនប្រដៅ ។ អ្នកអាចអញ្ជើញពួកគេឲ្យព្យាយាមត្រងត្រាប់តាមអ្វីៗ ដែលពួកគេបានសរសេរ ដើម្បីធ្វើជាគំរូកាន់តែប្រសើរឡើងដល់មនុស្សដទៃទៀត ។

រូបគំនូរ ដោយ អេឌ្វើដ ស៊ូហ្វ៊ីលប៉ៃ

ខ្លួនឲ្យនៅឯកោឡើយ ប៉ុន្តែរហ័សនឹងជួយកូនៗ ជួយលើកកូនៗរបស់ខ្លួនឡើងភ្លាម នៅពេលណាពួកគេជំពប់ជើងដួល ។ ហើយកិច្ចការឆ្លៀសវៃដែលត្រូវធ្វើនោះ គឺឪពុកអនុញ្ញាតឲ្យកូនជួបនូវការលំបាក ដោយដឹងថានេះអាចជាវិធីមួយដ៏ល្អបំផុត សម្រាប់ឲ្យពួកគេរៀន ។

**យើងទាំងអស់គ្នាគឺជាអ្នកប្រៀនប្រដៅ**

អំឡុងពេលដែលឪពុកនៅលើផែនដីនេះធ្វើកិច្ចការទាំងនេះចំពោះកូនៗរបស់ខ្លួន ស្មារតីនៃការប្រៀនប្រដៅ គឺជាអ្វីមួយដែលយើងចាំបាច់ត្រូវផ្តល់ឲ្យដល់កូនចៅទាំងអស់របស់ព្រះ ដោយមិនគិតពីអាយុ ទីកន្លែង ឬ កាលៈទេសៈណាឡើយ ។ ចូរចងចាំថា កូនចៅរបស់ព្រះគឺជាបងប្អូនប្រុសស្រីរបស់យើង យើងទាំងអស់គ្នាគឺជាគ្រួសារអស់កល្បជានិច្ចតែមួយជាមួយគ្នា ។

នៅក្នុងស្មារតីនេះ ចូរឲ្យយើងទាំងអស់គ្នាក្លាយជាអ្នកប្រៀនប្រដៅ—ដោយមានឆន្ទៈខ្នះខ្នែងជួយ និង ជួយគ្នាទៅវិញទៅមកដើម្បីបានខ្លាំងពូកែ ។ ដោយសារយើងគឺជាពូជពង្សរបស់ព្រះ នោះយើងមានសក្តានុពលដើម្បីប្រែក្លាយដូចជាទ្រង់ ។ ការស្រឡាញ់ព្រះ និង បងប្អូនរបស់យើង ការគោរពព្រះបញ្ញត្តិរបស់ព្រះ និង ការធ្វើតាមគំរូរបស់ព្រះគ្រីស្ទគឺជាផ្លូវតូច ហើយចង្អៀត ព្រមទាំងជាផ្លូវដែលពោរពេញដោយក្តីអំណរត្រឡប់ទៅកាន់វត្តមានរបស់ព្រះមាតាបិតាសួគ៌របស់យើងវិញ ។

ប្រសិនបើព្រះនៃសកលលោកនេះខ្វល់ខ្វាយជាខ្លាំងអំពីយើងនោះ ទ្រង់គឺជាអ្នកប្រៀនប្រដៅយើង ប្រហែលជាយើងអាចឈោងដៃទៅជួយបងប្អូនរបស់យើង ដោយមិនគិតអំពីពណ៌សំបុរ ពូជសាសន៍ ស្ថានភាពសង្គមសេដ្ឋកិច្ច ភាសា ឬ សាសនាឡើយ ។ ចូរឲ្យយើងក្លាយជាអ្នកប្រៀនប្រដៅដ៏បំផុសគំនិត ហើយប្រទានពរដល់ជីវិតនៃមនុស្សដទៃទៀត—ពុំមែនគ្រាន់តែដល់កូនចៅរបស់យើងផ្ទាល់ប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងប្រទានពរដល់កូនចៅទាំងអស់របស់ព្រះនៅទូទាំងពិភពលោកផងដែរ ។ ■

កំណត់ចំណាំ

១. សូមមើល កិច្ចការ ១៣:៥២; ភីលីព ២:១២។
២. ម៉ូសេ ១:៣៩។

កុមារ

## ជំនួយរបស់ព្រះវរបិតាសួគ៌

ដោយសារតែព្រះវរបិតាសួគ៌ស្រឡាញ់យើង នោះទ្រង់បានប្រទានមធ្យោបាយអំណោយទាន ឬ ជំនួយជាច្រើនដល់យើង ។ សូមផ្គូផ្គងអំណោយទាននិមួយៗជាមួយនឹងរូបភាពខាងក្រោមនេះ ។ តើអ្នកអាចប្រើប្រាស់អំណោយទានទាំងនេះ ដើម្បីផ្តល់ពរដល់ជីវិតរបស់អ្នក និង ជីវិតមនុស្សផ្សេងទៀតយ៉ាងដូចម្តេចខ្លះ ?





*សូមសិក្សាអត្ថបទនេះប្រកបដោយការអធិស្ឋាន ហើយព្យាយាមស្វែងរកអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងពី« ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » បង្កើនសេចក្ដីជំនឿរបស់អ្នកទៅលើព្រះ ហើយប្រទានពរដល់អ្នកទាំងឡាយដែលអ្នកមើលថែទាំតាមរយៈការបង្រៀនសួរសុខទុក្ខយ៉ាងដូចម្ដេច ? ចំពោះព័ត៌មានបន្ថែម សូមទស្សនាគេហទំព័រ reliefsociety.lds.org ។*

# ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ



រូបថតនៃព្រះវិហារបរិសុទ្ធក្រុង ណៅវូ រដ្ឋ អ៊ីលលីណយ

គ្រប់ពិធីបរិសុទ្ធទាំងអស់ដែលមានភាពចាំបាច់សម្រាប់សេចក្ដីសង្គ្រោះ និង ភាពតម្កើងឡើងគឺត្រូវបានផ្សារភ្ជាប់មកជាមួយនូវសេចក្ដីសញ្ញាជាមួយព្រះ ។ ស៊ិស្ទើរ លីនដា ខេ ប៊ើតុន ប្រធានសមាគមសង្គ្រោះទូទៅ បានមានប្រសាសន៍ថា « ការធ្វើ និង ការរក្សាសេចក្ដីសញ្ញាមានន័យថា ជាការជ្រើសរើសដើម្បីចងភ្ជាប់ខ្លួនយើងទៅនឹងព្រះបិតាសួគ៌យើង និង ព្រះយេស៊ូវគ្រីស្ទ ។[1]

អែលឌើរ នែល អិល អាន់ឌើរសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « ព្រះអម្ចាស់មានព្រះបន្ទូលថា ‹ នៅក្នុងពិធីបរិសុទ្ធ. . . អំណាចនៃភាពជាព្រះគឺត្រូវបានបង្ហាញចេញមក › ។

« មានពរជ័យពិសេសៗពីព្រះសម្រាប់មនុស្សគ្រប់រូប ដែលធ្វើបុណ្យជ្រមុជទឹក ទទួលព្រះវិញ្ញាណបរិសុទ្ធ និងទទួលទានសាក្រាម៉ង់យ៉ាងទៀងទាត់ » ។[2]

អែលឌើរ អិម រ័សុល បាឡឺដក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់មានប្រសាសន៍ថា « ពេលបុរស និង ស្ត្រីទៅព្រះវិហារបរិសុទ្ធ ពួកគេទាំងពីរនាក់ បានទទួលអំណាចដូចគ្នាដែលជាអំណាចបព្វជិតភាព. . .

. . .បុរស និង ស្ត្រីគ្រប់រូប មានសិទ្ធប្រើប្រាស់អំណាចនេះ សម្រាប់ជាជំនួយក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ។ អស់អ្នកទាំងឡាយណាដែលធ្វើសេចក្ដីសញ្ញាពិសិដ្ឋជាមួយព្រះអម្ចាស់ និង អស់អ្នកទាំងឡាយណាដែលគោរពតាមសេចក្ដីសញ្ញាទាំងនោះ មានសិទ្ធិទទួលបាននូវវិវរណៈផ្ទាល់ខ្លួន ត្រូវបានប្រទានពរដោយការបម្រើរបស់ពួកទេវតា ទាក់ទងជាមួយព្រះ ទទួលបាននូវភាពពោរពេញនៃដំណឹងល្អ ហើយទីបំផុតក្លាយជាអ្នកគ្រងមរតកជាមួយព្រះយេស៊ូវគ្រីស្ទនូវអ្វីៗទាំងអស់ដែលព្រះវរបិតាមាន » ។[3]

### *បទគម្ពីរបន្ថែម*

នីហ្វៃទី ១ ១៤:១៤; គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១៣; ៩៧:៨; ១០៩:២២

### *សូមពិចារណាអំពីសំណួរនេះ*

តើពិធីបរិសុទ្ធ និង សេចក្ដីសញ្ញានៅក្នុងព្រះវិហារបរិសុទ្ធ ពង្រឹង និង ផ្ដល់អំណាចដល់យើងយ៉ាងដូចម្ដេច ?

សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ

### *រឿងពិតដែលបានកើតឡើង*

នៅក្នុងឆ្នាំ ២០០៧ បួនថ្ងៃបន្ទាប់ពីមានការរញ្ជួយដីដ៏ខ្លាំងនៅក្នុងប្រទេសប៉េរូ អែលឌើរ ម៉ាកឹស ប៊ី ណាស្ស នៃពួកចិតសិបនាក់បានជួបប្រធានបេសកកម្ម វីនសេសឡោ ខុនដេ និង ភរិយារបស់លោក ផាមេឡា ។ « អែលឌើរ ណាស្ស បានសួរបងស្រី ខុនដេ ថា តើកូនតូចៗរបស់នាងយ៉ាងម៉េចដែរ ។ នាងបានតបទាំងញញឹមថា តាមរយៈព្រះគុណនៃព្រះពួកគេទាំងអស់មានសុខសុវត្ថិភាពល្អ ។ លោកបានសួរពីផ្ទះរបស់គ្រួសារខុនដេ ។

នាងបានតបដោយសាមញ្ញថា « ‹ វាខ្ទេចខ្ទីអស់ហើយ › ។

. . .អែលឌើរ ណាស្សបានពោលថា « ប៉ុណ្ណឹងហើយ បងស្រីនៅនិយាយទាំងញញឹមទៀត › ។

នាងបានតបថា « មែនហើយ ខ្ញុំបានអធិស្ឋាន ហើយខ្ញុំមានភាពសុខសាន្តក្នុងចិត្ត ។ យើងមានអ្វីគ្រប់យ៉ាងដែលយើងត្រូវការ ។ យើងមានគ្នីគ្នា យើងមានកូនចៅយើង យើងបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ យើងមានសាសនាចក្រដ៏អស្ចារ្យ ហើយយើងមានព្រះអម្ចាស់ ។ យើងអាចសង់ផ្ទះរបស់យើងម្ដងទៀតបានដោយមានជំនួយពីព្រះអម្ចាស់ › ។ . . .

« តើអ្វីទៅជាការធ្វើ និង ការរក្សាសេចក្ដីសញ្ញាជាមួយនឹងព្រះ ដែលប្រទានអំណាចឲ្យយើងញញឹមនៅក្នុងគ្រាដ៏លំបាកដើម្បីកែប្រែទុក្ខព្រួយឲ្យទៅជាជ័យជំនះ. . . ? »

« ប្រភពនោះគឺជាព្រះ ។ សិទ្ធិរបស់យើងដើម្បីប្រើប្រាស់អំណាចនោះគឺតាមរយៈសេចក្ដីសញ្ញារបស់យើងជាមួយទ្រង់ » ។[4]

កំណត់ចំណាំ

១. លីនដា ខេ ប៊ើតុន « អំណាច ក្ដីអំណរ និងក្ដីស្រឡាញ់ក្នុងការរក្សាសេចក្ដីសញ្ញា » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ១១១ ។
២. នែល អិល អាន់ឌើរសិន « Power in the Priesthood » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ទី ៩២ ។
៣. អិម រ័សុល បាឡឺដ « Men and Women in the Work of the Lord » *Liahona* ខែ មេសា ឆ្នាំ ២០១៤ ទំព័រ ៤៨–៤៩ ។
៤. សូមមើល ឌី ថត គ្រីស្តូហ្វឺសិន « The Power of Covenants » *Liahona* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ១៩, ២០–២១ ។

# យើងជឿលើការធ្វើតាមព្យាការី

ដូចជាសាសនាចក្រកាលពីជំនាន់ដើមដែលព្រះយេស៊ូវគ្រីស្ទបានស្ថាបនាឡើងអំឡុងពេលបម្រើនៃជីវិតរមែងស្លាប់របស់ទ្រង់ នោះសាសនាចក្រសព្វថ្ងៃនេះ « ត្រូវបានស្អាងឡើងលើជើងជញ្ជាំងនៃពួកសាវក និងពួកហោរា ហើយព្រះយេស៊ូវគ្រីស្ទនោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក » ( អេភេសូរ ២:២០ ) ។ យើងមានពួកសាវកដប់ពីរនាក់ ព្រមទាំងប្រធានសាសនាចក្រ និង ទីប្រឹក្សារបស់លោក ដែលជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ។ ពួកលោកត្រូវបានហៅដើម្បីថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និង បង្រៀនដំណឹងល្អរបស់ទ្រង់នៅទូទាំងពិភពលោក ។

ព្រះអង្គសង្គ្រោះជ្រើសរើសពួកព្យាការីរបស់ទ្រង់ ហើយរៀបចំពួកលោកឲ្យមានបទពិសោធន៍ជាច្រើនដើម្បីដឹកនាំសាសនាចក្រនេះ ។ នៅពេលសមាជិកសាសនាចក្រនិយាយពាក្យថាព្យាការី គឺពួកគេកំពុងនិយាយសំដៅដល់ប្រធានសាសនាចក្រ ដែលជាបុគ្គលតែម្នាក់គត់នៅលើផែនដីនេះ ដែលអាចទទួលវិវរណៈសម្រាប់សាសនាចក្រទាំងមូល ។

ដោយសារតែប្រធានសាសនាចក្រនិយាយជំនួសព្រះអម្ចាស់ ( សូមមើល គ. និង ស. ១:៣៨ ) វាពុំមែនជារឿងឆ្លៀសវៃដើម្បីគ្រាន់តែរើសយកផ្នែកនានាដែលយើងចង់ធ្វើតាមពីការទូន្មានរបស់លោកឡើយ ។ ផ្ទុយទៅវិញ យើងត្រូវធ្វើតាមការទូន្មាន និងការអញ្ជើញដូចដែលយើងបានទទួលឱវាទទាំងនោះផ្ទាល់ពីព្រះយេស៊ូវគ្រីស្ទ « ដោយសេចក្ដីអត់ធន់ និងសេចក្ដីជំនឿគ្រប់យ៉ាង » ( គ. និង ស. ២១:៥ ) ។

នៅពេលយើងជ្រើសរើសស្ដាប់ និង ធ្វើតាមព្យាការី និង សាវកដទៃផ្សេងទៀត នោះយើងនឹងទទួលពរនៅក្នុងការខិតខំរបស់យើងដើម្បីប្រែក្លាយឲ្យកាន់តែដូចជាព្រះយេស៊ូវគ្រីស្ទ ហើយយើងត្រូវបានការពារពីអសន្តិសុខ ព្រមទាំងសេចក្ដីឆបោករបស់ផងមនុស្ស ( សូមមើល អេភេសូ ៤:១១–១៤ ) ។

ឧទាហរណ៍ យើងរកឃើញសុវត្ថិភាពខាងវិញ្ញាណនៅក្នុងពិភពលោកដែលមានការផ្លាស់ប្ដូរសីលធម៌ និង គុណតម្លៃ តាមរយៈការរស់នៅតាមបែបផែនជីវិតដែលពុំអាចផ្លាស់ប្ដូរបាន ដែលព្យាការីនិង ពួកសាវកបង្រៀន ។ យើងក៏រកឃើញសុវត្ថិភាពខាងសាច់ឈាមនៅក្នុងការធ្វើតាមដំបូន្មានរបស់ព្យាការី ឲ្យចៀសវាងពីបំណុល ចេះសន្សំប្រាក់ និង ស្តុកអាហារទុក ។

ដោយសារប្រធានសាសនាចក្រ និង ពួកសាវកបានថ្វាយពេលវេលានៃជីវិតរបស់ពួកលោកចំពោះកិច្ចការរបស់ព្រះអម្ចាស់—ដោយធ្វើដំណើរជុំវិញពិភពលោកដើម្បីថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទ បង្រៀនពួកបរិសុទ្ធ ហើយគ្រប់គ្រងលើកិច្ចការរដ្ឋបាលនៃសាសនាចក្រទូទាំងពិភពលោក—នោះទ្រង់គាំទ្រ និងប្រទានពរដល់ពួកលោក និង ក្រុមគ្រួសាររបស់ខ្លួន ។ យើងក៏គាំទ្រដល់ពួកលោក នៅពេលយើងអធិស្ឋានសម្រាប់ពួកលោក ធ្វើតាមដំបូន្មានរបស់ពួកលោក ហើយព្យាយាមទទួលបានព្រះវិញ្ញាណបរិសុទ្ធបញ្ជាក់ដល់ពួកយើងអំពីសេចក្ដីពិតដែលពួកលោកបង្រៀន ។

នៅពេលយើងគាំទ្រដល់ព្យាការី និង ពួកសាវក នោះយើងទទួលបានទីបន្ទាល់មួយអំពីពួកលោកថាជាអ្នកបម្រើរបស់ព្រះ ។ ទោះបីជាពួកលោកមិនល្អឥតខ្ចោះក្ដី ព្រះវរបិតាសួគ៌នឹងមិនអនុញ្ញាតឲ្យពួក លោកដឹកនាំយើងឲ្យវង្វេងឡើយ ( សូមមើល ចោទិយកថា ១៨:១៨–២០ ) ។ ■

**ការណែនាំតាមរយៈព្យាការីនៅរស់**



« ព្រះធ្លាប់មានបន្ទូល និងកំពុងបន្តមានបន្ទូលដើម្បីផ្ដល់ការណែនាំដល់កូនចៅទាំងអស់របស់ទ្រង់ តាមរយៈព្យាការីដែលកំពុងនៅរស់សព្វថ្ងៃនេះ ។ ដូចដែលបានសន្យា យើងប្រកាសថា [ ព្រះ ] គង់នៅជាមួយអ្នកបម្រើរបស់ទ្រង់ជានិច្ច ហើយ ដឹកនាំកិច្ចការសាសនាចក្ររបស់ទ្រង់ទូទាំងពិភពលោក » ។

***Teachings of Presidents of the Church: Howard W. Hunter*** ( ឆ្នាំ ២០១៥ ) ទំព័រ ១១៥ ។

អ្នកអាចរៀនបន្ថែមអំពីការធ្វើតាមព្យាការីដោយអាន « Sustaining the Prophets » ( *Liahona* ខែវិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៧៤–៧៦ ) ដោយប្រធាន រ័សុល អិម ណិលសុន ដែលជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

**ទាំងនេះគឺជាពរជ័យដែលយើងបាន ទទួលតាមរយៈការរស់នៅ តាម ព្យាការីដែលកំពុងនៅរស់ ៖**



*ព្យាការី យ៉ូសែប ស្ម៊ីធ ( ឆ្នាំ ១៨០៥–៤៤ ) បានបកប្រែព្រះគម្ពីរមរមន « ដោយ អំណោយទាន និង ព្រះចេស្ដានៃព្រះ » ( សូមមើលបុព្វកថាព្រះគម្ពីរមរមន ) ។ ចាប់តាំងពីការបោះពុម្ពនៅក្នុងឆ្នាំ ១៨៣០ មកគម្ពីរនេះបានប្រទានពរដល់ជីវិតមនុស្ស រាប់លាននាក់ ។*



*នៅឆ្នាំ ១៩៣៦ អំឡុងពេលមានវិបត្តិធ្ងន់ធ្ងរ ប្រធាន ហ៊ីប៊ើរ ចេ គ្រាន្ត ( ឆ្នាំ ១៨៥៦–១៩៤៥ ) បានប្រកាសអំពីកម្មវិធី សុខុមាលភាពរបស់សាសនាចក្រ ។ សព្វថ្ងៃកម្មវិធីនេះជួយ មនុស្សគ្រប់ជំនឿទាំងអស់នៅជុំវិញពិភពលោក ។*



*នៅខែមេសា ឆ្នាំ ១៩៩៨ នៅពេលសាសនាចក្រ មានព្រះវិហារបរិសុទ្ធចំនួន៥១ កំពុង ដំណើរការ នោះប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ ១៩១០–២០០៨ ) បានប្រកាសពីកម្មវិធីមួយ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធតូចៗជាច្រើន ។ ឥឡូវ ព្រះវិហារបរិសុទ្ធទាំងនេះបានប្រទានពរ ដល់សមាជិកសាសនាចក្រពាសពេញពិភពលោក កាន់តែច្រើនឡើងៗ ។*



*ក្នុងឆ្នាំ ១៩១៥ ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ( ឆ្នាំ ១៨៣៨–១៩១៨ ) និង ទីប្រឹក្សារបស់លោកបានអញ្ជើញសមាជិក ទាំងអស់ឲ្យចាប់ផ្ដើមធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។ ក្រុមគ្រួសារ ជាច្រើននៅតែទទួលពរជ័យដ៏មហិមាជាលទ្ធផលដែលបាន សន្យា ។*



*នៅក្នុងឆ្នាំ២០១២ ប្រធាន ថូម៉ាស អេស ម៉នសុន បានប្រកាសពី ការបន្ថយអាយុឲ្យបម្រើជាអ្នក ផ្សព្វផ្សាយសាសនា បុរសមកត្រឹម អាយុ ១៨ ឆ្នាំ ហើយស្ត្រីអាយុ ១៩ វិញ ។ គ្រួសារ និង អ្នកផ្សព្វផ្សាយ សាសនារាប់ពាន់នាក់បានទទួល ពរ តាមរយៈលទ្ធផលនៃការបង្កើន កម្លាំងយ៉ាងច្រើននៃអ្នកផ្សព្វផ្សាយ សាសនា ។*

រូបគំនូរដោយ ជេ បេត ចិបស៊ុន

# គំរូនៃសេចក្ដីស្រឡាញ់របស់ឪពុកខ្ញុំ

ឈ្មោះត្រូវបានដកចេញ

*ឪពុករបស់ខ្ញុំបានបង្ហាញខ្ញុំពីរបៀបឲ្យស្រឡាញ់កូនដែលវង្វេងផ្លូវរបស់ខ្ញុំ ។*

ខ្ញុំបានចូលរួមក្នុងសាសនាចក្រ បន្ទាប់ពីទទួលយកការអញ្ជើញរបស់មិត្តពីរនាក់ឲ្យចូលរៀនថ្នាក់សិក្ខាសាលា ។ ឪពុកម្ដាយរបស់ខ្ញុំគាំទ្រខ្ញុំជានិច្ចចំពោះការសម្រេចចិត្តរបស់ខ្ញុំទទួលបុណ្យជ្រមុជទឹកបម្រើបេសកកម្ម និង រៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ។ ទោះជាយ៉ាងណា ខ្ញុំចាំថា ការឈឺចាប់ដែលខ្ញុំបានទទួល ( ហើយខ្ញុំគិតថា ឪពុកម្ដាយរបស់ខ្ញុំក៏បានទទួលវាដែរ ) ដោយដឹងថាពួកគាត់កំពុងរង់ចាំដោយអំណត់នៅក្នុងបន្ទប់ទទួលភ្ញៀវនៃព្រះវិហារបរិសុទ្ធប្រ្រូវ យូថាហ៍ ខណៈដែលកូនក្រមុំរបស់ខ្ញុំ និងខ្ញុំកំពុងត្រូវបានផ្សារភ្ជាប់ ។

ក្រោយមកពួកយើងមានកូនបួននាក់ ហើយខ្ញុំចាំពីសេចក្ដីអំណរដោយដឹងថា ពួកគេម្នាក់ៗត្រូវបានផ្សារភ្ជាប់នឹងពួកខ្ញុំ ដោយសារពួកគេបានកើតមកនៅក្នុងសេចក្ដីសញ្ញា ។ កូនៗរបស់យើងគឺជាចៅដំបូង ហើយទោះបីជាឪពុកម្ដាយ និង បងប្អូនបង្កើតរបស់ខ្ញុំពុំចូលសាសនាចក្រក្ដី ពួកគេបានរស់នៅយ៉ាងជិតស្និទ្ធជាមួយកូនរបស់ខ្ញុំគ្រប់គ្នា ។ អស់រយៈពេលជាច្រើនមកហើយ យើងបានរស់នៅក្បែរគ្នា ហើយឪពុកម្ដាយរបស់ខ្ញុំបានឃើញកូនៗរបស់យើងចូលសកម្មភាពនៅសាលារៀន និង សកម្មភាពកីឡានានា ។ ពួកគាត់បានចូលរួមគ្រប់ពិធីបុណ្យជ្រមុជទឹករបស់កូនៗពួកខ្ញុំ ។

ប៉ុន្ដែ ដល់ពេលកូនៗរបស់ពួកខ្ញុំពេញវ័យ នោះការចាត់តាំងនៃការងាររបស់ខ្ញុំបានឲ្យគ្រួសាររបស់យើងប្ដូរទីលំនៅទៅរដ្ឋមួយផ្សេងទៀត ។ ប៉ុន្ដែសូម្បីតែនៅក្នុងអំឡុងឆ្នាំទាំងនោះ ឪពុកម្ដាយរបស់ខ្ញុំបន្ដទាក់ទងយ៉ាងជិតស្និទ្ធជាមួយកូនៗរបស់យើងតាមរយៈការមកសួរសុខទុក្ខ និង សរសេរសំបុត្រមកលេងជាញឹកញាប់ ។

នៅពេលឪពុកម្ដាយរបស់ខ្ញុំមានអាយុកាន់តែច្រើន ម្ដាយរបស់ខ្ញុំបានមានជំងឺភ្លេចភ្លាំងស្មារតីមុនអាយុដែលគួរកើត ។ ឪពុករបស់ខ្ញុំបានសម្រេចចិត្តធ្វើជាអ្នកថែទាំម្ដាយរបស់ខ្ញុំយ៉ាងស្មោះត្រង់ បើទោះបីជាជំងឺរបស់គាត់តម្រូវ ឲ្យគេមើលថែទាំគាត់ពេញម៉ោងក្ដី ។ សូម្បីតែប៉ុន្មានឆ្នាំចុងក្រោយនេះ ឪពុករបស់ខ្ញុំបានទាក់ទងមកខ្ញុំជារៀងរាល់សប្ដាហ៍ ហើយមានពេលខ្លះ



*អំឡុងឆ្នាំទាំងនោះ ឪពុកម្ដាយរបស់ខ្ញុំបន្តទាក់ទង យ៉ាងជិតស្និទ្ធជាមួយកូនៗរបស់យើង តាមរយៈ ការមកសួរសុខទុក និង សរសេរសំបុត្រមកលេងជា ញឹកញាប់ ។*



ជារាល់ថ្ងៃ តាមរយៈការទូរសព្ទ និង សំបុត្រ ។ ខ្ញុំមានទំនាក់ទំនងជិតស្និទ្ធជានិច្ចជាមួយឪពុកម្ដាយខ្ញុំទាំងពីរ ប៉ុន្តែអំឡុងពេល ១០ឆ្នាំចុងក្រោយនេះនៃជីវិតរបស់ឪពុកខ្ញុំ យើងបានប្រែកាន់តែស្និទ្ធស្នាលខ្លាំងឡើង ។ ក្រោយមក ខ្ញុំបានដឹងថា គាត់ក៏បានជោគជ័យក្នុងការបង្កើតនូវភាពស្និទ្ធស្នាលជាមួយបងប្អូនបង្កើតទាំងបីនាក់របស់ខ្ញុំ ដូចជារូបខ្ញុំផងដែរ—បើទោះបីជាបានផ្ដល់នូវចំណាប់អារម្មណ៍ និង សេចក្ដីជំនឿផ្សេងៗគ្នាដែលយើងបានជ្រើសរើស នៅពេលពួកយើងទាំងអស់គ្នាកាន់តែចាស់ទៅៗក្ដី ។

ឪពុកម្ដាយ និង គ្រួសាររបស់ខ្ញុំបានរស់នៅផ្នែកម្ខាងទៀតនៃឈូងសមុទ្រសហរដ្ឋអំឡុងឆ្នាំនោះ ហើយពួកគាត់បានធ្វើដំណើរឆ្លងកាត់ប្រទេសចំនួនពីរដើងមកសួរសុខទុក្ខយើង ទោះបីជាជំងឺភ្លេចភ្លាំងស្មារតីរបស់ម្ដាយខ្ញុំបានឈានដល់កម្រិតធ្ងន់ធ្ងរ ដែលធ្វើឲ្យវាពិបាកក្នុងការធ្វើដំណើរតាមយន្តហោះដ៏វែងឆ្ងាយសម្រាប់ឪពុកខ្ញុំក្ដី ។

នៅពេលដំណាលគ្នានោះ កូនៗរបស់ខ្ញុំទាំងអស់បានសម្រេចចិត្តឈប់ចូលរួមព្រះវិហារម្ដងម្នាក់ៗ ។ ទីបំផុតមានកូនប្រុសពីរនាក់របស់ខ្ញុំត្រូវបានលុបឈ្មោះចេញពីកំណត់ត្រាសាសនាចក្រ ។ នេះគឺពិតជាឧបសគ្គដល់ជីវិតប្រពន្ធខ្ញុំ និង រូបខ្ញុំ ។ ហើយទោះបីជាគាត់ពុំមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយក្ដី ឪពុករបស់ខ្ញុំមានការឈឺចាប់ និង ភាន់ភាំងចំពោះការសម្រេចចិត្តរបស់កូនៗពួកខ្ញុំផងដែរ ។ គាត់ជាមនុស្សកាន់សាសនាផ្ទាល់ខ្លួន ហើយបានចូលរួមនឹងពួកយើងដើម្បីអធិស្ឋានក្នុងអំឡុងឆ្នាំទាំងនោះសម្រាប់ពួកគេ ។

នៅក្នុងឆ្នាំ ២០០៥ ឪពុករបស់ខ្ញុំបានចែកឋានទៅ បន្ទាប់ពីធ្វើរោគវិនិច្ឆ័យដឹងថាមានជំងឺមហារីក ហើយម្ដាយរបស់ខ្ញុំបានចែកឋាន តាមក្រោយគាត់បីឆ្នាំបន្ទាប់ ។ ភរិយារបស់ខ្ញុំ និង ខ្ញុំមានក្ដីរីករាយក្នុងការធ្វើពិធីជំនួសសម្រាប់ពួកគាត់នៅក្នុងការធ្វើពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធបន្ទាប់ពីមរណភាពរបស់ពួកគាត់ ។

ខ្ញុំបានអធិស្ឋានជាយូរយារដើម្បីយល់ ពីរបៀបល្អបំផុតដើម្បីប្រាប់កូនៗរបស់យើងឥឡូវនេះថាពួកគេពេញវ័យ ដែលមានកូនខ្លះមានស្វាមីភរិយា និង កូនផ្ទាល់ខ្លួន ដែលគ្មានគេណាម្នាក់ដែលជាពួកអិល. ឌី. អេស.នោះទេ ។ យើងមានភាពជិតស្និទ្ធជាមួយកូនៗទាំងបួននាក់របស់យើង ហើយយើងមានអំណរគុណថា ពួកគេបានទាក់ទងយើងដោយក្ដីស្រឡាញ់ជានិច្ច ។

ទីបំផុតខ្ញុំបានទទួលចម្លើយយ៉ាងច្បាស់ ពីរបៀបដែលខ្ញុំត្រូវដឹកនាំខ្លួនរបស់ខ្ញុំ ពេញមួយជីវិតរបស់ខ្ញុំទាក់ទងនឹងកូនៗពេញវ័យរបស់ខ្ញុំ ។ ខ្ញុំត្រូវតែធ្វើតាមអ្វីដែលឪពុករបស់ខ្ញុំបានធ្វើជាមួយខ្ញុំ ។ បើទោះបីជាយើងរស់នៅផ្សេងគ្នា ហើយមានទស្សនវិស័យខាងសាសនាផ្សេងគ្នាក្ដី ឪពុករបស់ខ្ញុំបានសម្រេចចិត្តមានទំនាក់ទំនងស្និទ្ធស្នាលជាមួយខ្ញុំដូចជាឪពុក និង មិត្តភក្ដិម្នាក់ ខណៈដែលខ្ញុំបានជួបនូវការឈឺចាប់ដោយឃើញកូនៗខ្លួន ជ្រើសរើសបែបផែននៃជីវិត និង ជំនឿផ្សេងពីខ្ញុំក្ដី ។ ខ្ញុំបានដឹងថាខ្ញុំត្រូវធ្វើតាមគំរូរបស់ឪពុកខ្ញុំ ដែលបានបង្រៀនខ្ញុំពីរបៀបប្រព្រឹត្តិចំពោះកូនៗដែលមានជំនឿផ្សេង ៖ ដោយស្រឡាញ់ពួកគេអស់ពីដួងចិត្ត គឺដូចព្រះអង្គសង្គ្រោះស្រឡាញ់មនុស្សទូទៅផងដែរ ។ ■

ខាងឆ្វេង រចនារូបថត © ISTOCK/THINKSTOCK ខាងស្តាំ ៖ រូបថតដោយ ឌែល ប៊ែរសឺន

# សូមមករកទ្រង់

និពន្ធទំនុកច្រៀងដោយ ឌិអូដេក អឺ. ខ៍ធីស
និពន្ធបទភ្លេងដោយ ហ្យូហ្គ ដបិលយូ. ខូហ្គល

ដោយត្រិះរិះពិចារណា ♩ = 80–92






រូបភាព © ISTOCK/THINKSTOCK

# អែលឌើរ ហ្គែរី អ៊ី ស្ទីវែនសុន

## ដួងចិត្តដែលមានការយល់ដឹង



ធំឡើងនៅក្នុងទីក្រុង កាឆេ ខោនធី រដ្ឋ យូថាហ៍ ស.រ.អា. ដែលមានព្រះវិហារបរិសុទ្ធ លូហ្គែន យូថាហ៍ នៅក្បែរ ( សូមមើលទំព័រម្ខាងទៀត ) ហ្គែរី ស្ទីវែនសុន បានរៀនមេរៀនជាច្រើនមកពីការបង្រៀនរបស់ឪពុក និង ម្ដាយលោក ។ ឪពុករបស់លោកបានបង្រៀនលោកឲ្យធ្វើតាមព្រះវិញ្ញាណបរិសុទ្ធ ហើយម្ដាយរបស់លោកបានជំរុញឲ្យលោកជ្រើសរើសត្រឹមត្រូវ ។ កាលនៅវ័យជំទង់ លោកបានរៀនថ្លែងអំណរគុណចំពោះការរាប់អាន និង ការបម្រើរបស់កូរ៉ុមបព្វជិតភាពលោក ដែលវាជាផ្នែកមួយនៃការរៀបចំលោកដើម្បីបម្រើនាពេលបច្ចុប្បន្ននេះនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

**ដោយ អែលឌើរ រ៉ូបឺត ឌី ហែល**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

កាលអែលឌើរ ហ្គែរី ស្ទីវែនសុន អាយុប្រហែលជា ១១ ឆ្នាំ ឪពុករបស់លោកបាននាំលោកទៅឡើងភ្នំ ។ លោកចាំថា « ខ្ញុំបានលោតពីថ្មមួយទៅថ្មមួយទៀត នៅមុខឪពុកខ្ញុំ ។ ខ្ញុំចង់ឡើងទៅលើថ្មធំមួយ ហើយមើលចុះមកក្រោម ។ ពេលខ្ញុំកំពុងឡើងទៅកំពូលដុំថ្មនោះ គាត់បានចាប់ខ្សែក្រវ៉ាត់ខ្ញុំ ហើយទាញខ្ញុំចុះក្រោមវិញ ។

‹ តើមានរឿងអ្វី ? › ខ្ញុំបាននិយាយ ហើយគាត់បានឆ្លើយថា ‹ កុំឡើងទៅលើថ្មនោះអី ។ ចូរយើងដើរទៅមុខទៀត › ។ មួយសន្ទុះក្រោយមក នៅពេលយើងមើលចុះទៅក្រោមពីលើផ្លូវដ៏ខ្ពស់នោះ យើងបានឃើញសត្វពស់នៅលើកំពូលថ្មនោះ កំពុងដេកហាលថ្ងៃ ។

ឪពុកខ្ញុំបានពន្យល់ថា « ‹ នោះហើយជាមូលហេតុដែលប៉ាទាញកូនចុះមកវិញ › ។

ក្រោយមកនៅពេលយើងកំពុងធ្វើដំណើរទៅផ្ទះវិញ ខ្ញុំបានដឹងថា គាត់បានរង់ចាំខ្ញុំឲ្យសួរសំណួរ ៖ ‹ តើប៉ាបានដឹងថាសត្វពស់នៅទីនោះដោយរបៀបណា ? › គាត់បាននិយាយថា ‹ ចាំប៉ាបង្រៀនកូនអំពីព្រះវិញ្ញាណបរិសុទ្ធ › ។ យើងបានមានមេរៀនមួយដោយពុំបានត្រៀងទុកអំពីតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធអាចមាននៅក្នុងជីវិតរបស់យើង ៖ អ្នកការពារ ព្រះដ៏ជាជំនួយ និង ជាអង្គដែលថ្លែងទីបន្ទាល់ ។ ឪពុករបស់ខ្ញុំបានចែកចាយថា ‹ នៅក្នុងករណីនេះ ព្រះវិញ្ញាណបរិសុទ្ធបានការពារកូនតាមរយៈប៉ា ។ ទ្រង់បានព្រមានប៉ាឲ្យទាញកូនចុះមកវិញ › » ។

បទពិសោធន៍នេះ ទោះបីជាវាសាមញ្ញក្ដី វាបានជួយអែលឌើរ ស្ទីវែនសុន យល់ថានៅពេលបានទទួលការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នោះពួកគេគប្បីទទួលយក ហើយធ្វើតាម ។



វាជាមេរៀនមួយក្នុងចំណោមមេរៀនជាច្រើនដែលលោកបានរៀនពីឪពុករបស់ខ្លួន ។

### ម្ដាយដ៏ឆ្នើម អ្នកប្រៀនប្រដៅដ៏អស្ចារ្យ

យោងតាមអែលឌើរ ស្ទីវែនសុន ម្ដាយរបស់លោកគឺជាគំរូនៃភាពល្អសុទ្ធសាធ ៖ « ក្ដីរំពឹងចង់បានរបស់គាត់បានជំរុញទឹកចិត្តខ្ញុំ ។ ស្ទើរតែគ្រប់ទង្វើទាំងអស់ដែលខ្ញុំបានធ្វើ គឺផ្អែកទៅនឹងគំនិតខ្ញុំថា ‹ ខ្ញុំពុំចង់ធ្វើឲ្យម្ដាយខ្ញុំអាក់អន់ចិត្តឡើយ › » ។

ទាំងឪពុក និង ម្ដាយរបស់លោកបានពង្រឹងគោលការណ៍ដំណឹងល្អ អំឡុងពេលរាត្រីជួបជុំគ្រួសារ និង សកម្មភាព ឬការជួបជុំផ្សេងៗទៀតរបស់គ្រួសារ ។ « ពួកលោកបានបោះយុថ្កានៃការបង្រៀនដំណឹងល្អនៅក្នុងគេហដ្ឋានរបស់យើង ។ លោកបានមានប្រសាសន៍ថា វាគឺជាមូលដ្ឋានគ្រឹះនៃជីវិតរបស់យើង ។

អ្នកទូន្មានដ៏សំខាន់ផ្សេងៗទៀតក៏បានដឹកនាំលោកផងដែរ ។ « ខ្ញុំចាំកាលពីការប្រជុំបំពាក់បំប៉នមុនៗរបស់ខ្ញុំក្នុងនាមជា អ្នក



មានសិទ្ធិអំណាចទូទៅដែលមានប្រធាន ហិនរី ប៊ី អាវរិង ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ បានផ្ដល់យោបល់ឲ្យយើងធ្វើបញ្ជីនៃមនុស្ស ២០ នាក់ដែលជះឥទ្ធិពលវិជ្ជមានមកលើជីវិតរបស់យើង ។ ខ្ញុំគិតថាមនុស្សគ្រប់គ្នាអាចទទួលបានប្រយោជន៍ពីការធ្វើកិច្ចការនេះ ។ វាជាការបំផុសគំនិតដើម្បីគិតពីមនុស្សល្អៗទាំងអស់ ដែលបានត្រៀមខ្លួនជួយខ្ញុំជាពិសេសកាលខ្ញុំនៅវ័យជំទង់ » ។

**បានរឹងមាំដោយសារគ្រួសារ និង មិត្តភក្តិ**

ហ្គែរី អ៊ី ស្ទីវិនសុន បានកើតនៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៥៥ ហើយត្រូវបានចិញ្ចឹមបីបាច់នៅក្នុងទីក្រុង លូហ្គែន រដ្ឋ យូថាហ៍ ស. រ. អា. ។ ឪពុកម្ដាយរបស់លោក អ៊ីវ៉ាន និង ជេន ហាល ស្ទីវិនសុន មានកូនបួននាក់ ។ ហ្គែរី ជាកូនទីពីរ និងជាកូនប្រុសច្បង ។

« ខ្ញុំមានទំនាក់ទំនងយ៉ាងស្និតស្មួតជាមួយបងប្អូនប្រុសស្រីរបស់ខ្ញុំ ។ បងស្រីរបស់ខ្ញុំ ដេប៊ី រំពឹងឲ្យខ្ញុំធ្វើរឿងត្រឹមត្រូវ ។ ប្អូនៗបង្កើតរបស់ខ្ញុំ ម៉េរីលី និង ដួង រំពឹងថាខ្ញុំនឹងធ្វើជាគំរូដល់ពួកគេ ។ យើងទាំងអស់គ្នាមានអារម្មណ៍ថាមានការទទួលខុសត្រូវរស់នៅដោយសុចរិត ហើយចូលរួមនៅក្នុងសកម្មភាពនានារបស់សាសនាចក្រ » ។ សាច់ញាតិគ្រួសាររបស់លោកក៏រំពឹងចង់បានខ្ពស់ពីលោកផងដែរ ៖ « ឧទាហរណ៍ នៅពេលបងប្រុសជីដូនមួយច្បងរបស់ខ្ញុំបានចេញបម្រើបេសកកម្ម នោះគាត់បានចុះហត្ថលេខាលើក្រដាសប្រាក់ ២ ដុល្លារ ហើយហុចវាឲ្យទៅប្អូនប្រុសជីដូនមួយបន្ទាប់







ទៀត ឲ្យត្រៀមខ្លួនបម្រើ ។ ក្រដាសប្រាក់ ២ ដុល្លារនោះបានហុចបន្តដល់បងប្អូនជីដូនមួយចំនួន ១៦ នាក់ ដែលបានបម្រើបេសកកម្មនៅទូទាំងពិភពលោក ដោយរំឭកគ្នាថាពួកគេរួមសាមគ្គីគ្នានៅក្នុងការបម្រើព្រះអម្ចាស់ » ។

មិត្តភក្តិអ្នកកាន់បព្វជិតភាពក៏ជះឥទ្ធិពលល្អដល់គាត់ផងដែរ ។ លោកមានប្រសាសន៍ថា « ខ្ញុំបានរៀនកាលពីក្មេងនូវអត្ថន័យនៃការទាក់ទងជាមួយកូរ៉ុម ពុំមែនគ្រាន់តែទាក់ទងពួកគេនៅតែថ្ងៃអាទិត្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាក់ទងពួកគេក្នុងនាមជាអ្នកភូមិផងរបងជាមួយ និង នៅក្នុងសាលារៀនផងដែរ ។ ការណ៍នេះបានផ្ដល់នូវការស្គាល់គ្នា ភាពជាការរាប់អានគ្នា ភាពជាបងប្អូននឹងគ្នា ព្រមទាំងការបម្រើ » ។ គាត់បានចាំយ៉ាងច្បាស់ពីការរួមធ្វើដំណើរជាមួយសមាជិកកូរ៉ុមម្នាក់ទៅប្រមូលដង្វាយតមអាហារពីបងស្រីម្នាក់នៅក្នុងវួដ ដែលមានជំងឺសម្រាកនៅផ្ទះ គាត់ពិការភ្នែក ហើយពុំសូវមានប្រាក់ចំណូលច្រើនទេ ។ គាត់បានរំឭកថា « ទោះបី

រូបថតទាំងអស់ដែលបានសិទ្ធិអនុញ្ញាតនៃគ្រួសាររបស់ស្ទីវិនសុន លើកលែងតែបានកត់សម្គាល់ ខាងឆ្វេង ៖ ផ្ទៃ © TUKKATA/ISTOCK/THINKSTOCK
ខាងស្ដាំ ៖ រូបថតព្រះវិហារបរិសុទ្ធ ឡូហ្គែន យូថាហ៍ ដោយតាមៅ ឌីជីថល



ជាស្ថានភាពគ្រួសារគាត់បែបណាក៏ដោយ គាត់តែងតែមានប្រាក់កាក់ថ្វាយជាដង្វាយតមអាហារជានិច្ច » ។



អែលឌើរ ស្ទីវែនសុន បានបម្រើបេសកកម្មពេញម៉ោងនៅក្នុងប្រទេសជប៉ុន ( ខាងក្រោមខាងស្ដាំ ) ហើយបានមានសេចក្ដីស្រឡាញ់កាន់តែខ្លាំងឡើងចំពោះទ្វីបអាស៊ី និង ប្រជាជននៅក្នុងទ្វីបនេះ ។ ពេលលោកត្រឡប់ទៅផ្ទះវិញ លោកបានជួបនឹងអនាគតភរិយារបស់លោក នៅពេលពួកគេចូលរៀននៅក្នុងថ្នាក់វិទ្យាស្ថានជាមួយគ្នា ។ ពួកគេបានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ អៃដាហូ ហ្វល អៃដាហូ ហើយមានកូនប្រុសបួននាក់ ៖ គ្រេក, ប្រាយអែន, ប្រ៊ីត និង ខែល ។ អែលឌើរ ស្ទីវែនសុនមានក្ដីរំភើបយ៉ាងខ្លាំងពេលនិយាយពីភរិយារបស់លោកថាជា « ពន្លឺក្នុងជីវិត និង ជាជីវិតរបស់ខ្ញុំ » ។

**អំណោយទានមួយដែលតម្រូវឲ្យធ្វើការ**

បន្ទាប់ពីចប់វិទ្យាល័យ ហើយបានចូលរៀនមួយរយៈនៅសាកលវិទ្យាល័យយូថាហ៍ស្ទេត អែលឌើរ ស្ទីវែនសុនត្រូវបានហៅឲ្យបម្រើនៅក្នុងបេសកកម្ម ហ្វូគូកា ប្រទេស ជប៉ុន ។ « ខ្ញុំមានអារម្មណ៍ជ្រួលច្របល់អំពីការរៀនភាសាជប៉ុន ។ កង្វល់របស់ខ្ញុំបានបន្តកើនឡើងនៅក្នុងមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ។ ប៉ុន្តែ ប្រហែលជាប្រាំមួយសប្ដាហ៍ក្រោយមក ដោយការអធិស្ឋានស្មោះសរ និង ការព្យាយាមសិក្សាបានធ្វើឲ្យខ្ញុំមានអារម្មណ៍សុខសាន្តថា ព្រះអម្ចាស់នឹងប្រទានដល់ខ្ញុំ ឲ្យរៀនចេះភាសាជប៉ុន ប៉ុន្តែពុំមែនដោយការខ្ជិលច្រអូសឡើយ ។ ការណ៍នេះបានបង្រៀនខ្ញុំថាអំណោយទានខាងភាសាគឺដូចជាសេចក្ដីជំនឿ និង ការងារ ព្រមទាំងគោលការណ៍ដទៃទៀតនៃដំណឹងល្អ ។ បន្ទាប់ពីអ្នកបានព្យាយាមអស់ពីសមត្ថភាពដែលអ្នកអាចធ្វើបាន នោះអ្នកនឹងទទួលបានពរជ័យ » ។

បន្ទាប់ពីបេសកកម្មរបស់លោកមក អែលឌើរ ស្ទីវែនសុន បានបង្កើនក្ដីស្រឡាញ់ចំពោះប្រវត្តិសាសនាចក្រ ការសិក្សាព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្ដីសញ្ញា ព្រមទាំងស្រាវជ្រាវរកទិនានុប្បវត្តិប្រវត្តិសាស្ត្រ និង ពង្សប្រវត្តិ ។ លោកបានចាប់អារម្មណ៍យ៉ាងខ្លាំងលើ យ៉ូសែប ស្ម៊ីធ និង គ្រួសាររបស់លោក គ្រួសារ វិតមើរ អូលីវើរ ខៅឌើរី និង ម៉ាទិន ហារីស ។ លោកបានស្រាវជ្រាវការបកប្រែ និង ការបោះពុម្ពព្រះគម្ពីរមរមនយ៉ាងច្រើន ។

ជាថ្មីម្ដងទៀត លោកបានរៀនថាសេចក្ដីជំនឿ និង ការខិតខំធ្វើការគឺដើរទន្ទឹមគ្នា ។ លោកបានទូន្មានថា « គ្រប់ចម្លើយទាំងអស់ចំពោះសំណួរនៃដំណឹងល្អពុំកើតឡើងភ្លាមៗឡើយ ។ ព្រះអម្ចាស់បានរពឹងចង់ឲ្យយើងអាន សិក្សា ពិចារណា ហើយអធិស្ឋាន ។ ហើយនៅពេលយើងធ្វើការណ៍នេះដោយសេចក្ដីជំនឿ និង បំណងប្រាថ្នាសុចរិត នោះយូរៗទៅសាក្សីដ៏ផ្អែមល្ហែមនឹងកើតមានឡើង » ។

ពេញមួយជីវិតរបស់ខ្លួន លោកធ្លាប់មានអារម្មណ៍ទទួលបានពរជ័យយ៉ាងពិសេស នៅពេលលោកត្រូវបានហៅឲ្យបង្រៀនសាលាថ្ងៃអាទិត្យដល់យុវវ័យ គោលលទ្ធិនៃដំណឹងល្អ និង ថ្នាក់យុវជន ។ ការហៅបម្រើទាំងនោះបានបណ្ដាលឲ្យលោកថ្លែងទីបន្ទាល់ពីអារម្មណ៍ដ៏ជ្រាលជ្រៅរបស់ខ្លួនចំពោះសេចក្ដីពិតនៃព្រះគម្ពីរ ជំនឿបានកើនឡើងតាមរយៈការសិក្សាអស់ពេលជាច្រើនឆ្នាំ ។

កាលនៅសាកលវិទ្យាល័យ យូថាហ៍ ស្ទេត អែលឌើរ ស្ទីវែនសុនបានត្រឡប់ទៅរៀនការគ្រប់គ្រងអាជីវកម្ម និង ទីផ្សារ ។ លោកបានចំណាយពេលយ៉ាងច្រើននៅក្នុងបណ្ណាល័យ ។ « គ្រប់ពេលខ្ញុំបានចូលក្នុងបណ្ណាល័យ នោះមានសញ្ញាមួយដាក់សម្រាប់ស្វាគមន៍ . . . ដែលសរសេរថា ‹ នោះចូរខំឲ្យបានយោបល់ផង › [សុភាសិត ៤:៧] » ។ ខគម្ពីរនេះបានប្រែកាន់តែឆ្លាក់ជាប់ដួងចិត្តរបស់លោក ហើយជាច្រើនឆ្នាំក្រោយមក ខគម្ពីរនោះបានក្លាយជាបាវចនានៃសុន្ទរកថានៃការប្រជុំធម្មនិដ្ឋានមួយដែលបាននិយាយនៅឯសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ។



លោកបានពន្យល់នៅក្នុងសុន្ទរកថានោះថា « *ការយល់ដឹងនេះកើតឡើងតាមរយៈ*ការពឹងផ្អែកលើការសិក្សា និង ការអធិស្ឋានរួមគ្នា ។ នៅពេលយើងទុកចិត្តលើព្រះអម្ចាស់ នោះទំហំនៃការយល់ដឹងកើតឡើងពីទ្រង់ទៅក្នុងដួងចិត្តរបស់យើង » ។[១]

**ស្នេហាកើតចេញពីថ្នាក់វិទ្យាស្ថាន**

អំឡុងពេលរៀនថ្នាក់ព្រះគម្ពីរសញ្ញាចាស់នៅក្នុងថ្នាក់វិទ្យាស្ថានសាសនា លោកបានជួបជាមួយ



ឡេសា ជិន ហ៊ីងលី ដែលប្ដូរមកពីរដ្ឋ កាលីហ្វូញ៉ា មករស់នៅរដ្ឋ អៃដាហូ ហើយក៏ជាសិស្សនៅសាកលវិទ្យាល័យយូថាហ៍ ស្តេត ។ គាត់និយាយទាំងញញឹមថា « គ្រូបង្រៀនបានសុំឲ្យឡេសាដើរតួជានាងអេវ៉ា ហើយឲ្យខ្ញុំដើរតួជាសាតាំងទៅល្បួងនាង ។ ជាលទ្ធផល វាចំណាយពេលអស់យូរក្រៃលែងដែលទំរាំខ្ញុំអាចបញ្ចុះបញ្ចូលនាងឲ្យដើរលេងជាមួយខ្ញុំ » ។ ពួកគេបានដើរលេងជាគូជាងមួយឆ្នាំ ហើយក្រោយមកបានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ អៃដាហូ ហ្វល អៃដាហូ ក្នុងឆ្នាំ ១៩៧៩ ។

អែលឌើរ ស្ទីវែនសុនមានក្ដីរីករាយយ៉ាងខ្លាំងពេលនិយាយពីឡេសា ។ លោកបាននិយាយអំពីនាងថាជា « ពន្លឺក្នុងជីវិត និង ជាជីវិតរបស់ខ្ញុំ » ។[២] ស៊ិស្ទើរ ស្ទីវែនសុនបានបញ្ចប់ការសិក្សាដោយទទួលបានសញ្ញាបត្រអប់រំផ្នែកសេដ្ឋកិច្ចក្នុងស្រុក បានបង្រៀននៅសាលាកាលពួកគេទើបតែបានរៀបការរួច ហើយនៅតែបន្តចំណាយពេលវេលា និង ទេពកោសល្យរបស់ខ្លួនរួមចំណែកជួយសាលារៀន ក្រុមប្រឹក្សា អង្គការ និង សកម្មភាពនានារបស់រដ្ឋ និង សហគមន៍ ។ ទោះជាយ៉ាងណាក្ដី អែលឌើរ ស្ទីវែនសុនបានចាត់ទុកថាអំណោយទានរបស់នាងក្នុងនាមមេផ្ទះម្នាក់ គឺជាអំណោយទានដ៏អស្ចារ្យបំផុតរបស់នាងដែលព្រះបានប្រទានឲ្យ ៖ « នាងមានសមត្ថភាពបង្កើតផ្ទះមួយដែលផ្ដោតលើដំណឹងល្អ បង្កើតបរិយាកាសនៃសុវត្ថិភាព និង ការស្វាគមន៍ដែលមានព្រះវិញ្ញាណគង់នៅ » ។ សមត្ថភាពនេះរួមជាមួយនឹងការយល់ដឹងយ៉ាងច្បាស់ថា ក្ដីអំណរពិតកើតមានឡើងតាមរយៈការបម្រើមនុស្សដទៃ បានប្រទានពរដល់ជីវិតនៃស្វាមី គ្រួសាររបស់នាង ព្រមទាំងអ្នកនៅជុំវិញនាង ។

អែលឌើរ និង ស៊ិស្ទើរ ស្ទីវែនសុន មានកូនប្រុសបួននាក់ ។ លោកមានប្រសាសន៍ថា « យើងលេងជាមួយគ្នាយ៉ាងរីករាយអស់ពេលជាច្រើនឆ្នាំមកនេះ ។ កូនៗលេងបាល់បោះ បាល់ឱប វាយកូនបាល់ និង តេននីស ។ យើងទាំងអស់គ្នាចែករំលែកក្ដីស្រឡាញ់រវាងគ្នានឹងគ្នាដោយលេងសកម្មភាពនៅក្រៅផ្ទះដូចជា ជិះម៉ូតូកង់បួន ជិះយានយន្តបើកលើទឹកកក លេងស្គី លេងក្ដារលើទឹកកក និង កីឡាលេងលើទឹកជាច្រើនផ្សេងទៀត ។ មិនត្រឹមតែប៉ុណ្ណោះ ឡេសាបានបង្រៀនវប្បធម៌មួយចំនួនដល់កូនប្រុសរបស់យើងផងដែរ ដោយបង្កើតឲ្យមានការចូលចិត្តតន្ត្រី និង សិល្បៈនៅក្នុងខ្លួនពួកគេ ។ ហើយពង្រីកអំណោយទាននៃការបម្រើដល់មនុស្សដទៃទៀតជាគ្រួសារ នោះវាជារឿងចាំបាច់ថា នាងត្រូវការ ‹ កម្លាំង › ចូលរួមចំណែកពីកូនៗ » ។

**ការបង្កើតជំនួញ**

មុខរបរជំនួញរបស់អែលឌើរ ស្ទីវែនសុនបានរីកចម្រើនឡើងដោយសារសេចក្ដីស្រឡាញ់របស់លោកចំពោះប្រជាជនតំបន់អាស៊ី ។ កាលលោកបានត្រឡប់ពីបេសកកម្មរបស់ខ្លួន លោក និង មិត្តភក្ដិមួយចំនួនទៀតបានចាប់ផ្ដើមនាំចូលវត្ថុអនុស្សាវរីយ៍មកពីទ្វីបអាស៊ី ។ ការណ៍នេះបានបង្កើនដល់ការលក់ផលិតផលកីឡា ។ ជាងបីទសវត្សរ៍ក្រោយមក ជំនួញខ្នាតតូចរបស់ពួកគេបានរីកចម្រើនក្លាយទៅជាក្រុមហ៊ុនមួយដ៏មានជោគជ័យដែលបានជួលបុគ្គលិកជាង ២៥០០ នាក់ឲ្យធ្វើការ ។

បុគ្គលិកម្នាក់បានចងចាំពីអ្វីដែលមាននៅក្នុងដួងចិត្តរបស់អែលឌើរ ស្ទីវែនសុនក្នុងនាមជាអ្នកជំនួញម្នាក់ ៖ « យើងកំពុងពិភាក្សាគ្នាពីការសម្រេចចិត្តផ្នែកជំនួញមួយដ៏ពិបាក ។ ខ្ញុំបានប្រាប់គាត់ថា យើងត្រូវប្រាកដថាយើងធ្វើត្រឹមត្រូវតាមច្បាប់ ។ លោកបានប្រាប់ខ្ញុំថា យើងមិនត្រឹមតែធ្វើកិច្ចការនោះឲ្យស្របតាមច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវធ្វើវាឲ្យបានត្រឹមត្រូវផងដែរ » ។

អែលឌើរ ស្ទីវែនសុន ថ្លែងថា « ចូរឲ្យអ្នកទទួលយក និង អនុវត្តគោលការណ៍ល្អនេះនៅក្នុងជំនួញគឺវាជាការណ៍ល្អសម្រាប់ជំនួញ ។ « ភាពថ្លៃថ្នូរ សម្ដីធ្វើការ ក្ដីអាណិតអាសូរ ការប្រព្រឹត្តិនឹងមនុស្សដទៃដោយការគោរព—ហើយស្របពេលជាមួយគ្នានោះតម្រូវឲ្យមានការទទួលខុសត្រូវ—គឺពុំមែនជាគោលការណ៍ដែលអ្នកគ្រាន់តែនិយាយ និង អនុវត្តនៅតែថ្ងៃអាទិត្យឡើយ ។ គោលការណ៍ទាំងនោះត្រូវតែអនុវត្តជារៀងរាល់ថ្ងៃនៅក្នុងសប្ដាហ៍ » ។

ពេលមុខជំនួញនោះបានរីកចម្រើន នោះវាក៏តម្រូវឲ្យលោកចំណាយពេលកាន់តែច្រើនផងដែរ ៖ « ខ្ញុំគឺជាបីស្សពវ័យក្មេង ដែលមានកូនតូចៗ ព្រមទាំងត្រូវធ្វើដំណើរទៅទ្វីបអាស៊ីជាច្រើនដងក្នុងមួយឆ្នាំៗ ។ ឪពុករបស់ខ្ញុំបានមកជួបខ្ញុំ ហើយមានប្រសាសន៍ថា ‹ ប៉ាសង្កេតឃើញថា នៅពេលកូននៅជាមួយគ្រួសារកូន នោះកូនហាក់បីដូចជាពុំនៅ *ជាមួយ* ពួកគេឡើយ ។ ប៉ាបារម្ភថា វាអាចមានន័យថា ពេលកូននៅកន្លែងធ្វើការ កូនពុំបានផ្ដោតយកចិត្តទុកដាក់លើកិច្ចការនៅទីនោះគ្រប់ជ្រុងជ្រោយឡើយ ហើយនៅពេលកូនបំពេញតួនាទីរបស់កូនក្នុងនាមជាបីស្សព នោះកូនអាចបារម្ភអំពីការងារ ឬ គ្រួសាររបស់កូន ។ កូនត្រូវតែមានតុល្យភាពប្រសើរជាងនេះនៅក្នុងជីវិត » ។

ការទូន្មាននេះមានឥទ្ធិពលយ៉ាងធំធេង ។ អែលឌើរ ស្ទីវែនសុន មានប្រសាសន៍ថា « ខ្ញុំបានរៀនថា វាជាកិច្ចការសំខាន់ដើម្បីរក្សាលំនឹងមួយនៃគ្រួសារ វិជ្ជាជីវៈ និង មុខងារក្នុងសាសនាចក្រ ហើយចូរប្រាកដថាអ្នកក៏ថែទាំខ្លួនឯងផងដែរ » ។

**ត្រូវបានហៅឲ្យបម្រើ—ម្ដងហើយម្ដងទៀត**

អ្នកដឹកនាំជំនួញដ៏គួរឲ្យគោរពម្នាក់បានលើកទឹកចិត្តអែលឌើរ ស្ទីវ៉េនសុនឲ្យ « រៀន រកប្រាក់ចំណូល និង បម្រើ » ។ នៅក្នុងឆ្នាំ ២០០៤ « ការបម្រើ » ដែលជាផ្នែកមួយនៃការទូន្មាននោះបានសាកល្បងដល់អែលឌើរ ស្ទីវ៉េនសុន និង ដៃគូជំនួញដ៏យូរអង្វែងរបស់លោកគឺ ស្កត់ វ៉តធើរសុន ដែលពួកលោកទាំងពីរត្រូវបានហៅឲ្យបម្រើជាប្រធានបេសកកម្ម ។ ពួកលោកមានអារម្មណ៍ថា ពួកលោកចាំបាច់ត្រូវពន្យល់ដល់អ្នករួមភាគហ៊ុន និង អតិថិជនជាច្រើនពីមូលហេតុដែលពួកលោកត្រូវចាកចេញជាបណ្ដោះអាសន្នពីក្រុមហ៊ុនរបស់ខ្លួន ។ ពួកលោកបានទៅសួរសុខទុក្ខពួកគេម្នាក់ម្ដងៗ ។

លោកមានប្រសាសន៍ថា « ពេលយើងរៀបរាប់ពីការហៅបម្រើរបស់យើង ថាយើងនឹងបម្រើរយៈពេលបីឆ្នាំដោយពុំបានប្រាក់កម្រៃអ្វីពីសាសនាចក្រ នោះពួកគេបានគោរពដល់សេចក្ដីល្អនៃការហៅនោះ » ។ ពួកលោកបានទុកជំនួញនោះនៅក្នុងដៃរបស់ក្រុមប្រតិបត្តិដ៏ជាទីទុកចិត្ត ហើយវាបានចម្រើនឡើង ។

ក្នុងនាមជាប្រធានបេសកកម្ម ណាហ្គោយ៉ា ប្រទេសជប៉ុន អែលឌើរ ស្ទីវ៉េនសុនបានឃើញថា សេចក្ដីស្រឡាញ់របស់លោកចំពោះទ្វីបអាស៊ីបានកើនឡើង ។ លោកមានប្រសាសន៍ថា « ខ្ញុំចាត់ទុកវាថាជាផ្ទះទីពីររបស់ខ្ញុំ » ។ សេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់លោកចំពោះភរិយាខ្លួនក៏បានកើនឡើងនៅពេលលោកបានឃើញថា នាងបានទទួលយកវប្បធម៌ក្នុងមូលដ្ឋាន ជួយមនុស្សដទៃ រួមទាំងអ្នកផ្សព្វផ្សាយសាសនា និងសមាជិក ហើយបន្តចិញ្ចឹមកូនប្រុសពីរនាក់របស់ពួកគេដែលបានទៅជាមួយពួកគេ ។ អ្នកប្រែចិត្តជឿមួយចំនួនបានជ្រមុជទឹកដោយសារកិច្ចខិតខំរបស់នាងក្នុងការធ្វើជាមិត្តភក្ដិជាមួយអស់អ្នកដែលនៅជុំវិញខ្លួននាង ។

បន្ទាប់ពីបានបម្រើបេសកកម្មរបស់ខ្លួន ពួកគេបានត្រឡប់មកផ្ទះវិញបានតែប្រាំពីរខែប៉ុណ្ណោះ នោះអែលឌើរ ស្ទីវ៉េនសុនត្រូវបានហៅឲ្យបម្រើនៅក្នុងកូរ៉ុមទីមួយនៃពួកចិតសិបនាក់នៅក្នុងឆ្នាំ ២០០៨ ។

« ខ្ញុំភ័យស្រឡាំងកាំង និង មានការបន្ទាបខ្លួន ។ ខ្ញុំបានគិតថា ‹ មានមនុស្សជាច្រើនដែលអាចបម្រើបានប្រសើរជាងខ្ញុំទៅទៀត › ។ ប៉ុន្តែខ្ញុំបានគិតពីគ្រាមុនៗ—កាលជាប្រធានកូរ៉ុមអែលឌើរ ក្រុមប្រឹក្សាជាន់ខ្ពស់ ប៊ីស្សព និង ទីប្រឹក្សានៅក្នុងគណៈប្រធានស្តេក—នៅពេលខ្ញុំមានអារម្មណ៍ថា ខ្ញុំគ្មានភាពចាស់ទុំគ្រប់គ្រាន់ដើម្បីធ្វើកិច្ចការដែលខ្ញុំត្រូវបានសុំឲ្យធ្វើ ។ ខ្ញុំបានរៀនថា ពីមុនយើងត្រូវបានហៅបម្រើ នោះយើងអាចនឹង *ពុំ* សក្ដិសមគ្រប់គ្រាន់នឹងការហៅនោះ ប៉ុន្តែពេលការហៅបម្រើ *ចាប់ផ្ដើម* នោះព្រះធ្វើឲ្យយើងមានគុណសម្បត្តិនឹងការហៅបម្រើនោះហើយ ។

« ខគម្ពីរមួយដែលខ្ញុំចូលចិត្តបានប្រាប់យើងនូវចំណុចពីរយ៉ាងដែលយើងគប្បីធ្វើ នៅពេលយើងត្រូវបានហៅឲ្យបម្រើ ៖ ទីមួយ ‹ ចូរមានចិត្តស្មោះត្រង់ › ។ ទីពីរ ចូរឈរនៅក្នុងតំណែងដែលយើងបានតែងតាំង ( សូមមើល គ. និង ស. ៨១:៥ ) ។ ចំពោះខ្ញុំការណ៍នេះមានន័យថា ការបង្ហាញសេចក្ដីជំនឿ រៀនអ្វីដែលចាំបាច់ ហើយបន្ទាប់មកធ្វើការឲ្យអស់ពីសមត្ថភាពដែលយើងអាចធ្វើបានដើម្បីតម្កើងការហៅបម្រើ ។ ប្រសិនបើយើងធ្វើបែបនេះ នោះព្រះអម្ចាស់នឹងតម្កើងហើយធ្វើឲ្យយើងមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីប្រទានពរដល់មនុស្សដទៃ » ។






**ទៅទ្វីបអាស៊ីសារជាថ្មីម្ដងទៀត**

ក្នុងនាមជាពួកចិតសិប អែលឌើរ ស្ទីវ៉េនសុនត្រូវបានចាត់តាំងជាទីប្រឹក្សាទីពីរនៅក្នុង

ក្នុងនាមជាពួកចិតសិបនាក់ និង គណៈប៊ីស្សពជាអធិបតី អែលឌើរ ស្ទីវ៉េនសុនត្រូវបានស្គាល់ថាមានក្ដីករុណាដែលសុភាពរាបសាដូចជាផ្កាឆឺរីរីក ( ផ្កាឆឺរីរីកគឺជានិមិត្តសញ្ញានៃការប្រារព្ធពិធីមួយរបស់ប្រទេសជប៉ុន ) ។ លោកបានជួយមនុស្សដែលនៅជិតផ្ទះ និង នៅឆ្ងាយពីផ្ទះឲ្យចែកចាយ « ការព្យាបាលដោយសេចក្ដីស្រឡាញ់នៃព្រះអង្គសង្គ្រោះ » ។ ក្នុងនាមជាសាវក លោកនឹងបន្តជួយដល់ជនក្រីក្រ និង ខ្វះខាតដើម្បី « ជួយអ្នកទន់ខ្សោយ លើកដៃដែលពោយ ហើយចូរចម្រើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រផង » ( គ. និង ស. ៨១:៥ ) ។









គណៈប្រធានតំបន់ ហើយក្រោយមកធ្វើជាប្រធានតំបន់អាស៊ីភាគខាងជើង ។

នៅក្នុងខែ មិនា ឆ្នាំ ២០១១ មានគ្រោះរញ្ជួយដី និង ស៊ូណាមីបានបំផ្លាញប្រទេស ជប៉ុន ។ ការរំញ្ជួយដែលមានកម្លាំង ៩ រិចទ័រ បានបង្កើតឲ្យមានការរំញ្ជួយរលកសមុទ្រដែលបានបណ្ដាលឲ្យមនុស្ស ២០000 នាក់បានស្លាប់ មនុស្សរាប់រយពាន់ប្ដូរទីលំនៅ ហើយផ្ទះ ៥៥0000 ខ្នងត្រូវបានបំផ្លិចបំផ្លាញ ។

លោកបានទៅមើលតំបន់ដែលគ្រោះធម្មជាតិនោះបានកើតឡើងជាច្រើនដង ។ លោកបានរំឭកថា « នៅពេលយើងបានជួបមនុស្សទាំងនោះ យើងមានអារម្មណ៍ក្ដុកក្ដួលយ៉ាងខ្លាំងចំពោះពួកគេ ។ « យើងបានសង្កេតឃើញក្នុងគ្រាជាមួយគ្នានោះនូវសោកនាកម្ម និង ការបាត់បង់ លាយឡំជាមួយនឹងក្ដីសង្ឃឹម និង ការស្ដារឡើងវិញ ។ យូរៗទៅយើងមានការរំជួលចិត្ត នៅពេលយើងបានឃើញពីការព្យាបាលដោយសេចក្ដីស្រឡាញ់នៃព្រះអង្គសង្គ្រោះ » ។

ក្រៅពីនោះ លោកបានឃើញដោយផ្ទាល់នូវរបៀបដែលសាសនាចក្រជួយដល់អស់អ្នកដែលត្រូវការជំនួយ ៖ « ដើម្បីអាចឆ្លើយតបទៅនឹងភ័យអន្តរាយ ហើយជួយរៀបចំក្នុងការឆ្លើយតប—នោះគឺជាការសម្ដែងឲ្យឃើញពីការបំពេញការទទួលខុសត្រូវមួយដ៏ទេវភាពរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ចំពោះការខ្វល់ខ្វាយដល់ជនទ័លក្រ និង អ្នកខ្វះខាត » ។ លោកបានរៀបរាប់ថា វាគឺជាឯកសិទ្ធិដ៏ពិសិដ្ឋ ដើម្បីបម្រើដល់អស់អ្នកដែលខ្វះខាត ហើយឃើញមនុស្សដទៃទៀតបានធ្វើកិច្ចការដូចគ្នានេះ ៖ « យើងបានរៀនពីសេចក្ដីល្អនៃមនុស្សធម៌ » ។

### កេរដំណែលនៃប៊ីស្សព

ការយល់ដឹងរបស់លោកអំពីសេចក្ដីអាណិតអាសូរបានកើតមានក្នុងដួងចិត្តរបស់លោកកាន់តែច្រើនឡើងនៅក្នុងឆ្នាំ ២០១២ កាលលោកត្រូវបានហៅឲ្យបម្រើជាប៊ីស្សពជាអធិបតី ។ នៅក្នុងមុខងារនោះ លោកបានរៀបចំក្រុមប្រឹក្សាបណ្ដាញសាសនាចក្រដែលបានផ្ដល់ជំនួយខាងសុខុមាលភាព និង ឆ្លើយតបភ្លាមៗដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ព្រមទាំងមនុស្សដទៃទៀត និង ជំនួយមនុស្សធម៌ទៅកាន់កូនចៅរបស់ព្រះវរបិតាសួគ៌នៅក្នុង « ទីកន្លែងដ៏លំបាកបំផុត ទីកន្លែងដ៏ក្រីក្របំផុត ទីកន្លែងដ៏សង្កត់សង្កិនបំផុត នៅជុំវិញពិភពលោក » ។[៣]

តួនាទីជាប៊ីស្សពមានសារៈសំខាន់យ៉ាងពិសេសចំពោះអែលឌើរ ស្ទីវែនសុន ។ លោករំឭកថា « កាលខ្ញុំអាយុ ១២ ឆ្នាំ ឪពុករបស់ខ្ញុំត្រូវបានហៅជាប៊ីស្សព ។ វួដនោះមានស្ត្រីមេម៉ាយជាច្រើន ហើយឪពុករបស់ខ្ញុំយកខ្ញុំទៅជាមួយគាត់ជានិច្ច នៅពេលគាត់ទៅបម្រើពួកគេ ។ គាត់ឲ្យខ្ញុំរើសកំប៉ុង សម្អាតផ្ទះ ឬ ឲ្យខ្ញុំយកមិត្តភក្តិរបស់ខ្ញុំទៅជាមួយដើម្បីបោសសំរាម ឬ ចូកព្រិល ។ នៅពេលយើងចាកចេញទៅវិញ ខ្ញុំមានអារម្មណ៍ល្អក្នុងចិត្តជានិច្ច ។ ការចុះសួរសុខទុក្ខស្ត្រីមេម៉ាយទាំងនោះបានជួយខ្ញុំឲ្យដឹងថា ផ្នែកមួយដែលប៊ីស្សពធ្វើនោះគឺបម្រើដល់មនុស្សម្នាក់ៗ ។ ប៊ីស្សពនៃសាសនាចក្រគឺជាវីរបុរសៈរបស់ខ្ញុំ » ។

### ការសន្យាមកពីព្យាការី

នៅថ្ងៃអង្គារពីមុនសន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០១៥ បន្ទាប់ពីប៊ីស្សព ស្ទីវែនសុន បានទទួលទូរសព្ទសុំឲ្យគាត់ជួបជាមួយប្រធាន ថូម៉ាស អេស ម៉នសុន និង ទីប្រឹក្សារបស់លោក ។

« ប្រធាន ម៉នសុន [ បានផ្ដល់ ] ការហៅបម្រើដល់ខ្ញុំក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ លោកបានសួរខ្ញុំប្រសិនបើខ្ញុំយល់ព្រមទទួលការហៅនោះឬអត់ ។ . . .ខ្ញុំបានឆ្លើយតបថាយល់ព្រម ។ ក្រោយមក . . . ប្រធានម៉នសុន បានថ្លែងមកខ្ញុំ ដោយរៀបរាប់ពីរបៀបដែល [ នៅពេល ] លោកត្រូវបានហៅកាលពីច្រើនឆ្នាំមុនឲ្យធ្វើជាសាវក . . .លោកក៏មានអារម្មណ៍ថាខ្លួនលោកខ្វះចន្លោះផងដែរ ។ លោកបានបង្គាប់ខ្ញុំដោយស្រទន់ថា‹ ប៊ីស្សព ស្ទីវែនសុន ព្រះអម្ចាស់នឹងធ្វើឲ្យអស់អ្នក ដែលទ្រង់បានហៅមានគុណសម្បត្តិសមនឹងកិច្ចការនោះ › ។ ពាក្យលួងលោមទាំងនេះរបស់ព្យាការីបានក្លាយជាប្រភពនៃភាពសុខសាន្ត [ ចាប់តាំងពីនោះមក ] » ។[៤]

អែលឌើរ ហ្គែរី អ៊ី ស្ទីវែនសុនគឺពិតជាបុរសម្នាក់ដែលឥតមានឧបាយកលឡើយ ។ ក្នុងនាមជាសាវក ក្នុងនាមលោកធ្វើជាគណៈប៊ីស្សពជាអធិបត ព្រមទាំងក្នុងនាមជាពួកចិតសិបនាក់ និង ក្នុងនាមជាអ្វីៗផ្សេងទៀតដែលបានធ្វើពេញមួយជីវិតរបស់លោក នោះលោកនឹងបន្តជួយដល់ជនទីទ័លក្រ និង ខ្វះខាត ។ លោកនឹងធ្វើតាមខគម្ពីរដែលបានបង្គាប់ថា « ចូរជួយអ្នកទន់ខ្សោយ ចូរលើកដៃដែលរោយ ហើយចូរចម្រើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រផង » ( គ. និង ស. ៨១:៥ ) ។ វាជាហៅបម្រើមួយដ៏លំបាក ប៉ុន្តែជាការហៅមួយដែលសក្តិសមយ៉ាងខ្លាំងចំពោះលោកដោយសារដួងចិត្តដែលមានការយល់ដឹងរបស់លោក ។ ■

កំណត់ចំណាំ
1. ហ្គែរី អ៊ី ស្ទីវែនសុន « Lean Not unto Thine Own Understanding » ( ការប្រជុំធម្មនិដ្ឋានសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤ ) ទំព័រ ២, ៣, speeches.byu.edu។
2. អែលឌើរ ហ្គែរី អ៊ី ស្ទីវែនសុន « Plain and Precious Truths » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៩២ ។
3. ហ្គែរី អ៊ី ស្ទីវែនសុន សន្និសីទសារព័ត៌មាន ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១៥ ។
4. ហ្គែរី អ៊ី ស្ទីវែនសុន « Plain and Precious Truths » ទំព័រ ៩១ ។

រូបថតដោយផ្ដល់សិទ្ធិអនុញ្ញាតពីកាសែត ដេសឺរ៉េត ញូវស៍ *DESERET NEWS* និង សារព័ត៌មាន ចឺច ញូវស៍ *CHURCH NEWS*




SANTA BIBLIA
EL LIBRO DE MORMÓN
OTRO TESTAMENTO DE JESUCRISTO





**ដោយ អែលឌើរ លីន ជី រ៉ូប៊ីន**
ក្នុងគណៈប្រធាននៃពួកចិតសិបនាក់

# ភ្នែករបស់មនុស្សខ្វាក់ នឹងមើលឃើញ

*យើងអាចពិចារណាពីការចេញមកនៃព្រះគម្ពីរមរមន ទុកជាការស្ដារឡើងវិញដ៏អស្ចារ្យនៃចក្ខុវិស័យខាងវិញ្ញាណ ។*

អេសាយបានព្យាករថា នៅថ្ងៃចុងក្រោយ ព្រះអម្ចាស់នឹងបន្តធ្វើ « ការណ៍ យ៉ាងអស្ចារ្យ ហើយចំឡែក » ហើយលោកបានព្យាករពីការចេញមកនៃព្រះគម្ពីរមរមនដោយថ្លែងថា « ភ្នែករបស់មនុស្សខ្វាក់នឹងមើលឃើញ ពីក្នុងសភាពជាងងឹត ហើយសូន្យសុង » ( អេសាយ ២៩:១៤, ១៨ ) ។

**« សភាពល្វិតល្វង់ »**

នៅក្នុងសម័យពីមុនការនិមិត្តដំបូងដ៏រុងរឿង ការរំជើបរំជួលខាងសាសនានៅភូមិ ម៉ែនឆែសស្ទើរ រដ្ឋ ញូវ យ៉ក ស.រ.អា. មានភាពច្របូកច្របល់យ៉ាងខ្លាំង ។ យ៉ូសែប ស្ម៊ីធបានថ្លែងថា « ការរំជួល និង ការឈ្លោះប្រកែកគ្នាជាខ្លាំងក្នុងចំណោមបក្សពួកផ្សេងៗ ដល់ម្ល៉េះបានជាពិបាកដល់ជនដូចរូបខ្ញុំ . . . ឲ្យចេះ សម្រេចចិត្តថានរណាមួយត្រូវ ហើយនរណាមួយខុសនោះឡើយ » ( យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៨ ) ។

ព្រះគម្ពីរមរមននិយាយសំដៅលើការរំជើបរំជួលពីមុនការស្ដារឡើងវិញនេះថាជា «*សភាពល្វិតល្វង់* . . . ដោយមកពីភាគដ៏ច្បាស់ និង ពិសេសទាំងប៉ុន្មាននៃដំណឹងល្អរបស់កូនចៀម ត្រូវបានយកចេញដោយសាសនាចក្រដ៏គួរខ្ពើមឆ្អើម » ( នីហ្វៃទី ១ ១៣:៣២ការសង្កត់ធ្ងន់ត្រូវបានបន្ថែម ) ។

ជាច្រើនសតវត្សរ៍មកហើយ ចក្ខុវិស័យខាងវិញ្ញាណដ៏ច្បាស់បានត្រូវផ្ដល់ឲ្យតាមរយៈ *ភាពស្រពិចស្រពិល* នៃព្រះគម្ពីរប៊ីប ដោយសារភាគដ៏ច្បាស់ និង ពិសេសៗទាំងប៉ុន្មានបានបាត់បង់ ពេលខ្លះបាត់បង់ដោយអចេតនាតាមរយៈការបកប្រែដោយខុសឆ្គង ហើយពេលខ្លះបាត់បង់ដោយចេតនាតាមរយៈការកែប្រែដ៏ពុករលួយ « ដែលពួកគេអាចធ្វើដើម្បីបង្ខូចផ្លូវដ៏ត្រឹមត្រូវទាំងឡាយនៃព្រះអម្ចាស់ ដើម្បីឲ្យពួកគេអាច *ធ្វើឲ្យភ្នែកទាំងឡាយខ្វាក់* ហើយធ្វើឲ្យចិត្តទាំងឡាយនៃកូនចៅមនុស្សរឹងរូស » ( នីហ្វៃទី ១ ១៣:២៧ការសង្កត់ធ្ងន់ត្រូវបានបន្ថែម ) ។

ខាងលើបំផុត ៖ រូបភាពដកស្រង់ចេញមកពី *ព្យាការីអេសាយព្យាករពីការប្រសូតរបស់ព្រះគ្រីស្ទ* ដោយ ហារី អែលឌើសុន

**« ពីដើមខ្ញុំខ្វាក់ តែឥឡូវនេះខ្ញុំមើលឃើញ » ( យ៉ូហាន ៩:២៥ )**

ការណ៍ដ៏អស្ចារ្យបំផុតមួយរបស់ព្រះអង្គសង្គ្រោះ គឺការស្ដារឡើងវិញនូវចក្ខុវិស័យដល់ភ្នែកដែលខ្វាក់នោះ ។[1] ប៉ុន្តែបេសកកម្ម និង អព្ភូតហេតុដ៏សំខាន់ជាងនេះទៀតរបស់ព្រះអង្គសង្គ្រោះនោះគឺការព្យាបាលភាពខ្វាក់ខាងវិញ្ញាណ ។ ទ្រង់បានបន្ទូលថា « ខ្ញុំបានមកក្នុងលោកីយ៍នេះ ឲ្យពួកអ្នកដែលមើលមិនឃើញបានភ្លឺឡើង » ( យ៉ូហាន ៩:៣៩ ) ។

ដោយប្រើការប្រៀបប្រដូចរបស់អេសាយ និង ការនិមិត្តនៃភាពខ្វាក់ខាងវិញ្ញាណរបស់នីហ្វៃនៅក្នុងសម័យចុងក្រោយនេះ យើងអាចពិចារណាពីការចេញមកនៃព្រះគម្ពីរមរមន ថាជាការស្ដារឡើងវិញដ៏អស្ចារ្យនៃចក្ខុវិស័យខាងវិញ្ញាណ ។

« ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់ក៏មិនព្រមឲ្យពួកសាសន៍ដទៃបន្តស្ថិតនៅក្នុង



២ ក. រូបតុក្កតាកូនក្មេងបង្ហាញពីកម្លាំងនៃការចាប់យកគំហើញនៃផ្ទៃសើរៗយ៉ាងច្បាស់ ។




១. មនុស្សមានដែនគំហើញជាអតិបរមាប្រមាណជា ១៩០ ដឺក្រេដោយប្រើភ្នែកទាំងគូ ប្រហែលជា ១២០ ដឺក្រេដែលឃើញដោយភ្នែកទាំងពីរ ។



២ ខ. ចំពោះសត្វ ភ្នែកទាំងពីររបស់វាផ្ដល់នូវសក្ដានុពលនៃការចាប់យកគំហើញនៃអាហារ ឬ ចាប់យកគំហើញយ៉ាងច្បាស់ដែលជួយវាដឹងពីការលាក់ខ្លួននៃពួកសត្វកាចសាហាវ ។

សភាព *ល្ងិតល្ងង់តទៅទៀតឡើយ* ។ . . .

« . . . យើងនឹងមេត្តាដល់ពួកសាសន៍ដទៃនៅថ្ងៃនោះ គឺដរាបដល់យើងនឹងនាំចេញមកដល់ពួកគេ ដោយអំណាចយើងផ្ទាល់ នូវភាគច្រើនដែលនៃដំណឹងល្អរបស់យើង ។ . . .

« ដ្បិតមើលចុះកូនចៀមមានព្រះបន្ទូលថា ៖ យើងនឹងសម្ដែងខ្លួនឲ្យពូជអ្នកឃើញ ដើម្បីឲ្យពួកគេសរសេរអំពីអ្វីៗជាច្រើន ដែលយើងនឹងធ្វើការងារបម្រើដល់ពួកគេ . . . [ ហើយ ] សេចក្ដីទាំងនេះនឹងត្រូវបានលាក់ទុក ដើម្បីឲ្យបានចេញមកដល់ពួកសាសន៍ដទៃដោយអំណោយទាន និង ព្រះចេស្ដានៃកូនចៀម ។

« កូនចៀមមានព្រះបន្ទូលថា ទាំងដំណឹងល្អ និង ថ្ម ហើយនឹងសេចក្ដីសង្គ្រោះរបស់យើង នឹងត្រូវបានសរសេរទុកនៅក្នុងគម្ពីរទាំងនេះ ។

« . . . បញ្ជីចុងក្រោយទាំងឡាយនេះ . . . នឹងតាំងនូវសេចក្ដីពិតអំពីគម្ពីរមុន ។ . . . បញ្ជីទាំងពីរនឹងត្រូវបានតាំងឡើងជារបស់តែមួយ » ( នីហ្វៃទី ១ ១៣:៣២, ៣៤–៣៦, ៤០–៤១ការសង្កត់ធ្ងន់ត្រូវបានបន្ថែម )—ចេញមករួមគ្នាដើម្បីជួយអ្នកឲ្យឃើញពីសេចក្ដីពិត ។

បញ្ជីទាំងពីរ « នឹងត្រូវបានតាំងឡើងជារបស់តែមួយ » គឺជារបៀបមួយដែលភ្នែកទាំងពីរមើលឃើញ ឬ ដំណើរការ ។ ដោយសារខ្ញុំមានជំងឺទឹកដក់ក្នុងភ្នែក នោះខ្ញុំត្រូវតែបន្តក់ថ្នាំដាក់ភ្នែកខ្ញុំទាំងសងខាងពីរដងក្នុងមួយថ្ងៃដើម្បីការពារកុំឲ្យខ្វាក់ភ្នែក ។ ពីមុនវេជ្ជបណ្ឌិតបានរកឃើញថាខ្ញុំមានជំងឺទឹកដក់ក្នុងភ្នែក នោះភ្នែកម្ខាងរបស់ខ្ញុំបានមើលឃើញដោយស្រវាំងទៅហើយ ។ ខ្ញុំមានអំណរគុណយ៉ាងខ្លាំងចំពោះថ្នាំសម័យទំនើបនេះ ដែលធ្វើឲ្យភ្នែកខ្ញុំមិនខ្វក់ ។ ខ្ញុំមានអំណរគុណផងដែរចំពោះភ្នែកទីពីរដ៏ល្អរបស់ខ្ញុំ ដែលវាជួយរក្សាគុណភាពនៃភ្នែកម្ខាងទៀតកុំឲ្យចុះអន់ខ្សោយ ។ រឿងប្រដូចនៃភ្នែកទាំងពីរនេះមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅ និង ផ្ទាល់ខ្លួនចំពោះខ្ញុំ ។

ការវិភាគជាច្រើននៃវិទ្យាសាស្ត្រ បង្ហាញពីគុណសម្បត្តិនៃការមានភ្នែកពីរជាជាងមានភ្នែកតែមួយ ។ ខ្ញុំនឹងបង្ហាញគុណសម្បត្តិទាំងប្រាំមួយនេះ និង រឿងប្រៀបប្រដូចខាងវិញ្ញាណនៃគុណសម្បត្តិទាំងនោះ ជាមួយនឹងព្រះគម្ពីរមរមនដែលជា *សាក្សីជាក់នឹងភ្នែក* ទីពីរនៃព្រះយេស៊ូវគ្រីស្ទនៅក្នុង *ការស្ដារឡើងវិញ* នៃចក្ខុវិស័យខាងវិញ្ញាណដល់ពិភពលោកនេះ ។

**១. ភ្នែកទាំងសងខាងបង្កើនដែននៃគំហើញ និង ភាពឃើញច្បាស់**

មនុស្សមានដែនគំហើញជាអតិបរមាប្រមាណជា ១៩០ ដឺក្រេដោយប្រើភ្នែកទាំងគូ ប្រហែលជា ១២០ ដឺក្រេនៅពេលដែនគំហើញនៃភ្នែកទាំងពីរត្រួតស៊ីគ្នា ឬ ឃើញដោយភ្នែកទាំងពីរ ។ លើសពីដែនគំហើញដែលប្រសព្វគ្នា ភ្នែកម្ខាងៗក៏អាចមានដែនគំហើញនឹងកន្ទុយភ្នែកយ៉ាងពិសេសរបស់វាដែរ ។[2]

បន្ទាប់ពីច្រើនសតវត្សរ៏នៃការបាត់បង់នូវភាពច្បាស់ និង ពិសេសៗមក ព្រះគម្ពីរប៊ីបបានរីករាយនឹងចក្ខុវិស័យដ៏ល្អឥតខ្ចោះតិចតួចណាស់ ។ ការចេញមកនៃព្រះគម្ពីរមរមនជាមួយនឹងចក្ខុវិស័យដ៏ល្អឥតខ្ចោះរបស់វា ពុំគ្រាន់តែបង្កើននូវដែនគំហើញខាងវិញ្ញាណប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្ដល់នូវភាពច្បាស់លាស់ដ៏ចាំបាច់ជាច្រើន

ទៅលើផ្នែកត្រួតស៊ីគ្នានៃភ្នែកខាងវិញ្ញាណទាំងពីរ ឬ ដែនគំហើញនៃភ្នែកទាំងគូ ( សូមមើលរូបភាពទី ១ )—ដែលយើងហៅតាមព្រះគម្ពីរថាជាច្បាប់នៃស្មរបន្ទាល់ពីរនាក់ ( សូមមើល ម៉ាថាយ ១៨:១៦; អេធើរ ៥:៤; គ. និង ស. ៦:២៨ ) ។

ដែនគំហើញត្រួតស៊ីគ្នា ឬ *គំហើញត្រួតស៊ីគ្នាដោយភ្នែកទាំងពីរ* បង្កើនលទ្ធភាពដើម្បីមើលឃើញវត្ថុដែលព្រាលៗនោះបានច្បាស់ ។[៣] យើងមើលឃើញច្បាស់ជាងនៅពេលរូបភាពផ្សេងៗដែលភ្នែកនិមួយៗនោះមើលឃើញ ផ្គុំគ្នាទៅជារូបភាពតែមួយដោយផ្ដល់នូវចំណុចរួមមួយនៃ *អ័ក្សគំហើញ*[៤] ហេតុដូច្នោះហើយវាលុបបំបាត់ចោលនូវ « ការរំជួល និង ការឈ្លោះប្រកែកគ្នា » ដែលធ្វើឲ្យយ៉ូសែបវ័យក្មេងសុញគំនិតនោះ ( សូមមើល យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៨ ) ។

ការពិតនោះគឺថា *មានភ្នែកទាំងគូគឺប្រសើរជាងមានភ្នែកតែម្ខាង* ដែលជាការពិតដ៏សាកល និង ជាក់ស្ដែង ដែលព្យាការីអេសាយប្រហែលជាពុំអាចរើសយកការប្រៀបប្រដូចណាទៀតបានសម្រាប់ការទទួលស្គាល់ទូទាំងពិភពលោក ដែលថា ៖ « ភ្នែករបស់មនុស្សខ្វាក់នឹងមើលឃើញ »( អេសាយ ២៩:១៨ ) ។ យើងសង្ឃឹមថាបច្ចុប្បន្ននេះអស់អ្នកដែលមើលឃើញដោយភ្នែកខាងវិញ្ញាណតែម្ខាង គឺព្រះគម្ពីរប៊ីប នោះនឹងទទួលស្គាល់ពីប្រាជ្ញានៃការពុំបដិសេធព្រះគម្ពីរមរមនដែលជាសាក្សីជាក់នឹងភ្នែកទីពីរនៃព្រះយេស៊ូវគ្រីស្ទ ពីមុនពួកគេសាកល្បងវាសិន ។ ពួកគេនឹងដឹងថា « បន្ទះឈើរបស់ពួកយូដា » និង « បន្ទះឈើរបស់ពួកយ៉ូសែប » ( អេសេគាល ៣៧:១៩ ) ផ្គុំគ្នាជាភ្នែកទាំងគូដែលបញ្ចូលគ្នាយ៉ាងល្អឥតខ្ចោះ ហើយមានភាពច្បាស់រួមគ្នា—ជា *បទពិសោធន៍* គួរឲ្យអស្ចារ្យពេកក្រៃ !

## ២. ការចាប់យកគំហើញ—ការចៀសវាងពីការឆបោក

« គំហើញនៃភ្នែកទាំងពីរ. . . ធ្វើឲ្យមនុស្សដើរឆ្លងកាត់ ឬ ដើរជុំវិញឧបសគ្គនានាដោយល្បឿនកាន់តែលឿន និង កាន់តែមានទំនុកចិត្ត » ដោយសារការចាប់យកគំហើញមានសភាពកាន់តែច្បាស់ ។[៥] ឧទាហរណ៍មួយអំពីការចាប់យកគំហើញយ៉ាងច្បាស់នៃផ្ទៃសើរៗ គឺត្រូវបានបង្ហាញនៅក្នុងរូបភាព ៣-D នៃកែវឃើតលើរូបភាពសាមញ្ញមួយ ( សូមមើលរូបភាពទី ២ ក ) ។

ចំពោះសត្វ ភ្នែកទាំងពីររបស់វាផ្ដល់នូវសក្ដានុពលនៃ *ការចាប់យកគំហើញ* នៃអាហារ ឬ ចាប់យកគំហើញយ៉ាងច្បាស់ ហើយមានលទ្ធភាពដូចជា៣-D ហេតុដូច្នោះហើយវា « ដឹងពីការលាក់ខ្លួននៃ [ ពួកសត្វកាចសាហាវ ] »[៦] ( សូមមើលរូបភាព ២ ខ ) ។

ព្រះគម្ពីរមរមនបានផ្ដល់ការការពារដល់ពិភពលោកនេះស្រដៀងនឹងការណ៍នេះផងដែរ ដោយការស្ដារឡើងវិញនូវភាពច្បាស់លាស់ និង ការញ្ញាណដឹងយ៉ាងជ្រាលជ្រៅពីព្រះតាមរយៈដែនគំហើញដ៏ច្បាស់នៃកែវឃើតខាងវិញ្ញាណ ដោយធ្វើឲ្យយើងអាចចៀសផុតពីការបន្លំ និង ការឆបោករបស់សាតាំង ។ លោកបានណែនាំពីការភាន់ច្រឡំនោះបានយ៉ាងឈ្លាសវៃ តាមរយៈការបកស្រាយផ្ទុយពីអត្ថន័យជាច្រើននៃវគ្គបទគម្ពីរនៃព្រះគម្ពីរប៊ីប ។ ព្រះគម្ពីរមរមនបានបំបែកភាពស្រពិចស្រពិលរបស់គម្ពីរប៊ីប ដោយការបញ្ជាក់យ៉ាងច្បាស់ដូចកែវចរណៃ « ចំពោះការផ្ចាញ់ផ្ចាល់នូវគោលលទ្ធិក្លែងក្លាយទាំងឡាយ » ( នីហ្វៃទី ២ ៣:១២ ) និង « ផ្ដាច់អស់ទាំងកលល្បិច និង អន្ទាក់ និង ឧបាយរបស់អារក្សឲ្យដាច់ពីគ្នា » ( ហេលេមិន ៣:២៩ ) ។

ប្រធាន អែសរ៉ា ថាហ្វ បែនសឹន ( ឆ្នាំ ១៨៩៩–១៩៩៤ ) បានចែកចាយការសន្យាដ៏ទុកចិត្តអំពីព្រះគម្ពីរមរមន ៖ « នៅក្នុងព្រះគម្ពីរមរមនមាននូវអំណាចមួយដែលនឹងចាប់ផ្ដើមចូលទៅក្នុងជីវិតអ្នក នៅខណៈដែលអ្នកចាប់ផ្ដើមសិក្សាព្រះគម្ពីរនេះដោយហ្មត់ចត់ ។ អ្នកនឹងរកឃើញអំណាចដែលកាន់តែមហិមា ដើម្បីទប់ទល់នឹងការល្បួង ។ អ្នកនឹងរកឃើញនូវអំណាចដើម្បី *ចៀសផុតពីការបោកបញ្ឆោត* ។ អ្នកនឹងរកឃើញអំណាច ដើម្បីឈរនៅលើផ្លូវតូច និង ចង្អៀត » ។[៧]



*៣. ការមើលឃើញដោយភ្នែកទាំងពីរជួយមនុស្សម្នាក់មើលឃើញកាន់តែច្បាស់ ឬ ឃើញទាំងស្រុងនូវវត្ថុដែលលាក់កំបាំង ។ តើអ្នកអាចប្រាប់ពីភាពខុសគ្នាដែរឬទេ ?*

## ៣. ការមើលឃើញឧបសគ្គនានាដែលនៅជុំវិញ

ការមើលឃើញដោយភ្នែកទាំងពីរជួយមនុស្សម្នាក់មើលឃើញកាន់តែច្បាស់ ឬ ឃើញទាំងស្រុងនូវវត្ថុដែលលាក់កំបាំង ។ គុណសម្បត្តិនេះត្រូវបានពន្យល់ប្រាប់ដោយ ឡេអូណាដូ ដា វីនឈី ដែលកត់សម្គាល់ឃើញថា ភាពស្រអាប់នៃវត្ថុមួយអាចបិទបាំងវត្ថុមួយចំនួន ឬ ទាំងអស់ពីភ្នែកខាងឆ្វេង ប៉ុន្តែវត្ថុនោះអាចមើលឃើញដោយភ្នែកស្ដាំ ។[៨] ( សូមមើលរូបភាពទី ៣ ) ។

ឧទាហរណ៍ខាងវិញ្ញាណនៃការណ៍នេះ គឺ មាននៅក្នុងព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះដល់ពួកសាសន៍យូដា ៖ « ខ្ញុំក៏មានចៀមឯទៀត ដែលមិនទាន់នៅក្នុងក្រោលនេះនៅឡើយ ត្រូវតែខ្ញុំនាំចៀមទាំងនោះមកដែរ វានឹងស្ដាប់តាមសំឡេងខ្ញុំនោះនឹងមានហ្វូងតែ១ និងអ្នកគង្វាលតែ១វិញ » ( យ៉ូហាន ១០:១៦ ) ។

ដោយសារព្រះយេស៊ូវពុំបានប្រាប់អំពីអត្តសញ្ញាណនៃចៀមទាំងនោះ នោះពួកសាសន៍យូដាពុំយល់ពីព្រះបន្ទូលរបស់ទ្រង់ឡើយ ។ ប៉ុន្តែជាមួយនឹង *ទស្សនវិស័យបន្ថែម* ចេញពីព្រះគម្ពីរមរមន ដែលថាវាត្រូវបានលាក់កំបាំងបានប្រែជាមើលឃើញ ៖ « យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាគឺជាពួកអ្នកដែលយើងបាននិយាយ

រូបថតសត្វក្ងោក © ISTOCK/THINKSTOCK

ថា ៖ យើងក៏មានចៀមឯទៀតដែលមិននៅក្នុងក្រោលនេះនៅឡើយ ត្រូវតែយើងនាំចៀមទាំងនោះមកដែរ ហើយវានឹងស្ដាប់តាមសំឡេងយើង នោះនឹងមានក្រោលតែមួយ និងអ្នកគង្វាលតែមួយវិញ » ( នីហ្វៃទី ៣ ១៥:២១ ) ។ លទ្ធផលនោះ គឺជាដែនគំហើញយ៉ាងច្បាស់ដោយគ្មានការយល់ច្រឡំពីអ្វីដែលព្រះអង្គសង្គ្រោះចង់មានព្រះបន្ទូល—ដែលគ្មាន *ឧបសគ្គ* នៃការយល់ខុសទៀតឡើយ ។

### ៤. គុណសម្បត្តិនៃការមើលឃើញនឹងកន្ទុយភ្នែករបស់ភ្នែកនីមួយៗ

« គំហើញនឹងកន្ទុយភ្នែកគឺជាផ្នែកមួយនៃគំហើញដែល កើតឡើងក្រៅពីការមើលដោយប្រើចំណុចកណ្ដាលនៃភ្នែក » ។[៩] ឬពាក្យម៉្យាងទៀតថា យើងមើលឃើញវត្ថុនានានៅក្នុងដែនគំហើញដែលយើងពុំផ្ចង់មើលវា ។ ផ្នែកនៃដែនគំហើញនោះ—គឺក្រៅពីរង្វង់នៃដែនគំហើញត្រួតស៊ីគ្នា ឬ *ការចាប់យកគំហើញ*—គឺជាលក្ខណៈពិសេសរបស់ភ្នែកម្ខាងៗ ( សូមមើលរូបភាពទី ១ ) ។

យើងមានអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះគម្ពីរប៊ីប និងអ្វីៗដ៏ពិសេស និង អស្ចារ្យដែលបានផ្ដល់យើង—សំខាន់បំផុតនោះគឺប្រវត្តិនៃព្រះជន្ម និង ការងារបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ ។

យើងក៏មានអំណរគុណយ៉ាងខ្លាំងចំពោះព្រះគម្ពីរមរមន និង គំហើញយ៉ាងល្អឥតខ្ចោះដែលគម្ពីរនេះផ្ដល់ដល់យើង ដែលបញ្ជាក់យ៉ាងច្បាស់ពីគោលលទ្ធិនៃព្រះគ្រីស្ទ ហើយបើកសម្ដែងនូវការបង្រៀនរបស់ទ្រង់តាមរយៈព្យាការីពីជំនាន់បុរាណនៅអាមេរិក ព្រមទាំងការយាងមកជួបផ្ទាល់ និងការបម្រើរបស់ទ្រង់ចំពោះសាសន៍នីហ្វៃ ។

ដូចជាភ្នែកទាំងគូដ៏ល្អឥតខ្ចោះដែរ ព្រះគម្ពីរប៊ីប និង ព្រះគម្ពីរមរមនគាំទ្រគ្នាទៅវិញទៅមក ដែលឆ្លុះបញ្ចាំងពីផ្ទាំងទស្សនីយភាពត្រួតស៊ីគ្នាដ៏អស្ចារ្យ ព្រមទាំងទិដ្ឋភាពយ៉ាងពិសេសចំពោះគ្នាទៅវិញទៅមក ។

### ៥. ការកម្ចាត់ចោលនូវផ្នែកមួយនៃភាពខ្វាក់របស់យើង

យើងទាំងអស់គ្នាមានផ្នែកមួយនៃភាពខ្វាក់នៃដែនគំហើញរបស់យើងដែលវាងាយស្រួលក្នុងការរកឃើញវា ។ សូមកាន់រូបរង្វង់ និង រូបផ្កាយ ( រូបភាពទី ៤ ) ដាក់ចំពីមុខអ្នកចម្ងាយមួយហោះដៃ ។ សូមបិទភ្នែកខាងឆ្វេងរបស់អ្នក ហើយប្រើភ្នែកស្ដាំរបស់អ្នកមើលឲ្យចំរង្វង់តូចនោះ ។ ដោយប្រើភ្នែកស្ដាំរបស់អ្នកសម្លឹងមើលរង្វង់នោះ សូមចាប់ផ្ដើមរំកិលរូបភាពនោះចូលមកជិតអ្នកយឺតៗ ។ នៅពេលរំកិលរូបភាពនោះបានប្រហែលជាពាក់កណ្ដាល ផ្កាយនោះ នឹងបាត់ពីគំហើញ *នៃកន្ទុយភ្នែក* ។

តើគួរឲ្យអស្ចារ្យទេ ? អ្នកពុំដឹងសោះថាអ្នកមានផ្នែកមួយនៃភាពខ្វាក់ដែរ ? ដោយសារភ្នែកទីពីររបស់អ្នកធ្វើឲ្យមានតុល្យភាពចំពោះផ្នែកមួយនៃភាពខ្វាក់នេះ នោះព្រះគម្ពីរមរមនផ្ដល់នូវអត្ថប្រយោជន៍ដូចគ្នានេះចំពោះព្រះគម្ពីរប៊ីប ។

ហើយដូចជាផ្កាយនោះបានបាត់ចេញពីភ្នែករបស់អ្នក នោះហេរ៉ូឌដែលពុំបានឃើញផ្កាយនៅបេថ្លេហិម ហើយបានសួរដល់ពួកហោរាថា « តើផ្កាយនោះបានលេចមកពីកាលណា » ( ម៉ាថាយ ២:៧ ) ។ វាគឺជា *ផ្នែកមួយនៃភាពខ្វាក់នឹងកន្ទុយភ្នែកនៃវិញ្ញាណរបស់ទ្រង់* ។ មានតែអស់អ្នកដែល *សម្លឹង* រកមើលផ្កាយតែប៉ុណ្ណោះទើបអាចឃើញវា ។

សព្វថ្ងៃនេះមានមនុស្សជាច្រើនដូចជាស្ដេចហេរ៉ូឌ ដែលបដិសេធពុំស្វែងរក និងមើលការណ៍នានានៃព្រះវិញ្ញាណ ។ « វេទនាដល់ពួកខ្វាក់ ដែលមិនព្រមមើល » ( នីហ្វៃទី ២ ៩:៣២ ) ។ ភាពឆ្មើងឆ្មៃក៏បានបណ្ដាលឲ្យពួកសាសន៍យូដា « [ មើលងាយ ] ដល់ព្រះបន្ទូលដ៏ច្បាស់លាស់ទាំងនេះ ហើយ . . . មកពីការខ្វាក់ [ ចំពោះពួកគេ ] ដោយមើលហួសទីដៅ » ( យ៉ាកុប ៤:១៤ ) ។



*៤. ការស្រាយបំភ្លឺពីផ្នែកមួយនៃភាពខ្វាក់*

ភាពច្បាស់លាស់មួយនៅក្នុង-*ការយល់ដឹងជ្រៅជ្រះ* នៃព្រះគម្ពីរមរមនគឺជាពាក្យព្រមានអំពីផ្នែកមួយនៃភាពខ្វាក់ជាសកលនៃ *អំនួត* « ជាអំពើបាបដែលងាយ *ឃើញ* នៅក្នុងខ្លួនមនុស្សដទៃ ប៉ុន្តែកម្រឃើញនៅក្នុងខ្លួនឯងឡើយ » ។[១០] វាគឺដូចជាការមានក្លិនខ្យល់ដង្ហើមអាក្រក់—ដែលមនុស្សគ្រប់គ្នាអាចដឹង លើកលែងតែសាមីខ្លួនប៉ុណ្ណោះដែលពុំដឹងខ្លួន ។

« នៅក្នុងក្រុមប្រឹក្សានៃជីវិតមុនជីវិតលើផែនដីនេះ វាជាភាពឆ្មើងឆ្មៃដែលលូស៊ីហ្វើរបានមាន » ។[១១] វាគឺជា « ភាពឆ្មើងឆ្មៃ . . . នៃសាសន៍នីហ្វៃ [ ដែល ] បានបញ្ជាក់ឲ្យឃើញនូវសេចក្ដីបំផ្លិចបំផ្លាញ » ( ម៉ូរ៉ូណៃ ៨:២៧ ) ។ អ្នកមានភាពឆ្មើងឆ្មៃនឹងត្រូវឆេះដូចជាជញ្រ្ជាំងនៅពេលព្រះយាងមកបោសសំអាតផែនដីនេះដោយភ្លើង ( សូមមើល ម៉ាឡាគី ៤:១; នីហ្វៃទី ៣ ២៥:១ ) ។

ការចាប់ផ្ដើមនៃផ្លូវតូច ហើយចង្អៀតត្រូវបានដាក់បង្ហាញយ៉ាងច្បាស់ដោយស្លាក « ព្រមាន » ៖ « ចូរប្រយ័ត្នពីសេចក្ដីឆ្មើងឆ្មៃ ក្រែងអ្នកកាល់គ្នាក្លាយទៅដូចជាពួកសាសន៍នីហ្វៃពីបុរាណ » ( គ. និង ស. ៣៨:៣៩ការសង្កត់ធ្ងន់ត្រូវបានបន្ថែម ) ។ ការចំអកដ៏ឈឺចាប់នោះគឺថាស្លាកសញ្ញានៃ « ការចូរប្រយ័ត្ន » *នោះ* គឺមាននៅក្នុង

ផ្នែកមួយនៃភាពខ្វាក់របស់មនុស្សឆ្មើងឆ្មៃជានិច្ច ។ ហេតុដូច្នោះហើយ « ចូរឲ្យអ្នកណាដែល [ ឆ្មើងឆ្មៃ ] ចេះមានប្រាជ្ញា ដោយការបន្ទាបខ្លួន និងដោយការអំពាវនាវដល់ព្រះអម្ចាស់ដ៏ជាព្រះរបស់ខ្លួន ប្រយោជន៍ឲ្យភ្នែកគេអាចបានបើកឡើង ដើម្បីឲ្យគេអាចមើលឃើញ » ( គ. និង ស. ១៣៦:៣២ ) ។

**៦. ទំនាក់ទំនងរវាងខួរក្បាល និង ភ្នែក**

សមីការនេះ ( សូមមើលរូបភាពទី ៥ ) បង្ហាញពីភាពត្រឹមត្រូវ ប៉ុន្តែវាពុំមែនត្រូវទាំងស្រុងនោះទេ ។ តាមពិតទៅប្រព័ន្ធរូបភាពនៃខួរក្បាលទេ ដែលប្រាប់យើងពីអ្វីដែលភ្នែករបស់យើងមើលឃើញ ។ ខួរក្បាលបង្កើតក្តីសុបិនរបស់យើងនៅពេលយប់ ហើយបកស្រាយនូវអ្វីដែលយើងមើលឃើញនៅពេលថ្ងៃ ។ ការមើលគឺពុំចាំបាច់ថាជាការជឿ ឬ ការមើលឃើញត្រឹមត្រូវឡើយ ។ ឧទាហរណ៍ « ប៉ុន្តែ ទោះបើ[ ព្រះយេស៊ូវ ] បានធ្វើទីសម្គាល់ នៅមុខគេជាច្រើនទាំងម្លេះក៏ដោយ គង់តែគេមិនបានជឿដល់ទ្រង់ដែរ » ( យ៉ូហាន ១២:៣៧ )។ ភ្នែកតែឯងពុំអាចជំរុញឲ្យមានសេចក្តីជំនឿ ឬ *មើលឃើញការពិតគ្រប់គ្រាន់ឡើយ* ។

ដូចដែលខួរក្បាលធ្វើការជាមួយភ្នែកដែរ នោះព្រះវិញ្ញាណធ្វើការជាមួយព្រះគម្ពីរដែលជួយយើងឲ្យមើលឃើញខាងវិញ្ញាណ ។ ដោយការគ្រាន់តែអានព្រះគម្ពីរគឺវាមិនគ្រាន់ ដើម្បីបង្កើតគំហើញខាងវិញ្ញាណឡើយ ព្រោះថា « មនុស្សខាងសាច់ឈាមគេមិនទទួលសេចក្តីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេក៏រកស្គាល់មិនបានដែរ ដ្បិតត្រង់ឯសេចក្តីទាំងនោះត្រូវពិចារណាយល់ខាងវិញ្ញាណវិញ » ( កូរិនថូសទី ១ ២:១៤ ) ។

ចំពោះព្រះគម្ពីរមរមនដើម្បីមានដំណើរការដូចភ្នែកខាងវិញ្ញាណ នោះយើងត្រូវតែទទួល និង ធ្វើតាមការអញ្ជើញរបស់មរ៉ូណៃដោយស្មោះសរនៅក្នុង មរ៉ូណៃ ១០:៣–៥។ វាគឺជាការអញ្ជើញដោយមានការសន្យាថាព្រះ «*នឹង* បង្ហាញសេចក្តីពិតដល់អ្នកដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ » ( ខទី ៤ការសង្កត់ធ្ងន់ត្រូវបានបន្ថែម ) ។

**សាក្សី និង អំណរគុណ**

ដើម្បីចៀសវាងពីភាពខ្វាក់ខាងវិញ្ញាណ នោះកូនប្រុសរបស់លីហៃបានប្រថុយជីវិតរបស់ខ្លួន ទៅយកផ្ទាំងលង្ហិន ( សូមមើល នីហ្វៃទី ១ ៣–៤ ) ។ ប្រសិនបើគ្មានផ្ទាំងនោះទេពួកគេ « ច្បាស់ជាចុះអន់ថយក្នុងការឥតជំនឿ » ( ម៉ូសាយ ១:៥ ) ។ សព្វថ្ងៃនេះ យើងមានអំណរគុណដល់កិច្ចការបោះពុម្ព និង ឧបករណ៍ឌីជីថលនានា ដែលយើងអាចទទួលបានព្រះគម្ពីរកាន់តែងាយស្រួល និង កាន់តែឆាប់រហ័ស ។ ប៉ុន្តែវាមានភាពខុសប្លែកបន្តិចចំពោះសាតាំង វារារាំងមនុស្សពុំឲ្យទទួលបានព្រះគម្ពីរ—ដែលជាយុទ្ធសាស្ត្ររបស់វានៅក្នុងយុគសម័យដ៏ខ្មៅងងឹត—ឬល្បួងមនុស្សកុំឲ្យអានព្រះគម្ពីរ—ដែលជាយុទ្ធសាស្ត្ររបស់វានៅក្នុងសម័យចុងក្រោយនេះ ។ ទោះជាតាមរបៀបណាមួយក្តី « អ័ព្ទនៃសេចក្តីងងឹត . . . *ធ្វើឲ្យភ្នែកទាំងឡាយនៃកូនចៅមនុស្សខ្វាក់* . . . [ ដោយជោគជ័យ ] . . . ដើម្បីឲ្យពួកគេវិនាស និង វង្វេងបាត់ទៅ » ( នីហ្វៃទី ១ ១២:១៧ការសង្កត់ធ្ងន់ត្រូវបានបន្ថែម ) ។

គឺដូចជាថ្នាំបន្តក់ភ្នែករបស់ខ្ញុំ *រៀងរាល់ថ្ងៃដែរ* វាមានតែតាមរយៈការ «*បន្ត* កាន់ដំបងដែកយ៉ាងខ្ជាប់ខ្ជួនជានិច្ច » ( នីហ្វៃទី ១ ៨:៣០ការសង្កត់ធ្ងន់ត្រូវបានបន្ថែម ) ដែលយើងអាចចៀសវាងពីការធ្វើឲ្យខ្វាក់ដោយអ័ព្ទនៃសម័យចុងក្រោយនេះដែលមានល្បិចយ៉ាងប៉ិនប្រសប់ និង ខ្លាំងក្លា ។ នៅពេលណាដែលបុគ្គលម្នាក់ប្រែជាពុំសូវសកម្ម ឬ ចាកចេញពីសាសនាចក្រ វាបង្ហាញស្ទើរតែច្បាស់ថា បុគ្គលនោះបានឈប់អានព្រះគម្ពីរមរមន ។

ព្រះគម្ពីរមរមនជា ៖សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ គឺពិតជាកិច្ចការចម្លែកហើយអស្ចារ្យ ។ វាគឺជា *សាក្សីជាក់នឹងភ្នែក* ទីពីរនៃព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អដ៏រុងរឿងរបស់ទ្រង់ ដោយផ្តល់នូវគុណសម្បត្តិទាំងអស់នៃភ្នែកទីពីរ ។

**ភ្នែកទាំងគូ = ពួកវាមើលឃើញ**

*៥.*

សូមឲ្យយើងកាន់ខ្ជាប់ជានិច្ចនឹងដំបងដែក ដើម្បីយើងអាចនឹងសមទៅនឹងពាក្យសរសើររបស់ព្រះអង្គសង្គ្រោះមានបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់ ៖ « អ្នករាល់គ្នាវិញ ភ្នែកអ្នកមានពរហើយ ដ្បិតមើលឃើញ » ( ម៉ាថាយ ១៣:១៦ ) ។ ■

**កំណត់ចំណាំ**

១. សូមមើល ម៉ាថាយ ៩:២៧–៣១; ១២:២២–២៣; ១៥:៣០–៣១; ២១:១៤; ម៉ាកុស ៨:២២–២៦; ១០:៤៦–៥២; លូកា ៧:២១–២២; យ៉ូហាន ៩; នីហ្វៃទី៣ ១៧:៧–៩; ២៦:១៥។
២. សូមមើល « Binocular Vision » Wikipedia, en.wikipedia.org ។
៣. សូមមើល រ៉ានដុហ្វ ប្លេក និង រ៉ូបឺត ហ្វុក « The Psychophysical Inquiry into Binocular Summation » *Perception & Psychophysics* ភាគទី ១៤ លេខ ១ ( ឆ្នាំ ១៩៧៣ ) ទំព័រ ១៦១–៦៨ សូមមើលផងដែរ « Binocular vision » ។
៤. សូមមើល « Vergence » Wikipedia, en.wikipedia.org ។
៥. « Binocular Vision » ។
៦. « Binocular Vision » ។
៧. *Teachings of Presidents of the Church: Ezra Taft Benson* ( ឆ្នាំ ២០១៤ ) ទំព័រ ១៤១ ។
៨. សូមមើល « Binocular Vision » ។
៩. « Peripheral Vision » Wikipedia, en.wikipedia.org ។
១០. *Teachings: Ezra Taft Benson,* ទំព័រ ១៨ ការសង្កត់ធ្ងន់ត្រូវបានបន្ថែម ។
១១. *Teachings: Ezra Taft Benson* ទំព័រ ២៣១ ។

# អព្ភូតហេតុ

## ទាំងប្រាំពីរនៅក្នុងដំណើរជីវិត



ដោយ អ៊ីហ្វ្រេម ស្មីធ

អំឡុងពេលបម្រើ និង បង្រៀនមនុស្សដ៏ល្អជាច្រើនរូបនៅក្នុងបេសកកម្ម រដ្ឋ តិចសាស ហ្វ៊ុដវើដ ជាញយៗខ្ញុំបានគិតពីពរជ័យនានានៅក្នុងជីវិតខ្ញុំ ។ ខ្ញុំមានការអស្ចារ្យយ៉ាងខ្លាំងចំពោះបទពិសោធន៍ទាំងប្រាំពីរ ដែលខ្ញុំបានចាត់ទុកថាជាអព្ភូតហេតុ ។

ដំបូង ខ្ញុំបានរស់នៅក្នុងជីវិតពីដើមរបស់ខ្ញុំ ដែលបានចាប់ផ្ដើមនៅក្នុងកាលៈទេសៈដ៏ក្រីក្របំផុត ។ ខ្ញុំបានកើតមកក្នុងខ្ទមរបស់ម្ដាយខ្ញុំនៅក្នុងដេស៊ី ប្រទេស អេត្យូពី ។ ម្ដាយរបស់ខ្ញុំគឺជាសាច់ញាតិតែម្នាក់គត់ដែលខ្ញុំស្គាល់ ហើយគាត់បានសង់ខ្ទមមួយរាងពោងដែលមានកំពស់ប្រហែល ២.៤ម៉ែត្រដោយខ្លួនគាត់ផ្ទាល់ ដោយប្រើឈើ និង ភក់ដែលគាត់ប្រកជាដំបូលដោយស្មៅ និង ស្លឹកឈើ ។ សហគមន៍របស់យើងគ្មានទឹកម៉ាស៊ីន និង បន្ទប់ទឹកប្រើឡើយ ។ ជំងឺ និង មរណភាពកើតឡើងរាលដាលនៅក្នុងភូមិ *កេបេឡេ* ឬ ភូមិរបស់យើង ។ យើងពិបាករកអាហារ និង ទិញអាហារបានណាស់ ។ ម្ដាយខ្ញុំ និង ខ្ញុំមានការស្រេកឃ្លានរាល់ថ្ងៃ ។

កាលខ្ញុំអាយុបួនឆ្នាំ ម្ដាយរបស់ខ្ញុំបានឈឺយ៉ាងធ្ងន់ធ្ងរ ដោយប្រឹងអស់ពីលទ្ធភាពសេសសល់របស់គាត់ យើងបានធ្វើដំណើរយ៉ាងត្រដាបត្រដួសទៅមន្ទីរពេទ្យ ដែលជាទីកន្លែងដែលម្ដាយដ៏ជាទីស្រឡាញ់ និង ហេវហត់របស់ខ្ញុំបានចែកឋានទៅ ។ បុគ្គលិកនៅមន្ទីរពេទ្យនោះបានជួយសង្គ្រោះជីវិតរបស់ខ្ញុំ ពីចិញ្ចើមថ្នល់ និង ពីភាពមរណាដោយគ្រោះទុរភិក្ស ដោយរៀបចំខ្ញុំឲ្យរស់នៅក្នុងមជ្ឈមណ្ឌលកុមារកំព្រានៅក្នុងទីក្រុង អាឌីស អាបាបា ដែលជារាជធានីនៃប្រទេស អេត្យូពី ។

អព្ភូតហេតុទីពីរបានកើតមាន នៅពេលមានការផ្លាស់ប្ដូរមួយយ៉ាងធំនៅក្នុងជីវិតរបស់ខ្ញុំ ។ ខ្ញុំបានរស់នៅក្នុងអគារដ៏មានអនាម័យនៅក្នុងមជ្ឈមណ្ឌលកុមារកំព្រា ដេកនៅលើគ្រែ ហើយបរិភោគអាហារគ្រប់យ៉ាងដែលខ្ញុំចង់ ។ ក្មេងកំព្រាផ្សេងទៀតក៏មានបទពិសោធន៍បាត់បង់មនុស្សជាទីស្រឡាញ់របស់ខ្លួនផងដែរ ហើយពួកគេបានបង្រៀនខ្ញុំ ពីរបៀបដើម្បីកាត់ចិត្តពីការបាត់បង់ម្ដាយរបស់ខ្ញុំ ។ នៅពេលល្ងាចយើងជួបជុំគ្នាច្រៀងចម្រៀងជាភាសាអង់គ្លេស ហើយអធិស្ឋានជាភាសាអាមហារីដែលជាភាសាកំណើតរបស់យើង ។ យើងបានអធិស្ឋានសម្រាប់គ្នាទៅវិញទៅមក ហើយទូលសុំដល់ព្រះឲ្យប្រទានពរដល់យើង ដើម្បីត្រូវបានគេយកទៅចិញ្ចឹម



*ព្រះអម្ចាស់បានប្រទានពរដល់ជីវិតរបស់ខ្ញុំជាច្រើន ដែលបានជួយខ្ញុំឲ្យដើរតាមផ្លូវដែលទ្រង់មានសម្រាប់ខ្ញុំ ។*

រូបគំនូរ ដោយ អ៊ែ ហានសិន

នៅក្នុងផ្ទះដែល « ស្អាត មានចិត្តទូលាយ និង ពេញដោយក្ដីស្រឡាញ់ » ។ ទាំងតន្ត្រី និង ការអធិស្ឋានមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងជីវិតរបស់ខ្ញុំ ។ ខ្ញុំពុំដែលឈប់អធិស្ឋានឡើយ ។

ទីបី ខ្ញុំត្រូវបានណែនាំឲ្យជួបអ្នកផ្សព្វផ្សាយសាសនា និង សាសនាចក្រកាលខ្ញុំអាយុ ៨ ឆ្នាំ ។ ខ្ញុំត្រូវបានអញ្ជើញឲ្យចូលរួមពិធីឧទ្ទិសឆ្លងអគារសាសនាចក្រ អិល. ឌី. អេស. ដំបូងគេនៅក្នុងប្រទេសអេត្យូពីនៅថ្ងៃអាទិត្យ ទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ។ នៅក្នុងពិធីឧទ្ទិសឆ្លងនោះ ខ្ញុំមានអារម្មណ៍យ៉ាងខ្លាំងពីព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ហើយអ្នកផ្សព្វផ្សាយសាសនាដែលបានចូលរួមនោះបានចែកចាយនូវក្ដីអំណរ សុភមង្គល និង អំណាចនៃព្រះវិញ្ញាណដូចគ្នានឹងខ្ញុំដែរ ។ ខ្ញុំបានចាំថា ខ្ញុំចង់ធ្វើដូចពួកគេ ។ ប៉ុន្តែខ្ញុំពុំដឹងសោះឡើយថា តើខ្ញុំអាចសម្រេចបានគោលដៅនេះដោយរបៀបណា ។

មិនយូរប៉ុន្មានអព្ភូតហេតុទីបួនបានកើតឡើង ។ មានគ្រួសារមួយនៅសហរដ្ឋបានសុំខ្ញុំយកទៅចិញ្ចឹម ។ ឪពុកថ្មីរបស់ខ្ញុំបានមកទទួលខ្ញុំពីមជ្ឈមណ្ឌលកុមារកំព្រា ហើយបានយកខ្ញុំទៅផ្ទះ ។ យើងបានចាប់ផ្ដើមស្គាល់គ្នា ហើយខ្ញុំបានចាប់ផ្ដើមសាំនឹងបរិយាកាសថ្មីរបស់ខ្ញុំ ។

មានឧបសគ្គរាប់មិនអស់បានកើតឡើងភ្លាមពេលខ្ញុំទៅដល់ទីនោះ ។ មនុស្សជាច្រើនបានសើចចំអកចំពោះភាសាអង់គ្លេសរបស់ខ្ញុំគ្រប់កន្លែងដែលខ្ញុំទៅ ។ ការអប់រំតិចតួចរបស់ខ្ញុំធ្វើឲ្យមានបញ្ហានានានៅសាលារៀន ។ ខ្ញុំបានអធិស្ឋានសុំជំនួយ ហើយក្រោយមកខ្ញុំបានខិតខំកាន់តែខ្លាំងឡើង និង កាន់តែឈ្លាសវៃដើម្បីបង្កើនចំណេះដឹងរបស់ខ្ញុំ ជាពិសេសភាសាអង់គ្លេស ។ ជាថ្មីម្ដងទៀតព្រះវរបិតាសួគ៌បានឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ ។ ពីរឆ្នាំក្រោយមក ខ្ញុំបានឡើងថ្នាក់ដោយមានមោទភាព ។

ក្រោយមកជីវិតខ្ញុំនៅផ្ទះនោះមានការប្រេះឆា ។ ការអធិស្ឋានដល់ព្រះអម្ចាស់ដាក់គោលដៅផ្ទាល់ខ្លួនយ៉ាងខ្ពស់ និង មានបំណងប្រាថ្នាយ៉ាងខ្លាំងដើម្បីមានជោគជ័យបានជួយខ្ញុំឲ្យហែលឆ្លងកាត់គ្រាដ៏លំបាកនោះ ។ ទីបំផុត ដោយមានជំនួយពីអ្នកធ្វើការខាងសង្គម ឪពុករបស់ខ្ញុំ និង ខ្ញុំបានយល់ព្រមបញ្ចប់ការសុំមកចិញ្ចឹម ។ នេះគឺជាគ្រាមួយនៃការអធិស្ឋាន ការអត់ធ្មត់ សេចក្ដីជំនឿ និង ជំនួយមកពីព្រះវរបិតាសួគ៌ ។

ឥឡូវអាយុ ១៥ ឆ្នាំខ្ញុំបានទៅរស់នៅជាមួយគ្រួសារចិញ្ចឹមមួយប្រមាណជាមួយឆ្នាំ ។ នោះគឺជាគ្រាដែលអព្ភូតហេតុទីប្រាំបានកើតឡើង ។ ខណៈកំពុងជិះគារទឹកកកជាមួយមិត្តភក្ដិពីរនាក់ នោះខ្ញុំបានជួបគ្រួសារអិល. ឌី. អេស. មួយ ដែលមានកូនស្រីរួសរាយពីរនាក់ ។ អំឡុងពេលធ្វើដំណើរមកផ្ទះវិញ មានកូនស្រីម្នាក់បាននិយាយថា « ខ្ញុំគិតថា ព្រះអម្ចាស់មានព្រះទ័យឲ្យយើងយកអេប្រ្ហែម ស្មីធ ទៅចិញ្ចឹម » ។ វាអស្ចារ្យណាស់ សមាជិកបីនាក់ទៀតក្នុងគ្រួសារនោះក៏បានទទួលអារម្មណ៍នៃការបំផុសគំនិតនោះដូចគ្នាផងដែរ ។ ឪពុកនៃគ្រួសារនោះបានធ្វើការជាមួយនាយកដ្ឋានសេវកម្មសង្គម ហើយមិនយូរប៉ុន្មានខ្ញុំបានប្ដូរទៅរស់នៅផ្ទះថ្មីរបស់ខ្ញុំ ។ ចាប់តាំងពីពេលដំបូងមកឪពុកថ្មីដ៏អស្ចារ្យរបស់ខ្ញុំបានផ្ដល់សិទ្ធិជ្រើសរើសដល់ខ្ញុំ ។ ឧទាហរណ៍ គាត់បានពន្យល់ថាគ្រួសាររបស់គាត់ទៅព្រះវិហារនៅរៀងរាល់ថ្ងៃអាទិត្យ ។ គាត់បានទុកសិទ្ធិឲ្យខ្ញុំជ្រើសរើសចូលរួមជាមួយពួកគេ ឬ នៅផ្ទះ គាត់បាននិយាយថា ពួកគេនៅតែស្រឡាញ់ខ្ញុំ បើទោះបីជាខ្ញុំជ្រើសរើសពុំចូលរួមព្រះវិហារក្ដី ។ ខ្ញុំបានជ្រើសរើសចូលរួមព្រះវិហារ ហើយចាប់ពីពេលនោះមក ខ្ញុំបានធ្វើការសម្រេចចិត្តនានាដោយសុចរិត ។

អព្ភូតហេតុទីប្រាំមួយបានកើតឡើង នៅពេលខ្ញុំបានទទួលទីបន្ទាល់មួយអំពីដំណឹងល្អ ។ នាថ្ងៃអាទិត្យមួយខ្ញុំបានអង្គុយនៅក្នុងម៉ោងប្រជុំសាក្រាម៉ង់ដោយច្រៀងបទ « ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យ » (*ទំនុកតម្កើង* លេខ ១១៥ ) ។ ខ្ញុំបានចាប់ផ្ដើមយំយ៉ាងខ្លាំង នៅពេលខ្ញុំបានទទួលទីបន្ទាល់ផ្ទាល់ខ្លួនថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយថាសាសនាចក្រនេះគឺជាសាសនាចក្រទ្រង់ ។

ទីបំផុត ប្រាំបួនឆ្នាំក្រោយមក ខ្ញុំបានដឹងពីរបៀបដែលខ្ញុំចង់ក្លាយដូចជាអ្នកផ្សព្វផ្សាយសាសនាទាំងនោះ ! ឥឡូវនេះអាយុអ្នកផ្សព្វផ្សាយសាសនាគឺ ១៨ ឆ្នាំ ប៉ុន្តែការសុំខ្ញុំមកចិញ្ចឹមពុំទាន់បំពេញសព្វគ្រប់នៅឡើយទេ ។ ខ្ញុំបានរង់ចាំរយៈពេលប្រាំពីរខែទៀតរហូតដល់ការសុំខ្ញុំមកចិញ្ចឹមបានបំពេញសព្វគ្រប់ ។ ទីបំផុត ទម្រង់បែបបទជាអ្នកផ្សព្វផ្សាយសាសនារបស់ខ្ញុំអាចដាក់ស្នើសុំបានហើយ ។ បួនថ្ងៃក្រោយមកខ្ញុំបានទទួលការហៅបម្រើបេសកកម្មរបស់ខ្លួន ។ គ្រាន់តែមួយសប្ដាហ៍ប៉ុណ្ណោះ ព្រះអម្ចាស់បានប្រទានពរដល់ខ្ញុំនូវឯកសារសម្រេចសុំខ្ញុំមកចិញ្ចឹម និង ការហៅបម្រើបេសកកម្មរបស់ខ្ញុំ ។ ខ្ញុំបានឲ្យតម្លៃយ៉ាងខ្ពស់ដល់ឯកសារទាំងពីរនេះយ៉ាងខ្លាំង ! ឯកសារនេះគឺជាអព្ភូតហេតុទីប្រាំពីររបស់ខ្ញុំ ។ មែនហើយ តាមពិតទៅ មានអព្ភូតហេតុច្រើនបានកើតឡើងក្នុងដំណើរជីវិតនេះចាប់តាំងពីខ្ញុំធ្វើពីភក់នៅក្នុងប្រទេសអេត្យូពីរហូតមកដល់បេសកកម្មដ៏មានតម្លៃរបស់ខ្ញុំ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ណារ៉ាដា ស.រ.អា. ។*

# ចូរមកតាមខ្ញុំ ៖ ការបង្រៀនមូលដ្ឋានគ្រឹះនៅក្នុងគេហដ្ឋាន

តាមរយៈគំរូនានានៃសមាជិកទាំងនេះ អ្នកក៏អាចយកគោលការណ៍នានាមកពីកម្មវិធីសិក្សារបស់យុវវ័យទៅក្នុងគេហដ្ឋានរបស់ខ្លួនបាន ។

ដោយ អាលីសា ស្តានចុន និង ណាថាលី ខេមបែល

ដូចដែលសាវកបានបង្រៀនម្តងហើយម្តងទៀតថា « ភាពជោគជ័យរបស់យើងម្នាក់ៗ និង សាសនាចក្រទាំងមូលនឹងត្រូវបានកំណត់យ៉ាងខ្លាំងទៅលើរបៀបដែលយើងផ្តោតចិត្តទុកដាក់យ៉ាងស្មោះត្រង់លើការរស់ នៅតាមដំណឹងល្អនៅគេហដ្ឋាន » ។[១]

ការរស់នៅតាមដំណឹងល្អគឺជារបៀបដ៏ល្អបំផុតដើម្បីរៀន និង បង្រៀនដំណឹងល្អ ។ នៅពេលយើងរស់នៅតាមគោលការណ៍នៃគោលលទ្ធិទាំងនេះ នោះយើងនឹងនាំគ្រួសារ និង ខ្លួនយើងឲ្យខិតកាន់តែជិតនឹងព្រះវិញ្ញាណ ។ ដោយមានជំនួយពីព្រះវិញ្ញាណ នោះយើងអាចរៀន និង បង្រៀនគោលការណ៍ទាំងនេះបានយ៉ាងល្អបំផុត ។ យើងនឹងត្រូវបានដឹកនាំទៅរកវិធីសាស្ត្ររៀនសូត្រដែលប្រកបដោយប្រសិទ្ធភាពបំផុតសម្រាប់សេចក្តីត្រូវការ និង កាលៈទេសៈរបស់យើង ព្រមទាំងគ្រួសារយើង ឲ្យរីកចម្រើនកាន់តែខិតជិតនឹងព្រះអង្គសង្គ្រោះ ។







# កក្កដា ៖

**ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញា**

ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាពិសិដ្ឋនៃបព្វជិតភាព—ការសន្យានានាដែលយើងបានធ្វើជាមួយព្រះវរបិតាសួគ៌—នាំមកនូវពរជ័យដ៏ខ្លាំងក្លាក្នុងជីវិតរបស់យើង ។ របៀបមួយដើម្បីមើលឃើញពីគោលបំណងនៃពិធីបរិសុទ្ធនោះ គឺ ការគិតពីពិធីទាំងនោះថា ជាពិធីសំខាន់នៅលើផ្លូវដែលនាំត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតាសួគ៌វិញ—គឺជីវិតដ៏នៅអស់កល្បជានិច្ច ។ យើងបន្តនៅលើផ្លូវនោះតាមរយៈការគោរពសេចក្ដីសញ្ញានានា ដែលយើងបានធ្វើ ។

ឧទាហរណ៍ យុវនារីម្នាក់បានពិពណ៌នា ពីរបៀបដែលនាងបានបន្តនៅលើផ្លូវនៃសេចក្ដីសញ្ញានេះ ៖ « មានគ្រាមួយនោះមិត្តរួមថ្នាក់របស់ខ្ញុំបានសុំឲ្យខ្ញុំជួយ ។ ខ្ញុំពុំបានគិតច្រើនពីការសុំជំនួយនោះទេ គឺគ្រាន់តែផ្ដល់នូវជំនួយដែលនាងត្រូវការប៉ុណ្ណោះ ។ ប៉ុន្តែក្រោយមក ព្រះវិញ្ញាណបានរំឭកខ្ញុំថា តាមរយៈការជួយទទួលបន្ទុករបស់នាង នោះខ្ញុំកំពុងរក្សាសេចក្ដីសញ្ញាដែលខ្ញុំបានធ្វើ នៅពេលខ្ញុំជ្រមុជទឹក ( សូមមើល ម៉ូសាយ ១៨:៨–១០ ) ។ ខ្ញុំមានអំណរគុណចំពោះឱកាសនានា ដែលព្រះវរបិតាសួគ៌បានប្រទានដល់ខ្ញុំរាល់ថ្ងៃឲ្យជ្រើសរើសដើរតាមផ្លូវនៃសេចក្ដីសញ្ញា » ។

ជាគ្រួសារ អ្នកអាចស្វែងរកពិធីបរិសុទ្ធនានាដែលសមាជិកម្នាក់ៗនៅតែត្រូវការទទួល ហើយក្រោយមកវាយតម្លៃថា តើអ្នកកំពុងរក្សាសេចក្ដីសញ្ញាដែលខ្លួនបានធ្វើនោះខ្លាំងប៉ុណ្ណា ។ ឧទាហរណ៍ តើការរៀបចំរបស់អ្នកដើម្បីទទួលពិធីបរិសុទ្ធសាក្រាម៉ង់ប្រចាំសប្ដាហ៍ឆ្លុះបញ្ចាំងពីការតាំងចិត្តរបស់អ្នកដូចម្ដេចខ្លះចំពោះសេចក្ដីសញ្ញានានានោះ ? ព្រះវិញ្ញាណបរិសុទ្ធអាចបង្រៀនអ្នកពីរបៀបដើម្បីកែលម្អ ។



ខាងលើ ៖ រូបថតដោយ ដារីន ស្មីធ

# សីហា ៖

**អាពាហ៍ពិពាហ៍ និង គ្រួសារ**

អាពាហ៍ពិពាហ៍ និង គ្រួសារគឺជាផ្នែកសំខាន់ចំពោះសុភមង្គលរបស់យើង និង ចំពោះផែនការរបស់ព្រះវរបិតាសួគ៌ សម្រាប់សេចក្ដីសង្គ្រោះរបស់យើង ។ គ្រួសារគឺជាអង្គភាពដ៏សំខាន់ក្នុងកាលវេលានេះ និងក្នុងភាពដ៏នៅអស់កល្បជានិច្ច ។

ការបង្រៀនកូនចៅរបស់អ្នកអំពីអាពាហ៍ពិពាហ៍ និង គ្រួសារ អាចមានភាពងាយស្រួល ដូចជាការចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន ។ យុវមជ្ឈិមវ័យម្នាក់បានចែកចាយពីរបៀប ដែលនាងបានកើនអំណរគុណចំពោះការផ្សារភ្ជាប់របស់នាងនៅក្នុងព្រះវិហារបរិសុទ្ធ ៖

« ខ្ញុំបានចាំពីការអង្គុយម្នាក់ឯងនៅក្នុងបន្ទប់សេឡេស្ទាលនៅក្នុងព្រះវិហារបរិសុទ្ធ ។ ខ្ញុំមានការភិតភ័យ ដោយពុំដឹងថាតើខ្ញុំនឹងត្រូវបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ នៅថ្ងៃនោះដែរឬទេ ដោយសារតែទំនាក់ទំនងមិនច្បាស់លាស់អំពីប័ណ្ណចូលព្រះវិហារបរិសុទ្ធរបស់គូដណ្ដឹងរបស់ខ្ញុំ ។



« ខ្ញុំបានអធិស្ឋានយ៉ាងខ្លាំងថា ព្រះអម្ចាស់នឹងអនុញ្ញាតឲ្យយើងបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធនៅថ្ងៃនោះ ។ នៅពេលខ្ញុំបានអធិស្ឋាន នោះមានគំនិតមួយបានផុសក្នុងដួងចិត្តខ្ញុំ ៖ ទោះបីអ្នកនៅតែឯងនៅក្នុងបន្ទប់សេឡេស្ទាលនេះក្ដី នគរសេឡេស្ទាលគឺជាពិភពសេឡេស្ទាលព្រោះថាអ្នកពុំនៅទីនោះតែឯងឡើយ ។ អ្នកនឹងនៅជាមួយគ្រួសារអស់កល្បជានិច្ចរបស់អ្នក និង គ្រួសារសួគ៌របស់អ្នក ។ ហើយនោះជាមូលហេតុដែលអ្នកត្រូវបានផ្សារភ្ជាប់ ។

« សែសិបនាទី និង បន្ទាប់ពីបានទូរសព្ទពីរបីដងក្រោយមក ស្វាមីរបស់ខ្ញុំ ហើយនឹងខ្ញុំអាចផ្សារភ្ជាប់បាន ។ ខ្ញុំមានអំណរគុណ និង មានអារម្មណ៍ធូរស្បើយយ៉ាងខ្លាំងក្រៃលែង ។ ពិធីបរិសុទ្ធនោះបានប្រែកាន់តែមានន័យចំពោះខ្ញុំ ដោយសារយើងអាចបង្កើតជីវិតសេឡេស្ទាលជាមួយព្រះ ជាទីកន្លែងដែលយើងនឹងមិននៅតែម្នាក់ឯងនោះទេ » ។

តើបទពិសោធន៍អ្វីខ្លះ ដែលបានបង្រៀនអ្នកអំពីតួនាទីនៃអាពាហ៍ពិពាហ៍ និង គ្រួសារនៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌ ? ព្រះវិញ្ញាណបរិសុទ្ធអាចជួយអ្នកឲ្យចាំ ហើយចែកចាយបទពិសោធន៍សមរម្យ ។ ដោយមិនគិតពីស្ថានភាពគ្រួសាររបស់អ្នក ព្រះវិញ្ញាណបរិសុទ្ធអាចបង្រៀនអ្នកពីរបៀប ដើម្បីអនុវត្តគោលការណ៍នៃអាពាហ៍ពិពាហ៍ និង គ្រួសារនៅក្នុងជីវិតអ្នក ។




# កញ្ញា ៖

### បទបញ្ញត្តិ

បទបញ្ញត្តិទាំងឡាយគឺជាក្រឹត្យវិន័យ និងជាតម្រូវការដែលព្រះវរបិតាសួគ៌ជាទីស្រឡាញ់បានប្រទានឲ្យដើម្បីប្រទានពរដល់ជីវិតរបស់យើង ។

របៀបមួយដ៏មានឥទ្ធិពលដើម្បីសិក្សាពីបទបញ្ញត្តិនោះគឺ ការស្រាវជ្រាវខគម្ពីរដើម្បីរៀនអំពីពរជ័យនានាដែលកើតឡើងមកពីការគោរពប្រតិបត្តិ ដូចដែលយុវមជ្ឈិមវ័យម្នាក់នេះបានធ្វើ ៖

« នៅពេលខ្ញុំសិក្សាអំពីបទបញ្ញត្តិ នោះខ្ញុំចង់អានខគម្ពីរទាំងអស់ដើម្បីខ្ញុំអាចរកវាឃើញ ហើយធ្វើបញ្ជីមួយនៃពរជ័យនានាដែលព្រះវរបិតាសួគ៌សន្យាដោយសារការគោរពប្រតិបត្តិរបស់ខ្ញុំ ។ ការរៀនបន្ថែមទៀតអំពីពរជ័យ ដែលបានសន្យាបានពង្រឹងដល់ទីបន្ទាល់របស់ខ្ញុំថា ព្រះវរបិតាសួគ៌ស្រឡាញ់ខ្ញុំ ហើយមានព្រះទ័យចង់ប្រទានពរដល់ខ្ញុំ » ។

ដើម្បីរៀន ឬ បង្រៀនអំពីបទបញ្ញត្តិនានា អ្នកអាចអានមេរៀនទី ៤ ជំពូកទី ៣ នៃ *ប្រកាសដំណឹងល្អរបស់យើង* ជាមួយកូនៗរបស់អ្នក សិក្សាខគម្ពីរដែលទាក់ទងគ្នាទាំងនោះ ហើយធ្វើបញ្ជីនៃពរជ័យដែលបានសន្យាផ្ទាល់ខ្លួនរបស់អ្នក ។ អ្នកអាចប្រើវិធីសាស្ត្រនេះដើម្បីរៀនអំពីពរជ័យនានាដែលទាក់ទងជាមួយនឹងគោលការណ៍នានានៃដំណឹងល្អ ។

# តុលា ៖

### ការប្រែក្លាយឲ្យកាន់តែដូចជាព្រះគ្រីស្ទ

អំឡុងពេលការបម្រើរបស់ព្រះគ្រីស្ទ ទ្រង់បានត្រាស់បង្គាប់យើងថា « ចូរឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ដូចព្រះវរបិតានៃអ្នកដែលគង់នៅស្ថានសួគ៌ទ្រង់គ្រប់លក្ខណ៍ដែរ » ( ម៉ាថាយ ៥:៤៨ ) ។ យើងព្យាយាមឈានទៅរកភាពគ្រប់លក្ខណ៍ នៅពេលយើងធ្វើការអភិវឌ្ឍយ៉ាងសាមញ្ញនូវលក្ខណៈមួយរបស់ព្រះគ្រីស្ទ មួយម្តងៗ ហើយព្យាយាមកែលម្អក្នុងបុគ្គលិកលក្ខណៈនោះដោយមានជំនួយពីទ្រង់ ។ យុវជនម្នាក់បានចាប់ផ្តើមដោយធ្វើការកែលម្អលើឧស្សាហ៍ព្យាយាម ។



« ខ្ញុំចង់អភិវឌ្ឍលក្ខណៈឲ្យកាន់តែដូចជាព្រះគ្រីស្ទ ដូច្នោះខ្ញុំបានសិក្សាព្រះគម្ពីររបស់ខ្ញុំ និង *ប្រកាសដំណឹងល្អរបស់យើង*។ នៅក្នុងជំពូកទី ៦នៃ *ប្រកាសដំណឹងល្អរបស់យើង* ខ្ញុំបានរកឃើញគំរូមួយដែលបានផ្តល់ជាយោបល់ ដើម្បីអភិវឌ្ឍលក្ខណៈដូចជាព្រះគ្រីស្ទ ហើយបានសម្រេចចិត្តព្យាយាមធ្វើវាជាមួយនឹងលក្ខណៈមួយនៃភាពឧស្សាហ៍ព្យាយាម ។ ដំបូងខ្ញុំបានសរសេរនិយមន័យនៃឧស្សាហ៍ព្យាយាម និងសំណួរនានាដែលខ្ញុំមានអំពីវា ។ ក្រោយមកខ្ញុំបានអានខគម្ពីរដែលបានផ្តល់ឲ្យនោះ ដែលស្តីអំពីភាពឧស្សាហ៍ព្យាយាម ហើយបានកត់ត្រានូវការបំផុសគំនិត និង ចម្លើយរបស់ខ្ញុំដែលខ្ញុំបានរកឃើញ ពេលខ្ញុំអាន ។ បន្ទាប់មក ខ្ញុំបានដាក់គោលដៅដើម្បីប្រែកាន់តែខំប្រឹងឧស្សាហ៍ព្យាយាមដោយធ្វើកិច្ចការសាលារបស់ខ្ញុំ ហើយនៅពេលអធិស្ឋានរាល់យប់ខ្ញុំបានមានអារម្មណ៍ជំរុញចិត្តកាន់តែខ្លាំង និង ខ្ជាប់ខ្ជួនចំពោះភាពឧស្សាហ៍ព្យាយាម »។

នៅពេលអ្នកព្យាយាមអភិវឌ្ឍ ហើយបង្រៀនកូនៗរបស់អ្នកពីរបៀបអភិវឌ្ឍលក្ខណៈដូចជាព្រះគ្រីស្ទ នោះធនធាននានារបស់សាសនាចក្រអាចជួយអ្នកឲ្យដឹងពីកន្លែងដែលអ្នកចាប់ផ្តើម ។ ព្រះគម្ពីរផ្តល់នូវគំរូរបស់ព្រះគ្រីស្ទជានិច្ច ហើយធនធាននានាដូចជា *ប្រកាសដំណឹងល្អរបស់យើង* ផ្តល់នូវគំរូដែលជួយយើងឲ្យបង្កើតនូវទម្លាប់នៃការសិក្សា និង ការដាក់គោលដៅ ។ នៅពេលយើងប្រើព្រះគម្ពីរ និង ធនធានដទៃទៀតជាមួយគ្នា នោះវាជួយយើងឲ្យអនុវត្តអ្វីដែលយើងរៀន ប្រយោជន៍ឲ្យយើងអាចប្រែកាន់តែដូចជាព្រះគ្រីស្ទ ។





# វិច្ឆិកា ៖

## ភាពខ្លួនទីពឹងខ្លួនខាងវិញ្ញាណ និង ខាងសាច់ឈាម



ការអភិវឌ្ឍន៍ភាពខ្លួនទីពឹងខ្លួន មានន័យថា ការអនុវត្តនូវសិទ្ធិជ្រើសរើសរបស់យើងដើម្បីខ្វល់ខ្វាយសម្រាប់ខ្លួនយើង និង គ្រួសារយើង ព្រមទាំងការធ្វើកិច្ចការឲ្យអស់ពីសមត្ថភាពរបស់យើង ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាផ្ទាល់ខ្លួនរបស់យើង ។ ការប្រែកាន់តែមានភាពខ្លួនទីពឹងខ្លួនផ្តល់ការបង្កើននូវសមត្ថភាពរបស់យើង ដើម្បីបម្រើនៅក្នុងផ្ទះ សាសនាចក្រ និង សហគមន៍របស់យើង ។ វិធីមួយដ៏ល្អបំផុតដើម្បីបង្រៀនមនោគតិទាំងនេះគឺតាមរយៈគំរូ ដូចដែលសមាជិករូបនេះបានពិពណ៌នា ៖

« តាមខ្ញុំនៅចាំបាន ម្តាយរបស់ខ្ញុំបានក្រោកពីព្រលឹមរាល់ថ្ងៃដើម្បីសិក្សាព្រះគម្ពីរ ។ ខ្ញុំបានឃើញរបៀបដែលគាត់បានអភិវឌ្ឍកម្លាំងខាងវិញ្ញាណដែលនាំគាត់ឲ្យឆ្លងកាត់គ្រាលំបាកនានា ។ គាត់បានពឹងផ្អែកលើទំនាក់ទំនងផ្ទាល់របស់គាត់ជាមួយព្រះវរបិតាសួគ៌ ដើម្បីធ្វើជាអ្នកគាំទ្រដល់គាត់ ។ ជាមួយនឹងកម្លាំងខាងវិញ្ញាណរបស់គាត់ នោះខ្ញុំមានចិត្តអស្ចារ្យយ៉ាងខ្លាំងចំពោះលទ្ធភាពរបស់គាត់ ដើម្បីមើលថែទាំដល់គ្រួសាររបស់យើង ។ ខ្ញុំបានឃើញពីថវិការបស់គាត់ ការលះបង់ចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរបស់គាត់ ព្យាយាមសិក្សាអប់រំ ហើយបង្ហាញពីការបន្ទាបខ្លួនជាច្រើនក្នុងរបៀបមួយដែលធ្វើឲ្យគាត់បំពេញនូវសេចក្តីត្រូវការខាងហិរញ្ញវត្ថុគ្រួសាររបស់យើង ហើយនៅតែនៅផ្ទះជាមួយកូនៗរបស់គាត់បន្ទាប់មកពីសាលារៀន ។ ខ្ញុំចង់បាននូវកម្លាំងដែលគាត់មាន ហើយខ្ញុំមានអំណរគុណយ៉ាងខ្លាំងចំពោះគំរូរបស់គាត់ដែលបង្រៀនខ្ញុំពីរបៀបដើម្បីទទួលបានគំរូនោះ » ។

តើអ្នកអាចកាន់តែក្លាយជាគំរូនៃការរស់នៅដោយមានការបម្រុងទុកឲ្យកាន់តែប្រសើរឡើង ចំពោះកូនៗរបស់អ្នកបានយ៉ាងដូចម្តេច ? ប្រសិនបើអ្នកពុំចេះច្រើនពីកត្តាជាក់លាក់នានានៃភាពខ្លួនទីពឹងខ្លួននោះនៅឡើយ នោះអ្នកអាចអញ្ជើញកូនៗរបស់អ្នកឲ្យរៀនជាមួយអ្នក ហើយថាវានឹងក្លាយជាគំរូមួយដ៏អស្ចារ្យនៅក្នុងរឿងនោះ ។



*រូបភាពដកស្រង់ចេញពី ស្ត្រីបានជាសះស្បើយ ដោយ ជេ ឃើក រីឆាដ*

# ធ្នូ ៖

## ស្ថាបនានគរព្រះនៅថ្ងៃចុងក្រោយនេះ

« ប្រហែលជាព្រះនាងបានតាំងឡើងក្នុងរាជ្យសម្រាប់ពេលនេះឯងទេដឹង ? » ( នាងអេសធើរ ៤:១៤ ) ។ នេះគឺជាសំណួរមួយ ដែលអ្នកអាចសួរខ្លួនអ្នក ឬ កូនៗរបស់អ្នកនៅពេលអ្នករកឃើញតួនាទីរបស់អ្នកនៅក្នុងការស្ថាបនានគរព្រះ ។

សមាជិករូបនេះបានរៀនទុកចិត្តលើព្រះអម្ចាស់ ដើម្បីជួយគាត់ស្ថាបនានគរព្រះ ៖ « ខ្ញុំចាំពីការបង្រៀនរបស់ឪពុកម្តាយរបស់ខ្ញុំ តាំងពីខ្ញុំនៅក្មេង ថាយើងតែងតែទទួលការហៅបម្រើរបស់យើងជានិច្ច ដោយសារការហៅបម្រើនោះគឺត្រូវបានប្រទានមកពីព្រះ ។ អំឡុងពេលរៀននៅមហាវិទ្យាល័យ ខ្ញុំត្រូវបានហៅឲ្យបម្រើជាប្រធានសមាគមសង្គ្រោះ ។ ខ្ញុំមានអារម្មណ៍ភិតភ័យ ប៉ុន្តែការណ៍នេះពុំធ្វើឲ្យខ្ញុំនិយាយបដិសេធពុំទទួលវាឡើយ ។ ដូច្នេះខ្ញុំបានចាប់ផ្តើមក្នុងឆ្នាំនោះជាមួយនឹងការមើលថែទាំដល់ស្ត្រីជាង ១០០ នាក់ ដោយខ្ញុំមានបទពិសោធន៍យ៉ាងតិចតួច ហើយមានជំនឿថាព្រះអម្ចាស់នឹងប៉ះប៉ូវនូវការផ្លាស់ប្តូរ ។ មួយឆ្នាំក្រោយមក ខ្ញុំត្រូវបានដោះលែង ។ នៅពេលខ្ញុំបានគិតត្រឡប់ទៅមើលពីគ្រានានានៃវិវរណៈ នៅពេលខ្ញុំដឹងយ៉ាងច្បាស់ពីមេរៀនដែលខ្ញុំត្រូវបង្រៀន ឬ យោបល់ដើម្បីចែកចាយ ឬ មានគ្រាជាច្រើននៅពេលដែលមាននរណាម្នាក់បានចំអិនអាហារឲ្យខ្ញុំ ដោយសារខ្ញុំរវល់ពេកពុំបានចំអិនអាហារ ឬ ពេលមានលិខិតលើកទឹកចិត្តខ្លីជាច្រើនដែលខ្ញុំបានទទួល នោះខ្ញុំបានដឹងយ៉ាងច្បាស់ថា ព្រះអម្ចាស់បានតម្កើងកិច្ចខិតខំប្រឹងប្រែងរបស់ខ្ញុំ នៅក្នុងការស្ថាបនានគរនេះ » ។

នៅពេលអ្នក និង កូនៗរបស់អ្នកគិតពីរបៀបនានា ដើម្បីស្ថាបនានគរព្រះ នោះចូរចងចាំថា សុំលើកទឹកចិត្តពួកគ និង ផ្តល់ឱកាសនានាដល់ពួកគេឲ្យបម្រើ ។ អ្នកអាចគិតពីការពិភាក្សាពីរបៀបនានា ដើម្បីបម្រើដល់មនុស្សដទៃនៅក្នុងការហៅបម្រើដែលអ្នកមាន ។ តើមានវិធីណាខ្លះទៀត ដែលអ្នកអាចជួយឲ្យកិច្ចការនេះបន្តឆ្ពោះទៅមុខ ? មិនថាអ្នកបម្រើនៅទីណាទេ កិច្ចខិតខំប្រឹងប្រែងរបស់អ្នកគឺមានតម្លៃណាស់ ។ ដូចប្រធាន ឌីថើរ អេហ្វ អុជដុហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយបានមានប្រសាសន៍ថា « ចូរឈរនៅក្បែរគ្នា ហើយលើកនៅកន្លែងដែល [ អ្នក ] ឈរ » ។[២] ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*



**កំណត់ចំណាំ**

១. ស្ពែនសើរ ដបុលយូ឴ ឃីមបឹល « Living the Gospel in the Home » *Ensign* ខែ ឧសភា ឆ្នាំ ១៩៧៨ ទំព័រ ១០១ សូមមើលផងដែរ អិល ថម ភែរី « Discipleship » *Liahona* ខែ មករា ឆ្នាំ ២០០១ ទំព័រ ៧២ ។

២. ឌៀថើរ អេហ្វ អុជដូហ្វ « Lift Where You Stand » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៥៦ ។

*ផ្នែកទី ១ នៃអត្ថបទនេះត្រូវបានបោះពុម្ពនៅក្នុង លីអាហូណាខែ មករា ឆ្នាំ ២០១៦ ។*

# តើយើងដឹងអ្វីខ្លះអំពី ជីវិតបន្ទាប់ពីសេចក្ដីស្លាប់ ?



**ដោយ ដេវីឌ អេ អេដវួដ**
ទស្សនាវដ្ដីសាសនាចក្រ

នៅក្នុងសម័យកាលទាំងអស់ មនុស្សរាប់មិនអស់បានសួរសំណួរដែលត្រូវបានចោទសួរដោយយ៉ូប ៖ « បើមនុស្សស្លាប់ទៅ តើនឹងមានជីវិតរស់ឡើងទៀតឬ ? » ( យ៉ូប ១៤:១៤ ) ។ ចម្លើយឆ្លើយថា « មែនហើយរស់ឡើងវិញ ! » ចំពោះសំណួរនេះ គឺជាឯកសិទ្ធិដ៏អស្ចារ្យមួយនៃអស់អ្នកដែលមានទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និង ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ។

ប៉ុន្តែមនុស្សជាច្រើននៅជុំវិញខ្លួនយើងដែលបានចែកឋានពីជីវិតនេះទៅ « ដោយគ្មានព្រះក្នុងលោកីយ៍នេះដែរ » ( អេភេសូរ ២:១២ ) ហើយត្រូវបង្ហាញនូវភាពខុសគ្នារវាងសេចក្ដីពិត និង ជំនឿផ្សេងៗទាក់ទងនឹងសេចក្ដីស្លាប់ ។ សម្រាប់មូលហេតុមួយនោះគឺមានភស្តុតាងដោយផ្ទាល់ភ្នែក ឬ មាន« សេចក្ដីពិតជាអកុសល » ដែលថាសេចក្ដីស្លាប់គឺរឿងទូទៅ និង ពិតប្រាកដ—នោះពួកគេពុំធ្លាប់ឃើញមាននរណាម្នាក់បានរស់ឡើងវិញឡើយ ។ បន្ទាប់មកមានរបាយការណ៍ជាច្រើនអំពីបទពិសោធន៍ហៀបនឹងស្លាប់ជាមួយនឹងអារម្មណ៍ដ៏អស្ចារ្យយ៉ាងជាក់ច្បាស់រវាងពួកគេ ។ ហើយក្រោយមកមានសេចក្ដីពិតដែលថា វប្បធម៌របស់មនុស្សទូទាំងពិភពលោកទាំងមូល តែងតែមានការយល់ឃើញអំពីលក្ខណៈមួយចំនួនអំពីជីវិតបន្ទាប់ពីជីវិតនេះ ជាអារម្មណ៍មួយដែលតម្រូវឲ្យមានការពន្យល់បកស្រាយ ។

ប៉ុន្តែការធានាអះអាងថាជីវិតរបស់យើងនឹងពុំបញ្ចប់ត្រឹមសេចក្ដីស្លាប់នេះ គឺមកពីព្រះ ដែលបានបើកសម្ដែងតាំងពីដើមដំបូងមកតាមរយៈសាក្សីជាច្រើនរូប រួមមានទាំងព្យាការី សាវក និង សំខាន់បំផុតនោះគឺព្រះវិញ្ញាណបរិសុទ្ធ ។



ផ្ទៃខាងក្រោយ © iStock/Thinkstock

*« បើមនុស្សស្លាប់ទៅ តើនឹងមានជីវិតរស់ឡើងទៀតឬ ? » មែន ហើយរស់ឡើងវិញ ! ប៉ុន្តែរឿងនោះវាយ៉ាងដូចម្ដេចវិញ ?*

**តាំងពីដំបូងឡើយ**

ផែនការនៃសេចក្ដីសង្គ្រោះបានបង្រៀនលើកដំបូងគេនៅលើផែនដីនេះដល់អ័ដាម និង អេវ៉ា ដែលជាឪពុកម្ដាយដើមរបស់យើង ។ ពួកគេបានរៀនអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និង របៀបដើម្បីត្រឡប់ទៅវត្តមានរបស់ព្រះវរបិតាសួគ៌វិញ—ហើយពួកគេបានយល់ថា *ការត្រឡប់ទៅវិញ* មានន័យថាយើងធ្លាប់រស់នៅជាមួយនឹងទ្រង់កាលពីមុន ។ ដូច្នេះ តាំងពីដំបូងឡើយ អ័ដាម និង អេវ៉ាបានដឹងយ៉ាងជាក់ច្បាស់ថាជីវិតនេះពុំមែនបញ្ចប់ត្រឹមនេះឡើយ ។ ពួកគេបានដឹង—ហើយបានបង្រៀនកូនៗរបស់ខ្លួន—ដោយសារដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះពួកគេត្រូវបានរស់ឡើងវិញបន្ទាប់ពីជីវិតនេះ ហើយប្រសិនបើពួកគេគោរពប្រតិបត្តិតាម នោះពួកគេទទួលជីវិតដ៏នៅអស់កល្បជានិច្ច ( សូមមើល ម៉ូសេ ៥:១០–១២ ) ។

ទ្រឹស្ដីក្នុងលោកនេះផ្ដល់យោបល់ថា ជំនឿលើជីវិតបន្ទាប់ពីជីវិតនេះគឺជាជំនឿឯករាជ្យ ដែលមានទំហំលើសពីតម្រូវការផ្នែកចិត្តសាស្ត្រទូទៅមួយចំនួន ។ ប៉ុន្តែគំនិតដែលដឹងឮពីជីវិតបន្ទាប់ពីសេចក្ដីស្លាប់ ដោយផ្ទុយទៅវិញ បង្កើតជាការចងចាំអំពីបុព្វការីជន ឬ ការចងចាំជាសង្គម ( ប្រសិនបើមិនមែនជាការចងចាំនៃជីវិតមុនឆាកជីវិតនេះ ) អំពីអ្វីដែលទាក់ទងនឹងការចាប់ផ្ដើមពីដំបូង ហើយបន្តពីមួយជំនាន់ទៅមួយជំនាន់ទៀត ។ មានគ្រាមួយនោះប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ( ឆ្នាំ ១៨៣៨–១៩១៨ ) បានមានប្រសាសន៍អំពីសណ្ដាប់នៃប្រពៃណីសាសនាទូទៅដែលអនុវត្តលើជំនឿទូទៅដូចជាជីវិតបន្ទាប់ពីសេចក្ដីស្លាប់នេះផងដែរ ៖ « ដោយពុំសង្ស័យអ្វីពីចំណេះដឹង [ នេះ ] . . . ដែលមានតាំងពីពូជពង្សរបស់អ័ដាមទៅដល់គ្រប់ដែនដីទាំងអស់ ហើយបន្ត . . . រហូតដល់ណូអេ . . . ទៅដល់អ្នកដែលស្វែងគំណែងពីលោក ដោយផ្សព្វផ្សាយគ្រប់ប្រជាជាតិ និង ប្រទេសទាំងអស់ » ( « Discourse » *Deseret News* ថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៨៧៣ ទំព័រ ៣៦ ) ។

ហេតុដូច្នោះហើយ គំនិតអំពីជីវិតបន្ទាប់ពីជីវិតនេះគឺជារឿងទូទៅមួយ ដោយសារប្រភពដើមរបស់វាកើតឡើងតំណាលគ្នានឹងប្រភពនៃពូជមនុស្ស ។

**សេចក្ដីដ៏ច្បាស់ និង ពិសេសៗ**

ក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងអាចជួយនាំមកនូវសេចក្ដីសង្ឃឹមដល់អស់ទាំងមនុស្ស ដែលរស់នៅដោយគ្មានព្រះនៅក្នុងលោកិយ៍នេះ ដោយថ្លែងទីបន្ទាល់ដ៏មានទំនុកចិត្តរបស់អ្នកអំពីសេចក្ដីពិតនៃជីវិតរបស់យើង ៖ សេចក្ដីស្លាប់ពុំមែនជាទីបញ្ចប់ទេ ។ ក្រៅពីនោះ យើងអាចឆ្លើយនឹងសំណួរជាច្រើនអំពីជីវិតបន្ទាប់ពីសេចក្ដីស្លាប់ ដោយសារសេចក្ដីពិតដ៏ច្បាស់ និង ពិសេសៗនៃដំណឹងល្អដែលបានស្ដារឡើងវិញបានបើកសម្ដែងហើយ ។ នេះគឺជាចម្លើយខ្លីៗចំពោះសំណួរមួយចំនួនបែបនោះ ។



**_តើមានអ្វីនឹងកើតឡើងចំពោះយើងបន្ទាប់ពីយើងស្លាប់ ?_**

នៅពេលស្លាប់ វិញ្ញាណរបស់យើងនឹងបែកចេញពីរូបកាយរបស់យើង ហើយចូលទៅក្នុងពិភពវិញ្ញាណ ( សូមមើល យ៉ាកុប ២:២៦; អាលម៉ា ៤០:១១ ) ។

**_តើវិញ្ញាណរបស់យើងនឹងទៅជាយ៉ាងណា ?_**

តួវិញ្ញាណរបស់យើងមានលក្ខណៈដូចជាវិញ្ញាណដែលយើងមានមុនឆាកជីវិតនេះ ៖ រូបកាយមនុស្សពេញវ័យក្នុងសភាពដ៏ល្អឥតខ្ចោះ ( សូមមើល អេធើរ ៣:១៦; *Teachings of Presidents of the Church: Joseph F. Smith* [ ឆ្នាំ ១៩៩៨ ] ទំព័រ ១៣១–៣២ ) ។ បន្ទាប់ពីស្លាប់ វិញ្ញាណរបស់យើងនឹងមានលក្ខណៈចំណង់ និង ក្តីប្រាថ្នាដូចរូបកាយរមែងស្លាប់របស់យើងនៅលើផែនដីនេះដែរ ( សូមមើល អាលម៉ា ៣៤:៣៤ ) ។

**_តើវិញ្ញាណគឺជាអ្វី ?_**

វិញ្ញាណគឺជាធាតុម្យ៉ាងដែល « ហ្មត់ ឬសុទ្ធសាធជាង » ( គ. និង ស. ១៣១:៧ ) ។

**_តើពិភពវិញ្ញាណមានលក្ខណៈបែបណា ?_**

មានស្ថានភាព ឬ ការបែងចែកដ៏ធំពីរនៅក្នុងចំណោមវិញ្ញាណ ដែលនៅក្នុងពិភពវិញ្ញាណ ៖ ស្ថានបរមសុខ និង ស្ថានឃុំព្រលឹង ។ វិញ្ញាណនៃពួកសុចរិតនឹងទៅស្ថានបរមសុខ ដែលជា « ស្ថានភាពឈប់សម្រាក ស្ថានភាពសុខសាន្ត ជាកន្លែងដែលគេនឹងបានសម្រាកពីអស់ទាំងកង្វល់ពីអស់ទាំងការបារម្ភ និង ពីទុក្ខព្រួយ » ( អាលម៉ា ៤០:១២ ) ។ វិញ្ញាណនៃអស់អ្នកដែលពុំទាន់ទទួលយកដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទនៅឡើយ គឺត្រូវបាននិយាយថារស់នៅក្នុងស្ថានឃុំព្រលឹង ។ ( សូមមើល ពេត្រុសទី ១ ៣:១៨–២០ ) ។ ពួកគេនៅតែអាចជ្រើសរើសដើម្បីធ្វើល្អ ឬ អាក្រក់ និង ទទួលយក ឬ បដិសេធដំណឹងល្អ ។ វិញ្ញាណនានានៅក្នុងស្ថានបរមសុខអាចផ្សាយដំណឹងល្អ ដល់ពួកគេ ( សូមមើល គ. និង ស. ១៣៨ ) ។ អស់ទាំងអ្នកណាដែលមានវិញ្ញាណបែកពីរូបកាយអស់ពេលយ៉ាងយូរបានចាត់ទុកការបែកនេះថាជា « ការជាប់ឃុំឃាំង » ( គ. និង ស. ៤៥:១៧; ១៣៨:៥០ ) ។

**_តើស្ថានសួគ៌ជាអ្វី ?_**

ជាទូទៅស្ថានសួគ៌ត្រូវបានពន្យល់ថា ជាកន្លែងដែលព្រះគង់នៅ និង មនុស្សសុចរិតអាចនៅទីនោះផងដែរ ។ នៅក្នុងន័យនេះ គឺវាខុសពីស្ថានបរមសុខនៃពិភពវិញ្ញាណ ។

**_តើស្ថាននរកជាអ្វី ?_**

នៅក្នុងព្រះគម្ពីរ *ស្ថាននរក* អាចសំដៅលើកន្លែងពីរយ៉ាង (១) « ជាទីបណ្ដោះអាសន្ននៅពិភពវិញ្ញាណ សម្រាប់ពួកអ្នកដែលមិនបានគោរពតាមកាលរស់នៅលើផែនដី ឬ (២) ជាកន្លែងដ៏អចិន្ត្រៃដល់អស់អ្នកណាដែលមិនត្រូវបានប្រោសលោះដោយសារដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ » ( សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ស្ថាននរក » scriptures.lds.org ) ។ ការយល់ដឹងជាទូទៅ វាគឺជាលក្ខខណ្ឌខាងវិញ្ញាណមួយដែលរងការឈឺចាប់ដោយអស់អ្នកដែលបានបដិសេធដំណឹងល្អ ។ យ៉ូសែប ស្ម៊ីធបានបង្រៀន ៖ « ទុក្ខលំបាកដ៏ធំនៃវិញ្ញាណដែលបានចាកចេញទៅ . . . គឺការដឹងថា ពួកគេពុំទទួលបានសិរីរុងរឿង ដែលមនុស្សដទៃទៀតរីករាយ ហើយថាពួកគេអាចមានក្តីរីករាយចំពោះខ្លួនពួកគេ ហើយពួកគេគឺជាអ្នកចោទប្រកាន់ខ្លួនឯង » ( *Teachings of Presidents of the Church: Joseph Smith* [ ឆ្នាំ ២០០៧ ] ទំព័រ ២២៤ ) ។

**_តើអ្វីទៅជាដំណើររស់ឡើងវិញ ?_**

ដំណើររស់ឡើងវិញគឺជាការផ្គុំគ្នាជាថ្មីនៃវិញ្ញាណ និង រូបកាយដ៏ល្អឥតខ្ចោះ ក្នុងស្ថានភាពអមតៈ ( សូមមើល អាលម៉ា ១១:៤៣ ) ។

**_តើនរណានឹងបានរស់ឡើងវិញ ?_**

មនុស្សទាំងអស់ដែលបានរស់នៅលើផែនដីនឹងបានរស់ឡើងវិញ ( សូមមើល កូរិនថូសទី ១ ១៥:២២; អាលម៉ា ១១:៤៤ ) ។

**_តើយើងនឹងរស់ឡើងវិញនៅពេលណា ?_**

មនុស្សនឹងរស់ឡើងវិញនៅក្នុងពេលផ្សេងៗគ្នា ។ ការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទនាំឲ្យមានដំណើររស់ឡើងវិញទីមួយ ឬ ដំណើររស់ឡើងវិញនៃមនុស្សសុចរិត ។ មនុស្សសុចរិតមួយចំនួនបានរស់ឡើងវិញហើយចាប់តាំងពីគ្រានោះមក ។ បន្ទាប់ពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ នោះមនុស្ស

រូបថតនៅខាងក្រៅព្រះវិហារបរិសុទ្ធ ញូផត ប៊ិច កាលីហ្វ័រញ៉ា ។



សុចរិតជាច្រើនទៀតនឹងរស់ឡើងវិញ ។ ក្នុងអំឡុងសហស្សវត្សរ៍ នោះមនុស្សល្អដទៃទៀតនឹងរស់ឡើងវិញ ។ បន្ទាប់ពីសហស្សវត្សរ៍ នោះមនុស្សទុចរិតនឹងរស់ឡើងវិញ ។ ( សូមមើល គ. និង ស. ៧៦:៣២–១១២; ៨៨:៩៧–១០១ ) ។

***តើរូបកាយដែលបានរស់ឡើងវិញមានសភាពយ៉ាងណា ?***

រូបកាយដែលរស់ឡើងវិញមានសភាពជាសាច់ និង ឆ្អឹង ( សូមមើល លូកា ២៤:៣៩ ) អមតៈ ( សូមមើល អាលម៉ា ១១:៤៥ ) ល្អឥតខ្ចោះ ( សូមមើល អាលម៉ា ១១:៤៣ ) មានសិរីរុងរឿង និង ស្រស់ស្អាត ។ « គ្មានអ្វីដែលស្រស់ស្អាតជាងពេលមើលទៅបុរស ឬស្ត្រីដែលបានរស់ឡើងវិញនោះទេ » ( ប្រធាន ឡូរ៉េនសូ ស្នូ [ ឆ្នាំ ១៨១៤–១៩០១ ] *The Teachings of Lorenzo Snow* បានរៀបចំបោះពុម្ពដោយ ស៊ីនឌី ជេ វិល្លាម [ ឆ្នាំ ១៩៩៦ ] ទំព័រ ៩៩ ) ។

***តើអ្វីខ្លះកើតឡើង បន្ទាប់ពីយើងបានរស់ឡើងវិញ ?***

បន្ទាប់ពីមនុស្សទាំងអស់បានរស់ឡើងវិញ និង ពេលសហស្សវត្សរ៍បានបញ្ចប់ នោះយើងនឹងត្រូវបាននាំទៅក្នុងវត្តមាននៃព្រះដើម្បីជំនុំជំរះស្របតាមពាក្យសម្ដី ទង្វើ គំនិត និង បំណងប្រាថ្នា ( សូមមើល វិវរណៈ ២០:១២; អាលម៉ា ១២:១៤; គ. និង ស. ១៣៧:៩ ) ។ ព្រះយេស៊ូវគ្រីស្ទនឹងធ្វើជាចៅក្រមរបស់យើង ( សូមមើល យ៉ូហាន ៥:២២, ២៧–២៩; រ៉ូម ១៤:១០ ) ។

***តើមានអ្វីខ្លះកើតឡើង បន្ទាប់ពីសេចក្ដីជំនុំជំរះចុងក្រោយ ?***

បន្ទាប់ពីសេចក្ដីជំនុំជំរះចុងក្រោយ យើងនឹងទទួលនូវរង្វាន់ដ៏អស់កល្បមួយដូចតទៅ ៖

*នគរសេឡេស្ទាល ៖* ដំណាក់នៃព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និង អស់អ្នកដែលសក្ដិសមនឹងទទួលបានជីវិតអស់កល្បជានិច្ច ដោយការធ្វើ និង រក្សាគ្រប់សេចក្ដីសញ្ញាទាំងអស់នៃដំណឹងល្អ ( សូមមើល គ. និង ស. ៧៦:៥០–៧០ ) ។

*នគរទេរេសស្រ្ទាល ៖* ជាផ្ទះនៃអស់ទាំងមនុស្សល្អដែលពុំទទួលយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែបានទទួលវានៅក្នុងពិភពវិញ្ញាណ ឬ អស់អ្នកដែលគ្មានក្ដីក្លាហាននៅក្នុងទីបន្ទាល់នៃព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិត ( សូមមើល គ. និង ស. ៧៦:៧១–៨០ ) ។

*នគរទេឡេស្ទាល ៖* ជាផ្ទះនៃអស់ទាំងមនុស្សដែលទុច្ចរិត និង ពុំទទួលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ជាអស់អ្នកដែលពុំទាន់រស់ឡើងវិញឡើយរហូតក្រោយពីសហស្សវត្សរ៍ ( សូមមើល គ. និង ស. ៧៦:៨១-៨៩ ) ។

*ការដាក់ទោសមិនចេះចប់មិនចេះហើយ ៖* ជាស្ថានភាពចុងក្រោយនៃកូនហិនវិនាស ព្រមទាំងសាតាំង និង ពួកទេវតារបស់វា ( សូមមើល គ. និង ស. ៧៦:៣១–៤៩ ) ។

***តើមនុស្សនឹងធ្វើអ្វីខ្លះនៅក្នុងនគរសេឡេស្ទាល ?***

អស់អ្នកដែលគ្រងមរតកកម្រិតខ្ពស់បំផុតនៃនគរសេឡេស្ទាល នឹងត្រូវបានតម្កើងឡើង ដែលមានន័យថាពួកគេនឹងមានជីវិតដ៏នៅអស់កល្បជានិច្ច ប្រែក្លាយដូចជាព្រះវរបិតាសួគ៌ ហើយទទួលនូវអ្វីៗទាំងអស់ដែលព្រះវរបិតាមាន ។ ដើម្បីប្រែក្លាយដូចជាព្រះវរបិតាសួគ៌មានន័យថា តម្រូវឲ្យមានលក្ខណៈគ្រប់លក្ខណ៍របស់ទ្រង់ រួមមានសេចក្ដីស្រឡាញ់ និង ការបម្រើ ។[1] វាក៏មានន័យថា ចែករំលែកកិច្ចការ និង សិរីល្អរបស់ទ្រង់ដែល « ដើម្បីនាំឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( ម៉ូសេ ១:៣៩ ) ។ ភាពតម្កើងឡើងរួមមានការផ្សារភ្ជាប់នៅក្នុងអាពាហ៍ពិពាហ៍សម្រាប់ភាពអស់កល្បជានិច្ច រស់នៅក្នុងគ្រួសារអស់កល្ប និង មានកូនចៅខាងវិញ្ញាណអស់កល្ប ។ ( សូមមើល គ. និង ស. ៧៦:៥៩, ៦២; ១៣០:២; ១៣២:១៩–២៣ ) ។

***តើមនុស្សនឹងធ្វើអ្វីនៅក្នុងនគរផ្សេងទៀត ?***

អស់អ្នកនៅក្នុងនគរផ្សេងទៀតនឹងក្លាយជាពួកទេវតាដែល « ជាអ្នកបម្រើខាងការបម្រើ ដើម្បីបម្រើដល់អស់អ្នកណាដែលសំណំ នឹងទម្ងន់នៃសិរីល្អដ៏ធំជាង និង ដ៏លើសលប់ និង ដ៏នៅអស់កល្បជានិច្ច » ( គ. និង ស. ១៣២:១៦ ) ។ ពួកគេនឹងពុំរៀបអាពាហ៍ពិពាហ៍ ឬ មានកូនខាងវិញ្ញាណឡើយ ( សូមមើល គ. និង ស. ១៣១:១–៤; ១៣២:១៦–១៧ ) ។ ■

**កំណត់ចំណាំ**

១. « ការបម្រើគឺពុំមែនជាអ្វីដែលយើងស៊ូទ្រាំនៅលើផែនដីនេះឡើយ ដូច្នោះយើងអាចទទួលនូវឯកសិទ្ធិរស់នៅក្នុងនគរសេឡេស្ទាល ។ ការបម្រើគឺជារចនាសម្ព័ន្ធដ៏សំខាន់ដែលបង្កើតឲ្យមានជីវិតតម្កើងឡើងនៅក្នុងនគរសេឡេស្ទាល » ( ប្រធាន ម៉ារ៉ុន ជី រ៉មនី [ ឆ្នាំ ១៨៩៧–១៩៨៨ ] ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ « The Celestial Nature of Self-Reliance » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨២ ទំព័រ ៩៣ ) ។



*យើងឃើញក្ដី
អំណរក្នុងកិច្ចខិតខំ
ដោយខ្ជាប់ខ្ជួននៃ
បទពិសោធន៍ផ្លាស់ប្ដូរ
ដួងចិត្ត នៅពេល
យើងឱបក្រសោប
ដង្វាយធួនរបស់
ព្រះយេស៊ូវគ្រីស្ទក្នុង
ជីវិតរបស់យើង ។*

# ការដកបទពិសោធន៍នៃ

# ការផ្លាស់ប្ដូរ ដួងចិត្ត



**ដោយអែលឌើរ អែតវើត ឌូប**
នៃពួកចិតសិបនាក់

រ៉ូសម៉ារី កូនច្បងរបស់យើង គឺជាទារកដ៏ស្រស់ស្អាតម្នាក់ ពេលម្ដាយរបស់ខ្ញុំបានសួរសុខទុក្ខពួកយើង ដែលគាត់មកពីភូមិរបស់គាត់នៅភាគកណ្ដាលនៃប្រទេស ស៊ីមបាបវ៉េ ។ ក្នុងនាមជាឪពុកម្ដាយថ្មីថ្មោង ភរិយារបស់ខ្ញុំ ណាអ៊ូមី និង រូបខ្ញុំមានក្ដីរំភើបជាខ្លាំងចំពោះការសួរសុខទុក្ខរបស់ម្ដាយខ្ញុំ ។ យើងមានចិត្តចង់រៀនអ្វីៗគ្រប់យ៉ាងខ្លាំង ដែលយើងចាំបាច់ត្រូវដឹងអំពីការចិញ្ចឹមបីបាច់កូន ។

ពេលមកដល់ផ្ទះ ម្ដាយរបស់ខ្ញុំបានបង្ហាញខ្សែក្រណាត់មួយជុំ ។ គាត់បានពន្យល់ថា ក្រណាត់រុំនេះគឺជាវត្ថុមន្តគាថាស័ក្ដិសិទ្ធិ ។ គាត់បានហុចខ្សែកនោះឲ្យទៅ ណាអ៊ូមី ដើម្បីពាក់ឲ្យរ៉ូសម៉ារី ។ ដោយយល់ពីអារម្មណ៍ស្ទាក់ស្ទើររបស់ ណាអ៊ូមី ភ្លាមនោះម្ដាយរបស់ខ្ញុំនិយាយថា ៖ « តាំងពីម៉ែនៅក្មេង ម្ដាយរបស់ម៉ែ និង ជីដូនម៉ែបានឲ្យវត្ថុមន្តគាថាស័ក្ដិសិទ្ធិនេះដល់ម៉ែ វាបានការពារម៉ែ និង កូនៗព្រមទាំងស្វាមីរបស់ឯងផងដែរ ។ វត្ថុស័ក្ដិសិទ្ធិនេះនឹងការពារកូនស្រីរបស់ឯងពីជំងឺ និង ពីការធ្វើអំពើផ្សេងៗដែលអាចធ្លាក់មកលើវា ហើយវានឹងឈ្នះលើបញ្ហាលំបាកនានាក្នុងជីវិត ។ វានឹងត្រូវពាក់ខ្សែកនេះរហូតដល់វាអាយុប្រាំឆ្នាំ » ។

កាលនោះខ្ញុំកំពុងបម្រើជាប្រធានសាខា ហើយភ្លាមនោះខ្ញុំបានគិតថា « តើសមាជិកក្នុងវួដរបស់ខ្ញុំនឹងគិតយ៉ាងដូចម្ដេច នៅពេលពួកគេឃើញខ្សែក ‹ មន្តគាថា › នេះពាក់នៅលើ-ករបស់កូនយើងនោះ » ? ក្រោយមកខ្ញុំបានគិតថា « ប្រហែលជាយើងអាចគ្របបាំងវា ដូច្នេះគេនឹងមិនអាចឃើញទេ‌ឡើយ » ។ ខ្ញុំបានក្រឡេកមើលណាអ៊ូមី នាងបានបង្ហាញអាការៈដល់ខ្ញុំថា យើងមិនគួរទទួលយកអំណោយនេះឡើយ ។ ខ្ញុំបានសុំឲ្យម្ដាយខ្ញុំ ថាប្រសិនបើគាត់អាចធ្វើខ្សែកនោះឲ្យតូចជាង គឺស្ដើងជាងនេះ ដែលវាមិនសូវជាអាចមើលឃើញ ។ គាត់បានឆ្លើយថា ខ្សែកនេះពុំអាចធ្វើវាតូចជាងនេះបានឡើយ ហើយថាវត្ថុស័ក្ដិសិទ្ធនេះនឹងស័ក្ដិសិទ្ធខ្លាំងបំផុតតាមទំហំដែលគាត់បានធ្វើនោះ ។

ជាថ្មីម្ដងទៀត ណាអ៊ូមីបានមើលមកខ្ញុំដោយបង្ហាញយ៉ាងជាក់ច្បាស់ពីការពុំយល់ព្រមរបស់នាង ។ ខ្ញុំបានបែរទៅម្ដាយរបស់ខ្ញុំ ហើយបានពន្យល់គាត់ថា ក្នុងនាមជាប្រធានសាខានៅក្នុងក្រុមជំនុំក្នុងតំបន់របស់ពួកយើង ខ្ញុំពុំមានអារម្មណ៍ល្អដើម្បីពាក់ខ្សែកនេះឲ្យកូនរបស់យើងឡើយ ។ ម្ដាយរបស់ខ្ញុំបានឆ្លើយដោយការព្រមានថា ៖ គាត់បានប្រាប់យើងថា ប្រសិនបើគ្មានខ្សែកនោះទេ កូនរបស់យើងនឹងស្លាប់ ។

## គ្រាមួយនៃវិបត្តិដ៏គួរឲ្យភ័យខ្លាច

ពីរបីសប្ដាហ៍បន្ទាប់ពីព្រឹត្តិការណ៍នេះ កូនស្រី រ៉ូសម៉ារីរបស់យើងបានឈឺយ៉ាងធ្ងន់។ យើងគ្មានប្រាក់យកនាងទៅជួបវេជ្ជបណ្ឌិតឡើយ ។ វាគឺជាពេលយប់ ហើយនៅគ្រានោះខ្ញុំបានចាប់ផ្ដើមគិតអំពីអ្វីដែលម្ដាយរបស់ខ្ញុំបានមានប្រសាសន៍នៅក្នុងការប្រមានរបស់គាត់ ។ ខ្ញុំបានចាប់ផ្ដើមប្រាថ្នាថាខ្ញុំគួរទទួលយកខ្សែកនោះ ។ ខ្ញុំចង់យកវាមកពាក់លើ-ករបស់រ៉ូសម៉ារី ។ នៅក្នុងគ្រាដ៏ភ័យរន្ធត់នោះ ខ្ញុំបានឮសំឡេងតូចរហៀងជំរុញខ្ញុំឲ្យអនុវត្តសេចក្ដីជំនឿរបស់ខ្លួនលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ ភ្លាមនោះខ្ញុំបានស្លៀកពាក់សម្លៀកបំពាក់ថ្ងៃអាទិត្យរបស់ខ្ញុំយ៉ាងស្អាត ។ ខ្ញុំបានបីកូនតូចរបស់ខ្ញុំ ហើយបានប្រសិទ្ធិពរបព្វជិតភាពដល់នាង ។ ខ្ញុំមានអារម្មណ៍សុខសាន្ត និង លួងលោមចិត្ត ហើយខ្ញុំមានអារម្មណ៍ថា ភរិយារបស់ខ្ញុំក៏មានអារម្មណ៍ដូចនេះផងដែរ ។ មួយរំពេចនោះទាំងណាអ៊ូមី និង កូនតូច រ៉ូសម៉ារីបានគេងលង់លក់យ៉ាងស្រួល ។ កូនស្រីរ៉ូសម៉ារីរបស់យើងបានជាសះស្បើយ ។ នៅថ្ងៃបន្ទាប់មកនាងបានជាបន្តិចម្ដងៗ និង មានសុខភាពល្អឡើងវិញសន្សឹមៗ ។ នេះពិតជាអព្ភូតហេតុដ៏អស្ចារ្យអ្វីម្ល៉េះ ! ព្រះអម្ចាស់បានឈោងព្រះហស្តមកជួយខ្ញុំ ហើយពង្រឹងសេចក្ដីជំនឿរបស់ខ្ញុំលើទ្រង់ ដោយសេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់របស់ទ្រង់ ។

ខ្ញុំមានអំណរគុណ ប៉ុន្តែក៏មានអារម្មណ៍អៀនខ្មាសផងដែរ ។ កាលនោះខ្ញុំគឺជាអ្នកត្រឡប់ពីផ្សព្វផ្សាយសាសនា ហើយកំពុងបម្រើជាប្រធានសាខា ប៉ុន្តែខ្ញុំមានការខ្វាយខ្វល់ពីអ្វីដែលមនុស្សនឹងនិយាយជាជាងជឿលើព្រះ ( សូមមើល ម៉ូសាយ ៤:៩ ) ។ មែនហើយ ទោះបីជាម្ដាយរបស់ខ្ញុំ ដែលខ្ញុំស្រឡាញ់ និង កោតសរសើរគាត់ជាខ្លាំង ក៏គាត់ពុំអាចដឹងកិច្ចការគ្រប់យ៉ាងឡើយ ។ ខ្ញុំ



រូបគំនូរដោយ រ៉ូប៊ឺត ហាន់ គំនូរលម្អក្រណាត់ © ISTOCK/THINKSTOCK

ចាំបាច់ក្លាយជាមនុស្សម្នាក់ដែលមិនមែនគ្រាន់តែជាអ្នកត្រឡប់ពីបេសកកម្មទេ មិនមែនគ្រាន់តែជាប្រធានសាខាទេ ខ្ញុំត្រូវតែផ្លាស់ប្ដូរ ៖ ដើម្បីដកពិសោធន៍អ្វីដែលអាលម៉ាបានមាន ។

## គ្រាមួយនៃការផ្លាស់ប្ដូរដ៏ធំ

អាលម៉ាជាសង្ឃរបស់ស្ដេចទុច្ចរិត ណូអេ ទំនងជាបានពិនិត្យមើលខ្លួនលោកយ៉ាងហ្មត់ចត់ នៅពេលព្យាការីអ័ប៊ីណាដៃ បានសួរសំណួរស្រាវជ្រាវនេះ ៖ « អ្នករាល់គ្នាពុំបានតាំងចិត្តរៀនឲ្យយល់ ហេតុដូច្នេះហើយអ្នករាល់គ្នាពុំមានប្រាជ្ញាទេ ។ ហេតុដូច្នេះហើយ តើអ្នករាល់គ្នាបង្រៀនអ្វីដល់ប្រជាជននេះ ? » ( ម៉ូសាយ ១២:២៧ ) ។ ដូចជាអាលម៉ាដែល ខ្ញុំត្រូវតែមាន « ការផ្លាស់ប្ដូរដ៏ធំនៅក្នុងដួងចិត្ត [ របស់ខ្ញុំ ] ( អាលម៉ា ៥:១២ ) ។

ក្នុងនាមជាសង្ឃនៅក្នុងដំណាក់ស្ដេចណូអេ នោះអាលម៉ាបានទម្លាប់ខ្លួនរស់នៅក្នុងជីវិតដែលមានអភ័យឯកសិទ្ធិ ។ លោកបានទទួលជំនួយសម្រាប់ការចិញ្ចឹមជីវិតខ្លួនតាមរយៈពន្ធរបស់ប្រជាជន ។ លោករីករាយនឹងតំណែងដែលមានអំណាច និង មានមុខមាត់ ។ លោកគឺជាមនុស្សម្នាក់ក្នុងចំណោមអស់អ្នកដែល « លើកខ្លួនឡើងក្នុងការឆ្មើងឆ្មៃនៃចិត្តរបស់ខ្លួន » ( ម៉ូសាយ ១១:៥ ) ។ ប៉ុន្តែនៅពេលអាលម៉ាបានរៀនអំពីការយាងមករបស់ព្រះអង្គសង្គ្រោះមកកាន់ពិភពលោក —អំពីការបង្រៀន ការរងទុក្ខ ការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ហើយថា ព្រះយេស៊ូវគ្រីស្ទគឺជា « ពន្លឺ ហើយជាជីវិតនៃពិភពលោក មែនហើយ ជាពន្លឺមួយដែលមិនចេះចប់មិនចេះហើយ គឺពុំអាចមានសេចក្ដីស្លាប់ទៀតឡើយ » ( ម៉ូសាយ ១៦:៩ )—លោកបានត្រៀមខ្លួនជាស្រេចដើម្បីផ្លាស់ប្ដូរ ។ លោកថែមទាំងបានត្រៀមខ្លួនជាស្រេចដើម្បីស្លាប់ ប្រសិនបើចាំបាច់ ។

ទោះមានការប្រឆាំង និង ការគំរាមកំហែងដល់អាយុជីវិតយ៉ាងគ្រោះថ្នាក់នៅជុំវិញលោកក្ដី អាលម៉ាបានទូលអង្វរស្ដេចណូអេដោយក្លាហានឲ្យដោះលែងអ័ប៊ីណាដៃឲ្យចាកចេញដោយសុខសាន្ត ។ ទង្វើរបស់អាលម៉ាកើតចេញពីដួងចិត្តរបស់លោក លោកបានទទួលអារម្មណ៍ពីក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ មានចំពោះលោកតាមរយៈ អ័ប៊ីណាដៃដែលជាព្យាការីរបស់ព្រះអម្ចាស់ ។

នៅពេលម្ដាយរបស់ខ្ញុំបានឲ្យខ្សែកការពារមកខ្ញុំដើម្បីពាក់ឲ្យកូនរបស់ខ្ញុំ នោះខ្ញុំផ្ដោតកង្វល់របស់ខ្ញុំទៅលើរបាំងខាងក្រៅខ្លួនទៅវិញ ។ ខ្ញុំបានព្រួយបារម្ភថាតើសមាជិកនៅសាខាខ្ញុំនឹងគិតយ៉ាងណាចំពោះខ្ញុំ ។ ច្បាស់ណាស់ខ្ញុំពុំទាន់មានបទពិសោធន៍នៃ « ការផ្លាស់ប្ដូរចិត្តដ៏ធំ » ពេញលេញនោះនៅឡើយ ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានដឹងថា ភាពជោគជ័យ និង សុភមង្គលរបស់យើងគឺផ្អែកលើថាតើយើងមានឆន្ទៈខ្លាំងប៉ុណ្ណាដើម្បីទទួលយកដំណឹងល្អមកក្នុងដួងចិត្តរបស់ខ្ញុំ ។ ដើម្បីឲ្យយើងស្វែងរកសុភមង្គល ក្ដីអំណរ និង ភាពសុខសាន្តពិត « ដំណឹងល្អដ៏បរិសុទ្ធរបស់ព្រះយេស៊ូវគ្រីស្ទត្រូវតែចូលជ្រៅទៅក្នុងដួងចិត្ត [ របស់យើង ] . . . ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ » ។[១]

## ឱកាសដើម្បីថ្លែងទីបន្ទាល់

ជាមួយនឹងការផ្លាស់ប្ដូរនេះ ដោយសម្លឹងឆ្ពោះទៅរកព្រះអង្គសង្គ្រោះនៅក្នុងគ្រប់កិច្ចការ និង ទីកន្លែងទាំងអស់ធ្វើឲ្យយើងអាចឈោងទៅជួយដល់មនុស្សដទៃ ។ អាលម៉ាបានក្លាយជាអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យ បានជួយដល់មនុស្សជាច្រើន ហើយរៀបចំសាសនាចក្រនៃព្រះគ្រីស្ទនៅក្នុងចំណោមប្រជាជនរបស់លោក ដែលបានរត់គេចពីស្ដេចណូអេ ។

តើអ្នកអាចឃើញពីឱកាសដែលខ្ញុំបានខកខាន ដោយពុំបានចែកចាយដំណឹងល្អជាមួយម្ដាយរបស់ខ្ញុំ ពេលគាត់បានឲ្យវត្ថុស័ក្ដិសិទ្ធិនោះដល់យើង ដែលគាត់បានជឿថាវាការពារខ្លួនគាត់ និង កូនៗរបស់គាត់ជានិច្ចមកនោះដែរឬទេ ? ខ្ញុំអាចក្លាយជាឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់—គឺធ្វើដូចជាអាលម៉ា—ដែលបានផ្សាយដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ

*ខ្ញុំបានបីកូនតូចរបស់ខ្ញុំ ហើយបានប្រសិទ្ធិពរបព្វជិតភាពដល់នាង ។*





**ការប្រែចិត្តជឿជាបន្តបន្ទាប់**

« យើងត្រូវប្រែចិត្តជឿជាបន្តបន្ទាប់ ដោយបង្កើនសេចក្ដីជំនឿយើងលើព្រះយេស៊ូវគ្រីស្ទ និងភាពស្មោះត្រង់របស់យើងចំពោះដំណឹងល្អរបស់ទ្រង់នៅក្នុងជីវិត—ពុំមែនតែម្ដងទេ ប៉ុន្តែជាដរាបទៅ » ។

**អែលឌើរ អិម រ័សុល បាឡឺដ នៃ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Stay in the Boat and Hold On ! » ។ *Liahona* វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៩០ ។**



*អាលម៉ាបានទូលអង្វរស្ដេច ណូអេដោយក្លាហានឲ្យដោះលែងអ័ប៊ីណាដៃឲ្យចាកចេញដោយសន្តិភាព ។*

ហើយ « កែប្រែចិត្តរបស់គេ មែនហើយលោកបានដាស់ពួកគេ ឲ្យភ្ញាក់ពីដំណេកដ៏លង់លក់ ហើយគេក៏បានភ្ញាក់ឡើងចំពោះព្រះ » ( អាលម៉ា ៥:៧ ) ។

នៅពេលខ្ញុំបានគិតពីគ្រាជាមួយម្ដាយរបស់ខ្ញុំនោះ ខ្ញុំឆ្ងល់ថា តើអាចមានហេតុការណ៍អ្វីកើតឡើង ប្រសិនបើខ្ញុំបានឆ្លើយតបឲ្យកាន់តែដូចអាលម៉ានោះ ។ ម្ដាយរបស់ខ្ញុំអាចភ្ញាក់ឡើងចំពោះព្រះ ហើយការផ្លាស់ប្ដូររបស់គាត់អាចជះឥទ្ធិពលវិជ្ជមានលើបងប្អូនបង្កើតរបស់ខ្ញុំ ។ ការផ្លាស់ប្ដូរនេះ អាចជះឥទ្ធិពលដ៏ធំធេងនៅក្នុងជីវិតកូនៗរបស់បងប្អូនបង្កើតរបស់ខ្ញុំ ហើយពូជពង្សរបស់ពួកគេផងដែរ ។

ការផ្លាស់ប្ដូរដ៏ធំរបស់អាលម៉ា ពុំគ្រាន់តែបានទទួលដោយអស់អ្នកដែលលោកបានបង្រៀន និង អ្នកដែលលោកបានថ្លែងទីបន្ទាល់ប្រាប់ឡើយ ប៉ុន្តែថែមទាំងមានដល់កូនរបស់លោក ព្រមទាំងពូជពង្សរបស់លោកផងដែរ ។ កូនរបស់លោកគឺអាលម៉ា នៅពេលបង្រៀនប្រជាជននៅក្នុង និង ជុំវិញដែនដី សារ៉ាហិមឡា បានរំឭកប្រាប់អំពីទីបន្ទាល់របស់ឪពុកលោកអំពីព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ៖

« មើលចុះខ្ញុំអាចប្រាប់អ្នកថា—តើពុំមែនឪពុកខ្ញុំអាលម៉ាបានជឿដល់ពាក្យសម្ដីដែលបានប្រកាសចេញពីមាត់របស់អ័ប៊ីណាដៃទេឬអី ? . . .

« ហើយដោយសារសេចក្ដីជំនឿរបស់លោក ទើបមានការផ្លាស់ប្ដូរដ៏ធំនៅក្នុងចិត្តលោក » ( អាលម៉ា ៥:១១–១២ ) ។

ចំពោះយុវជនដូចជាអាលម៉ា នេះគឺជាការផ្លាស់ប្ដូរដ៏ធំនៃដួងចិត្ត ដែលបានចាប់ផ្ដើមដោយការអញ្ជើញរបស់អ័ប៊ីណាដៃ ឲ្យអនុវត្តដួងចិត្តរបស់មនុស្សម្នាក់ ឲ្យយល់ពីព្រះបន្ទូលរបស់ព្រះ គឺជាគន្លឹះឆ្ពោះទៅរកសុភមង្គល និង ជោគជ័យនៅក្នុងការឈោងទៅជួយអ្នកដទៃ ៖ « ហើយមើលចុះ គាត់បានផ្សាយព្រះបន្ទូលទាំងនោះដល់ពួកអយ្យកោរបស់អ្នក ហើយការផ្លាស់ប្ដូរដ៏ធំមួយបានកើតឡើងនៅក្នុងដួងចិត្តរបស់ពួកគេ ហើយពួកគេបានបន្ទាបខ្លួន ហើយបានដាក់ទីទុកចិត្តរបស់គេទៅលើព្រះដ៏ពិត ហើយមានព្រះជន្មរស់នៅ ។ ហើយមើលចុះពួកគេមានចិត្តស្មោះត្រង់រហូតដល់ទីបំផុត ហេតុដូច្នេះហើយទើបពួកគេបានសង្គ្រោះ » ( អាលម៉ា ៥:១៣ ) ។

**បន្តធ្វើការផ្លាស់ប្ដូរជាប់ជានិច្ច**

យុវវ័យមួយចំនួនសព្វថ្ងៃនេះត្រូវបានជាប់ជំពាក់រវាងការជ្រើសរើសអ្វីដែលត្រឹមត្រូវនៅក្នុងព្រះនេត្ររបស់ព្រះ ឬ ផ្គាប់ចិត្តឪពុកម្ដាយ ឬ អាណាព្យាបាលខ្លួន ដែលប្រហែលជាគ្មានអារម្មណ៍ស្រដៀងនឹងពួកគេអំពីភាពពិតពេញលេញនៃដំណឹងល្អ ។ នៅពេលប្រឈមមុខនឹងជម្រើសបែបនោះ សូមសួរខ្លួនឯងថា « តើការសម្រេចចិត្តនេះជួយខ្ញុំឲ្យទទួលអារម្មណ៍ថា ‹ កិច្ចការរបស់ខ្ញុំសុទ្ធសឹងជាកិច្ចការសុចរិតឬទេ › ( អាលម៉ា ៥:១៦ ) ហើយថាតើការសម្រេចចិត្តនេះធ្វើឲ្យខ្ញុំទទួលអារម្មណ៍ ‹ ច្រៀងនូវចម្រៀងនៃសេចក្ដីស្រឡាញ់ដែលប្រោសលោះឬទេ ? › » ( អាលម៉ា ៥:២៦ ) ។

ដោយសារយើងគប្បីស្រឡាញ់ និង គោរពសរសើរឪពុកម្ដាយរបស់យើង នោះយើងត្រូវតែដឹងថា ជម្រើសរបស់យើងនឹងមានឥទ្ធិពលផ្ទាល់លើកូនៗ និង ពូជពង្សរបស់យើង ។ ចំពោះពួកយើងវាប្រហែលជាចាំបាច់ត្រូវងាកចេញពីស្ថានភាពសុខស្រួលរបស់ខ្លួន ដូចជាអាលម៉ាបានធ្វើ ដែលបានគេចខ្លួនពីអ្នកបម្រើរបស់ស្ដេចណូអេ ហើយបានបង្រៀនដំណឹងល្អនៅក្នុងស្ថានភាពមួយដ៏យ៉ាប់យ៉ឺន ។ លោកពុំគ្រាន់តែនាំឲ្យមានការផ្លាស់ប្ដូរនៅក្នុងគ្រួសាររបស់លោកប៉ុណ្ណោះទេ ប៉ុន្តែដល់គ្រួសារដទៃទៀតផងដែរ ។ ដើម្បីដកបទពិសោធន៍នៃការផ្លាស់ប្ដូរចិត្ត វាសំខាន់ថាយើងគិតអំពីអ្នកដទៃ ហើយ « រួមគ្នាតមអាហារ ហើយអធិស្ឋានឲ្យអស់ពីចិត្តដែរ ដើម្បីសុខុមាលភាពដល់ព្រលឹងនៃពួកអ្នកដែលពុំ [ ស្គាល់ ] ព្រះ » ( អាលម៉ា ៦:៦ ) ។

តើមានអ្វីកើតឡើងប្រសិនបើកូនតូចរ៉ូសម៉ារីរបស់យើងពុំមានជីវិតរស់ពីជំងឺរបស់នាងនោះ—បើទោះបីជាបន្ទាប់ពីខ្ញុំបានផ្ដល់ការប្រសិទ្ធពរបព្វជិតភាពដល់នាងហើយនោះ ? ការក្រើនរំឭករបស់ព្រះអម្ចាស់ គឺជាកម្លាំងមួយដ៏អស្ចារ្យដល់ខ្ញុំ ៖ « អ្នកណាដែលរកបានជីវិតខ្លួន នោះនឹងត្រូវបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិត ដោយយល់ដល់ខ្ញុំ អ្នកនោះនឹងបានជីវិតវិញ » ។ ( ម៉ាថាយ ១០:៣៩ ) ។

យើងរកឃើញក្ដីអំណរក្នុងកិច្ចខិតខំដោយខ្ជាប់ខ្ជួននៃបទពិសោធន៍ផ្លាស់ប្ដូរដួងចិត្ត នៅពេលយើងឱបក្រសោបដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទក្នុងជីវិតរបស់យើង ។ ខ្ញុំមានអំណរគុណចំពោះចំណេះដឹងនេះ ហើយខ្ញុំស្គាល់ដួងចិត្តខ្ញុំថា ព្រះអង្គសង្គ្រោះរបស់យើងបានយាងទៅដោយ « រងការឈឺចាប់ និង ទុក្ខវេទនា និង ការល្បួងគ្រប់បែបយ៉ាង ហើយទ្រង់ធ្វើយ៉ាងនេះ គឺដើម្បីឲ្យបានបំពេញនូវពាក្យទាំងឡាយ ដែលបានចែងមកថា ទ្រង់នឹងលើកដាក់លើខ្លួនទ្រង់នូវការឈឺចាប់ និង ជំងឺទាំងឡាយរបស់រាស្ត្រទ្រង់ » ( អាលម៉ា ៧:១១ ) ។ ខ្ញុំដឹងថា មាននូវសុវត្ថិភាព និង ការការពារនៅក្នុងការសម្លឹងមើលឆ្ពោះទៅកាន់ព្រះអម្ចាស់ ហើយធ្វើតាមព្រះឱវាទរបស់ទ្រង់ ។ ■

កំណត់ចំណាំ

១. ហិនរី ប៊ី អាវរិង « We Must Raise Our Sights » *Ensign* ខែ កញ្ញា ឆ្នាំ ២០១៤ ទំព័រ ១៦ ។

រូបគំនូរស្រង់ចេញពី *អ័ប៊ីណាដៃបានថ្លែងទីបន្ទាល់* ដោយ វ៉ាល់ធើរ រ៉េន ។ ខ្ញុំបានទទួលការអនុញ្ញាតពីវិចិត្រករ សារមន្ទីរប្រវត្តិសាស្ត្ររបស់សាសនាចក្រ

# ជយោ !

ដោយ ដី ហ្វ្រេក ឃីសើរ

*ក្មេងអាយុបួនឆ្នាំម្នាក់បានជួយខ្ញុំឲ្យមានអំណរគុណពិធីសាក្រាម៉ង់ ក្នុងរបៀបមួយ ថ្មីស្រឡាង ។*

ចិត្តរបស់ខ្ញុំបានផ្ដោតចិត្តទុកដាក់លើព្រះអង្គសង្គ្រោះ នៅពេលក្រុមជំនុំបានច្រៀងទំនុកតម្កើងសាក្រាម៉ង់ចប់ ប៉ុន្តែនៅពេលខ្ញុំបានចាប់ផ្ដើមបិទសៀវភៅទំនុកតម្កើង នោះតន្ត្រីនៅតែបន្តលេងទៅមុខ ។ ក្រុមជំនុំនៅថ្ងៃនោះមានមនុស្សចូលរួមច្រើនដែលធ្វើឲ្យអ្នកលេងព្យាណូលេងទំនុកតម្កើងបន្ថែមពីរវគ្គទៀត ដើម្បីឲ្យពួកសង្ឃបញ្ចប់ការកាច់នំបុ័ង ។ ខ្ញុំមានអំណរគុណចំពោះម៉ោងបន្ថែមនោះ ។ វាធ្វើឲ្យខ្ញុំមានពេលបន្ថែមទៀត ដើម្បីស្មឹងស្មាតដោយគារវភាពពីមុនការអធិស្ឋានសាក្រាម៉ង់ ។

អំឡុងពេលអធិស្ឋាន ខ្ញុំផ្ទៀងតាមពាក្យដែលពួកសង្ឃសូត្រយ៉ាងយកចិត្តទុកដាក់ នៅពេលពួកគេប្រសិទ្ធិពរនូវបដិរូបនៃការពលិកម្មរបស់ព្រះគ្រីស្ទសម្រាប់ពួកយើង ។ នៅពេលការអធិស្ឋានត្រូវបានបញ្ចប់ ហើយនាគ្រាដែលក្រុមជំនុំបានបន្លឺសម្លេងថា អាម៉ែន នោះក្មេងប្រុសអាយុបួនឆ្នាំម្នាក់ដែលអង្គុយនៅពីក្រោយខ្ញុំពីរជួរ បានស្រែកបន្ទរពេលក្រុមជំនុំស្រែក « អាម៉ែន » នោះ ។

វាបានបន្លឺឡើងថា « ជយោ ! » ។

សំឡេងស្រែករបស់ក្មេងប្រុសនោះបានឮខ្លាំងល្មមដែលធ្វើឲ្យក្មេងៗមួយចំនួននៅជិតនេះសើចកក្អើក ។ ខ្ញុំសារភាពថា សំឡេងនោះបានធ្វើឲ្យខ្ញុំញញឹមទាំងមានចម្ងល់ ។

« ជយោ ? » ខ្ញុំបានគិត ។ វាជាការឆ្លើយតបយ៉ាងចម្លែកចំពោះការអធិស្ឋានសាក្រាម៉ង់ ។ វាពិតជាការឆ្លើយតបមួយដែលខ្ញុំពុំធ្លាប់ឮពីមុនសោះ ហើយទំនងជានឹងពុំឮម្ដងទៀតឡើយ ។ បន្ទាប់មកយើងបានបញ្ចប់ការអធិស្ឋានរបស់យើងដោយពោលថា « អាម៉ែន » ។

ប្រហែលជាក្មេងប្រុសនោះមានអារម្មណ៍នៃសេចក្ដីពិតជាជាងរូបខ្ញុំ ។

*ជយោ* គឺជាពាក្យដែលបង្ហាញពីក្ដីរំភើបចិត្ត ។ វាជាការស្រែកប្រកាសចំពោះក្ដីអំណរ ជាទូទៅគឺសម្រាប់ជ័យជំនះ ។ ពេលខ្លះ ពាក្យនេះគេស្រែក ដើម្បីបង្ហាញពីការយល់ព្រមចំពោះនរណាម្នាក់ដែលបានបញ្ចប់កិច្ចការលំបាកបានយ៉ាងល្អ ។[១]

រំពេចនោះ ខ្ញុំចូលចិត្តគំនិតនោះ ។ មែនហើយ ខ្ញុំបានគិតថា ជយោ ដែលព្រះយេស៊ូវគ្រីស្ទបានឈ្នះលើសេចក្ដីស្លាប់ ប្រយោជន៍ឲ្យយើងទាំងអស់គ្នាអាចរស់ឡើងវិញ ! ជយោ ដោយសារដង្វាយធួនរបស់ទ្រង់នោះទ្រង់អាចអភ័យទោសចំពោះអំពើបាបរបស់យើង ! កាន់តែពិសេសជាងនេះទៀតនោះ ទ្រង់អាចអភ័យទោសដល់អំពើបាប *របស់ខ្ញុំ* ! ជយោ ដោយសារតាមរយៈព្រះគុណទ្រង់ នោះខ្ញុំអាចត្រឡប់ទៅកាន់ព្រះវរបិតាសួគ៌របស់ខ្ញុំ ហើយរីករាយនឹងសេចក្ដីសង្ឃឹមនៃជីវិតដ៏នៅអស់កល្បជានិច្ច ! មែនហើយ ! ជយោ !

នៅពេលខ្ញុំបានស្រែកនូវពាក្យសរសើរនៃការថ្លែងអំណរគុណទាំងនេះចំពោះព្រះវរបិតាសួគ៌របស់ខ្ញុំ នោះព្រះវិញ្ញាណបរិសុទ្ធបានចូលមកយ៉ាងពេញក្នុងដួងចិត្តខ្ញុំ ដោយក្ដីអំណរដែលស្ទើរតែធ្វើឲ្យខ្ញុំយំ ។ ក្មេងតូចនោះបានដឹកនាំខ្ញុំនៅថ្ងៃនោះ ( សូមមើល អេសាយ ១១:៦ ) ហើយខ្ញុំបានត្រេកអរដោយទស្សនវិស័យដ៏ស្រស់ត្រកាល ចំពោះពរជ័យនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់ខ្ញុំ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ អូរីហ្គិន ស.រ.អា. ។*

កំណត់ចំណាំ

១. សូមមើល *Merriam Webster's Collegiate Dictionary* ការបោះពុម្ព ( ឆ្នាំ ២០០៣ ) « hooray » សូមមើលផងដែរ en.wiktionary.org/wiki/hooray ។




រូបគំនូរ ដោយ ខារ៉ូលីន វីបើគ

# គ្មានរឿងបែបនោះកើតឡើងឡើយ !

ដោយ ប្រេត ជេ ផតទើរ

*គន្លឹះនៃភាពជោគជ័យរបស់យើងនោះគឺត្រូវស្រឡាញ់យុវជនទាំងនោះ ពេលយើងបម្រើពួកគេ ។*

ខ្ញុំមានភាពស្និទ្ធិស្នាលជាមួយគ្រួសារមួយ ដែលមានកូនប្រុសម្នាក់នៅក្នុងថ្នាក់យុវជន ។ អំឡុងពេលសកម្មភាពមួយ កាលគាត់នៅជាឌីកុន អ្នកដឹកនាំម្នាក់បានដាក់វិន័យដល់គាត់ ហើយធ្វើឲ្យគាត់អាម៉ាស់នៅមុខក្រុមយុវជនគាត់ ។ ក្រោយៗមក គាត់មានអារម្មណ៍អៀនខ្មាស មិនចូលរួមសកម្មភាពនានា ហើយស្វែងរកមិត្តភក្តិក្រៅពីវួដរបស់ខ្លួន ។

រឿងនោះមានឥទ្ធិពលយ៉ាងធំធេងចំពោះខ្ញុំ ។ ខ្ញុំបានប្ដេជ្ញាចិត្តថា នឹងគ្មានរឿងបែបនោះកើតឡើងឡើយ ប្រសិនបើខ្ញុំត្រូវបានហៅឲ្យបម្រើជាមួយក្រុមយុវជន ។ ពីរឆ្នាំក្រោយមក ខ្ញុំត្រូវបានហៅឲ្យបម្រើជាមួយពួកឌីកុន ។

អំឡុងពេលពីរបីខែ ខ្ញុំបានឃើញថា ខ្ញុំកំពុងធ្វើការជាមួយយុវជនម្នាក់ដែលមានអត្តចរិតព្រហើនជាញយៗ ។

ទីបំផុតដោយសារទង្វើរបស់គាត់ ខ្ញុំបាននិយាយថា « នេះគឺជាដែនកំណត់ » ។ ចូរកុំធ្វើល្មើសនឹងច្បាប់កំណត់នេះឡើយ ។

គាត់បានល្មើសលើដែនកំណត់នោះ ហើយយើងបានទាស់សម្ដីគ្នា ហើយគាត់ក៏បានដើរចេញទៅ ។

ក្រោយមក ខ្ញុំបានជជែកជាមួយគាត់ដើម្បីដោះស្រាយការខ្វែងគំនិតរបស់យើងទាំងពីរនាក់ ។ ខ្ញុំបាននិយាយថា « ដាវីឌ ខ្ញុំស្រឡាញ់ប្អូន ហើយប្អូនគឺជាយុវជនល្អ ប៉ុន្តែខ្ញុំមិនរីករាយនឹងទង្វើមួយចំនួនរបស់ប្អូនទេ ។ យុវជនផ្សេងទៀតមើលមកប្អូន ថាជាអ្នកដឹកនាំម្នាក់ ហើយប្រសិនបើពួកគេឃើញប្អូនធ្វើអ្វីមួយដែលមិនសមរម្យ នោះពួកគេប្រហែលនឹងសាកល្បងធ្វើវាផងដែរ » ។

យើងបានដោះស្រាយនូវបញ្ហានោះ ហើយគាត់បានទទួលយកវា ហើយយើងជាអ្នកដឹកនាំបានជួយកាត់បន្ថយនូវឧបសគ្គផ្ទាល់ខ្លួនមួយចំនួនរបស់គាត់ ។ ពេលគាត់មានអាយុ ១៨ឆ្នាំ គាត់បានសុំខ្ញុំឲ្យតែងតាំងគាត់ក្នុងតំណែងជាគ្រូ ។ ជាច្រើនឆ្នាំក្រោយមក ដែលជាពេលបច្ចុប្បន្ននេះ គាត់បានឱបខ្ញុំយ៉ាងខ្លាំងរាល់ពេលគាត់ឃើញខ្ញុំ ហើយគាត់និយាយស្ដីដោយសរសើរអំពីកាលគាត់នៅក្នុងក្រុមយុវជន ។

នៅពេលយើងស្រឡាញ់ក្រុមយុវជន ហើយនៅជាមួយពួកគេដោយរីករាយ នោះពួកគេដឹងពីក្ដីស្រឡាញ់នោះ ។ នោះជាហេតុផលដែលទីប្រឹក្សារបស់ខ្ញុំ និង រូបខ្ញុំបានយកចិត្តទុកដាក់អស់ពីចិត្តលើយុវជនរបស់យើង ។ យើងពុំបានធ្វើសកម្មភាពដោយសារវាមាននៅក្នុងកាលវិភាគនោះទេ យើងធ្វើសកម្មភាពដោយសារយើងបានដឹងថា យុវជននឹងរៀនជំនាញ ហើយរីកចម្រើន ព្រមទាំងរីករាយទៀតផង ។



មានគ្រាមួយនោះ យើងមានយុវជនម្នាក់ដែលឪពុកម្ដាយរបស់គាត់ពុំចាប់អារម្មណ៍ពីកម្មវិធីរបស់យើងឡើយ ។

ខ្ញុំបានប្រាប់ពួកគាត់ថា « មិនជាថ្វីទេ ប៉ុន្តែតើអ្នកមីង និង លោកពូមិនប្រកាន់ទេឬ ប្រសិនបើកូនរបស់អ្នកទាំងពីរនៅតែបន្តមកចូលរួម រៀន ហើយនឹងរីករាយនោះ ? »

យើងបានដាក់គាត់ឲ្យចូលរួមក្នុងកម្មវិធីយើង ហើយមិនយូរប៉ុន្មានឪពុកម្ដាយរបស់គាត់បានយល់ព្រមឲ្យគាត់ចូលរួមជាមួយយើងយ៉ាងពេញទំហឹង ។ ពួកគាត់បានឃើញថាកូនគាត់បានរៀន ហើយមានភាពសប្បាយរីករាយ ។ ក្រោយមកគាត់បានបម្រើបេសកកម្មពេញម៉ោង ។ ប្អូនប្រុសរបស់គាត់មានចិត្តពុះកញ្ជ្រោលបម្រើបេសកកម្មផងដែរ ។

យើងបានឃើញពីទំនាក់ទំនងដ៏ល្អរវាងថ្នាក់ដឹកនាំដោយចាប់អារម្មណ៍លើយុវជនម្នាក់ ហើយថាយុវជនបានរៀន រីកចម្រើន ហើយទីបំផុតបម្រើបេសកកម្ម ។ វាជាការគាប់ចិត្តយ៉ាងខ្លាំង ដែលមើលឃើញយុវជនរីកចម្រើន ហើយវាជាក្ដីរីករាយណាស់ដើម្បីរៀនជាមួយពួកគេ ។ គន្លឹះនៃភាពជោគជ័យរបស់យើងនោះគឺត្រូវស្រឡាញ់ពួកគេ ពេលយើងបម្រើពួកគេ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ កាលីហ្វូញ៉ា ស.រ.អា. ។*

# មនុស្សគ្រប់គ្នាអាចរៀនពីព្យាការី

កាលខ្ញុំមានអាយុ ១៧ ឆ្នាំ ខ្ញុំបានធ្វើការនៅសណ្ឋាគារមួយនៅទីក្រុង កៃលូ កូណា ហាវ៉ៃ ស.រ.អា. ។ ដោយធ្វើជាអ្នកជញ្ជូនឥវ៉ាន់ពីឡាននោះខ្ញុំបានជួបមនុស្សល្បីៗជាច្រើននាក់ដែលជាភ្ញៀវនៃសណ្ឋាគារ រួមមាន ចន វ៉េនី ដ្យូធី ឡាម៉ូរ និង អេសធើរ វិល្លាម ។

នាល្ងាចមួយ បន្ទាប់ពីភ្ញៀវជាច្រើនបានមកដល់ ខ្ញុំបានឆ្លៀតពេលសម្រាកបន្តិចនៅខាងមុខសណ្ឋាគារនោះ នៅពេលឡានពណ៌ខ្មៅដ៏ប្រណិតមួយបានឈប់លើចិញ្ចើមថ្នល់ ហើយមានមនុស្សប្រាំពីរនាក់បានចុះពីឡាន ដោយស្លៀកខោខ្មៅ អាវ-ស និង ក្រវ៉ាត់ក ។ មានបុរសម្នាក់ទៀតពាក់ខោអាវធំពណ៌ខ្មៅបានដើរចេញមកជាមួយពួកគេ ។ បន្ទាប់ពីតែកុងឡានបានចតឡានរួច ពួកគេទាំងអស់គ្នាបានចូលទៅបន្ទប់អាហារដើម្បីបរិភោគអាហារពេលល្ងាច ។ ខ្ញុំបានគិតថា ពួកគេដូចជាពួក អេហ្វ ប៊ី អាយ នៅពេលខ្ញុំបានត្រឡប់ទៅក្នុងសណ្ឋាគារវិញ ដើម្បីបន្តភារៈកិច្ចខ្ញុំដោយបម្រើសេវ៉ាតាមបន្ទប់ ។

មួយម៉ោងក្រោយមក ខ្ញុំបានចេញមកក្រៅសណ្ឋាគារម្តងទៀតជក់បារី ខ្ញុំបានឃើញមនុស្សមួយក្រុមដដែលនោះ ដែលខ្ញុំបានឃើញពីមុនបានត្រឡប់មកឡានរបស់ពួកគេវិញ ហើយរង់ចាំនៅចិញ្ចើមថ្នល់ ។ ពួកគេបានដើរទៅកាន់ឡានរបស់ខ្លួន ហើយបានបើកទ្វារឡានខាងក្រោយ ឲ្យបុរសពាក់ខោអាវធំខ្មៅនោះចូល ។ ផ្ទុយទៅវិញបុរសពាក់ខោអាវធំខ្មៅនោះពុំចូលឡានទេ លោកបានឈប់ បែរមកក្រោយហើយងាកមើលខ្ញុំ ហើយដើរសំដៅមកខ្ញុំដែលកំពុងផ្អែកខ្នងទៅនឹងជញ្ជាំងអគារ ។

គាត់ខ្ពស់ ហើយស្គម ដោយពាក់វ៉ែនតាតូចស្តើងព្រមទាំងមានពុកចង្កាស្តើងជុំវិញមាត់ ។ គាត់បានលូកដៃមកចាប់ដៃខ្ញុំ ហើយដាក់ដៃម្ខាងទៀតលើស្មាខ្ញុំ ។ ខ្ញុំមានការភ្ញាក់ផ្អើលថា បុរសដែលមើលទៅមានភាពថ្លៃថ្នូរបានមក ហើយនិយាយជាមួយខ្ញុំ ដែលជាយុវជនម្នាក់ដែលគាត់មិនស្គាល់សោះ ។

ខ្ញុំពុំអាចចាំអស់ពីពាក្យដែលគាត់និយាយមកកាន់ខ្ញុំឡើយ ក្រៅពីពាក្យថា « សារធាតុទាំងនោះមិនល្អសម្រាប់អ្នកឡើយ » គាត់កំពុងតែនិយាយអំពីការជក់បារីរបស់ខ្ញុំ ។ ចិត្តសប្បុរស និង អត្តចរិតរបស់គាត់បានធ្វើឲ្យខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំង ។

មួយឆ្នាំជាងក្រោយមក ខ្ញុំបានរៀនជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនា ហើយបានជ្រមុជទឹក ។

ខណៈកំពុងមើលរូបភាពរបស់ថ្នាក់ដឹកនាំសាសនាចក្រ នោះខ្ញុំបានកត់សម្គាល់ឃើញរូបភាពមួយរបស់ប្រធាន ចច អ័លប៊ើត ស្ម៊ីធ ( ឆ្នាំ ១៨៧០–១៩៥១ ) ហើយបានស្គាល់លោកភ្លាមថាជាបុរសម្នាក់ដែលមានចិត្តសប្បុរស និង មានភាពថ្លៃថ្នូរនោះដែលខ្ញុំបានជួបនៅមុខសណ្ឋាគារ ។ ខ្ញុំមានអារម្មណ៍កោតសរសើរកាន់តែខ្លាំងថា ប្រធាននៃសាសនាចក្រធ្វើនូវកិច្ចការបែបនោះចំពោះមនុស្សដូចជាខ្ញុំ ដែលជាក្មេងម្នាក់មិនមែនជាសមាជិកសាសនាចក្រ ហើយមិនទាំងសំខាន់ផងនោះ ។

លោកជាបុរសម្នាក់អស្ចារ្យអ្វីម្ល៉េះ ដែលបានបង្ហាញសេចក្តីស្រឡាញ់និង កង្វល់បែបនោះចំពោះក្មេងម្នាក់ដែលធ្វើការនៅក្នុងតំណែងមួយដែលមិនសំខាន់ ហើយគ្មានការយល់ដឹងពីដំណឹងល្អ ឬសេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌ចំពោះយើង ។

ហុកសិបប្រាំឆ្នាំក្រោយមក ខ្ញុំមានការយល់ដឹងកាន់តែច្បាស់អំពីការយកចិត្តទុកដាក់ និង សេចក្តីស្រឡាញ់នោះ ហើយខ្ញុំព្យាយាមមើលមនុស្សដែលនៅជុំវិញខ្លួនខ្ញុំដូចជាប្រធានស្ម៊ីធបានមើលមកខ្ញុំដែរ ។ ■

ហែនរី ស៊ីរ៉ែន ស៊ីញ៉រ រដ្ឋ ហាវ៉ៃ ស.រ.អា.

ផ្ទុយទៅវិញ បុរសពាក់ខោអាវធំខ្មៅនោះពុំបានចូលក្នុងឡានឡើយ គាត់បានឈប់ ហើយដើរសំដៅមករកខ្ញុំ ។



រូបគំនូរដោយ អេលែន ហ្គានស៍

# តើវាស័ក្តិសមនឹងការខំប្រឹងប្រែងដែរឬទេ ?

កូនប្រុសអាយុបួនឆ្នាំរបស់យើង ខូលតុន បានបង្ហាញក្រដាសមួយសន្លឹកដោយមានមោទភាពដែលគាត់វាបានទទួលពីគ្រូថ្នាក់បឋមសិក្សារបស់ខ្លួន ដែលមានប្រាប់ពីផ្នែករបស់គាត់នៅក្នុងកម្មវិធីថ្នាក់បឋមសិក្សាបន្ទាប់ទៀត ។ តួនាទីរបស់យើងគឺដើម្បីបង្រៀនពាក្យប្រាំពីរជួរដល់គាត់ ពីមុននឹងកម្មវិធីសម្តែងក្នុងរយៈពេលពីរសប្តាហ៍ទៀត ។

នៅល្ងាចថ្ងៃចន្ទមួយ យើងបានផ្លាស់ប្តូរពីរាត្រីជួបជុំគ្រួសារឲ្យទៅជាការហាត់សមដ៏ធំមួយ ។ ខូលតុនបានព្យាយាមធ្វើការហាត់សមជាច្រើនដងទាំងញញឹម ដោយមានការផ្តល់មតិពីភរិយាខ្ញុំ និង រូបខ្ញុំដូចជា « សុំកុំឡេះឡោះ ពេលកូននិយាយវា ហើយសូមប្រាកដថាកូននិយាយវាច្បាស់ៗ » ។

ទោះបីជាមានការខិតខំអស់ពីសមត្ថភាពយើងក្តី យើងពុំប្រាកដថាយើងបានធ្វើប្រសើរជាងពេលយើងចាប់ផ្តើមនោះឡើយ ។

ការរៀបចំខ្លួនទៅព្រះវិហារនៅថ្ងៃអាទិត្យបន្ទាប់ រួមមានទាំងកូនរបស់យើងពីរនាក់បានបាត់ស្រោមជើង កូនម្នាក់អាយុប្រាំបីខែដែលធ្មេញកំពុងដុះ និង កូនអាយុបួនឆ្នាំដែលយំស្រែក ។

ការប្រជុំបានចាប់ផ្តើម ពេលចម្រៀងបើកបានចប់ ខ្ញុំបានដើរចេញទៅសាលពីរដងដោយសារកូនយំ ។ នៅពេលក្រុមចម្រៀងបានក្រោកឈរច្រៀង ខ្ញុំហៀបនឹងបោះបង់ក្តីសង្ឃឹមថានឹងមានបទពិសោធន៍នៃការស្អាងឡើង ហើយបែបជាគិតថាយើងមិនអាចនៅរហូតដល់ចប់ការប្រជុំឡើយ ។

នៅពេលគេនិយាយពាក្យថា អាម៉ែនជាលើកចុងក្រោយ នោះខ្ញុំមានអារម្មណ៍ធូរស្បើយជាខ្លាំង ។ ប៉ុន្តែនៅពេលខ្ញុំបានព្យាយាមជំនះលើការលំបាកនោះ ខ្ញុំបានឆ្ងល់ថា « តើវាសក្តិសមនឹងនឹងការខំប្រឹងប្រែងដែរឬទេ ? តើយើងមានការរីកចម្រើនជាមួយកូនៗរបស់យើងដោយការនាំពួកគេមកព្រះវិហាររៀងរាល់សប្តាហ៍ដែរឬទេ ? »

ប្រសាសន៍របស់អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានផុសចេញមកក្នុងគំនិតខ្ញុំ ។ លោកមានប្រសាសន៍ ៖ « នៅពេលស៊ីស្ទើរ បែដណា និង ខ្ញុំមានការធុញថប់ ដោយសារតែទម្លាប់សុចរិត ដែលយើងបានខិតខំយ៉ាងខ្លាំងដើម្បីចិញ្ចឹមកូនហាក់បីដូចជាពុំទទួលបានផ្លែផ្កាខាងវិញ្ញាណភ្លាមៗតាមដែលយើងចង់បាន និង រំពឹងទុក ។ . . .

« ស៊ិស្ទើរ បែដណា និង ខ្ញុំបានគិតជួយកូនប្រុសរបស់យើងឲ្យយល់ពីមាតិកានៃមេរៀនសំខាន់ៗ ឬ ខគម្ពីរជាក់លាក់មួយដែលទីបំផុតវាលេចចេញនូវផ្លែផ្កា ។ ប៉ុន្តែលទ្ធផលបែបនោះពុំកើតឡើងគ្រប់ពេលដែលយើងសិក្សា ឬ អធិស្ឋាន ឬ រៀនជាមួយគ្នានោះទេ ។ ភាពខ្ជាប់ខ្ជួននៃបំណងចិត្ត និង កិច្ចការរបស់យើងទេដែលអាចជាមេរៀនដ៏ល្អ—ជាមេរៀនដែលយើងពុំសូវមានអំណរគុណពេញលេញនៅគ្រានោះ » ( « More Diligent and Concerned at Home » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ១៩ ) ។

ដោយមានទំនុកចិត្តជាថ្មី ខ្ញុំបានត្រឡប់ទៅផ្ទះ ហើយបន្តអនុវត្តម្តងហើយម្តងទៀតជាមួយកូនរបស់ខ្ញុំ ។ នៅពេលដល់វេនគាត់និយាយ នោះយើងមានអារម្មណ៍រំភើបជាខ្លាំង ដើម្បីស្តាប់ឮគាត់និយាយច្បាស់ៗ និង ប្រកាសដោយទំនុកចិត្តថា « ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ » ។

យើងបានស្តាប់ឮគាត់និយាយឃ្លាជាច្រើនដងហើយពីមុនការសម្តែង ប៉ុន្តែនៅពេលឮគាត់និយាយឃ្លានោះនៅក្រៅផ្ទះ ដោយខ្លួនឯង នោះវាពិតជាអស្ចារ្យ ហើយជាទីពេញចិត្តកាន់តែខ្លាំង ។

យើងមានការបង្រៀនជាច្រើនពីមុនកូនប្រុសរបស់យើងពេញវ័យ ប៉ុន្តែយើងនឹងបន្តចូលរួមការប្រជុំរបស់យើងឲ្យអស់ពីសមត្ថភាព ធ្វើរាត្រីជួបជុំក្រុមគ្រួសារ ហើយអធិស្ឋានរាល់ថ្ងៃ ដោយសង្ឃឹមថាថ្ងៃណាមួយនៅពេលពេលគាត់នៅឆ្ងាយពីផ្ទះ ហើយនៅតែឯងនោះគាត់នឹងចងចាំឃ្លាដ៏សំខាន់នោះជាថ្មីទៀត ៖ « ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ » ។ ■

ប្រាដុន ឌុមស្តុក រដ្ឋយូថាហ៍ ស.រ.អា.





ខាលីមានចិត្តអន្ទះសារចង់យកកូនរបស់នាងទៅព្រះវិហារបរិសុទ្ធ ប្រយោជន៍ឲ្យពួកគេអាចស្គាល់វា ។

# អារម្មណ៍សុខសាន្តនៃព្រះវិហារបរិសុទ្ធ

ខ្ញុំមានឱកាសទៅសួរសុខទុក្ខកូនស្រីខ្ញុំ ខាលី នៅទីក្រុង ឡាស វ៉េហ្គាស រដ្ឋ ណាវ៉ាដា ស.រ.អា. ដែលនាងទើបតែបានប្ដូរទៅនៅទីនោះជាមួយស្វាមី និង កូនពីរនាក់របស់នាង ។ វួដរបស់ខាលីជួបប្រជុំនៅពេលថ្ងៃត្រង់ ដូច្នោះនៅពេលព្រឹកយើងមានពេលវេលាដ៏រីករាយដើម្បីរៀបចំខ្លួន ហើយពិភាក្សាពីកិច្ចការនានាបន្ទាប់ពីព្រះវិហារ ។ ដោយសារខាលីគ្មានឱកាសទៅលេងព្រះវិហារបរិសុទ្ធនៅឡើយ នោះយើងបានសម្រេចចិត្តទៅ ហើយថតរូបមួយចំនួនរបស់កូនយើងលេងនៅបរិវេណព្រះវិហារបរិសុទ្ធ ។

នៅពេលយើងទាំងអស់គ្នានៅព្រះវិហារបរិសុទ្ធ បរិវេណព្រះវិហារបរិសុទ្ធ ឡាស វ៉េហ្គាស ណាវ៉ាដាមានភាពស្រស់ស្អាត ហើយមានការរក្សាសណ្ដាប់ធ្នាប់ដោយមានប្រភពទឹក និង ផ្កាដ៏ស្រស់ស្អាត ។

បន្ទាប់ពីអានរឿងមួយដែលប្រធាន ថូម៉ាស អេស ម៉ នសុនបានប្រាប់ ខាលីមានចិត្តអន្ទះសារចង់យកកូនរបស់នាងទៅព្រះវិហារបរិសុទ្ធ ប្រយោជន៍ឲ្យពួកគេអាចស្គាល់វា ( សូមមើល « Finding Peace » *Liahona* ខែ មិនា ឆ្នាំ ២០០៤ ទំព័រ ៥–៦ ) ។ ចំណុចដំបូងដែលនាងបានពន្យល់ដល់កូនស្រីរបស់នាង ស្ដេឡានោះគឺអំពីភាពពិសិដ្ឋ និង សារៈសំខាន់នៃព្រះវិហារបរិសុទ្ធ ។

ស្ដេឡាបានយល់ស្មើនឹងកុមារអាយុបីឆ្នាំអាចយល់អំពីការណ៍នោះ ហើយយើងបានជំរុញចិត្តឲ្យនាងស្គាល់ព្រះវិហារបរិសុទ្ធ ។ យើងបានថតរូបជាច្រើនរបស់ស្ដេឡា និង ប្អូនប្រុសអាយុបីខែរបស់នាងស្គាល់ព្រះវិហារបរិសុទ្ធ ។

ដល់ពេលត្រូវត្រឡប់ទៅវិញ ស្ដេឡាមានចិត្តស្ទាក់ស្ទើរមិនចង់ទៅ ។ យើងគិតថា យើងបានយល់ពីមូលហេតុនោះ នាងបានមានពេលដ៏រីករាយនៅក្នុងបរិវេណដ៏ស្រស់ត្រកាលនោះ និង គ្មានអារម្មណ៍សង្ស័យដែលជាអារម្មណ៍ដូចដែលយើងមានដែរ ។

បន្ទាប់ពីយកនាងដាក់ក្នុងឡាន ហើយពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពហើយ យើងបានចាប់ផ្ដើមចេញដំណើរ ។ ខ្ញុំបានងាកក្រោយ ហើយលើកដៃគ្រវី ហើយនិយាយដាក់ស្ដេឡា ថា « ចូរលាព្រះវិហារបរិសុទ្ធ » ទៅកូន ។ នាងបានក្រឡេកមើលព្រះវិហារបរិសុទ្ធ ហើយលើកដៃគ្រវី ហើយនិយាយថា « លាហើយព្រះវិហារបរិសុទ្ធ ។ លាហើយលោកតា » ។ ខ្ញុំពុំបានដឹងច្បាស់ទេ ថាខ្ញុំបានឮត្រឹមត្រូវពីអ្វីដែលនាងនិយាយ ប៉ុន្តែនៅពេលខ្ញុំបានងាកមើលខាលី ហើយបានឃើញនាងយំ ខ្ញុំបានដឹងថាយើងទាំងពីរនាក់បានឮដូចគ្នានូវអ្វីដែលនាងបាននិយាយ ។

ជីតារបស់ស្ដេឡា—គឺស្វាមីរបស់ខ្ញុំ ធីម—បានចែកឋានទៅបួនឆ្នាំមុនស្ដេឡាកើត ។ នាងបានឃើញរូបថតរបស់គាត់ ហើយបានស្ដាប់ឮគ្រួសារយើងនិយាយអំពីគាត់ ប៉ុន្តែយើងពុំបាននិយាយអ្វីពីគាត់នៅថ្ងៃនោះទេ ។

កាលធីមបានចែកឋានទៅ យើងមានតែចៅម្នាក់គត់ ។ ឥឡូវយើងមានចៅ ១២នាក់ ហើយនៅពេលណាខ្ញុំបីចៅតូចដ៏មានតម្លៃទាំងនោះដែលទើបនឹងចាកចេញមកពីវត្តមានរបស់ព្រះវរបិតាសួគ៌របស់យើង នោះខ្ញុំចង់សួរថា « តើចៅៗបានជួបជីតារបស់ចៅទេ ? តើលោកតាបានផ្ដល់ដំបូន្មានអ្វីខ្លះមកជាមួយចៅ ? »

ទីបន្ទាល់របស់ខ្ញុំអំពី ភាពពិសិដ្ឋនៃព្រះវិហារបរិសុទ្ធមានភាពរឹងមាំនៅថ្ងៃនោះ ។ យើងពុំអាចនាំកូនតូចរបស់យើងទៅក្នុងព្រះវិហារបរិសុទ្ធជាមួយយើងឡើយ ប៉ុន្តែយើងអាចយកពួកគេទៅកាន់ទ្វារព្រះវិហារ ហើយឲ្យពួកគេដាក់ដៃខ្លួនលើទ្វារនោះ ដែលមានសមាជិកសក្តិសមជាច្រើនរាប់មិនអស់បានធ្លាប់ចូលរួមក្នុងដំណាក់របស់ព្រះអម្ចាស់ ។ ■

ខាធី រូសើរ រដ្ឋកាលីហ្វូញ៉ា ស.រ.អា.

រូបគំនូរដោយ អេរ៉ែល ហ្វានស៍

# តើអ្វីដែលសំខាន់បំផុតចំពោះខ្ញុំ ?

ប្រហែលជាពាក់កណ្ដាលឆ្នាំទីបីនៃមហាវិទ្យាល័យរបស់ខ្ញុំ នោះខ្ញុំបានដឹងថាប្រាក់ដែលខ្ញុំបានសន្សំសម្រាប់បង់ថ្លៃជួលផ្ទះ និង ថ្លៃ ទឹកភ្លើងនឹងមិនគ្រប់គ្រាន់រហូតដល់រដូវក្ដៅនេះឡើយ ។ នៅគ្រានោះជាពេលដែលខ្ញុំអាចធ្វើការ ដើម្បីបង់ថ្លៃសិក្សាសម្រាប់ឆមាសបន្ទាប់ ។ ខ្ញុំបានធ្វើការក្រៅម៉ោងជាជំនួយការហាងលក់ទំនិញ ។

កិច្ចការនោះបានដំណើរការបានយ៉ាងល្អ រហូតដល់កាលវិភាគធ្វើការរបស់ខ្ញុំបានផ្លាស់ប្ដូរទៅធ្វើនៅថ្ងៃអាទិត្យវិញ ។ អំឡុងពេលសម្ភាសការងារនោះ ខ្ញុំពុំបាននិយាយអ្វីអំពីការពុំធ្វើការនៅថ្ងៃអាទិត្យឡើយ ដោយសារពេលនោះហាងបិទនៅថ្ងៃអាទិត្យ ។ ទោះបីជាយ៉ាងណាក៏ដោយ ការងារនោះសំខាន់ចំពោះខ្ញុំណាស់ ហើយខ្ញុំចូលចិត្តអ្វីដែលខ្ញុំកំពុងធ្វើ ។ ខ្ញុំបានធ្វើការជាមួយមិត្តម្នាក់ ហើយយើងទាំងពីរនាក់សម្រាកថ្ងៃអាទិត្យពីរដង និង ធ្វើការថ្ងៃអាទិត្យពីរដងក្នុងមួយខែ ។ ការណ៍នេះអាចឲ្យខ្ញុំចូលរួមការប្រជុំនៅព្រះវិហារ និង ចូលរួមការហៅបម្រើរបស់ខ្ញុំបានមួយចំនួន ។

ប៉ុន្តែ មិនយូរក្រោយមក ខ្ញុំបានឃើញថា ខ្ញុំពុំអាចធ្វើតាមកាលវិភាគនេះទៀតឡើយ ។ ខ្ញុំពិតជាមានអារម្មណ៍ថា ខ្ញុំពុំអាចបំពេញការទទួលខុសត្រូវរបស់ខ្ញុំនៅថ្ងៃអាទិត្យ ទោះបីជាខ្ញុំពុំធ្វើការរាល់ថ្ងៃអាទិត្យក្ដី ។ ខ្ញុំបានចាប់ផ្ដើមសួរខ្លួនឯងថា តើខ្ញុំអាចធ្វើអ្វីខ្លះដើម្បីផ្លាស់ប្ដូរស្ថានភាពនេះ ។ បន្ទាប់ពីខ្ញុំបានអធិស្ឋានទូលសួរសុំនូវផ្លូវមួយ ដើម្បីបន្ទន់ចិត្តរបស់អ្នកគ្រប់គ្រងខ្ញុំ នោះខ្ញុំបានអាន នីហ្វៃទី ១ ៧។ ខ្ញុំបានចាំថាអានខទី ១៩ កន្លែងដែលនីហ្វៃបានអធិស្ឋាន ហើយចិត្តរបស់បងប្អូនលោកត្រូវបានបន្ទន់ ។ ទីបំផុតខ្ញុំអាចនិយាយជាមួយនិយោជករបស់ខ្ញុំអំពីការមិនធ្វើការនៅថ្ងៃអាទិត្យ ។

ខ្ញុំបានប្រាប់អ្នកគ្រប់គ្រងខ្ញុំថា ខ្ញុំគឺជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយពួកគាត់បានសួរខ្ញុំអំពីសេចក្ដីជំនឿរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ នៅពេលខ្ញុំបានសុំពួកគេដើម្បីឈប់សម្រាកនៅថ្ងៃអាទិត្យ ចម្លើយពួកគេគឺពុំអាចឈប់បានឡើយ ។ ពួកគេបានលើកបង្ហាញថា អំឡុងពេលសម្ភាសលើកដំបូងរបស់ខ្ញុំ ខ្ញុំបាននិយាយថាខ្ញុំអាចធ្វើការថ្ងៃណាក៏បាននៅក្នុងមួយសប្ដាហ៍ ហើយពុំធ្លាប់បាននិយាយអ្វីពីតម្រូវការនៃសាសនាឡើយ ។

អស់ពេលជាច្រើនខែបានកន្លងផុតទៅដោយគ្មានការផ្លាស់ប្ដូរអ្វីឡើយ រហូតដល់ថ្ងៃអាទិត្យមួយ ខ្ញុំបានប្រញាប់ប្រញាល់ចេញពីការប្រជុំនៅព្រះវិហារដើម្បីទៅធ្វើការ ។ ខ្ញុំបានសួរខ្លួនឯងថា « តើអ្វីដែលសំខាន់បំផុតចំពោះអ្នក ? » ចម្លើយបានមកភ្លាមៗ ហើយពុំអាចប្រកែកបាន ៖ គឺព្រះវិហារ ដំណឹងល្អ ការបម្រើក្នុងការហៅរបស់ខ្ញុំ ការចូលរួមការប្រជុំនៅថ្ងៃអាទិត្យដោយអស់ពីដួងចិត្តខ្ញុំ និង ភាពជាសិស្សទាំងពាក្យសម្ដី និង ទង្វើ ។

ខ្ញុំបានសម្រេចចិត្តថា ខ្ញុំនឹងសុំមិនធ្វើការនៅថ្ងៃអាទិត្យសារជាថ្មីម្ដងទៀត ប៉ុន្តែលើកនេះ ខ្ញុំនឹងសុំដោយមានសរសេរលិខិតលាឈប់ពីការងារផងដែរ ក្នុងករណីដែលពួកគាត់ប្រាប់ខ្ញុំថាពុំអាចឈប់បាននោះជាលើកទីពីរ ។

ខ្ញុំបានអធិស្ឋាន តមអាហារ ហើយបានទទួលសារគាំទ្រពីមិត្តភក្តិ ។

ដល់ពេលសម្ភាសនោះ ទោះបីជាចិត្តខ្ញុំភ័យញាប់ញ័រក្ដី ក៏ខ្ញុំមានភាពសុខសាន្ត ដោយសារខ្ញុំដឹងថាខ្ញុំកំពុងធ្វើអ្វីដែលត្រឹមត្រូវ ។ ម្ដងនេះ អ្នកគ្រប់គ្រងរបស់ខ្ញុំបានឆ្លើយថា ខ្ញុំអាចឈប់បាន ។ ខ្ញុំបានទទួលចម្លើយចំពោះការអធិស្ឋានខ្ញុំ ។ ខ្ញុំបានហែកលិខិតលាឈប់ពីការងារខ្ញុំចោលភ្លាមពេលខ្ញុំទៅដល់ផ្ទះ ។

ខ្ញុំបានទទួលពរជ័យជាច្រើនមកពីបទពិសោធន៍នេះ ប៉ុន្តែពរជ័យភ្លាមៗ និង ជាក់ស្ដែងបំផុតនោះ គឺថាខ្ញុំអាចរក្សាការងារខ្លួន ហើយនៅតែអាចរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ ចំពោះការណ៍នេះខ្ញុំពិតជាមានអំណរគុណចំពោះព្រះអម្ចាស់ណាស់ ។ ■

អ៊ីឡេអូណូរ៉ា សុនណោលីនី ទីក្រុង ទ្រីស ប្រទេស អ៊ីតាលី



ថ្ងៃអាទិត្យមួយ ខ្ញុំបានប្រញាប់ប្រញាល់ចេញពីការប្រជុំនៅព្រះវិហារដើម្បីទៅធ្វើការ ។ ខ្ញុំបានសួរខ្លួនឯងថា « តើអ្វីដែលសំខាន់បំផុតចំពោះអ្នក ? »

គំនូរដោយ ស្ទេន ហ្វែឡូស



**ដោយ អែលឌើរ ដាវីឌ អែហ្វ អ៊ីវីនស៍**
នៃពួកចិតសិបនាក់

# ការតស៊ូស៊ិតស្វាញ និង ភាពជាសិស្ស

រចនានុចក្រមតាមអ៊ិនធើរណែតមួយបានឲ្យនិយមន័យនៃពាក្យ *ការតស៊ូស៊ិតស្វាញ* ថា « ការតស៊ូ ស្មារតីលះបង់ និង ការប្ដេជ្ញាចិត្តដ៏ស៊ិតស្វាញ » ។ វាក៏បានថ្លែងថា « ការតស៊ូស៊ិតស្វាញគឺជាគុណសម្បត្តិដែលបានបង្ហាញឡើងដោយនរណាម្នាក់ដែលពុំព្រមចុះចាញ់—គឺជាអ្នកដែលរក្សាការឧស្សាហ៍ព្យាយាមរហូតដល់ពួកគេបានឈានដល់គោលដៅខ្លួន » ។[១]

យើងត្រូវមានការតស៊ូស៊ិតស្វាញ ដើម្បីក្លាយទៅជាកូនសិស្សពិតរបស់ព្រះអង្គសង្គ្រោះ ហើយសម្រេចបាននូវគោលដៅល្អពិតៗ—ដោយក្លាយជាអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យ បញ្ចប់ការអប់រំរបស់យើង ស្វែងរកដៃគូអស់កល្បជានិច្ច ហើយចាប់ផ្ដើមគ្រួសារ—ដែលព្រះវរបិតាសួគ៌របស់យើងជ្រាបថា យើងត្រូវការសម្រេចឲ្យបានដើម្បីរៀបចំសម្រាប់ភាពអស់កល្បជានិច្ច ។ សមត្ថភាពរបស់យើងដើម្បីតស៊ូស៊ិតស្វាញនៅក្នុងគ្រប់កិច្ចការល្អទាំងអស់ នឹងកំណត់ថាតើយើងប្រែក្លាយជាបុត្រា និង បុត្រីរបស់ព្រះ ដែលទ្រង់ជ្រាបដឹងថាយើងអាច ហើយត្រូវតែប្រែក្លាយខ្លួនទៅជាបុត្រទ្រង់បានដែរឬទេ ។

ពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងជំនាន់សព្វថ្ងៃនេះត្រូវបានហៅថាជា « អ្នកផ្សព្វផ្សាយសាសនានៃជំនាន់ដ៏អស្ចារ្យបំផុតនៅក្នុងប្រវត្តិសាស្ត្រសាសនាចក្រ » ហើយប្រៀបបានទៅនឹងកងទ័ពកំឡោះទាំង ២០០០ នាក់របស់ហេលេមិន ។[២] ម្យ៉ាងវិញទៀត ដោយលក្ខណៈ និងសេចក្ដីជំនឿនៃការតស៊ូដ៏ស៊ិតស្វាញអស្ចារ្យ និងកិច្ចខិតខំរបស់យុវជនទាំងនេះ នោះហេលេមិនជាអ្នកដឹកនាំពួកគេថ្លែង ៖ « មានចំនួនពីររយនាក់នៅក្នុងចំណោមពីរពាន់ហុកសិបនាក់របស់ខ្ញុំ ដែលត្រូវសន្លប់ដោយសារអស់ឈាម ទោះជាយ៉ាងណាក៏ដោយ គង់តែស្របតាមសេចក្ដីល្អសប្បុរសនៃព្រះ និងចំពោះសេចក្ដីអស្ចារ្យរបស់យើងជាខ្លាំង និងចំពោះសេចក្ដីអំណររបស់កងទ័ពយើងទាំងមូលផង នោះគ្មានអ្នកណាម្នាក់ នៅក្នុងចំណោមពួកគេត្រូវវិនាសឡើយ » ( អាលម៉ា ៥៧:២៥ ) ។

ពួកគេត្រូវបានរំដោះឲ្យរួច « ដោយសារតែសេចក្ដីជំនឿដ៏លើសលប់របស់គេនៅក្នុងអ្វីៗដែលពួកគេត្រូវបានបង្រៀនឲ្យជឿ—ថាមានព្រះដ៏យុត្តិធម៌មួយអង្គ ហើយអស់អ្នកណាដែលមិនសង្ស័យ អ្នកនោះនឹងត្រូវបានរក្សាទុកឲ្យគង់វង្សដោយព្រះចេស្ដាដ៏អស្ចារ្យរបស់ទ្រង់ » ( អាលម៉ា ៥៧:២៦ ) ។

ហេលេមិននិយាយពីពួកគេ ៖ « ពួកគេនៅក្មេង ហើយគំនិតគេរឹងប៉ឹង ហើយពួកគេដាក់ទីទុកចិត្តរបស់គេទៅលើព្រះរហូត » ( អាលម៉ា ៥៧:២៧ ) ។

ដូច្នេះយើងក៏ដូចគ្នាផងដែរ ។ នៅក្នុងជីវិតនេះ នៅពេលមានភ្លៀងធ្លាក់មក ហើយទឹកជន់ឡើង និងខ្យល់បក់បោកមកប៉ះយើង និង ផ្ទះរបស់យើង នោះយើងកំណត់ថាតើសេចក្ដីជំនឿរបស់យើងរឹងមាំ ហើយថាតើយើងដាក់ទីទុកចិត្តរបស់យើងលើព្រះរហូតឬអត់ទេ ។ ជាទូទៅគ្មានការសាកល្បងឡើយ លុះត្រាតែមានសេចក្ដីវេទនា ។

**ចូរមានសេចក្ដីជំនឿលើព្រះ និង ការសន្យារបស់ទ្រង់ ហើយធ្វើអ្វីដែលត្រឹមត្រូវគ្រប់ពេលវេលា ដោយពុំគិតថាមានអ្នកដឹង ឬ មិនដឹងក៏ដោយ ។**

### កុំរសាយចិត្តឡើយ

ច្រើនឆ្នាំមកហើយ ភរិយារបស់ខ្ញុំ ម៉ារី និង ខ្ញុំបានធ្វើជាអធិបតីលើបេសកកម្ម ណាហ្គោយ៉ា ប្រទេសជប៉ុន ។ ពាក្យ *អង់អាច*, *ក្លាហាន*, *មានកម្លាំង*, *សកម្ម* និង *ស្មោះត្រង់* ដែលពិពណ៌នាពីទ័ពកំឡោះ ២០០០ នាក់ ( សូមមើល អាលម៉ា ៥៣:២០ ) ក៏បានពិពណ៌នាពីពួកអ្នកផ្សព្វផ្សាយសាសនាដែលយើងបម្រើជាមួយនេះផងដែរ ។ ការពិពណ៌មួយផ្សេងទៀតនៃទ័ពកំឡោះ ២០០០ នាក់នោះ—មានអ្នកខ្លះ *បានសន្លប់* ( សូមមើល អាលម៉ា ៥៧:២៥ )—ក៏ពិពណ៌នាពីអ្នកផ្សព្វផ្សាយសាសនាមួយចំនួនរបស់យើងដែរ ។

បេសកកម្មពុំងាយស្រួលឡើយ ។ ជីវិតក៏មិនងាយស្រួលដែរ ។ មនុស្សគ្រប់គ្នានឹងមានគ្រោះថ្នាក់

រូបភាព © ISTOCK/THINKSTOCK



នៅតាមផ្លូវនេះ ។ ការឈឺចាប់មួយចំនួនកើតឡើង ពីការពុំដោះស្រាយនូវការរំលងនានា ។ ការឈឺចាប់ផ្សេងទៀតកើតឡើងដោយចៃដន្យ ឬ ជំងឺដង្កាត់ ។ ការឈឺចាប់ខ្លះទៀតកើតឡើង នៅពេលយើងឃើញអស់អ្នកដែលយើងស្រឡាញ់បដិសេធដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ឬ ប្រែជាពុំស្មោះត្រង់ចំពោះអ្វីដែលពួកគេបានដឹងថាជាការពិត ។ ប៉ុន្តែតាមរយៈការណ៍ទាំងនេះ យើងប្រែជាស្គាល់ព្រះ ហើយយើងរីកចម្រើនប្រែក្លាយជាសិស្សរបស់ព្រះអង្គសង្គ្រោះ ។ ដួងចិត្តរបស់យើងផ្លាស់ប្ដូរ ហើយការផ្លាស់ប្ដូរនោះក្លាយជាអចិន្ត្រៃយ៍ នៅពេលយើងបន្តជ្រើសរើសសេចក្ដីសុចរិតជាជាងអំពើបាប និង ការសង្ស័យ ។

កងទ័ពកំឡោះ ២០០០ នាក់នោះបានតស៊ូយ៉ាងស្វិតស្វាញតាមបំណងប្រាថ្នារបស់ខ្លួន ។ ពួកគេពុំបោះបង់ដោយងាយៗឡើយ ទោះជានៅពេលផ្លូវរបស់ពួកគេមានការលំបាកក្ដី ។ អាំម៉ូនបានបង្រៀនមនុស្សជំនាន់មុនដែលជាឪពុកម្ដាយរបស់ពួកគេ និង បងប្អូនរបស់គេ ។ ពួកអ្នកផ្សព្វផ្សាយសាសនាទាំងនោះ មានជោគជ័យដ៏មហិមា ប៉ុន្តែពួកគេក៏បានស៊ូទ្រាំ ហើយមិនបោះបង់ឡើយ នៅពេលបេសកកម្មរបស់ពួកគេបានប្រែជាពិបាក ហើយបាក់ទឹកចិត្តនោះ ។

អាំម៉ូនពិពណ៌នាពីគ្រាទាំងនោះ ៖ « ឥឡូវនេះ កាលណាយើងនឿយណាយក្នុងចិត្ត ហើយយើងសឹងតែត្រលប់ទៅវិញ មើលចុះ ព្រះអម្ចាស់ ទ្រង់បានកម្សាន្តចិត្តយើង ហើយមានព្រះបន្ទូលថា ៖ ចូរទៅក្នុងចំណោមបងប្អូនអ្នក គឺពួកសាសន៍លេមិន ហើយចូរទ្រាំដោយសេចក្ដីអត់ធ្មត់នូវការទុក្ខវេទនាទាំងឡាយរបស់អ្នកចុះ ហើយយើងនឹងប្រទានដល់អ្នកនូវជ័យជំនះ » ( អាលម៉ា ២៦:២៧ ) ។

ដោយមានការអត់ធ្មត់ និង ការតស៊ូស្វិតស្វាញ អាំម៉ូន និង ដៃគូរបស់លោកបានធ្វើការប្រឡូកឆ្លងកាត់ទុក្ខលំបាក ហើយនៅទីបំផុតបានសម្រេចនូវជោគជ័យដ៏អស្ចារ្យ ។

## ការតស៊ូដ៏ស្វិតស្វាញនៅក្នុងដំណឹងល្អ

នៅក្នុងឆ្នាំ ១៩៩៩ ស៊ិស្ទើរ ម៉ាស៊ី បា មកពីកូឡុំបឺស អូហៃអូ ស.រ.អា.បានមកបេសកកម្ម ណាហ្គោយ៉ា ប្រទេស ជប៉ុន ។ នាងមានការលំបាកនិយាយភាសាជប៉ុន ប៉ុន្តែនាងបានតស៊ូយ៉ាងស្វិតស្វាញ ។ នៅពេលនាងបានរៀនចេះនិយាយហើយ នាងពុំអាចឈប់និយាយជាមួយមនុស្សអំពីដំណឹងល្អឡើយ ។

ការសន្យាដ៏អស្ចារ្យបានប្រទានដល់អ្នកផ្សព្វផ្សាយទាំងអស់ណាដែលស្មោះត្រង់ ស៊ូទ្រាំ និង តស៊ូយ៉ាងស្វិតស្វាញ ដែលបើកមាត់របស់ខ្លួនដោយក្លាហាន និង ក្ដីស្រឡាញ់ ព្រមទាំងអស់អ្នកដែលធ្វើការដោយអស់ពីចិត្តខ្លួន តាមរបៀបដែលព្រះអម្ចាស់បានរៀបចំ ( សូមមើល គ. និង ស. ៣១:៧ ) ។ ប៉ុន្តែមានពួកអ្នកផ្សព្វផ្សាយសាសនាមួយចំនួនបានប្រែទៅជាញញើតចំពោះការបដិសេធ ហើយធ្វើឲ្យការភ័យខ្លាចរបស់ពួកគេឈ្នះលើសេចក្ដីស្រឡាញ់ដ៏អង់អាចរបស់ខ្លួន ។

ប៉ុន្តែ ស៊ិស្ទើរ បា ពុំធ្វើបែបនេះឡើយ ! គាត់បានស្វែងរក ហើយបង្រៀន ហើយគាត់បានបង្រៀន ហើយស្វែងរកមនុស្សទាំងអស់នៅក្នុងបេសកកម្មរបស់ខ្លួន ។

នៅថ្ងៃបញ្ចប់បេសកកម្មរបស់គាត់ ស៊ិស្ទើរ បា បានធ្វើដំណើរទៅផ្ទះបេសកកម្មនៅទីក្រុង ណាហ្គោយ៉ា ។ នៅយប់នោះខ្ញុំបានសម្ភាសគាត់ ហើយប្រាប់គាត់ថាគាត់បានធ្វើកិច្ចការយ៉ាងល្អអស្ចារ្យ ។ ថ្ងៃស្អែកគាត់នឹងទៅផ្ទះហើយ ។

អំឡុងពេលធ្វើដំណើរ គាត់បានឃើញសិស្សវិទ្យាល័យមួយក្រុម–ជាសិស្សស្រីកំពុងជជែកគ្នានៅតាមផ្លូវ ។ គាត់បានទៅជួបពួកគេ ហើយសុំទៅសួរសុខទុក្ខពួកគេនៅពេលក្រោយ ។ គាត់បាននិយាយពីដំណឹងល្អ និង ការស្ដារឡើងវិញនៃដំណឹងល្អ ។ ក្រោយមកគាត់បានឲ្យកូនសៀវភៅអ្នកផ្សព្វផ្សាយសាសនាដល់សិស្សម្នាក់ដែលហាក់បីដូចជាចាប់អារម្មណ៍ ហើយបានប្រាប់នាងពីអ្នកផ្សព្វផ្សាយសាសនាស៊ិស្ទើរដែលអាចបង្រៀនដំណឹងល្អដល់នាង ។

ក្រោយមក ស៊ិស្ទើរ បាបានមកផ្ទះបេសកកម្ម ហើយបានសម្ភាស ដោយពុំបានប្រាប់ខ្ញុំពីរឿងដែលគាត់បានមាននៅតាមផ្លូវនោះឲ្យខ្ញុំដឹងឡើយ ។ ចំពោះគាត់នេះគឺជារឿងសាមញ្ញ ។ គាត់បានធ្វើអ្វីដែលគាត់បានដឹងថាត្រឹមត្រូវ តាំងពីដើមរហូតដល់ចប់ ។ ប្រហែលនោះជានិយមន័យដ៏ល្អបំផុតនៃ *ការតស៊ូស្វិតស្វាញ* នៅក្នុងដំណឹងល្អ ខ្ញុំដឹង ៖ មិនថាមានអ្វីកើតឡើងឡើយ ចូរបន្តសេចក្ដីជំនឿលើព្រះ និង ការសន្យារបស់ទ្រង់ ហើយធ្វើអ្វី ដែលត្រឹមត្រូវគ្រប់ពេលវេលា ដោយពុំគិតថាមានអ្នកដឹង ឬ មិនដឹងនោះទេ ។

ស៊ិស្ទើរ បាបានត្រឡប់ទៅផ្ទះនៅ កូឡុំប៊ឺវិញ ។ នៅក្នុងវួដនិស្សិតនោះនាងបានជួបនឹងអនាគតស្វាមីរបស់ខ្លួន ហើយពួកគេកំពុងចិញ្ចឹមគ្រួសារខ្លួននៅក្នុងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

សិស្សស្រីនៅតាមផ្លូវនោះ—ហ៊ីតូមី គីតាយ៉ាម៉ា—បានរៀនជាមួយស៊ីស្ទើរអ្នកផ្សព្វផ្សាយសាសនា ។ ហ៊ីតូមីបានរក្សា និង បង្ហាញនូវការតស៊ូស្វិតស្វាញរបស់ខ្លួននាងផ្ទាល់ នៅពេលនាងបានចាប់យកសេចក្ដីពិតនៃដំណឹងល្អ យកឈ្នះលើការប្រឆាំងរបស់សមាជិក និង ចម្ងល់ផ្ទាល់ខ្លួនរបស់នាង ។

ជិតប្រាំមួយឆ្នាំក្រោយមកយើងបានជួប ហ៊ីតូមីនៅសន្និសីទបេសកកម្មទីក្រុង តូក្យូ ដែលនាងកំពុងបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ នាងបានប្រាប់យើងអំពីការជួបជាមួយ ស៊ិស្ទើរ បា នៅតាមផ្លូវនោះ និង ពីការប្រែចិត្តជឿរបស់នាងលើដំណឹងល្អនាពេលក្រោយមក ។

បន្ទាប់ពីបេសកកម្ម នាងបានជួប និង រៀបការជាមួយអ្នកត្រឡប់ពីបេសកកម្មម្នាក់ឈ្មោះ ស៊ីប៊ី យ៉ាម៉ាស៊ីតា ។ គួរឲ្យចាប់អារម្មណ៍ណាស់ ស៊ីប៊ី គឺជាកូនប្រុសរបស់បុរសម្នាក់ដែលអែលឌើរ រ៉ាឌី ផែកឃិត និង ខ្ញុំបានបង្រៀនគាត់កាលពីរដូវក្ដៅឆ្នាំ ១៩៧១ ខណៈ





**ចូរព្យាយាមអនុវត្តវិន័យឲ្យកាន់តែប្រសើរឡើង**

« យ៉ាងណាក៏ដោយ ខ្ញុំសូមលើកទឹកចិត្តបងប្អូនទាំងចាស់ ទាំងក្មេង ឲ្យរំឭកពីគោលដៅ និង ទិសដៅនានា ហើយព្យាយាមអនុវត្តវិន័យឲ្យកាន់តែប្រសើរឡើង ។ ការប្រព្រឹត្ត និងជម្រើសប្រចាំថ្ងៃយើង គួរតែស្របជាមួយគោលដៅរបស់យើង » ។

**អែលឌើរ ឃ្វីនថិន អិល ឃុក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Choose Wisely » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៤៩ ។**

ខ្ញុំបម្រើបេសកកម្មដំបូងរបស់ខ្ញុំនៅប្រទេសជប៉ុន ។

វាមិនគ្រាន់តែជាការផ្សាយដំណឹងល្អប៉ុណ្ណោះទេ ដែលយើងត្រូវតែមានការតស៊ូស្វិតស្វាញដើម្បីធ្វើអ្វីដែលត្រឹមត្រូវនោះ ។ យើងត្រូវការការតស៊ូស្វិតស្វាញដ៏សុចរិតដូចគ្នានេះ នៅពេលយើងព្យាយាមយកឈ្នះលើអំពើបាប និង ការល្បួងផ្ទាល់ខ្លួន ចូបញ្ចប់ការអប់រំរបស់យើង ហើយស្វែងរកការរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ព្រមទាំងមានគ្រួសារអស់កល្បមួយ ។ យើងនឹងត្រូវការការតស៊ូស្វិតស្វាញសេចក្ដីស្រឡាញ់ និង ភាពរឹងមាំ នៅពេលយើងស៊ូទ្រាំចំពោះស្វាមី ឬ ភរិយា និង កូនៗ ព្រមទាំងការងាររបស់យើង ឆ្លងកាត់ឧបសគ្គនានា ដែលកើតមានឡើងនៅក្នុងគ្រប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។ ហើយយើងនឹងត្រូវការការតស៊ូស្វិតស្វាញ ការប្ដេជ្ញាចិត្ត និងការអត់ធ្មត់ នៅពេលពរជ័យដែលយើងចង់បាន ពុំទាន់បានកើតឡើងនៅក្នុងកាលកំណត់ដែលយើងរំពឹងទុកជាមុន ។

គ្រប់កិច្ចការទាំងនេះ និង គ្រប់កិច្ចការសុចរិតផ្សេងទៀត នោះការប្ដេជ្ញាចិត្តរបស់យើង ដើម្បីធ្វើកិច្ចការត្រឹមត្រូវ និង ធ្វើខ្លួនឲ្យបានត្រឹមត្រូវនឹងជួបនូវឧបសគ្គដោយសារតែលោកិយ ។ ប៉ុន្តែយើងមិនត្រូវឈប់ឡើយ ។ យើងចាំបាច់ត្រូវបន្តព្យាយាមរហូតដល់យើងសម្រេចបាននូវគោលដៅរបស់យើង ។ គោលដៅធំបំផុតរបស់យើង គឺជីវិតដ៏នៅអស់កល្បជានិច្ចជាមួយស្វាមី ឬ ភរិយា ជាមួយកូនៗរបស់យើង ព្រមទាំងជាមួយកូនៗរបស់ពួកគេជាច្រើនជំនាន់ក្រោយៗទៀត ។

**ដាក់គោលដៅឲ្យមានភាពសក្ដិសម**

តើយើងអាចបង្កើនការប្ដេជ្ញាចិត្តរបស់យើងធ្វើអ្វីដែលត្រឹមត្រូវយ៉ាងដូចម្ដេច ហើយតើយើងទទួលបានកម្លាំងដើម្បីបន្តរក្សាវាយ៉ាងដូចម្ដេច ?

ទីមួយ យើងដាក់គោលដៅឲ្យមានភាពសក្ដិសមដើម្បីសម្រេចឲ្យបាន និង ស្របគ្នាទៅនឹងគោលដៅចុងបង្អស់របស់យើងគឺជីវិតដ៏នៅអស់កល្បជានិច្ច ។ គោលដៅនោះរួមមាន ការអប់រំ និង ការងារ ដែលវានឹងដឹកនាំ ព្រមទាំងស្របគ្នាជាមួយនឹងគ្រួសារ ការរីកចម្រើនផ្ទាល់ខ្លួន ការបម្រើ សកម្មភាពនៅក្នុងសាសនាចក្រ និង សុភមង្គលផ្ទាល់ខ្លួន ។ ជម្រើសផ្ទាល់ខ្លួនរបស់យើងនឹងក្លាយជាផ្នែកមួយនៃការដាក់គោលដៅទាំងនេះ ប៉ុន្តែផ្នែកមួយទៀតត្រូវរួមបញ្ចូលនូវការអធិស្ឋាន និង វិវរណៈផ្ទាល់ខ្លួន ។ ប្រសិនបើយើងយកចិត្តទុកគ្រប់គ្រាន់ដើម្បីស្វែងរកព្រះឆន្ទៈរបស់ព្រះនោះទ្រង់នឹងឆ្លើយតប ។

ក្នុងចំណោមអ្វីៗជាច្រើន ដែលអ្នកគប្បីអធិស្ឋានទូលសុំនោះគឺ ការស្វែងរកដៃគូដ៏សក្ដិសម ដែលជាបុគ្គលម្នាក់ដែលអ្នកអាចទៅព្រះវិហារបរិសុទ្ធ ហើយចុះសេចក្ដីសញ្ញាពិសិដ្ឋជាមួយគ្នា ។ *ប្រសិនបើអ្នកចង់ចុះ និង រក្សាសេចក្ដីសញ្ញាពិសិដ្ឋ ហើយមានកម្លាំងចិត្ត ដើម្បីសម្រេចឲ្យបាននូវគោលដៅដ៏សុចរិតបំផុតរបស់អ្នក នោះសូមស្វែងរកពរជ័យ និង ការទទួលខុសត្រូវនៃអាពាហ៍ពិពាហ៍ដោយការគិតគូរបំផុត* ។

ចំពោះរឿងនេះ និង កិច្ចការផ្សេងទៀតនៅក្នុងជីវិតអ្នក សូមស្វែងយល់ពីអ្វីដែលព្រះមានព្រះទ័យចង់ឲ្យអ្នកធ្វើ ។ ចូរសិក្សាវាចុះ ។ ធ្វើការសម្រេចចិត្ត ចូរថ្វាយការសម្រេចចិត្តនោះទៅព្រះអម្ចាស់ ហើយស្វែងយល់ពីវា ។ បន្ទាប់មកបន្តឆ្ពោះទៅមុខដោយសម្រេចបាននូវគោលដៅរបស់អ្នក ។

ចំពោះកិច្ចការទាំងនេះ ប្រសិនបើយើងមានការតស៊ូស្វិតស្វាញនៅក្នុងកិច្ចការសុចរិត នោះយើងត្រូវបន្តនៅក្បែរព្រះអម្ចាស់ តាមរយៈការរស់នៅដោយសុចរិត ។ មានកិច្ចការមួយចំនួនដែលនឹងបង្វែរយើងចេញឆ្ងាយពីការសម្រេចនូវគោលដៅសុចរិតរបស់យើង ដែលធ្វើឲ្យយើងគ្មានភាពសក្ដិសមចំពោះពរជ័យនៃព្រះវិញ្ញាណនៅក្នុងជីវិតរបស់យើង ។

ចូរដាក់គោលដៅធ្វើកិច្ចការសុចរិត ។ ចូរអធិស្ឋាន និង ស្វែងរកការដឹកនាំពីព្រះអម្ចាស់ជានិច្ច ។ ចូរមានភាពសក្ដិសម ហើយចៀសវាងពីកិច្ចការណាដែលនឹងបង្វែរអ្នក ឬ បង្អាក់អ្នកពីភាពរីកចម្រើន ។ ចូរមានបណ្ណ័ចូលព្រះវិហារបរិសុទ្ធ ហើយប្រើប្រាស់វា ។ ចូររក្សាសេចក្ដីសញ្ញារបស់អ្នក ជាពិសេសនៅពេលជីវិតជួបនូវការលំបាក ។ ចូរស្វែងរកពរជ័យនៃអាពាហ៍ពិពាហ៍ និងគ្រួសារដ៏អស់កល្បជានិច្ច ។ បន្ទាប់មកប្រកាន់វាឲ្យខ្ជាប់ខ្ជួន ។ ចូរកុំចុះចាញ់ឡើយ ។ ចូរកុំឈប់ឡើយ ។

ចូរមានការតស៊ូស្វិតស្វាញ នៅក្នុងគ្រប់កិច្ចការសុចរិតទាំងអស់ ។ អ្នកនឹងឃើញថាសេចក្ដីជំនឿរបស់អ្នកនឹងរឹងមាំ ហើយអ្នកនឹងឃើញថាកម្លាំង និងទេពកោសល្យរបស់អ្នកកាន់តែមានច្រើន ហើយកើនឡើង នៅពេលសេចក្ដីជំនឿរបស់អ្នករីកចម្រើន ។ ហើយចូរចាំនូវអ្វីដែលអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានសន្យា ៖ « ពរជ័យខ្លះកើតឡើងភ្លាមៗ ខ្លះទៀតកើតឡើងពេលក្រោយ ហើយខ្លះទៀតមិនកើតឡើងឡើយ លុះត្រានៅស្ថានសួគ៌ទើបវាកើតឡើង ប៉ុន្តែអស់អ្នកដែលឱបក្រសោបដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនោះ *ពរជ័យទាំងនោះនឹងកើតមានឡើង* » ។[៣] ■

*ដកស្រង់ចេញពីសុន្ទរកថា « Tenacity » ដែលបានផ្ដល់នៅក្នុងនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ។ ដើម្បីទទួលបានសុន្ទរកថាទាំងស្រុង ជាភាសាអង់គ្លេស សូមចូលទៅ speeches.byu.edu*។

**កំណត់ចំណាំ**

១. Vocabulary.com/dictionary/tenacity ។
២. សូមមើល អិម រ័សុល បាឡឺដ « The Greatest Generation of Missionaries » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០២ ទំព័រ ៤៧, ៤៨ ចំពោះព្រះគម្ពីរមរមនពិពណ៌នាពីពួកគេនោះ សូមមើល អាលម៉ា ៥៣:១៧–២១; ៥៦:១៧, ៤៥–៤៨; ៥៧:២០–២១ ។
៣. ជែហ្វ្រី អ័រ ហូឡិន « An High Priest of Good Things to Come » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ទំព័រ ៣៨ ។

# ជើងឯកនៃថ្ងៃឈប់សម្រាក

ដោយ សាមែនថា ម៉ាក់ហ្វែដយិន



ខ្ញុំមិនធ្លាប់គិតសោះថា ជម្រើសរបស់យើងដើម្បីរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ នឹងជះឥទ្ធិពលដល់មនុស្សជាច្រើន ។

នៅពេលគ្រូបង្វឹកបាល់ឱបរបស់ខ្ញុំបានប្រាប់ក្រុមរបស់យើងថា ការប្រកួតកីឡាវគ្គចុងក្រោយថ្នាក់ជាតិរបស់យើងគឺធ្វើឡើងនៅថ្ងៃអាទិត្យ អ្វីដែលខ្ញុំអាចគិតនោះគឺថា « ហេតុអ្វីទើបតែប្រាប់ពេលនេះ ? »

ក្រុមរបស់ខ្ញុំ គឺក្រុមបាល់ឱបស្ត្រីរបស់សាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ឆ្នាំ ២០១០ បានរៀបចំខ្លួនសម្រាប់ការប្រកួតជើងឯកពេញមួយរដូវកាលនោះ ។ យើងបានទន្ទឹងរង់ចាំលេងជាមួយក្រុមដែលបានឈ្នះយើងកាលពីការប្រកួតឆ្នាំមុន ។ ខ្ញុំមានទំនុកចិត្តថាយើងអាចឈ្នះបាន—យើងមានកីឡាករដ៏ខ្លាំងពូកែមួយចំនួននៅក្នុងប្រទេស ។ យើងចង់បង្ហាញខ្លួនយើងទៅកាន់ក្រុមបាល់ឱបពិភពលោក ដោយយកជ័យជាជើងឯកថ្នាក់ជាតិ ប៉ុន្តែព្រះវរបិតាសួគ៌មានផ្លូវមួយផ្សេងទៀតសម្រាប់យើង ។

## ការនៅបន្តកាន់ខ្ជាប់នូវបទដ្ឋានរបស់យើង

មន្ត្រីនៃការប្រកួតកីឡានោះបានបញ្ជាក់ដល់យើងថាការប្រកួតរបស់យើងនឹងធ្វើឡើងនៅថ្ងៃសុក្រ និងថ្ងៃសៅរ៍ ប៉ុន្តែដោយសារតែកំហុសមួយ នោះការប្រកួតបែរទៅជាដាក់នៅ ថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យទៅវិញ ។ យើងពុំបានដឹងពីកំហុសនោះឡើយ រហូតសល់តែប្រាំថ្ងៃពីមុនការប្រកួតនោះ ដែលបានប្រារព្ធឡើងនៅទីក្រុង សាន់ហ្វត រដ្ឋ ហ្លរីដា ស.រ.អា. ។ ដោយសារបាល់ឱបស្ត្រីពុំមែនជាក្រុមកីឡាផ្លូវការមួយរបស់ក្រុមប៊ី.វ៉ាយ.យូ. នៅគ្រានោះ ដូច្នេះយើងជាអ្នកសម្រេចចិត្តថាលេង ឬ មិនលេងវា ។ យើងបានជ្រើសពុំលេងវាឡើយ ។ វាគឺជាការសម្រេចចិត្តដ៏ឯកច្ឆន្ទមួយ ហើយគ្មាននរណាម្នាក់ត្អូញត្អែរឡើយ ។

ការលេងនៅថ្ងៃអាទិត្យគឺពុំមែនជាជម្រើសមួយឡើយ ។ សម្រាប់ខ្ញុំ វាមិនធ្លាប់កើតឡើងឡើយ ។ ឪពុកម្ដាយរបស់ខ្ញុំបានបង្រៀនខ្ញុំឲ្យរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ហើយគោរពតាមបទបញ្ញត្តិនោះពេញមួយជីវិតខ្ញុំ ។ ការគោរពតាមបទបញ្ញត្តិរបស់ព្រះវរបិតាសួគ៌យើងគឺរិតតែសំខាន់ជាងការប្រកួតកីឡាបាល់ឱបនេះទៅទៀត ។

ប៉ុន្តែការដឹងថាយើងកំពុងធ្វើទង្វើត្រឹមត្រូវ ពុំបានធ្វើឲ្យវាមានភាពងាយស្រួលជាងនោះឡើយ ។ យើងស្រងាកចិត្តនៅពេលយើងជិះយន្តហោះទៅរដ្ឋ ហ្លរីដា បើទោះជាយើងឈ្នះ ឬ ចាញ់ក្តី ថ្ងៃសៅរ៍គឺជាការប្រកួតចុងក្រោយរបស់យើង ។

បន្ទាប់ពីទៅដល់រដ្ឋ ហ្លរីដា យើងបានទទួលទូរសព្ទមួយមកពីអ្នកយកព័ត៌មាន *New York Times* ដែលចង់ដឹងព័ត៌មានរបស់ពួកយើង ។ យើងមានការភ្ញាក់ផ្អើលណាស់ ។ យើងពុំធ្លាប់រំពឹងទុកថាមានអ្នកខ្វល់ខ្វាយពីជម្រើសរបស់យើង ដើម្បីគោរពថ្ងៃឈប់សម្រាកនោះឡើយ ទោះបីជាក្រុមហ៊ុនកាសែតតូចមួយក៏ដោយ ។

ប្រសិនបើកាលវិភាគប្រកួតមិនខុសទេ នោះយើងប្រហែលជាកំពុងប្រកួតបាល់ហើយ ប៉ុន្តែនៅថ្ងៃសុក្រនោះយើងបានទៅព្រះវិហារបរិសុទ្ធ អូលែនដូ ហ្លរីដាដើម្បីធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជនវិញ ។ បន្ទាប់ពីធ្វើពិធីបរិសុទ្ធនោះរួច ប្រធានព្រះវិហារបរិសុទ្ធបាននិយាយមកកាន់ពួកយើង ។ លោកបានទាញយកអត្ថបទមួយដែលបានសរសេរអំពីពួកយើង ហើយអាននូវការបញ្ចេញមតិរបស់អ្នកអានមួយចំនួនដែលបានចុះផ្សាយលើអ៊ិនធើរណែត ក្នុងការគាំទ្រដល់ការសម្រេចចិត្តរបស់យើង ។

ក្រោយមកទៀតគ្រូបង្វឹករបស់យើងបានអានការបញ្ចេញមតិបន្ថែមទៀតដែលគាត់បានទទួល ។



ពួកបរិសុទ្ធថ្ងៃចុងក្រោយ និង មនុស្សដទៃទៀតបានថ្លែងអំណរគុណដល់យើង ចំពោះគំរូយើង ហើយបានប្រាប់យើងថា វាល្អវិសេសដើម្បីឃើញមនុស្សដែលបន្តនៅកាន់ខ្ជាប់នូវបទដ្ឋានរបស់ខ្លួន ។ ពាក្យសម្ដីរបស់ពួកគេបានលើកស្ទួយវិញ្ញាណរបស់យើង ។ នោះគឺជាពេលដែលយើងបានចាប់ផ្ដើមដឹងពីឥទ្ធិពលដែលយើងអាចមានដោយពុំចាំបាច់ក្លាយជាជើងឯកជម្រើសជាតិឡើយ ។

ខ្ញុំបានដឹងថា ព្រះវរបិតាសួគ៌ជ្រាបដឹងពីពួកយើង ប៉ុន្តែខ្ញុំពុំធ្លាប់គិតសោះថាមាននរណាទៀតកំពុងមើលពួកយើងឡើយ ។ ចម្លើយចំពោះការសម្រេចចិត្តរបស់យើងបានផ្ដល់នូវគោលបំណងថ្មីសម្រាប់ការនៅក្នុងរដ្ឋហ្វ្លរីដា ៖ យើងពុំបាននៅទីនោះដើម្បីឈ្នះការប្រកួតឡើយ ប៉ុន្តែដើម្បីយើងការពារបទដ្ឋានរបស់យើង ។

### ផ្លូវដ៏ល្អប្រសើរ

នៅថ្ងៃសៅរ៍បានចូលមកដល់ ហើយយើងបានឈ្នះការប្រកួតរបស់យើង ៤៦ ទល់នឹង ៧ ។ ក្រោយមក យើងបានដើរទៅកាន់មន្ត្រីរៀបចំការប្រកួតនោះ ហើយបានប្រាប់ពួកគេថា យើងសូមចុះចាញ់ការប្រកួតដែលគ្រោងនឹងធ្វើឡើងនៅថ្ងៃអាទិត្យ— ដែលជាក្រុមដែលបានប្រកួតឈ្នះយើងកាលពីឆ្នាំមុននោះ ។ ខ្ញុំបានខកចិត្តដែលរដូវកាលប្រកួតរបស់យើងបានបញ្ចប់ទៅបែបនេះ ។ ខ្ញុំប្រាថ្នាថា ពួកយើងអាចលេងជាមួយក្រុមនេះ ប៉ុន្តែខ្ញុំពុំប្រាថ្នាចង់លេងជាមួយពួកគេ ឬ ក្រុមណាទៀតនៅថ្ងៃអាទិត្យឡើយ ។

មានអត្ថបទជាច្រើនបានសរសេរអំពីពួកយើង ហើយយើងបានបន្តទទួលបានលិខិត និង អ៊ីម៉ែលគាំទ្រជាច្រើន ។ តាមរយៈការការពារនូវបទដ្ឋានរបស់យើង នោះយើងបានជួបមនុស្សជាច្រើនដែលយើងអាចជួប ប្រសិនបើយើងឈ្នះជាជើងឯកនោះ ។

ខ្ញុំបានរៀនទុកចិត្តលើព្រះវរបិតាសួគ៌ ឲ្យដឹកនាំខ្ញុំទៅរកផ្លូវដែលល្អប្រសើរជាងដែលមានក្នុងគំនិតខ្ញុំផ្ទាល់ ។ ក្រុមរបស់ខ្ញុំចង់បង្ហាញខ្លួនពួកគេ តាមរយៈការក្លាយជាជើងឯក ប៉ុន្តែឥឡូវនេះ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌យើងមានព្រះទ័យចង់ឲ្យយើងធ្វើនូវទង្វើមួយផ្សេងពីនោះទាំងស្រុង ។ ទ្រង់បានដឹកនាំយើងទៅកាន់ឱកាសមួយដើម្បីធ្វើជាគំរូ នៅពេលយើងបានគិតថាគ្មាននរណាម្នាក់កំពុងមើលមកយើងនោះ ហើយទ្រង់អាចប្រើយើងសម្រាប់សេចក្ដីល្អ ដោយសារយើងបានជ្រើសរើសដើម្បីគោរពតាម ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ វ៉ាស៊ីងតោន ស.រ.អា. ។*



### គោរពប្រតិបត្តិតាមថ្ងៃឈប់សម្រាក

« ព្រះអង្គសង្គ្រោះលើកនាមទ្រង់ថា ជាម្ចាស់លើថ្ងៃឈប់សម្រាក ។ វាជាថ្ងៃរបស់ទ្រង់ ! ទ្រង់បញ្ជាដដែលៗឲ្យយើង *គោរព* ថ្ងៃឈប់សម្រាក ឬ *ចាត់ទុក* ថ្ងៃឈប់សម្រាកជាថ្ងៃដ៏វិសុទ្ធ ។ យើងចុះសេចក្ដីសញ្ញាដើម្បីធ្វើដូច្នោះ ។

. . . [ យើង ] សួរ [ ខ្លួនយើង ] យ៉ាងសាមញ្ញថា ‹ តើ *ទីសម្គាល់* ណាដែលខ្ញុំចង់បង្ហាញដល់ព្រះ ? › សំណួរនោះ [ ធ្វើឲ្យ ] ជម្រើសរបស់យើងនៅថ្ងៃឈប់សម្រាកមានភាពច្បាស់លាស់ឡើង ។ . . .

« . . . យើងដឹងថា ថ្វីបើយើងរស់នៅទីណាក៏ដោយ យើងត្រូវធ្វើជាគំរូដល់ពួកអ្នកជឿក្នុងគ្រួសារយើង អ្នកជិតខាង និង មិត្តភក្ដិ ។ អ្នកជឿដ៏ស្មោះស្ម័គ្រ រក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។

ប្រធាន រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « **The Sabbath Is a Delight** » ***Liahona*** ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១២៩–១៣០ ១៣២ ។



រចនាលំអរូបថតរបស់ក្រុមបាល់ឱបស្ត្រី ( ប៊ី.វ៉ាយ.យូ. ) និង ប៉ុល មៃយើរ

# នៃការធ្វើជា ផ្នែកដ៏លំបាកបំផុត អ្នកផ្សព្វផ្សាយសាសនា

*ពេលខ្លះ ឧបសគ្គដ៏ធំបំផុតនៅក្នុងកិច្ចការអ្នកផ្សព្វផ្សាយសាសនាគឺពុំមែនជាកិច្ចការផ្សព្វផ្សាយសាសនាឡើយ ។*

**ដោយ បណ្ឌិត វេនឌី អ៊ុលរីច**

មានគ្រាមួយនោះអ្នកផ្សព្វផ្សាយសាសនាបានប្រាប់ខ្ញុំថា « នៅពេលមនុស្សបាននិយាយថាបេសកកម្មប្រហែលជាលំបាក នោះខ្ញុំបានសន្មត់ថា ខ្ញុំនឹងមានការលំបាក ឬ ជួបប្រទះនឹងស្ថានភាពរស់នៅដ៏លំបាកលំបិន ឬ មានការលំបាកជាមួយនឹងភាសា ។ ប៉ុន្តែសម្រាប់ខ្ញុំវិញ ផ្នែកដ៏លំបាកបំផុតនោះគឺជាអ្វីដែលនៅក្នុងខួរក្បាលខ្ញុំជាប់ជានិច្ច—ដូចជាអារម្មណ៍បាក់ទឹកចិត្ត ឬ មានភាពស្មុគស្មាញជាមួយដៃគូ ឬ ពុំចូលចិត្តនិយាយជាមួយមនុស្សប្លែកមុខ—គឺទាក់ទងជាមួយនឹងភាពមួយថ្ងៃកាត់មួយថ្ងៃកោរ ការបដិសេធ ការផ្លាស់ប្ដូរ » ។

ដើម្បីរៀបចំខ្លួនទៅបម្រើបេសកកម្ម អ្នកអាច ហើយគប្បី អាន *ប្រកាសដំណឹងល្អរបស់យើង* សិក្សាព្រះគម្ពីរ និង រៀនពីរបៀបចម្អិនអាហារ ព្រមទាំងការបោកគក់ ។ ប៉ុន្តែអ្នកគួរតែស្វែងរកនូវបទពិសោធន៍នៃជំនាញ *ផ្លូវចិត្ត សង្គម និង ជំនាញផ្សេងៗទៀត* ក្នុងពេលឥឡូវនេះផងដែរ ដែលអ្នកនឹងត្រូវការក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ។ នេះគឺជាបញ្ជីមួយចំនួននៃជំនាញទាំងនេះ ។ អ្នកអាចគូសជំនាញនេះ មួយ ឬ ពីរដើម្បីចាប់ផ្ដើមអនុវត្តវាចាប់ពីឥឡូវនេះ ។

## ជំនាញនៃការបន្ទាបខ្លួនដោយគ្មានអារម្មណ៍អៀនខ្មាស

ស៊ិស្ទើរ ជាអ្នកផ្សព្វផ្សាយសាសនាម្នាក់នៅក្នុងរដ្ឋ អាឡាបាម៉ា ស.រ.អា. បានប្រាប់ខ្ញុំថា « ខ្ញុំបានគិតថា នៅពេលពួកគេបានញែកខ្ញុំចេញ នោះខ្ញុំនឹងទទួលអំណាចដ៏អស្ចារ្យ ។ ដូច្នេះ ខ្ញុំមានការភ្ញាក់ផ្អើលណាស់ ដែលឃើញថា នៅពេលខ្ញុំទៅតំបន់បេសកកម្ម នោះខ្ញុំនៅតែជារូបខ្ញុំដដែល ។ ខ្ញុំនៅតែមានអារម្មណ៍ទន់ខ្សោយ ភ័យខ្លាច និង គ្មានសមត្ថភាព ។ ហើយអារម្មណ៍ទាំងនោះពិតជាមិនរសាយបាត់ទៅឡើយ ។ ខ្ញុំបានរៀនពីរបៀបដើម្បីទប់ទល់ជាមួយអារម្មណ៍នៃការខ្វះសមត្ថភាពក្នុងការធ្វើការរបស់ព្រះអម្ចាស់ » ។

មិនថាអ្នកមកក្នុងបេសកកម្មដោយមានជោគជ័យពីមុនៗច្រើនប៉ុណ្ណានោះទេ ប្រសិនបើអ្នកបន្ទាបខ្លួន ងាយនឹងប្រដៅ និង មានឆន្ទៈព្យាយាម និង ធ្វើការ នោះព្រះអម្ចាស់អាចជួយអ្នកបាន ។

ប៉ុន្តែ ជំនាញក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនារបស់អ្នកនឹងរីកចម្រើនបាននៅពេលអ្នកអនុវត្ត សួរសំណួរ ទទួលជំនួយ និង បន្តព្យាយាមតែប៉ុណ្ណោះ ។ ប្រសិនបើអ្នកជឿថាមនុស្សទូទៅជាមនុស្សពូកែ ( ឬ អន់ ) ចំពោះកិច្ចការផ្សព្វផ្សាយសាសនា ភាសាទីបន្ទាល់ ឬ ការទាក់ទង នោះអ្នកនឹងមានការលំបាកហើយ ។

មានគ្រាមួយអ្នកផ្សព្វផ្សាយសាសនាម្នាក់បាននិយាយប្រាប់ខ្ញុំថា « ខ្ញុំបានរៀនថា វាគឺជាកិច្ចការរបស់ព្រះអម្ចាស់ មិនមែនជាកិច្ចការខ្ញុំទេ ។ ហើយវាមិនជាថ្វីទេ ប្រសិនបើខ្ញុំមានអារម្មណ៍ខ្វះសមត្ថភាពចំពោះកិច្ចការនេះ ដោយសារខ្ញុំ *គឺ* មានភាពខ្វះសមត្ថភាព ។ ខ្ញុំនឹងគ្មានសមត្ថភាពដើម្បីធ្វើនូវអ្វីដែលព្រះអាចធ្វើបានឡើយ ។ មានកិច្ចការជាច្រើនដែលខ្ញុំអាចធ្វើដើម្បីកែលម្អ ប៉ុន្តែខ្ញុំពុំចាំបាច់ត្រូវស្វែងរកវាទាំងអស់ដោយខ្លួនឯងឡើយ ។ ខ្ញុំអាចទុកចិត្តលើទ្រង់បាន » ។

រូបគំនូរដោយ ហ៊ីឌើរ ឡៃនឌីស



ចូរព្យាយាមធ្វើកិច្ចការថ្មីៗ និង លំបាកៗ ។ នោះអ្នកនឹងគ្មានអារម្មណ៍ថាខ្វះសមត្ថភាពទៀតឡើយ ។ ឧទាហរណ៍ ៖

- ចូរព្យាយាមធ្វើកិច្ចការដែលលើសពីអ្វីដែលអ្នកអាចធ្វើបាន ដូចជាការងារថ្មី កម្មវិធីសិក្សាបន្ថែម ឬ ចូលរៀនថ្នាក់ថ្មីផ្សេងទៀត ។ សួរសំណួរ ទទួលជំនួយ វិភាគកំហុសឆ្គង ហើយបន្តព្យាយាម ។ ចូរយកកិច្ចការដែលអ្នកត្រូវតែអនុវត្ត ហើយធ្វើកិច្ចការនោះ ដូច្នេះអ្នករៀនទុកចិត្តខ្លួនឯងថាអ្នក *និង* ពង្រីកនូវកិច្ចការនោះ ។
- ចូរឆ្លើយតបទៅនឹងគំនិតដែលផុសចេញមកនៅក្នុងគំនិតអ្នក ដែលវាប្រាប់អ្នកថា មនុស្សទូទៅកើតមកមានទេពកោសល្យប្រាជ្ញា ឬ ជំនាញសង្គមស្រាប់ ឬ ថាពួកគេគ្មានអ្វីៗទាំងនេះឡើយ ។ អត្តពលករ តន្ត្រីករ អ្នកប្រាជ្ញ ដ៏អស្ចារ្យបំផុតនៅលើពិភពលោកនេះ—និង អ្នកផ្សព្វផ្សាយសាសនា—ធ្លាប់មានបទពិសោធន៍បរាជ័យជាច្រើនលើកច្រើនគ្រា ហើយបានហាត់សមអស់ពេលជាច្រើនម៉ោងនៅក្នុងជីវិតពួកគេដើម្បីទទួលបានជោគជ័យ ។






### ជំនាញនៃការប្រឈមមុខនឹងការបដិសេធ ( និង ការពិតជាក់ស្តែង ) ដែលអាចសម្រេចបាន

ការបដិសេធ និង ការខកចិត្តគឺជាបទពិសោធន៍ដែលមានរាល់ថ្ងៃនៅក្នុងបេសកកម្ម ។ ចូរអនុវត្តទទួល និង ប្រឈមមុខនឹងការបដិសេធនានា ដូច្នោះអ្នកត្រៀមខ្លួនបានកាន់តែប្រសើរចំពោះអារម្មណ៍បែបនោះ ។

- ដាក់ពាក្យធ្វើការងារ ធ្វើការសម្ភាសការងារ ហើយធ្វើការក្រៅម៉ោង ឬ ពេញម៉ោង ។
- ចូរសាកល្បងធ្វើការ ឬ លេងជាក្រុម ។
- ចូរសុំគេដើម្បីណាត់ដើរលេងជាគូ ឬ ទៅសកម្មភាពនានា ។
- ប្រសិនបើកិច្ចការនានាមិនរលូនទៅមុខទេ ចូរកត់ចំណាំពីគំនិត និង ទង្វើនានាដែលជួយអ្នកដោះស្រាយបញ្ហាទាំងនោះ និង មានអារម្មណ៍ប្រសើរឡើង ។
- រៀនពីឧបសគ្គ និងព្យាយាមម្តងទៀត ។




### ជំនាញគ្រប់គ្រងការជំរុញទឹកចិត្ត

យើងទាំងអស់គ្នាត្រូវស្វែងយល់ពីរបៀបលើកទឹកចិត្តខ្លួនឯង នៅពេលយើងធុញទ្រាន់ ហើយរម្ងាប់អារម្មណ៍ខ្លួននៅពេលយើងមានអារម្មណ៍តានតឹងចិត្តជាខ្លាំងនោះ ។

- ប្រសិនបើ មានស្ថានភាពធុញទ្រាន់ ឬ គ្មានភាពរីកចម្រើន ចូរព្យាយាមស្វែងរកអ្វីដែលធ្វើឲ្យកើតមានអារម្មណ៍នោះ និង របៀបដោះស្រាយវា ធ្វើវាទៅជាល្បែងកម្សាន្ត ដោយមិនចាំបាច់ព្រួយបារម្ភយ៉ាងហួសហេតុ ឬ ដោយស្វែងយល់ពីអ្វីដែលអ្នកអាចរៀនឡើយ ។
- ចូរកត់ចំណាំនៅពេលអ្នកមានភាពតានតឹងចិត្តខ្លាំង ហើយរៀនពីកិច្ចការនានាដែលអ្នកនៅតែអាចធ្វើនៅក្នុងបេសកកម្ម ដើម្បីរម្ងាប់អារម្មណ៍ ( ជជែកវែកញែកជាមួយនរណាម្នាក់ សម្រាក សរសេរសំបុត្រ ច្រៀង ដើរកម្សាន្ត ) ។ ចូរពិចារណាពីស្ថានភាពនោះ វិភាគបែងចែកបញ្ហាជាផ្នែកតូចៗ រកជំនួយពីមនុស្សដទៃ បោះជំហានទៅមុខបន្តិចម្តងៗ អធិស្ឋាន និង និយាយលួងលោមពីអារម្មណ៍អវិជ្ជាមានអំពីខ្លួនឯងនោះ ។

### ជំនាញគ្រប់គ្រងភាពខុសប្លែកគ្នា

ដៃគូ ថ្នាក់ដឹកនាំ សមាជិក និង សាសនាគន់ការី នឹងក្លាយជាមនុស្សអស្ចារ្យ ប៉ុន្តែក៏នឹងតម្រូវឲ្យអ្នកមានការអត់ធ្មត់ជាច្រើនផងដែរ ។

ចូរអនុវត្តជាមួយបងប្អូនបង្កើត និង មិត្តភក្តិដើម្បី ៖

- រៀនថ្លែងអំណរគុណដល់មនុស្សដទៃ ដោយសួររកមូលហេតុដែលពួកគេធ្វើនូវកិច្ចការរបស់ខ្លួន ។
- ទទួលយកការទទួលខុសត្រូវ និង ការសុំអភ័យទោសដោយស្មោះសរ នៅពេលអ្នកធ្វើឲ្យនរណាម្នាក់មានការឈឺចាប់ បើទោះបីជាអ្នកគ្មានចេតនាធ្វើទុក្ខទោសដល់គេក៏ដោយ ។
- ចូររកមើលហេតុផលនៃចិត្តមេត្តាចំពោះអាកប្បកិរិយារបស់មនុស្សម្នាក់ទៀត ។ សូមកុំចងគំនុំនឹងនរណាម្នាក់ឡើយ ។
- ចូរលើកយកបញ្ហានោះមកជជែកវែកញែក ហើយសុំជំនួយដោះស្រាយ ជាជាងត្អូញត្អែរ ឬ រញ៉ុំរញ៉ូវក្នុងចិត្ត ។
- នៅពេលមានជម្លោះកើតឡើង ចូរប្រើសំឡេងស្រទន់ ហើយបង្ហាញការគោរពរបស់យើងចំពោះអារម្មណ៍របស់អ្នកដទៃ ។
- ធ្វើជាមិត្តជាមួយនឹងអ្នកដែលមានចរិតលក្ខណៈខុសពីអ្នក ។ ចូរមានភាពវិជ្ជមាន ហើយចង់ដឹងចង់យល់ពីចំណូលចិត្តរបស់ពួកគេ ។







## ជំនាញនៃការសន្ទនា

ទោះបីជាអ្នកមិនសូវចេះមាត់ក ( អឹមអៀន ) ឬ រាក់ទាក់ ( រួសរាយ ) ក្តី នោះអ្នកអាចរៀនជំនាញទំនាក់ទំនងល្អ ដែលអ្នកនឹងត្រូវការនៅក្នុងបេសកកម្ម និង ពេញមួយជីវិតអ្នក ។

ប្រសិនបើអ្នកជាមនុស្សអៀនខ្មាសខ្លាំង ៖

- ដាក់គោលដៅជជែកជាមួយមនុស្សថ្មីៗ ( ជាពិសេសមនុស្សដែលពុំធ្លាប់ស្គាល់ ) រយៈពេលប្រាំនាទីរៀងរាល់សប្តាហ៍ ។
- ញញឹម ចូរមានចិត្តចង់ដឹងចង់យល់ពីមនុស្សទូទៅ ហើយរៀនសួរសំណួរល្អៗដែលជួយឲ្យមនុស្សផ្សេងទៀតចង់និយាយ ។
- ស្វែងរកវិធីនានាចាប់ផ្តើមការសន្ទនាមួយ ហើយបញ្ចប់ការសន្ទនាដោយសមរម្យ ។
- កត់សម្គាល់ពីពេលដែលមនុស្សដទៃកំពុងព្យាយាមចាប់ផ្តើមការសន្ទនា ដូច្នេះអ្នកអាចបើកការសន្ទនា ហើយឆ្លើយតប ។

ប្រសិនបើអ្នកជាមនុស្សរួសរាយរាក់ទាក់ ៖

- ចូរធ្វើឲ្យមនុស្សដទៃទៀតនិយាយដោយសេរី តាមរយៈការសួរសំណួរ ។
- អនុវត្តធ្វើជាអ្នកពូកែស្តាប់ ។
- រកមើលសញ្ញាដែលអ្នកស្តាប់របស់អ្នកធុញទ្រាន់ ។ ផ្តល់ឱកាសដល់មនុស្សដទៃទៀតនិយាយ ។





## ជំនាញដែលធ្វើឲ្យរូបរាងកាយមានសុខភាពល្អ

ក្នុងនាមជាប្រធានបេសកកម្ម ស្វាមីរបស់ខ្ញុំបាននិយាយជាមួយអ្នកផ្សាយសាសនាម្នាក់ដែលក្រៀមក្រំចិត្ត និង មានការលំបាក ។ ស្វាមីរបស់ខ្ញុំបានមានអារម្មណ៍បំផុសគំនិតឲ្យសួរគាត់ថា « អែលឌើរ តើអ្នកបរិភោគអ្វីសម្រាប់ជាអាហារពេលព្រឹក ?

ការ៉េម ។

តើអ្នកបរិភោគអ្វីសម្រាប់ជាអាហារពេលថ្ងៃត្រង់ ?

ដំឡូងចៀន ។

តើអ្នកបរិភោគអ្វីសម្រាប់ជាអាហារពេលល្ងាច ?

ដំឡូងចៀន និង ការ៉េម ។

តើអ្នកបរិភោគតែដំឡូងចៀន និង ការ៉េមនេះអស់រយៈពេលប៉ុន្មានហើយ ?

ប្រហែលជាមួយខែ ។

នេះជាការចាត់តាំងមួយសម្រាប់អ្នក ៖ ទៅផ្ទះ ហើយបរិភោគអាហារដែលមានពណ៌បៃតង—ប៉ុន្តែមិនមែនជាការ៉េមរសជាតិម៉ុងតុលឡើយ ។

របបអាហារ និង ការហាត់ប្រាណពិតជាជះឥទ្ធិពលលើអារម្មណ៍របស់យើងអំពីជីវិតខ្លួន ។ ចូរចាប់ផ្តើមឥឡូវនេះដើម្បី ៖

- រៀនអំពីអាហារដែលមានជីវជាតិល្អ ។ បរិភោគអាហារដែលធ្វើឲ្យមានសុខភាពល្អ ។ ប្រសិនបើអ្នកហូបរើសបន្តិច ចូរសាកល្បងអាហារថ្មីៗ ។
- ហាត់ប្រាណ ។ ការហាត់ប្រាណទៀងទាត់ជួយឲ្យមនុស្សគ្រប់គ្នាគ្រប់គ្រងលើភាពតានតឹងផ្លូវចិត្ត និង ការបាក់ទឹកចិត្តបានកាន់តែប្រសើរ ។ ចូរចាប់ផ្តើមការធ្វើលំហាត់ប្រាណបន្តិចម្តងៗ ហើយបង្កើនវាឡើងដោយសន្សឹមៗ ដូចជាការដើរពេលយប់ ( ប្រហែលជាដើរជាមួយមិត្តភក្តិ ឬ ហាត់ដោយស្តាប់តន្ត្រី ) រត់នៅ មួយកន្លែងពេលកំពុងមើលការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ ឬ ការអង្គុយងើបចុះឡើង និង អារ៉ង់ជាដើម ។
- រៀនថែទាំរបស់ទ្រព្យ សម្លៀកបំពាក់ ប្រាក់កាក់ និង ពេលវេលារបស់អ្នកឲ្យបានល្អ ។
- ចូរគ្រប់គ្រងការដេកពួន ។ ប្រសិនបើអ្នកមានការពិបាកដេក ឬ ភ្ញាក់ពីដេក ចូរសុំឲ្យគេផ្តល់យោបល់ដល់អ្នក ។ ចូរចូលដេក និង ភ្ញាក់ពីដេក ឲ្យទៀងម៉ោងដែលអ្នកអាចប្រើវាបានក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ។





## ជំនាញនៃការមានភាពវិជ្ជមាន

- បង្កើនភាពសប្បាយរីករាយ ។ សើចចំអន់ឲ្យខ្លួនឯង ប៉ុន្តែកុំសើចចំអន់ដាក់គេឡើយ ។ កុំហ្មត់ចត់ពេកដែលធ្វើឲ្យអ្នកមានការតានតឹងចិត្ត ។
- សួរអ្នកផ្សព្វផ្សាយសាសនាពីមុនៗឲ្យប្រាប់អ្នកនូវអ្វីដែលពិបាកសម្រាប់ពួកគេ និង របៀបដើម្បីដោះស្រាយវា ។ ចូរស្វែងរកយោបល់នានាដែលអ្នកអាចប្រើបាន ។
- ចូរសរសេរខគម្ពីរ និង ទំនុកតម្កើងដែលលើកស្ទួយអ្នក ហើយធ្វើឲ្យអ្នកមានជំនឿ ។
- និយាយប្រាប់ទៅកាន់គំនិតអវិជ្ជមានដែលមាននៅក្នុងចិត្តអ្នក ជាមួយនឹងអ្វីដែលវិជ្ជមាន ។ ប្រសិនបើគំនិតនោះ ជាការចំអកបញ្ឈឺចិត្ត រិះគន់ចំអក អាម៉ាស់ កំហឹងឃោរឃៅ ឬ ធ្វើឲ្យអ្នកអស់សង្ឃឹម ឬ គ្មានប្រយោជន៍ វាមិនមែនមកពីព្រះអម្ចាស់ឡើយ ។ ព្រះសូរសៀងរបស់ទ្រង់នឹងធ្វើឲ្យមានសង្ឃឹម ជាការលើកទឹកចិត្ត និង មានក្ដីអាណិតអាសូរជានិច្ច ជាពិសេសនៅពេលអ្នកកំពុងខិតខំព្យាយាម ។



## ជំនាញដែលធ្វើឲ្យវិញ្ញាណល្អ



- អធិស្ឋានដោយស្មោះ ។ យាងព្រះវរបិតាសួគ៌មកគង់ក្បែរអ្នក ហើយទូលទៅកាន់ទ្រង់ដោយបើកចំហអំពីបញ្ហា បំណងប្រាថ្នា និង អំណរគុណរបស់អ្នក ។ ចូរសាកល្បងអធិស្ឋានឲ្យឮៗ អធិស្ឋានដោយមានក្រដាស និង ខ្មៅដៃ កត់នូវការបំផុសគំនិតនានា ឬ គ្រាន់តែអធិស្ឋានដើម្បីថ្លែងអំណរគុណ ។
- ចូរសិក្សាព្រះគម្ពីរ ។ ចូរស្វែងរក និង រំពឹងរង់ចាំចម្លើយចំពោះកង្វល់របស់អ្នក ។
- ចូរធ្វើជាអ្នកផ្សព្វផ្សាយសាសនាក្នុងពេលឥឡូវនេះ ! ទៅ ហើយបម្រើជាមួយអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង សូមជជែកគ្នាអំពីប្រធានបទនៃដំណឹងល្អរៀងរាល់ថ្ងៃជាមួយមិត្តភក្ដិរបស់អ្នក ។ ជជែកជាមួយមិត្តភក្ដិរបស់អ្នក ចាត់ទុកពួកគេដូចជាសមាជិក ហើយថ្លែងទីបន្ទាល់យ៉ាងស្មោះត្រង់នៅព្រះវិហារ ។ អ្នកនឹងទទួលបាននូវក្ដីរំភើបកាន់តែខ្លាំង អំពីកិច្ចការផ្សព្វផ្សាយសាសនា នៅពេលអ្នកបានធ្វើនូវកិច្ចការនេះ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

## មនុស្សពីរបែបដែលជួបនូវការលំបាកញឹកញាប់

មនុស្សដែលជួបការលំបាកខាងផ្លូវចិត្តនៅក្នុងបេសកកម្មញឹកញាប់រួមមាន ៖

- **អស់អ្នកដែលពុំខិតខំរៀននៅសាលា ។** អស់អ្នកដែលឈ្លាសវៃ ឬ មានទេពកោសល្យគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាដោយពុំបានខិតខំជាខ្លាំង អាចឃើញថាអំណោយទានរបស់ពួកគេគឺស័ក្ដិសិទ្ធ ។ នៅពេលភាពស័ក្ដិសិទ្ធនោះអស់ឥទ្ធិពល ( ហើយវានឹងអស់ឥទ្ធិពលនៅពេលណាមួយ ) ពួកគេពុំដឹងថាត្រូវធ្វើអ្វីឡើយ ក្រៅពី ការព្យាយាមលាក់បាំងកំហុសខ្លួន ។ សរុបមក គ្រប់គ្នាត្រូវរៀនបន្ទាបខ្លួន ខិតខំធ្វើការ អត់ធ្មត់ ទទួលជំនួយ ហើយយកឈ្នះលើឧបសគ្គ និង បរាជ័យនានា ដើម្បីបន្តរីកចម្រើន និង កាន់តែប្រសើរឡើង ។
- **អស់អ្នកដែលគ្មានបទពិសោធន៍ជោគជ័យច្រើន ។** មនុស្សមួយចំនួនមើលឃើញការលំបាក ថាជាការបញ្ជាក់ថាពួកគេចោលម្សៀត ឬ គ្មានទេពកោសល្យ ។ ប៉ុន្តែខួរក្បាលរបស់មនុស្សម្នាក់នឹងកាន់តែឈ្លាសវៃ និង មានសមត្ថភាពជាងមុន នៅពេលពួកគេផ្ដោតចិត្តទុកដាក់ វិភាគអ្វីដែលពុំដំណើរការត្រឹមត្រូវនោះ ព្យាយាមរកដំណោះស្រាយដោយស្វាហាប់ ទទួលជំនួយ ខិតខំធ្វើកិច្ចការ និង អនុវត្ត ។

ប្រសិនបើអ្នកនៅក្នុងក្រុមណាមួយក៏ដោយ សូមរំឭកខ្លួនអ្នកជានិច្ចថា គ្មាននរណាម្នាក់កើតមកក្លាយជាអ្នកផ្សព្វផ្សាយសាសនាអស្ចារ្យនោះទេ ។ ជំនាញផ្សព្វផ្សាយសាសនាកើនឡើងដោយការអត់ធ្មត់ ខិតខំធ្វើការយ៉ាងខ្លាំង ទទួលយកការប្រថុយប្រថាន យកឈ្នះលើឧបសគ្គ សាកល្បងម្ដងទៀតបន្ទាប់ពីបានធ្វើកំហុសហើយ រៀនពីមនុស្សដទៃ ហើយពឹងផ្អែកទាំងស្រុងលើព្រះអម្ចាស់ ។ ទ្រង់ស្រឡាញ់អ្នក ហើយនឹងជួយអ្នកបំពេញបេសកកម្មផ្ទាល់ខ្លួនអ្នក ព្រមទាំងបេសកកម្មពេញម៉ោងផងដែរ ។

## រៀបចំខ្លួនដើម្បីរស់នៅជាអ្នកផ្សព្វផ្សាយសាសនា

*សម្រាប់គំនិតបន្ថែមទៀតអំពីរបៀប ដើម្បីរៀបចំខ្លួនទៅបេសកកម្មក្នុងពេលឥឡូវនេះ ចូរយកកូនសៀវភៅធនធាន* ការសម្របខ្លួនទៅនឹងជីវិតជាអ្នកផ្សព្វផ្សាយសាសនា *នៅក្នុងគេហទំព័រ store.lds.org ឬ យកវាពីប៊ីស្សពរបស់អ្នក ។*









# ទីកន្លែងរបស់យើង

*តើអ្នកធ្លាប់ជកពិសោធន៍នូវអំណាចនៃព្រះគម្ពីរមរមននៅក្នុងជីវិតរបស់អ្នកដែរឬទេ ? សូមយកវាមកអនុវត្តដូចជាពួកអ្នកផ្សព្វផ្សាយសាសនាទាំងនេះបានធ្វើ !*



## ខ្ញុំបានរកឃើញបំណែកដែលខ្វះនោះហើយ

កាលខ្ញុំរៀននៅវិទ្យាល័យ ខ្ញុំមានការអាក់អន់ចិត្តអំពីគោលលទ្ធិមួយចំនួនរបស់សាសនាចក្រ ។ ទីបំផុត វាបានធ្វើឲ្យខ្ញុំក្លាយជាមិនសូវសកម្ម ។ ខ្ញុំបានចូលរួមសកម្មភាពមួយចំនួននៅឯព្រះវិហារផ្សេងទៀត ប៉ុន្តែខ្ញុំគ្មានក្តីអំណរពេញលេញឡើយ ។ វាហាក់បីដូចជាខ្វះអ្វីមួយ ។

ខ្ញុំបានចំណាយពេលដើម្បីស្វែងរកអ្វីដែលខ្វះនោះ ប៉ុន្តែថ្ងៃមួយបន្ទាប់ពីខ្ញុំបានអធិស្ឋាន ខ្ញុំបានបើកភ្នែក ហើយឃើញព្រះគម្ពីរមរមននៅលើតុរបស់ខ្ញុំ ។ ខ្ញុំហៀបនឹងចូលដេកទៅហើយ នៅពេលគំនិតមួយបានផុសក្នុងចិត្តខ្ញុំ ៖ « ខ្ញុំកើតមកក្នុងត្រកូលជាពួកមរមន ។ ហេតុអ្វីខ្ញុំមិនបានអានព្រះគម្ពីរមរមនឲ្យចប់ដូច្នេះ ? » ដូច្នេះនៅថ្ងៃនោះខ្ញុំបានសម្រេចចិត្តថា ខ្ញុំនឹងអានព្រះគម្ពីរមរមនឲ្យចប់ ។

បន្ទាប់ពីការស្រាវជ្រាវជាច្រើន នៅទីបំផុតខ្ញុំបានរកឃើញបំណែកដែលខ្ញុំខ្វះនៃការមានសុភមង្គលនោះ ។ ■

អែលឌើរ ជេមី ប្រូមីស បេសកកម្ម ហ្វីលីពីន ឃ្វីសូន ស៊ីធី

## ពេលមនុស្សបើកព្រះគម្ពីរ

នៅក្នុងបេសកកម្មរបស់ខ្ញុំ ខ្ញុំបានឃើញមនុស្សផឹកស្រា ជក់បារី និង ប្រើប្រាស់ថ្នាំញៀនបើកព្រះគម្ពីរមរមន ហើយបានកែប្រែទម្លាប់ និងត្រឡប់មករកក្រុមគ្រួសារ និង សាសនាចក្ររបស់ខ្លួនវិញ ។ ខ្ញុំបានឃើញកូនប្រុសខ្ជះខ្ជាយត្រឡប់មកផ្ទះវិញ ហើយបម្រើបេសកកម្មបន្ទាប់ពីពួកគេបានបើកព្រះគម្ពីរនេះ ។ ខ្ញុំបានឃើញក្រុមគ្រួសារដែលបែកបាក់គ្នា បានអានព្រះគម្ពីរមរមនជាមួយគ្នា ហើយក្រោយមកបានផ្សារភ្ជាប់ នៅក្នុងព្រះវិហារបរិសុទ្ធ ។ ខ្ញុំបានឃើញមនុស្សដែលតែលតោលទាំងស្រុង ហើយពុំដឹងថាត្រូវធ្វើអ្វី បានបើកព្រះគម្ពីរនេះ ហើយអ្វីៗគ្រប់យ៉ាងបានចាប់ផ្តើមដំណើរការល្អប្រសើរឡើងវិញ ។

នៅពេលណាដែលខ្ញុំបើកព្រះគម្ពីរមរមន ហើយប្រើខគម្ពីរមួយជួយនរណាម្នាក់ នោះអព្ភូតហេតុកើតឡើង ។ ព្រះចេស្តានៃព្រះបង្កប់នៅក្នុងទំព័រនៃព្រះគម្ពីរនោះ ទន្ទឹងរង់ចាំនូវការផ្លាស់ប្តូរជីវិត រង់ចាំបើកសម្តែងនូវអព្ភូតហេតុ ។ ខ្ញុំអាចសន្យានឹងអ្នកថា អព្ភូតហេតុកើតឡើងគ្រប់ពេលវេលាដែលអ្នកបើកព្រះគម្ពីរមរមន ។ អព្ភូតហេតុទាំងនោះនឹងមិនកើតឡើងទៅតាមបំណងចិត្តរបស់យើង ឬ កើតឡើងតាមអ្វីដែលយើងចង់ឲ្យវាកើតឡើងនោះឡើយ ប៉ុន្តែវានឹងកើតឡើង ។ ■

អែលឌើរ បេនយ៉ាមីន បាវ៉ាឌី បេសកកម្ម ហ្វីលីពីន បាកូឡូត

រូបគំនូរដោយ ប្រាយអិន ខល



រចនាលម្អរូបថតដោយ ដេវីត ស្តូកឃើរ

# មនុស្សម្នាក់ដែលស្រេកអំពាវនាវ

*គាត់មើលទៅដូចជាមនុស្សម្នាក់ដែលមិនគួរឲ្យចង់និយាយជាមួយឡើយ ។ ថ្វីបើខ្ញុំមានអារម្មណ៍មួយភ័យខ្លាចក្ដី ប៉ុន្តែអារម្មណ៍មួយទៀតគឺពិតជាចង់និយាយជាមួយគាត់ណាស់ ។*

**ដោយ ស្ទេផាន ឌូឌែល**

ខ្ញុំមានឱកាសបម្រើជាអ្នកផ្សព្វផ្សាយសាសនានៅក្នុងទីក្រុង កាតានៀ ប្រទេសអ៊ីតាលី ។ មានគ្រាមួយនោះក្នុងបេសកកម្ម យើងមានការលំបាកក្នុងការផ្សព្វផ្សាយណាស់ ។ យើងបរាជ័យពេញមួយសប្ដាហ៍ ហើយរាល់ថ្ងៃវាគឺជាការសាកល្បងដល់យើងថាប្រសិនបើយើងនឹងបន្តមានឥរិយាបថវិជ្ជមាន បន្តញញឹម ហើយបន្តព្យាយាមខំធ្វើការដែរឬអត់ ។

នាល្ងាចមួយយើងបានប្ដេជ្ញាចិត្តដើម្បីផ្លាស់ប្ដូរលទ្ធផលនៃកិច្ចការរបស់យើង ។ យើងបានទៅតំបន់ជុំវិញនោះ ហើយនិយាយជាមួយមនុស្សនៅក្នុងសួនឧទ្យានក្បែរផ្ទះរបស់យើង ហើយយើងបានជួបបុរសម្នាក់អង្គុយនៅលើកៅអីវែង ឈ្ងោកមុខចុះ ហើយកំពុងជក់បារី ។ គាត់ស្លៀកពាក់ខោអាវខ្មៅពីក្បាលរហូតដល់ចុងជើង ហើយពាក់មួកដែលជាប់នឹងអាវនោះ ។ គាត់មើលទៅដូចជាមនុស្សម្នាក់ដែលមិនគួរឲ្យចង់និយាយជាមួយឡើយ ។ ខ្ញុំបានមើលគាត់ ដៃគូខ្ញុំបានមើលគាត់ យើងបានមើលគ្នាទៅវិញទៅមក ហើយបានមើលត្រឡប់ទៅគាត់វិញ ។

អែលឌើរ ហ្វាលី បានសួរខ្ញុំថា « តើយើងធ្លាប់និយាយជាមួយគាត់ពីមុនដែរឬទេ ? »

ខ្ញុំបានឆ្លើយថា « ខ្ញុំគិតថា យើងធ្លាប់បាននិយាយជាមួយគាត់ហើយ ដោយសារខ្ញុំគិតថា ខ្ញុំពិតជាស្គាល់គាត់ » ។

អែលឌើរ ហ្វាលី បាននិយាយថា « មែនហើយ ខ្ញុំក៏គិតអញ្ចឹងដែរ » ។

ដូច្នេះយើងក៏ចាប់ផ្ដើមដើរទៅរកគាត់ ។ ខ្ញុំមានអារម្មណ៍មួយភ័យខ្លាចដោយសារថា តាមធម្មតាគាត់មិនមែនជាមនុស្សម្នាក់ដែលខ្ញុំនឹងនិយាយជាមួយឡើយ ប៉ុន្តែអារម្មណ៍មួយទៀតគឺថាខ្ញុំពិតជាចង់និយាយជាមួយគាត់ណាស់ ។

យើងបានសួរគាត់ « សាយ័ន្តសួស្ដី តើអ្នកសុខសប្បាយទេ ? » ។

គាត់បានងើយមើលយើងដោយរង្វង់ភ្នែកពណ៌ខ្មៅ ហាក់ដូចជាការនិយាយថា « នរណាគេរំខានការដេកពួនរបស់ខ្ញុំ ! ? » ក្រោយមកគាត់បាននិយាយដ៏ស្រទន់ថា « សាយ័ន្តសួស្ដី » ។ យើងបានណែនាំខ្លួនយើងថាជាពួកអ្នកផ្សព្វផ្សាយសាសនា ហើយគាត់បានប្រាប់យើងភ្លាមថា គាត់ជាអ្នកបដិសេធព្រះ ហើយពុំជឿលើអ្វីទាំងអស់ ។ យើងបានសួរគាត់អំពីមូលហេតុ ដែលខ្ញុំគិតថាបានធ្វើឲ្យគាត់ភ្ញាក់ផ្អើល ។

« មែនហើយ ដោយសារ ម្ដាយ ឪពុក បងស្រី និង ក្មួយស្រីខ្ញុំស្លាប់ក្នុងរយៈពេលតែមួយខែ ហើយខ្ញុំរស់នៅក្នុងក្ដីរន្ធត់យ៉ាងខ្លាំងក្នុងជីវិតឯកោបែបនេះដោយសារតែរឿងនោះ ។ សាសនាមិនបានជួយអ្វីដល់ខ្ញុំឡើយ តែធ្វើឲ្យមានរឿងកាន់តែអាក្រក់ចំពោះខ្ញុំ » ។

យើងបានសួរគាត់ ថាតើគាត់ដឹងថាមនុស្សជាទីស្រឡាញ់របស់គាត់ទាំងនោះនៅទីណាទេ ។

គាត់និយាយថា « សពរបស់ពួកគេ ត្រូវបានបញ្ចុះក្នុងទីបញ្ចុះសពទីក្រុងកាតានៀ ពួកគេនៅទីនោះយូរហើយ » ។

យើងបានពន្យល់គាត់ពីពិភពវិញ្ញាណ និង ដំណើររស់ឡើងវិញ ។ យើងបានប្រាប់គាត់ថា សព្វថ្ងៃនេះ យើងម្នាក់ៗមានវិញ្ញាណ និង រូបកាយ ហើយថាសេចក្ដីស្លាប់គឺជាការបែកចេញបណ្ដោះអាសន្នរវាងវិញ្ញាណ និង រូបកាយ ។ យើងបានប្រាប់គាត់ថា សមាជិកគ្រួសារគាត់កំពុងរង់ចាំគាត់ រហូតដល់ពួកគេគ្រប់រូបអាចត្រូវបានរួមគ្នាជាថ្មីឡើងវិញជាមួយរូបកាយពួកគេ ហើយរស់នៅជាមួយគ្នាជារៀងរហូតអស់កល្បជានិច្ច ។

គាត់បានមើលមុខពួកយើង ដោយស្រឡាំងកាំង ហើយបាននិយាយថា « ខ្ញុំពុំដែលយល់ពីរឿងទាំងនេះទេ ។ តើអ្នកអាចនិយាយរឿងទាំងនោះម្ដងទៀតបានទេ ? »

**ជាសមាជិកនៃគ្រួសារព្រះ**

« [ មនុស្ស ] ទាំងអស់គ្នាជាកូនចៅរបស់ព្រះគឺជាបងប្អូនប្រុសស្រីរបស់អ្នក ។ ព្រះស្រឡាញ់ពួកគេ ដូចជាទ្រង់ស្រឡាញ់អ្នកផងដែរ ។ មនុស្សជាច្រើននៃមនុស្សទាំងនេះកំពុងតែស្រាវជ្រាវរកពីគោលបំណងក្នុងជីវិត ។ ពួកគេបារម្ភចំពោះគ្រួសារពួកគេ ។ ពួកគេត្រូវការញាណនៃកម្មសិទ្ធិ ដែលមកពីចំណេះដឹងមួយដែលថាពួកគេជាកូនរបស់ព្រះ ជាសមាជិកនៃគ្រួសារដ៏អស់កល្បជានិច្ចរបស់ទ្រង់ » ។

*ប្រកាសដំណឹងល្អរបស់យើង ៖ មគ្គុទេសន៍ចំពោះការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* ( ឆ្នាំ ២០០៤ ) ទំព័រ ១ ។

ដូច្នេះយើងបាននិយាយរឿងគ្រប់យ៉ាងម្តងទៀត ។ ក្រោយមកគាត់បានញាក់ចិញ្ចើមដោយងឿងឆ្ងល់ហើយនិយាយថា « ឈប់សិន តើខ្ញុំមានវិញ្ញាណ និងរូបកាយឬ ? ហើយគ្រួសាររបស់ខ្ញុំកំពុងតែរង់ចាំខ្ញុំ ហើយកំពុងរៀនឥឡូវនេះឬ ? »

យើងអានខគម្ពីរមួយចំនួនចេញពី អាលម៉ា ៤០ ឲ្យគាត់ស្តាប់ ព្រមទាំងជំពូកផ្សេងទៀតៗ ហើយគាត់បានមើលមុខយើង ហើយសួរថា « បើអញ្ចឹងមែន ហេតុអ្វីបានជាខ្ញុំពុំដែលធ្លាប់ឮរឿងនេះពីមុន ? »

ខ្ញុំពុំដែលគិតសោះថាខ្ញុំជួបមនុស្សដែលពិតជាបន្ទាបខ្លួននៅក្នុងជីវិតរបស់ខ្ញុំឡើយ ។ បុរសម្នាក់នេះបានរង្វេងផ្លូវ ភ័ន្តច្រឡំយ៉ាងខ្លាំង ឯកោអស់ពេលជាយូរយារណាស់មកហើយ ។ គាត់បានស្តាប់អ្វីគ្រប់យ៉ាងដែលយើងបាននិយាយ ដោយប្រាប់ពួកយើងថាគាត់បានយល់តិចតួចពីរឿងនោះ ដោយសាររឿងទាំងនោះគាត់ពុំធ្លាប់ឮពីមុនឡើយ ប៉ុន្តែគាត់ចូលចិត្តរឿងទាំងនោះ ។

យើងបានបង្រៀនគាត់អំពីរបៀបដែលយើងអាចទទួលចម្លើយតាមរយៈការអធិស្ឋាន ។ គាត់ពុំបានអធិស្ឋានអស់ជាង ៣០ ឆ្នាំហើយ ហើយពេលចុងក្រោយគេដែលគាត់បានសូត្រការអធិស្ឋាននៅក្នុងព្រះវិហារនោះគឺតាំងពីគាត់នៅក្មេងម្ល៉េះ ។ បន្ទាប់មកយើងបាននិយាយគ្នាអំពីចម្លើយមកពីព្រះវិញ្ញាណ គាត់បានសួរយើងថាតើអារម្មណ៍ពីព្រះវិញ្ញាណជាអារម្មណ៍បែបណា ។ ដោយសារអារម្មណ៍នោះវាផ្សេងៗពីគ្នាចំពោះមនុស្សម្នាក់ៗ នោះយើងទាំងពីរនាក់បានចែកចាយពីអារម្មណ៍នោះដែលពួកយើងមានរៀងៗខ្លួន ។ ខ្ញុំបានប្រាប់គាត់ថា ចំពោះខ្ញុំអារម្មណ៍នោះគឺដូចជាការឱបពីម្តាយរបស់អ្នក ក្រោយពីអ្នកមិនដែលជួបគាត់អស់កាលដ៏យូរ ។ ខ្ញុំទទួលអារម្មណ៍បំផុសគំនិតឲ្យសន្យានឹងគាត់ថា គាត់អាច ហើយនឹងមានអារម្មណ៍ដូចគ្នានេះ ជាអារម្មណ៍ដូចម្តាយគាត់ឱបគាត់ដែលម្តាយគាត់បានចាកចេញពីជីវិតគាត់អស់ពេលជាយូរមកហើយ ។ យើងបានសុំអធិស្ឋានជាមួយគាត់ ។ គាត់ពិតជាច្របូកច្របល់ ហើយបានសួរថា « អធិស្ឋានឥឡូវនេះមែនទេ ? នៅក្នុងសួនឧទ្យាននេះឬ ? »

ខ្ញុំបានប្រាប់គាត់ថា « យើងអាចអធិស្ឋាននៅគ្រប់ពេល គ្រប់ទីកន្លែងដែលយើងចង់ ។ ព្រះចង់ស្តាប់យើង ហើយជាពិសេសទ្រង់ពិតជាចង់ស្តាប់អ្នក ដោយសារទ្រង់ពុំដែលឮអ្នកអធិស្ឋានយូរមកហើយ » ។



គាត់ពុំធ្លាប់ឮការអធិស្ឋានពីមុនឡើយ ដែលពុំមែនជាការអធិស្ឋានសូត្រចាំនោះទេ ដូច្នេះគាត់មានចិត្តអន្ទះសារចង់អធិស្ឋានជាខ្លាំង ។ យើងបានឱនក្បាល ហើយដៃគូរបស់ខ្ញុំបានអធិស្ឋានសម្រាប់មិត្តភក្តិថ្មីរបស់យើង អាលហ្វីអូ ហើយបានទូលសុំពរជ័យ ជំនួយ និង ការលួងលោមចិត្តដល់គាត់ ។ គាត់បានសុំឲ្យអាលហ្វីអូទទួលចម្លើយដែលថាគ្រួសាររបស់គាត់មានសុខសុវត្ថិភាព ហើយថាពិតជាមានព្រះមែន ។ យើងបានអធិស្ឋានចប់ ហើយអាលហ្វីអូបានមើលមុខពួកយើងដោយបើកភ្នែកធំៗ ។

គាត់បាននិយាយថា « ខ្ញុំត្រូវតែប្រាប់អ្នកនូវអ្វីមួយ ។ ខ្ញុំពុំមែនជាមនុស្សម្នាក់ដែលកុហកឡើយ ជាពិសេសចំពោះរឿងបែបនេះ ។ ខ្ញុំមានអារម្មណ៍ថា ម្តាយខ្ញុំទើបតែឱបខ្ញុំយ៉ាងណែន ។ ខ្ញុំពុំធ្លាប់មានអារម្មណ៍ថានរណាម្នាក់ឱបខ្ញុំជាយូរយារណាស់មកហើយ ។ វាជាអារម្មណ៍ល្អណាស់ ។ ខ្ញុំចង់ដឹងថាតើខ្ញុំអាចមានអារម្មណ៍បែបនេះម្តងទៀតយ៉ាងដូចម្តេច ដោយសារខ្ញុំចង់មានអារម្មណ៍បែបនេះទៀត » ។

---

« **ចាប់តាំងពីការអធិស្ឋាននោះមក ខ្ញុំបានដើរដោយងើយមុខឡើង ហើយខ្ញុំអាចមើលអ្វីៗគ្រប់យ៉ាង ។ ពិភពលោកនេះស្រស់ត្រកាលណាស់ ។** »

---

ថ្ងៃស្អែកឡើងយើងជួបគ្នាម្តងទៀត ។ អាលហ្វីអូ បានអង្គុយនៅក្បែរយើងនៅលើកៅអីដដែលនោះ ហើយបាននិយាយថា « អែលឌើរ ពេញមួយជីវិតហើយដែលខ្ញុំបានដើរដោយពាក់មួកជាប់អាវនេះ ហើយឈ្ងោកមុខសម្លឹងមើលតែដីទេ ។ ខ្ញុំមិនធ្លាប់ដើរងើយមុខទាល់តែសោះ ។ ចាប់តាំងពីការអធិស្ឋាននោះមក ខ្ញុំបានដើរដោយងើយមុខឡើង ហើយខ្ញុំអាចមើលអ្វីៗគ្រប់យ៉ាង ។ ពិភពលោកនេះស្រស់ត្រកាលណាស់ » ។

វាមិនមែនជារឿងភ្ញាក់ផ្អើលឡើយ យើងបានបន្តជួយអាលហ្វីអូ ឲ្យទទួលអារម្មណ៍ពីព្រះវិញ្ញាណ ទទួលពន្លឺបន្ថែម ព្រមទាំងមានជីវិតកាន់តែប្រសើរឡើង ។ បុរសម្នាក់មើលទៅគួរឲ្យខ្លាច អង្គុយលើកៅអី ដែលទំនងថាគាត់ស្អប់យើង គឺពិតជាមនុស្សម្នាក់ដែលស្រែកអំពាវនាវ សុំនូវសេចក្តីស្រឡាញ់ពីព្រះវរបិតាសួគ៌ម្តងទៀត ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ មិសសួរី ស.រ.អា. ។*

ចម្លើយមកពីថ្នាក់ដឹកនាំសាសនាចក្រ



**អែលឌើរ ដេវីឌ អេ បែដណា**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*



# របៀប ជួយអ្នកផ្សព្វផ្សាយសាសនា

យើងអធិស្ឋានយ៉ាងត្រឹមត្រូវសម្រាប់សុវត្ថិភាព និងភាពជោគជ័យរបស់អ្នកផ្សព្វផ្សាយសាសនានៅទូទាំងពិភពលោក ។ ហើយរឿងធម្មតានៅក្នុងការអធិស្ឋានរបស់យើង គឺជាសំណូមពរឲ្យអ្នកផ្សព្វផ្សាយសាសនាត្រូវបានដឹកនាំទៅរកមនុស្ស និងក្រុមគ្រួសារដែល ត្រូវបានរៀបចំឲ្យទទួលសារលិខិតនៃការស្ដាឡើងវិញ ។ ប៉ុន្តែ នៅទីបំផុត វាគឺជាទំនួលខុសត្រូវរបស់ខ្ញុំ និងទំនួលខុសត្រូវរបស់អ្នកដើម្បីស្វែងរកមនុស្សសម្រាប់ឲ្យអ្នកផ្សព្វផ្សាយសាសនាបង្រៀន ។ ពួកអ្នកផ្សព្វផ្សាយសាសនា គឺជាគ្រូបង្រៀនពេញម៉ោង អ្នក និងខ្ញុំគឺជាអ្នកស្វែងរកពេញម៉ោង ។ ហើយអ្នក និងខ្ញុំក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាពេញមួយជីវិត ពុំគួរធ្វើការអធិស្ឋានសុំពួកឲ្យអ្នកផ្សព្វផ្សាយសាសនាធ្វើកិច្ចការឲ្យយើងនោះទេ !

ប្រសិនបើអ្នក និងខ្ញុំអធិស្ឋានដោយអស់ពីចិត្ត ហើយសុំដោយសេចក្ដីជំនឿ ដូចជា យ៉ូសែប ស្ម៊ីធ—បើយើងអធិស្ឋានដោយមានការរំពឹងទុកថានឹងធ្វើ មិនត្រឹមតែនិយាយ—នោះកិច្ចការប្រកាសដំណឹងល្អនឹងដំណើរការទៅមុខ គួរឲ្យកត់សម្គាល់ ។ ការអធិស្ឋានដោយសេចក្ដីជំនឿ អាចរួមបញ្ចូលចំណុចសំខាន់មួយចំនួនដូចខាងក្រោម ៖

- ថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌ សម្រាប់គោលលទ្ធិ និងពិធីបរិសុទ្ធទាំងឡាយ នៃការស្ដារដំណឹងល្អនៃព្រះយេស៊ូវឡើងវិញ ដែលនឹងនាំមកនូវសេចក្ដីសង្ឃឹម និងសុភមង្គលនៅក្នុងជីវិតរបស់ពួកយើង ។
- ចូរសុំភាពក្លាហាន និងភាពមោះមុត ដើម្បីបើកមាត់របស់យើង និងចែកចាយដំណឹងល្អជាមួយនឹងក្រុមគ្រួសារ និងមិត្តភក្ដិរបស់យើង ។
- សូមទទូចអង្វរដល់ព្រះវរបិតាសួគ៌ឲ្យជួយយើងសម្គាល់ឃើញបុគ្គល និងក្រុមគ្រួសារដែលនឹងទទួលយកការអញ្ជើញរបស់យើង ដើម្បីរៀនជាមួយអ្នកផ្សព្វផ្សាយសាសនានៅក្នុងផ្ទះរបស់យើង ។
- សូមប្ដេជ្ញាធ្វើផ្នែករបស់យើង ក្នុងថ្ងៃនេះ និងសប្ដាហ៍នេះ ហើយសូមជំនួយដើម្បីយកឈ្នះភាពអន្ទះសា ការភ័យខ្លាច និងការស្ទាក់ស្ទើរ ។
- សូមស្វែងរកអំណោយទាននៃការវិនិច្ឆ័យ—ឲ្យភ្នែកមើលឃើញ និងត្រចៀកស្ដាប់ឮនៅពេលដែលមានឱកាសផ្សព្វផ្សាយសាសនា ។
- អធិស្ឋានយ៉ាងក្លៀវក្លាសុំកម្លាំង ដើម្បីធ្វើអ្វីដែលយើងគួរធ្វើ ។

អំណរគុណនឹងត្រូវបានធ្វើឡើង ហើយពរជ័យផ្សេងទៀតអាចត្រូវបានសុំ នៅក្នុងការអធិស្ឋានបែបនេះ ដែលនឹងត្រូវបានបញ្ចប់ទៅក្នុងព្រះនាមនៃព្រះអង្គសង្គ្រោះ ។ ហើយបន្ទាប់មកកិច្ចការដែលបានតែងតាំងនៃការអធិស្ឋាននោះនឹងបន្ត ហើយចម្រើនឡើង ។

គំរូដូចគ្នានៃការប្រាស្រ័យទាក់ទងបរិសុទ្ធ និងកិច្ចការដែលបានតែងតាំង អាចត្រូវបានអនុវត្តនៅក្នុងការអធិស្ឋានរបស់យើងសម្រាប់អ្នកក្រីក្រ និង អ្នកកំសត់ទុគត៌ អ្នកឈឺ និងអ្នកដែលរងទុក្ខវេទនាសម្រាប់សមាជិកគ្រួសារ និង មិត្តភក្ដិដែលកំពុងមានវិបត្តិ និង សម្រាប់អ្នកទាំងឡាយណាដែលពុំបានចូលរួមក្នុងការប្រជុំសាសនាចក្រ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ការអធិស្ឋានកាន់តែមានអត្ថន័យ នៅពេលដែលយើងសុំដោយចិត្តជឿ ហើយធ្វើតាម ។ ខ្ញុំសូមអញ្ជើញយើងទាំងអស់គ្នាឲ្យអធិស្ឋានដោយសេចក្ដីជំនឿ អំពីបទបញ្ញត្តិមកពីព្រះមកកាន់យើងទាំងអស់គ្នាថាយើងគប្បីចែកចាយដំណឹងល្អ ។ នៅពេលដែលយើងធ្វើដូច្នេះ ខ្ញុំសូមសន្យាថាទ្វារទាំងឡាយនឹងបើកឡើង ហើយយើងនឹងត្រូវបានប្រទានពរដើម្បីយល់ និង ធ្វើតាមឱកាសនានាដែលនឹងត្រូវបានផ្ដល់ឲ្យ ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅក្នុងសន្និសីទទូទៅ ខែមេសា ឆ្នាំ ២០០៨ ។*

## « ឪពុកម្ដាយរបស់ខ្ញុំប្រើពាក្យជេរ ស្ដាប់ចម្រៀងឮខ្លាំងៗ និង មើលកម្មវិធីទូរទស្សន៍ដែលមិនសមរម្យ ។ តើខ្ញុំអាចធ្វើអ្វីដើម្បីមានអារម្មណ៍ពីព្រះវិញ្ញាណនៅផ្ទះ ជាពិសេសនៅថ្ងៃអាទិត្យ ? »

ពេលអ្នកជ្រមុជទឹក អ្នកបានទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ នេះមានន័យថា មិនថានៅក្នុងកាលៈទេសៈបែបណានោះទេ អ្នកអាចមានភាពជាដៃគូនៃព្រះវិញ្ញាណប្រសិនបើខ្លួនអ្នកផ្ទាល់មានភាពសក្ដិសម ហើយធ្វើការសម្រេចចិត្តផ្ទាល់ខ្លួនល្អត្រឹមត្រូវនោះ ។

នៅពេលអ្នកទទួលទានសាក្រាម៉ង់រាល់សប្ដាហ៍ អ្នកនឹងត្រូវបានរំឭកពីសេចក្ដីសញ្ញារបស់អ្នកជាមួយព្រះវរបិតាសួគ៌ថា « លើកដាក់មកលើខ្លួន [ អ្នក ] នូវព្រះនាមនៃព្រះរាជបុត្រារបស់ [ ទ្រង់ ] . . . ប្រយោជន៍ឲ្យ [ អ្នក ] អាចបានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹង [ អ្នក ] ជាដរាប » ( គ. និង ស. ២០:៧៧ ) ។ តាមរយៈការរក្សាសេចក្ដីសញ្ញារបស់អ្នក នោះអ្នកអាចបន្តមានភាពសក្ដិសមធ្វើជាដៃគូនៃព្រះវិញ្ញាណ ។

ការចូលរួមការប្រជុំសាក្រាម៉ង់ និង ការប្រជុំផ្សេងៗទៀតនៃព្រះវិហារគឺពុំមែនជារបៀបតែមួយដែលផ្ដោតលើការរក្សាសេចក្ដីសញ្ញារបស់អ្នកនៅថ្ងៃអាទិត្យឡើយ ។ ដោយពុំគិតពីកាលៈទេសៈក្នុងផ្ទះរបស់អ្នកបែបណាឡើយ អ្នកអាចបង្ហាញព្រះវរបិតាសួគ៌នូវការប្ដេជ្ញាចិត្តរបស់ខ្លួន ចំពោះសេចក្ដីសញ្ញារបស់អ្នក តាមរយៈការធ្វើពង្សប្រវត្តិ ការសិក្សាដំណឹងល្អ ហើយបម្រើអ្នកដទៃ ជាពិសេសអស់អ្នកដែលឯកោ ឬ ឈឺស្កាត់ ។ ដោយការជ្រើសធ្វើកិច្ចការទាំងនេះ ទោះបីជាគ្រួសាររបស់អ្នកពុំធ្វើក៏ដោយ នោះអ្នកនឹងមានអំណរ និង ក្ដីរីករាយ ។ ( សូមមើល វ៉េសុល អិម ណិលសុន « The Sabbath Is a Delight » *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១២៩–៣២ ) ។



### លើករឿងនោះមកនិយាយ

ទោះបីជាឪពុកម្ដាយរបស់អ្នកជាសមាជិក ឬ មិនមែនសមាជិកសាសនាចក្រក្ដី សូមជជែកវែកញែកជាមួយពួកគេថាតើវាសំខាន់ខ្លាំងប៉ុណ្ណាចំពោះអ្នក ដើម្បីមានព្រះវិញ្ញាណគង់ជាប់ជាដរាបនៅក្នុងផ្ទះរបស់អ្នក ជាពិសេសនៅថ្ងៃអាទិត្យ ។ ចំពោះករណីនេះ អ្នកអាចជ្រើសយកកន្លែងដែលស្ងប់ស្ងាត់បំផុតនៅក្នុងផ្ទះ ហើយអញ្ជើញសមាជិកផ្សេងទៀតនៃសាសនាចក្រឲ្យមកជាមួយអ្នក ហើយពួកគេទាំងអស់គ្នាអញ្ជើញព្រះវិញ្ញាណឲ្យគង់នៅទីនោះ ។ ខ្ញុំដឹងថា ប្រសិនបើអ្នករក្សាថ្ងៃឈប់សម្រាកឲ្យបានបរិសុទ្ធ នោះព្រះអម្ចាស់នឹងប្រទានពរដល់អ្នកយ៉ាងច្រើនក្រាស់ក្រែល ។

*ចូសការែស ស៊ី អាយុ ១៦ ឆ្នាំ ទីក្រុង សាន់ឌីអាហ្គូ ដូមីនហ្គូ សាធារណៈរដ្ឋ ដូមីនីហ្គែន*



### អធិស្ឋានឲ្យឪពុកម្ដាយអ្នក

អ្នកអាចអធិស្ឋានសម្រាប់ឪពុកម្ដាយអ្នក ។ ដូចមរមនបានសរសេរថា « ព្រះអម្ចាស់នឹងនឹកចាំដល់សេចក្ដីអធិស្ឋានទាំងឡាយនៃពួកសុចរិតដែលត្រូវបានថ្វាយដល់ទ្រង់ដើម្បីពួកគេ » ( មរមន ៥:២១ ) ។ ឪពុកម្ដាយរបស់អ្នកប្រហែលជាពុំឈប់ធ្វើបែបនោះភ្លាមទេ ប៉ុន្តែព្រះអម្ចាស់នឹងជួយអ្នក ។

*ខូល អិម អាយុ ១៧ ឆ្នាំ រដ្ឋ អារីហ្សូណា ស.រ.អា.*

### ផ្ដោតចិត្តធ្វើកិច្ចការល្អៗ

ថ្ងៃអាទិត្យជាថ្ងៃមួយលំបាកជានិច្ចចំពោះខ្ញុំពេលនៅផ្ទះ ។ ខ្ញុំជាសមាជិកនៃសាសនាចក្រតែម្នាក់ឯងនៅក្នុងគ្រួសាររបស់ខ្ញុំ ហើយឪពុកម្ដាយ និង បងប្អូនរបស់ខ្ញុំមើលទូរទស្សន៍ ហើយស្ដាប់តន្ត្រីផ្សេងៗនៅថ្ងៃអាទិត្យ ។ ខ្ញុំចង់បង្ហាញសេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះព្រះវរបិតាសួគ៌របស់ខ្ញុំ តាមរយៈការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ ខ្ញុំអាចទៅបន្ទប់ដេក



*ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និង ទស្សនវិស័យ មិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*

របស់ខ្ញុំហើយអានព្រះគម្ពីរ ស្ដាប់តន្ត្រីសាសនាចក្រ ព្រមទាំងទៅសួរសុខទុក្ខមិត្តភក្តិរបស់ខ្ញុំ ឬ ទៅជាមួយអ្នកផ្សព្វផ្សាយសាសនា ។ ខ្ញុំមានអំណរគុណជាខ្លាំងចំពោះជំនួយរបស់ព្រះអម្ចាស់ ដើម្បីគោរពថ្ងៃឈប់សម្រាកដោយឧស្សាហ៍ព្យាយាម និង កម្លាំងដែលទ្រង់ប្រទានដល់ខ្ញុំជានិច្ច ។

*ឡេស ឌី ហូសឺ អិម អាយុ ១៩ ឆ្នាំ ទីក្រុង សើហ្គីប ប្រទេសប្រេស៊ីល*



ប្រើធនធាននានារបស់សាសនាចក្រ

ប្រសិនបើអ្នកមានទូរសព្ទដៃស្មាតហ្វូន ឬ tablet នោះអ្នកអាចទាញយកកម្មវិធី Mormon Channel និង LDS Youth ។ កម្មវិធីនេះមានពេញដោយចម្រៀង វីដេអូ និង សុន្ទរកថាដ៏អស្ចារ្យ ដែលយាងព្រះវិញ្ញាណឲ្យមកជានិច្ចនៅពេលយើងស្ដាប់វា ! វាជាអ្វីដែលសាមញ្ញ ប៉ុន្តែវាពិតជាជួយខ្ញុំមានព្រះវិញ្ញាណ ទោះបីជាមានសំឡេងអ៊ូអរហ៊ុំព័ទ្ធជុំវិញខ្ញុំក្ដី ។ វាមានការផ្លាស់ប្ដូរ ហើយនាំក្ដីសុខសាន្តចូលមកក្នុងផ្ទះទាំងមូល ។

*ហាន់ធើរអឺរ វី អាយុ ១៦ ឆ្នាំ រដ្ឋ តិចសាស ស. រ. អា.*

បែរទៅរកព្រះគម្ពីរ

សូមនិយាយជាមួយឪពុកម្ដាយរបស់អ្នកអំពីសកម្មភាពដែលពួកគាត់ធ្វើ ប៉ុន្តែប្រសិនបើពួកគាត់ពុំស្ដាប់ទេ អ្នកអាចអធិស្ឋានទូលសុំការណែនាំអំពីរបៀបដែលជួយអ្នកឲ្យមានអារម្មណ៍ពីព្រះវិញ្ញាណនៅក្នុងផ្ទះរបស់អ្នក ។ ដើម្បីទទួលអារម្មណ៍ពីព្រះវិញ្ញាណនៅក្នុងផ្ទះរបស់ខ្ញុំ ខ្ញុំអានព្រះគម្ពីរ ហើយការណ៍នេះបានយាងព្រះវិញ្ញាណមកក្នុងបន្ទប់របស់ខ្ញុំជានិច្ច ។

*ប្លែក អ៊ី អាយុ ១៤ ឆ្នាំ រដ្ឋ យូថាហ៍ ស.រ.អា.*

ធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ

វាសំខាន់ថាផ្ទះត្រូវមានព្រះវិញ្ញាណគង់នៅ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺថាបុគ្គលម្នាក់នោះត្រូវមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយ ។ ព្រះគ្រីស្ទគឺជាគំរូល្អអំពីការមានព្រះវិញ្ញាណគង់នៅជាមួយទ្រង់គ្រប់ពេលវេលាទាំងអស់ ។ ចូរព្យាយាមរស់នៅឲ្យកាន់តែដូចជាព្រះគ្រីស្ទ មានចិត្តសប្បុរសចំពោះមនុស្សដទៃ ហើយមើលពិភពលោកនេះតាមរបៀបដែលទ្រង់ទតមើល នោះប្រហែលជាវិធីមួយល្អបំផុតដើម្បីរក្សាព្រះវិញ្ញាណឲ្យគង់នៅជាមួយអ្នកមិនថាអ្នកនៅទីណាឡើយ ។

*អ៊ីសាប៉ែត ដ័បុលយូ អាយុ ១៦ ឆ្នាំ រដ្ឋ អូរ៉េហ្គិន ស.រ.អា.*

ផ្ដល់យោបល់សម្រាប់សកម្មភាពគ្រួសារ

នៅថ្ងៃអាទិត្យ អាចមានសកម្មភាពនានាដែលអ្នកអាចធ្វើជាមួយគ្រួសារបាន ។ សូមផ្ដល់យោបល់មួយចំនួនដែលគ្រួសារអាចធ្វើកិច្ចការជាមួយគ្នា ដោយកុំឲ្យអ្វីៗដែលមិនសមរម្យនោះកើតឡើងឡើយ ។ ប្រសិនបើអ្នកកំពុងធ្វើកិច្ចការអ្វីមួយជាគ្រួសារ នោះវានឹងនាំឲ្យអ្នកមានភាពស្និទ្ធស្នាលនឹងគ្នា ។ ហើយយោបល់នោះផ្ដល់គំនិតផ្សេងៗដល់សមាជិកគ្រួសារអំពីអ្វីដែលអ្នកអាចធ្វើនៅថ្ងៃអាទិត្យ ។ ប្រហែលជាសប្ដាហ៍ក្រោយពួកគេនិយាយថា « ហេ៎ អ្វីដែលយើងបានធ្វើកាលពីសប្ដាហ៍មុននោះសប្បាយណាស់—តោះយើងធ្វើវាម្ដងទៀត » ។

*រាយអែន ប៊ី អាយុ ១៩ ឆ្នាំ រដ្ឋ អៃដាហូ ស.រ.អា.*



**ចូរធ្វើតាមការបំផុសគំនិត**

« ខ្ញុំសូមផ្ដល់ការលើកទឹកចិត្តនេះ ។ អ្នកធ្លាប់មានគ្រាដែលអ្នកទទួលអារម្មណ៍ពីព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ . . .

« អ្នកអាចចាត់ទុកគ្រានៃ ការបំផុសគំនិតនេះប្រៀបដូចជាគ្រាប់ពូជនៃសេចក្ដីជំនឿដែលអាលម៉ាបានរៀបរាប់ ( សូមមើល អាលម៉ា ៣២:២៨ ) ។ ចូរដាំវាម្ដងមួយៗ ។ អ្នកអាចធ្វើដូច្នេះបានដោយធ្វើតាមការបំផុសដែលអ្នកមាន ។ ការបំផុសគំនិតដ៏មានតម្លៃបំផុតនឹងជាអ្វីដែលអ្នកត្រូវដឹងថាព្រះនឹងឲ្យអ្នកធ្វើ ។ . . .

« នៅពេលអ្នកធ្វើតាម ការបំផុសគំនិតមកពីព្រះវិញ្ញាណនោះ ព្រះវិញ្ញាណនឹងកើតមានកាន់តែញឹកញាប់ ហើយកាន់តែខិតជិតនឹងភាពជាដៃគូដ៏ខ្ជាប់ខ្ជួន ។ អំណាចក្នុងការរើសផ្លូវត្រូវរបស់អ្នកនឹងកើនឡើង » ។

ប្រធាន ហិនរី ប៊ី. អាវរិង ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ « **The Holy Ghost as Your Companion** » ***Liahona*** ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ១០៥ ។

**សំណួរបន្ទាប់**

« មិត្តភក្តិជិតស្និទ្ធរបស់ខ្ញុំនិយាយថា នាងពុំជឿលើព្រះឡើយ ។ តើខ្ញុំអាចចែកចាយដំណឹងល្អជាមួយនាងយ៉ាងដូចម្ដេច ? »

ប្រសិនបើអ្នកមានបំណងចង់ឆ្លើយ សូមផ្ញើចម្លើយរបស់អ្នក និង រូបថតច្បាស់មួយសន្លឹក ត្រឹម ថ្ងៃទី ១ខែ កក្កដា ឆ្នាំ ២០១៦ នៅគេហទំព័រ liahona.lds.orgតាមអ៊ីមែលទៅអាសយដ្ឋាន liahona@ldschurch.orgឬតាមសំបុត្រ ( សូមមើលអាសយដ្ឋាននៅទំព័រទី ៣ ) ។

ព័ត៌មាន និង ការអនុញ្ញាតខាងក្រោម ត្រូវតែបញ្ចូលនៅក្នុងអ៊ីម៉ែល ឬ សំបុត្ររបស់អ្នក ៖ (១) នាមត្រកូលទាំងមូល (២) ថ្ងៃខែឆ្នាំកំណើត (៣) វួដ ឬ សាខា (៤) ស្ដេក ឬ មណ្ឌល (៥) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយបើសិនអ្នកមានអាយុក្រោម ១៨ ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្ដាយរបស់អ្នកជាលាយលក្ខណ៍អក្សរ ( អ៊ីម៉ែលអាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ ប្រសិនបើវាវែងពេក ឬ មិនសូវច្បាស់លាស់ ។

# របៀបដើម្បីធ្វើជាមិត្តភក្តិល្អ

ដោយ ដេវីឌ ម៉ូរ៉ែល

យើងទាំងអស់គ្នាចង់មានអារម្មណ៍ថាត្រូវគេរាប់អានខ្លួន ។ នេះគឺជាអ្វីដែលអ្នកអាចធ្វើ ប្រសិនបើអ្នក ឬ នរណាម្នាក់ផ្សេងទៀតមានអារម្មណ៍ថាគេមិនរាប់រក ។

ខ្ញុំបានចាប់ផ្ដើមស្វែងយល់ពីសាសនាចក្រកាលខ្ញុំនៅវ័យជំទង់ ប៉ុន្តែខ្ញុំឈប់ចូលរួមការប្រជុំនៅថ្ងៃអាទិត្យ ដោយសារខ្ញុំមានអារម្មណ៍ថា យុវវ័យជាច្រើនពួកគេមិនរាប់រកខ្ញុំទេ ។ មានពេលក្រោយមក យុវជនម្នាក់បានបបួលខ្ញុំទៅសកម្មភាពសាសនាចក្រ ។ ខ្ញុំបានទទួលការអញ្ជើញនោះ ហើយចូលចិត្តសកម្មភាពទាំងនោះណាស់ ដោយសារមានសកម្មភាពជាច្រើនដែលខ្ញុំរីករាយនឹងធ្វើគឺ ៖ សម្ដែងលេងបាល់បោះ និង ការរត់ ។



## របៀបធ្វើជាមិត្តភក្តិល្អ

វាឈឺចាប់ណាស់ដែលគេមិនរាប់រកយើង ប៉ុន្តែការអាក់អន់ចិត្ត ឬ ការចងគំនុំនោះពុំជួយធ្វើឲ្យអ្នកមានអារម្មណ៍ប្រសើរឡើងឡើយ ។ ផ្ទុយទៅវិញ សូមព្យាយាមធ្វើកិច្ចការទាំងនេះ ៖

- ចូលរួមនៅក្នុងសកម្មភាពនានាសាសនាចក្រ ។ សកម្មភាពទាំងនេះជាឱកាសល្អ ដើម្បីឲ្យអ្នកនៅជាមួយមនុស្សដែលគោរពដល់បទដ្ឋានរបស់អ្នក ។
- រៀន និង អភិវឌ្ឍជំនាញ ។ ចូលរួមសមាគមនិស្សិត ក្រុមកីឡា ឬ ក្លឹបគឺជារបៀបល្អមួយដើម្បីរាប់អានដល់មនុស្ស ដែលមានចំណាប់អារម្មណ៍ស្រដៀងនឹងអ្នក ។
- សូមកុំរង់ចាំឲ្យមនុស្សដទៃមកសុំអ្នកធ្វើជាមិត្តភក្តិឡើយ ។ សូមណែនាំខ្លួនអ្នកដល់មនុស្សដទៃ ។
- សូមធ្វើជាបុគ្គលដ៏ល្អបំផុត ដែលអ្នកអាចធ្វើបាន ហើយរក្សាបទដ្ឋានរបស់អ្នក ។ អ្នកនឹងរកឃើញមិត្តភក្តិដែលរីករាយចំពោះអ្នក សម្រាប់អត្តចរិករបស់អ្នក និង ពន្លឺដែលអ្នកមាន ។
- សូមចំណាយពេលនៅជាមួយគ្រួសាររបស់អ្នក ។ អ្នកអាចដឹងថា មិត្តភក្តិស្និទ្ធស្នាលមួយចំនួនរបស់អ្នកគឺរកបាននៅក្នុងផ្ទះផ្ទាល់ខ្លួនអ្នក ។

នៅពេលខ្ញុំបន្តចូលរួមសកម្មភាព ខ្ញុំបានស្គាល់យុវជនទាំងនោះបានដឹងថា មានពួកគេជាច្រើននាក់រៀនសាលាជាមួយខ្ញុំ ។ យូរៗទៅ ខ្ញុំបានបង្កើនមិត្តភាពជាមួយយុវជន និង យុវនារីដែលមានបទដ្ឋានដូចដែលខ្ញុំរស់នៅតាម ។ ខ្ញុំមានអំណរគុណ ដែលមានម្នាក់បានអញ្ជើញខ្ញុំឲ្យចូលរួមសកម្មភាពព្រះវិហារ ហើយខ្ញុំមានអំណរគុណដោយព្រោះខ្ញុំបានទទួលយកការអញ្ជើញនោះ ។

តើអ្នកធ្លាប់មានអារម្មណ៍ដូចខ្ញុំដែរឬទេ ៖ គឺអារម្មណ៍ថាគេមិនរាប់រក ឬ ជាមនុស្សដែលចូលមិនចុះក្នុងចំណោមគេ ? ឬ តើអ្នកធ្លាប់ស្គាល់នរណាម្នាក់ដែលមានអារម្មណ៍ថាគេមិនទទួលស្គាល់ខ្លួន ឬ គ្មានមិត្តភក្តិច្រើនដែរឬទេ ? ទោះបីនៅសាលារៀន ព្រះវិហារ ឬ កន្លែងដទៃទៀតក្តី មានមនុស្សជាច្រើនមានអារម្មណ៍បែបនោះ នៅក្នុងជីវិតរបស់ពួកគេ ។



រូបគំនូរដោយ ចាប៉ូ លីប៉ីក



**ចូរមានចិត្តសប្បុរសចំពោះអ្នកដទៃ**

« ខ្ញុំសង្ឃឹមថាយើងនឹងព្យាយាមជានិច្ច ដើម្បីធ្វើជាមនុស្សមានចិត្តសប្បុរស ហើយគិតពីគំនិត និង អារម្មណ៍ព្រមទាំងស្ថានភាពនៃមនុស្សដែលនៅជុំវិញយើង ។ ចូរយើងកុំបន្ទាបបន្ថោក ឬ រិះគន់គ្នាឡើយ ។ ផ្ទុយទៅវិញ ចូរយើងមានចិត្តមេត្តា និង ការគោរព » ។

ប្រធាន ថូម៉ាស អេស. ម៉នសុន « **Love—the Essence of the Gospel** » *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៩៣ ។

## របៀបដាក់បញ្ចូលមនុស្សដទៃឲ្យចូលរួម

ពេលខ្លះ វាហាក់បីដូចជាមានការលំបាក ដើម្បីធ្វើអ្វីដែលយើងពិបាកធ្វើ ហើយមានចិត្តរួសរាយដល់មនុស្សដទៃ ប៉ុន្តែនៅពេលយើងចាំថា យើងទាំងអស់គ្នាគឺជាកូនចៅរបស់ព្រះ នោះយើងនឹងមើលឃើញនូវសារៈសំខាន់នៃការជួយមនុស្សដទៃ ។ ទាំងនេះគឺជាយោបល់ ៖

- និយាយជាមួយមនុស្សថ្មីៗនៅសាលារៀន និង ព្រះវិហារ ។ ណែនាំពួកគេឲ្យស្គាល់មិត្តភក្តិរបស់អ្នក ។
- អញ្ជើញនរណាម្នាក់ដែលត្រូវការមិត្តភក្តិទៅសកម្មភាពសាលារៀន ឬ សាសនាចក្រ ។
- ប្រឈមមុខ—ដោយចិត្តសប្បុរស និង អំណត់—ជាមួយមនុស្សដែលមានចេតនាធ្វើឲ្យមនុស្សដទៃមានអារម្មណ៍ថាពុំស្វាគមន៍គេ ។
- អង្គុយជាប់មនុស្សដែលឯកោ ឬ អញ្ជើញពួកគេឲ្យអង្គុយជាមួយអ្នក និង មិត្តភក្តិរបស់អ្នក ។
- សូមអធិស្ឋានទៅព្រះវរបិតាសួគ៌នៅពេលអ្នកមិនដឹងពីរបៀប ដើម្បីជួយនរណាម្នាក់ ។ ទ្រង់ជ្រាបដឹងយ៉ាងច្បាស់ពីអ្វីដែលបុគ្គលម្នាក់នោះត្រូវការ ដើម្បីមានចិត្តរីករាយ ហើយអាចជួយអ្នកផ្តល់នូវជំនួយនោះ ។ ■

*អ្នកនិពន្ធរស់នៅទីក្រុង សាន់តា គ្រូស ប្រទេស បូលីវី ។*

# ការពារអ្វីដែលត្រឹមត្រូវ

ដោយ អាសឺ តាន រដ្ឋ យូថាហ៍ ស. រ. អា.



## សួស្តី ខ្ញុំឈ្មោះអ៊ីវ៉ាន !

ខ្ញុំរស់នៅប្រទេស អៀឡង់ ខ្ញុំចូលចិត្តលេងកីឡាមួយដែលហៅថាកីឡាវាយកូនបាល់ ។ វាជាកីឡាអៀរឡង់ដែលដូចជាកីឡាវាយកូនបាល់លើទឹកកកដែរ ។ មុខវិជ្ជាដែលខ្ញុំចូលចិត្តរៀននោះគឺគណិតវិទ្យា ។ ធ្វើជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជាពរជ័យមួយសម្រាប់ខ្ញុំ ។



### ការឈរយ៉ាងរឹងមាំនៅសាលារៀន

*ក្មេងប្រុសម្នាក់ទើបចូលរៀននៅសាលាបានសម្លុតប្អូនស្រីរបស់ខ្ញុំ ។ ខ្ញុំបានចូលទៅឈរចំកណ្តាលពួកគេហើយបានការពារប្អូនស្រីរបស់ខ្ញុំ ។ ខ្ញុំក៏គោរពតាមពាក្យសម្តីនៃប្រាជ្ញាវាងវៃផងដែរ ។ សិស្សជាច្រើននៅសាលារៀនផឹកតែ និង កាហ្វេ ។ ពេលមាននរណាម្នាក់ឲ្យតែខ្ញុំផឹក ខ្ញុំនិយាយថា « ខ្ញុំអត់ផឹកទេ សូមអរគុណ » ។*



## យោបល់របស់អ៊ីវ៉ាន ដើម្បីឈរយ៉ាងរឹងមាំ

វាតម្រូវឲ្យចិត្តក្លាហានដើម្បីរស់នៅតាមដំណឹងល្អ ។

- សូមកុំចុះចាញ់ឡើយ ។
- សូមស្ដាប់តាមព្រះវិញ្ញាណបរិសុទ្ធ ។ ទ្រង់នឹងដឹកនាំអ្នក ។
- សូមចាំថា ការជួយនរណាម្នាក់ឲ្យទទួលដំណឹងល្អ នឹងធ្វើឲ្យជីវិតរបស់ពួកគេកាន់តែរីករាយ ។

### អធិស្ឋានជាមួយមិត្តភក្ដិ

*ខ្ញុំទៅរៀននៅសាលាកាតូលិក ។ ប្អូនស្រីរបស់ខ្ញុំ និង ខ្ញុំគឺជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយដែលរៀននៅទីនោះ ។ ពេលជីដូនរបស់ខ្ញុំឈឺ ខ្ញុំបានសុំគ្រូរបស់ខ្ញុំប្រសិនបើខ្ញុំអាចអធិស្ឋានសម្រាប់គាត់ ។ សិស្សទាំងអស់នៅក្នុងថ្នាក់ឱបដៃ ហើយ ឱនក្បាលចុះ ។ ខ្ញុំបានអធិស្ឋានឮៗពីសិស្សក្នុងថ្នាក់ ។*

### បងប្រុសច្បងដ៏ល្អបំផុត

*ខ្ញុំដាក់គោលដៅបន្តធ្វើអ្វីដែលត្រឹមត្រូវ ។ ខ្ញុំជួយឪពុកម្ដាយខ្ញុំមើលថែប្អូនស្រីរបស់ខ្ញុំ ។ នៅពេលប្អូនស្រីរបស់ខ្ញុំភ័យខ្លាច នោះខ្ញុំលេងជាមួយពួកគេរហូតដល់ពួកគេភ្លេចភាពខ្លាចនោះ ។ មានគ្រាមួយនោះ នៅពេលឪពុកម្ដាយខ្ញុំមិននៅផ្ទះ ខ្ញុំបាននិទានរឿងឲ្យប្អូនស្រីខ្ញុំស្ដាប់រហូតដល់នាងដេកលក់ ។*

### សូមផ្ញើស្នាមបាតជើងរបស់អ្នកមកកាន់យើង !

តើអ្នកឈរយ៉ាងរឹងមាំក្នុងការធ្វើតាមព្រះយេស៊ូវយ៉ាងដូចម្ដេច ? សូមគូសស្នាមបាតជើងរបស់អ្នក ហើយផ្ញើរឿង និង រូបថតរបស់អ្នកមកកាន់យើងខ្ញុំ ព្រមជាមួយនឹងការអនុញ្ញាតពីឪពុកម្ដាយរបស់អ្នកមកផងដែរ ។ សូមផ្ញើវាមកតាមរយៈគេហទំព័រ liahona.lds.org ( ចុច « Submit an Article » ) ឬ អ៊ីម៉ែល liahona@ldschurch.org ។

### ធ្វើជាគំរូ

*មិត្តភក្ដិរបស់ខ្ញុំនៅសាលារៀនឃើញថាខ្ញុំមានចិត្តរីករាយ ។ ខ្ញុំធ្វើជាគំរូល្អដោយមិនប្រើពាក្យជេរ ឬ យកព្រះនាមរបស់ព្រះអម្ចាស់ជាអសាឥតការឡើយ ។ ខ្ញុំអាចធ្វើជាគំរូដល់គ្រួសារខ្ញុំផងដែរ ។*





# ដៃគូសិក្សារបស់យ៉័រដាន់

**ដោយ យើស្ទីន អ៊ីត**

ផ្អែកទៅលើដំណើររឿងពិត

« *ព្រះវិញ្ញាណនឹងដឹកនាំ ដាក់ក្នុងចិត្តខ្ញុំ ដឹងថាព្រះគម្ពីរពិត* » ( ចម្រៀងកុមារ *ទំព័រ ៦៦* ) ។

យ៉័រដាន់ពុំបានឃើញបងស្រីរបស់ខ្លួន យើស៊ី ជាងមួយឆ្នាំហើយ—វាមានអារម្មណ៍ថាដូចជាយូរណាស់ ! មិនយូរប៉ុន្មាន គាត់នឹងត្រឡប់មកពីបេសកកម្មវិញដើម្បីទទួលការវះកាត់ ។ យ៉័រដាន់សោកស្ដាយដែលគាត់ឈឺ ប៉ុន្តែវារីករាយដែលពួកគេនឹងអាចនៅជាមួយគ្នាក្នុងពេលឆាប់ៗនេះ ។

នៅថ្ងៃបន្ទាប់ ក្រោយពីវាត្រឡប់មកពីសាលារៀនវិញ យើស៊ីកំពុងអង្គុយនៅលើសាឡុង ។ យ៉័រដាន់បានរត់ទៅរកគាត់ ហើយឱបគាត់ ។

« សួស្ដី យ៉័រដាន់ ! បងនឹងប្អូនណាស់ ! » យើស៊ីនិយាយ ។

យ៉័រដាន់ញញឹម ។ « ប្អូនក៏នឹងបងដែរ ! ប្អូនស្ដាយណាស់ដែលបងឈឺ » ។

យើស៊ី និយាយថា « អរគុណ ប្អូនសម្លាញ់ » ។ គាត់កំពុងដាក់ព្រះគម្ពីរមរមននៅលើភ្លៅរបស់ខ្លួន ។

វាបានសួរថា « តើខ្ញុំអាចអានជាមួយបងផងបានទេ ?

សូមប្អូនទៅយកគម្ពីរមរមនរបស់ប្អូនមក ហើយយើងអាចចាប់ផ្ដើមអានពីដំបូងមកជាមួយគ្នា » ។

យ៉័រដាន់ បានរត់ទៅបន្ទប់ខ្លួន ហើយចាប់យកគម្ពីរមក ។ វាបានស្រែកពេលវារត់ត្រឡប់មកវិញថា « នេះគម្ពីរខ្ញុំ ! » ។ វាបានប្រញាប់ទៅអង្គុយក្បែរយើស៊ី ។

ពួកគេបានបើកទៅទំព័រចំណងជើង ។ យ៉័រដាន់អានថា « ព្រះគម្ពីរមរមន ៖ សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ » ។ ពួកគេបានផ្លាស់វេនគ្នាអាន ។

យើស៊ីបាននិយាយថា « នៅក្នុងបេសកកម្មរបស់បង បងបានសិក្សាព្រះគម្ពីរជាមួយដៃគូរាល់ថ្ងៃ » ។

រូបគំនូរដោយ ម៉ាក រ៉ូបឺនសុន



*យ៉ាដាន់នឹកពីគ្រាដែលនៅជាមួយមិត្តភក្តិសិក្សារបស់ខ្លួនគឺ យើស៊ី ។ ប៉ុន្តែក្រោយមក គាត់មានគំនិតអស្ចារ្យមួយ !*

តើប្អូននឹងធ្វើជាដៃគូសិស្សរបស់បង រហូតដល់ពេលបងត្រូវត្រឡប់ទៅបេសកកម្មរបស់បងវិញបានទេ ? » យើស៊ីសួរ ។

វានិយាយថា « បាទ បាន ! » ។

ពីរបីថ្ងៃក្រោយយើស៊ីបានទទួលការវះកាត់ ។ នាងបានត្រឡប់មកពីមន្ទីរពេទ្យវិញ សម្រាកនៅផ្ទះ ហើយបានជាសះស្បើយរយៈពេលពីរបីសប្តាហ៍ ។ នាង និង យ៉ាដាន់បានសិក្សាព្រះគម្ពីរមរមនជាមួយគ្នារៀងរាល់ថ្ងៃ ។

ពីមុននាងត្រឡប់ទៅបេសកកម្មរបស់ខ្លួនវិញ យើស៊ីបាននិយាយថា « យ៉ាដាន់ បងចង់សូមឲ្យប្អូនអានព្រះគម្ពីរមរមនឲ្យចប់ពីមុនប្អូនជ្រមុជទឹក ! »

យ៉ាដាន់បានគិតអំពីរឿងនោះ ។ វានឹងឈានដល់អាយុប្រាំបីឆ្នាំក្នុងរយៈពេលតែពីរបីខែទៀតប៉ុណ្ណោះ ។ វានឹងមានគម្ពីរជាច្រើនដែលត្រូវអាន ។ ប៉ុន្តែវាចង់អានគម្ពីរនោះ ។ យ៉ាដាន់និយាយថា « បាទ » ។

« ពេលប្អូនអាន តើប្អូននឹងអធិស្ឋាន ហើយសួរថាគម្ពីរនេះពិតដែរឬទេ ? » យើស៊ីសួរ ។ « ម៉្យាណៃ បានសន្យាថា ប្រសិនបើយើងធ្វើបែបនោះ ព្រះវិញ្ញាណបរិសុទ្ធនឹងប្រាប់យើងថាគម្ពីរនេះពិត ឬ អត់ » ។

យ៉ាដាន់និយាយថា « បាទ យល់ព្រម » ។

ត្រឹមពេលដែលយើស៊ីត្រឡប់ទៅបេសកកម្មរបស់នាងវិញ ពួកគេបានអានដល់នីហ្វៃទី ២ ជាមួយគ្នា ។

យ៉ាដាន់ពិតជានឹកយើស៊ីណាស់ ។ ជាពិសេស វានឹកពីគ្រានៅជាមួយដៃគូសិក្សារបស់ខ្លួន ។ ប៉ុន្តែក្រោយមក គាត់មានគំនិតអស្ចារ្យមួយ !

លុះស្អែកឡើងនៅសាលារៀន វាបានដើរទៅកាន់គូមិត្តភក្តិស្និទ្ធស្នាលរបស់វាគឺជេក ។

យ៉ាដាន់បាននិយាយថា « ខ្ញុំនឹងអានព្រះគម្ពីរមរមនឲ្យចប់ពីមុនខ្ញុំជ្រមុជទឹក ។ ដោយសារយើងទាំងពីរនាក់ជ្រមុជទឹកនៅថ្ងៃជាមួយគ្នា តើឯងចង់អានវាឲ្យចប់ដែរឬទេ ? »

ជេកបានពោលថា « បាន យល់ព្រម ។ ខ្ញុំមិនធ្លាប់អានព្រះគម្ពីរមរមនទាំងអស់ពីមុនឡើយ » ។

រាល់ថ្ងៃនៅសាលារៀន ពួកគេបានសួរគ្នាទៅវិញទៅមកនូវសំណួរដូចគ្នា ។

« តើឯងអានដល់ណាហើយ ?

ចប់គម្ពីរយ៉ាកុបហើយ ។ តើឯងអានដល់ណាហើយ ? »

មិនយូរប៉ុន្មាន ពួកគេពុំបានសួរសំណួរនោះទៀតឡើយ ។ ពួកគេមើលគ្នាទៅវិញទៅមក ហើយពួកគេបានដឹងពីសំណួរទៅហើយ ។

យ៉ាដាន់និយាយថា « ខ្ញុំគិតថា យើងនឹងអានវាចប់ល្មមពេលយើងជ្រមុជទឹក » ។

នៅទីបំផុត ថ្ងៃជ្រមុជទឹកបានមកដល់ ។

យ៉ាដាន់ បាបខ្សឹបថា « ខ្ញុំបានអានចប់យប់មិញនេះ » ។

ខ្ញុំក៏ដូចគ្នាដែរ ! ជេកបាននិយាយ ។ « ហើយខ្ញុំបានអធិស្ឋានដើម្បីដឹងថាតើគម្ពីរមរមនពិតដែរឬទេ ហើយខ្ញុំទទួលអារម្មណ៍ថាកក់ក្តៅ និង រីករាយក្នុងចិត្ត » ។

យ៉ាដាន់ញញឹម ។ « ខ្ញុំក៏ដូចឯងដែរ ។ ខ្ញុំបានទទួលអារម្មណ៍រីករាយណាស់ នៅពេលខ្ញុំអធិស្ឋាន » ។ វាមានអំណរគុណយ៉ាងខ្លាំងចំពោះការអញ្ជើញរបស់យើស៊ី ។ ឥឡូវនេះវាបានស្គាល់បទទីបន្ទាល់ផ្ទាល់ខ្លួនហើយ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ វឺជីញ៉ា ស.រ.អា. ។*



# គ្រប់គ្រឿងសឹករបស់ព្រះ

ខគម្ពីរបង្រៀនថា យើងគួរតែពាក់ « គ្រប់គ្រឿងសឹក » របស់ព្រះ ( សូមមើល អេភេសូរ ៦:១១–១៨ និង គ. និង ស. ២៧:១៥–១៨ ) ។ នៅពេលយើងសិក្សាព្រះគម្ពីរហើយអធិស្ឋាន គឺដូចជាយើងពាក់គ្រឿងសឹក ដែលជួយយើងឲ្យមានសុវត្ថិភាព ។



**មួកនៃសេចក្តីសង្គ្រោះ**
មួកសុវត្ថិភាពការពារក្បាល ។ យើងរក្សាគំនិតខ្លួនឲ្យមានសុវត្ថិភាព នៅពេលយើងធ្វើតាមព្រះយេស៊ូវ ហើយធ្វើអ្វីដែលទ្រង់ចង់ឲ្យពួកយើងធ្វើ ។

**ខែលនៃសេចក្តីជំនឿ**
សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទគឺដូចជាខែលការពារ ។ នៅពេលយើងជឿលើព្រះយេស៊ូវ ហើយព្យាយាមឲ្យប្រែក្លាយដូចទ្រង់ នោះយើងអាចជ្រើសរើសធ្វើល្អ ទោះបីជាមានរឿងលំបាកក៏ដោយ ។



រូបគំនូរ ដោយ ប្រាន់ឌិន ធំមិន

**ប្រដាប់បាំងទ្រូងនៃសេចក្ដីសុចរិត**
ប្រដាប់បាំងទ្រូងការពារបេះដូង ។ ពេលយើងស្រឡាញ់ព្រះអស់ពីដួងចិត្តរបស់យើង នោះយើងព្យាយាមគោរពបទបញ្ញត្តិរបស់ទ្រង់ ។ យើងទទួលពរនៅពេលយើងជ្រើសរើសត្រឹមត្រូវ ។

**ក្រវ៉ាត់នៃសេចក្ដីពិត**
ក្រវ៉ាត់គឺជាខ្សែក្រវ៉ាត់ដែលជួយការពាររូបកាយរបស់ទាហាន ។ ការស្គាល់សេចក្ដីពិតនឹងការពារពួកយើង ។ ដំណឹងល្អគឺពិត ហើយការរស់នៅតាមដំណឹងល្អធ្វើឲ្យយើងរឹងមាំ ។

**ស្បែកជើងនៃការរៀបចំនៃភាពសុខសាន្ត**
ស្បែកជើងការពារជើង ។ យើងព្យាយាមធ្វើតាមស្នាមព្រះបាទព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឲ្យយើងអាចរស់នៅជាមួយទ្រង់នៅថ្ងៃខាងមុខ ។

**ដាវនៃព្រះវិញ្ញាណ**
ដាវជួយវាយប្រឆាំងនឹងសេចក្ដីខុសឆ្គង ។ ព្រះវិញ្ញាណជួយយើងនៅពេលយើងជួបរឿងអាក្រក់ ឬ លំបាក ។ ស្ដាប់តាមព្រះវិញ្ញាណជួយយើងឲ្យមានសុវត្ថិភាព ។

តើអ្នកអាចធ្វើអ្វីខ្លះជារៀងរាល់ថ្ងៃដើម្បីរក្សាវិញ្ញាណរបស់អ្នកឲ្យមានសុវត្ថិភាព និង រីករាយ ?

ចម្លើយមកពីសាវក



# តើយើងសន្យាអ្វីខ្លះនៅពេលធ្វើពិធីបុណ្យជ្រមុជទឹក ?


**ដោយ អែលឌើរ នែល អិល អាន់ឌើរសិន**

ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់




យើងលើកដាក់លើខ្លួនយើងនូវព្រះនាមនៃព្រះគ្រីស្ទ ហើយក្លាយជាសមាជិកនៃសាសនាចក្ររបស់ទ្រង់ ។

បន្ទាប់មក នៅពេលយើងទទួលទានសាក្រាម៉ង់រាល់សប្ដាហ៍ យើងសន្យាថាចងចាំព្រះយេស៊ូវ ។ យើងសន្យារក្សាបទបញ្ញត្តិរបស់ទ្រង់ ។





យើងជឿលើទ្រង់ ។
យើងថ្វាយបង្គំទ្រង់ ។
យើងធ្វើតាមទ្រង់ ។

*ដកស្រង់ចេញពី « Thy Kingdom Come » Liahona ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១១៩–១២៣ ។*


រូបគំនូរដោយ ហ្គេលី ហ្វ៊ុបបើត ; រូបថតទឹក ដោយ ISTOCK/THINKSTOCK

# ទំព័ររបស់យើង




*ខ្ញុំមានអារម្មណ៍ល្អអំឡុងពេលនៃពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍ភ័យបន្តិចក្នុងពេលចាប់ផ្ដើម ប៉ុន្តែបន្ទាប់ពីខ្ញុំបានចូលទៅក្នុងទឹកហើយនោះ ការភ័យខ្លាចនោះបានរសាយបាត់អស់ ។ ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពណាស់ពេលនៅក្នុងអាងជ្រមុជទឹក ។ ខ្ញុំមានចិត្តរីករាយជាខ្លាំងដែលខ្ញុំបានសម្រេចចិត្តជ្រមុជទឹក ។ ខ្ញុំដឹងថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយជាសាសនចក្រពិត ហើយថាមានព្រះដែលមានព្រះជន្មរស់ ។*

នីលីអាណា វី អាយុ ៨ ប្រទេស ប្រេស៊ីល



*គ្រួសារខ្ញុំ និង ខ្ញុំបានទៅព្រះវិហារបរិសុទ្ធ ហើយខ្ញុំដឹងថាព្រះវិហារបរិសុទ្ធគឺជាដំណាក់ដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ ។*

ហេឡាម អេ អាយុ ៥ ឆ្នាំ ប្រទេស ពេរូ





*ឪពុក និង ម្ដាយរបស់ខ្ញុំនិយាយជាមួយពួកយើងអំពីព្រះវិហារបរិសុទ្ធ ។ ពួកគាត់បានបង្ហាញរូបភាពព្រះវិហារបរិសុទ្ធមួយដល់យើង ហើយថ្លែងទីបន្ទាល់អំពីពរជ័យអស់កល្បជានិច្ចរបស់ព្រះវិហារបរិសុទ្ធ ។*

ត្រេសើរ អាយ អាយុ ៧ ឆ្នាំ ប្រទេសកុងហ្គោ

## ការបង្កបង្កើត

ដោយសេចក្ដីសុចរិតព្រះវរបិតាសួគ៌បានបង្កើតពិភពលោកនេះ ។
ទ្រង់បាននាំពន្លឺមកក្នុងទីងងឹត ហើយបានបង្កើតខ្យល់ មហាសមុទ្រ និង ដីគោក ។
ដោយមានអ្វីៗជាច្រើន និង មានការផ្លាស់ប្ដូររដូវកាលដើម្បីបន្ថែមទៅលើការបង្កើតទាំងនោះ ។
ក្រោយមកមានព្រះអាទិត្យ ព្រះចន្ទ និង តារាទាំងពួង ព្រមទាំងមានសត្វមកនៅជាមួយយើងផងដែរ ។
ក្រោយមកមនុស្សត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងលើផែនដីនេះ ។
ឥឡូវនេះព្រះវរបិតាសួគ៌របស់យើងអាចបានសម្រាកហើយ ។
នៅថ្ងៃបរិសុទ្ធរបស់ទ្រង់ យើងរៀនពីសេចក្ដីពិតទាំងនេះ ។

**ស៊ី លីង យៅ អាយុ ១០ ឆ្នាំ ប្រទេស តៃវ៉ាន់**

# អ័ប៊ីសជាអ្នកផ្សាយសាសនា

ឪពុករបស់អ័ប៊ីសបានបង្រៀននាងឲ្យជឿលើព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងទីក្រុងរបស់គាត់ ពុំសូវមានគេជឿលើព្រះយេស៊ូវឡើយ ។ បន្ទាប់ពីអាំម៉ូនបានមកកាន់ប្រជាជនរបស់នាង ហើយបានបង្រៀនស្ដេច ឡាម៉ូណៃ អ័ប៊ីសបានដឹងថាព្រះវរបិតាសួគ៌ចង់ឲ្យនាងចែកចាយដំណឹងល្អជាមួយមនុស្សទូទៅ ។ ទីបំផុតនាងអាចប្រាប់មនុស្សគ្រប់គ្នាអំពីព្រះយេស៊ូវ ។



នៅពេលគ្រួសាររបស់យើងបានធ្វើផែនការបេសកកម្ម ។ យើងបានសម្រេចចិត្តពីអ្វីដែលយើងម្នាក់ៗនឹងធ្វើ ។ ខ្ញុំបានសម្រេចចិត្តជូនព្រះគម្ពីរមរមនមួយក្បាលដល់គ្រូបង្រៀនថ្នាក់ទីពីររបស់ខ្ញុំ ។ នៅពេលខ្ញុំបានឲ្យវាទៅគាត់ គាត់បាននិយាយថា « អរគុណ អ័ដាម ។ អ្នកគ្រូចូលចិត្តអាន » ។ ខ្ញុំពិតជារីករាយណាស់ ដែលយើងអាចធ្វើផែនការបេសកកម្មគ្រួសារ ។

**អ័ដាម ដ័បុលយូ អាយុ៨ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា.**



*« អ័ប៊ីស និង ម្ចាស់ក្សត្រី » ម៉ាលី ឌី អាយុ ៦ ឆ្នាំ រដ្ឋ វ៉ាស៊ីនតោន ស.រ.អា.*

រូបគំនូរដោយ យ៉ារ៉េត ប៊េក ស្រ៊ុន

កាត់ បត់ ហើយរក្សាកាតសំណូមពរនេះ !




## ខ្ញុំអាចធ្វើជាអ្នកផ្សព្វផ្សាយសាសនា !

- ☐ សូត្រ អាលម៉ា ១៩:៣៦ ។
- ☐ អញ្ជើញមិត្តម្នាក់មកថ្នាក់បឋមសិក្សាដើម្បីរៀនដំណឹងល្អ ។
- ☐ ជួយឲ្យទីបន្ទាល់របស់អ្នកកើនឡើង តាមរយៈការចែកចាយវាជាមួយអ្នកផ្សេងទៀត !
- ☐ ខ្ញុំសំណូមពរដល់ខ្លួនឯងដើម្បី . . .

______________________________

## ខគម្ពីរសម្រាប់ខែនេះ

បន្ទាប់ពីអ្នកអានវគ្គបទគម្ពីរមួយហើយ សូមផាត់ពណ៌លើផ្នែកមានចុះលេខដែលត្រូវគ្នាលើគ្រាប់ពូជ !

**១** អាលម៉ា ៣១:៥–៦, ១២–១៦, ២៤–២៦

**២** អាលម៉ា ៣២:១, ៤–៧, ២១–២៣, ២៨

**៣** អាលម៉ា ៣៤:១, ៨–១០, ១៧–២៨

**៤** អាលម៉ា ៣៦:៥–១១, ១៨–២៤

**៥** អាលម៉ា ៣៧:៣–៧, ១៤–១៧

**៦** អាលម៉ា ៣៨:១, ៩

**៧** អាលម៉ា ៤០:១១–១២, ២៣–២៦

**៨** អាលម៉ា ៤១:១០




រូបគំនូរដោយ ម៉ាក់ឃើ ប៊ើក ស្កេន



## ការរីកចម្រើននៃសេចក្ដីជំនឿ

អាលម៉ា និង អាមូលេកបានបង្រៀនមនុស្សជាច្រើនអំពីព្រះយេស៊ូវគ្រីស្ទ ។ ពួកគេបានផ្លាស់ប្ដូរជីវិតមនុស្ស តាមរយៈការដាំគ្រាប់ពូជនៃសេចក្ដីជំនឿ ។ អាលម៉ា និង មនុស្សដទៃគឺជាអ្នកផ្សព្វផ្សាយសាសនា ហើយបានបង្រៀនព្រះបន្ទូលនៃព្រះ ។ សូមរកមើលសំណួមពរ សម្រាប់ការអានផ្សេងទៀតនៅខែក្រោយ ! ■

# អាលម៉ាបង្រៀនរបៀបអធិស្ឋាន



អាលម៉ាជាកូនបានទៅជាមួយអ្នកឯទៀត ដើម្បីបង្រៀនសាសន៍សូរាំ ។ សាសន៍សូរាំធ្លាប់ជឿលើព្រះវរបិតាសួគ៌ ប៉ុន្តែពុំបានរក្សាបទបញ្ញត្តិរបស់ទ្រង់ទៀតឡើយ ។ ពួកគេពុំបានជឿលើព្រះយេស៊ូវទេ ។

ហើយពួកគេពុំបានចាំពីរបៀបត្រឹមត្រូវដើម្បីអធិស្ឋានឡើយ ។

ក្នុងមួយសប្ដាហ៍ម្ដង សាសន៍សូរាំបានប្ដូរវេនគ្នាអធិស្ឋាន ។ ពួកគេបានឡើងទៅលើទីខ្ពស់មួយ ។ ពួកគេលើកដៃរបស់ខ្លួនឡើងលើ ។ បន្ទាប់មកពួកគេថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌ថា ពួកគេប្រសើរជាងមនុស្សដទៃផ្សេងទៀត ។ មនុស្សគ្រប់គ្នាបានអធិស្ឋានដូចគ្នាបេះបិត ។



រូបគំនូរដោយ អាបរីល ស្តុត



សាសន៍សូរាំបានអធិស្ឋានតែក្នុងពេលដែលពួកគេឡើងទៅទីខ្ពស់នោះប៉ុណ្ណោះ ។ ពួកគេពុំគិតអំពីព្រះវរបិតាសួគ៌ ឬ អធិស្ឋានទៅកាន់ទ្រង់នៅផ្ទះ ឬ កន្លែងផ្សេងទៀតឡើយ ។



អាលម៉ាបានបង្រៀនប្រជាជននេះថាពួកគេអាចអធិស្ឋានគ្រប់ពេល ។ ពួកគេអាចអធិស្ឋាននៅផ្ទះ នៅទីវាល ឬ នៅក្នុងទីរហោស្ថាន ។ លោកបានបង្រៀនថា ពួកគេអាចអធិស្ឋានអំពីអ្វីគ្រប់យ៉ាង ហើយព្រះវរបិតាសួគ៌នឹងជួយពួកគេ ។



យើងអាចអធិស្ឋានតាមរបៀបអាលម៉ាបានបង្រៀន ។ យើងអាចអធិស្ឋានគ្រប់ពេល និង គ្រប់ទីកន្លែង ។ យើងអាចអធិស្ឋានស្ងាត់ៗក្នុងចិត្តរបស់យើង ។ ព្រះវរបិតាសួគ៌នឹងឮយើងជានិច្ច ! ■

# ខ្ញុំអាចមានគារវភាព



រូបគំនូរដោយ អាបរីល ស្តុត



ប្រធាន ស្ពែនសើរ ដបុលយូ.ឃីមបឹល
( ឆ្នាំ ១៨៩៥–១៩៨៥ )
ប្រធានទីដប់ពីរនៃសាសនាចក្រ

# មូលហេតុ និង របៀប ព្រមទាំងអ្វីដែលត្រូវថ្លែងទីបន្ទាល់

*គ្រប់ពេលដែលអ្នកថ្លែងទីបន្ទាល់របស់ខ្លួន នោះវាកាន់តែមានរឹងមាំ ។*



មនុស្សគ្រប់រូបនៅក្នុងពិភពលោកនេះអាចមានវិវរណៈ ដូចជាវិវរណៈមួយដែលពេត្រុសមាន [ សូមមើល ម៉ាថាយ ១៦:១៣–១៧] ។ ថាវិវរណៈនោះនឹងក្លាយជាទីបន្ទាល់ ជាចំណេះដឹងថាព្រះគ្រីស្ទមានព្រះជន្មរស់ ថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះប្រោសលោះនៃពិភពលោកនេះ ។ មនុស្សគ្រប់រូបអាចមានការធានាអះអាងនេះ ហើយនៅពេលបុគ្គលម្នាក់ទទួលទីបន្ទាល់នេះ វានឹងកើតឡើងមកពីព្រះ ពុំមែនគ្រាន់តែការសិក្សាតែមួយមុខនោះទេ ។ ពិតណាស់ការសិក្សាគឺជាធាតុសំខាន់មួយ ប៉ុន្តែវាត្រូវតែរួមបញ្ចូលនឹងការសិក្សាការអធិស្ឋានយ៉ាងច្រើន និង ការព្យាយាម ហើយបន្ទាប់មកវិវរណៈនេះកើតមានឡើង ។ . . .

ការប្រជុំថ្លែងទីបន្ទាល់គឺជាការប្រជុំដ៏ល្អបំផុតនៅក្នុងវួដក្នុងមួយខែៗ ប្រសិនបើអ្នកមានព្រះវិញ្ញាណ ។ ប្រសិនបើអ្នកមានការធុញទ្រាន់នឹងការប្រជុំថ្លែងទីបន្ទាល់ នោះមានអ្វីមួយដែលខុសប្លែកជាមួយអ្នកហើយ ពុំមែនមកពីមនុស្សដទៃទេឡើយ ។ អ្នកអាចក្រោកឡើង ហើយថ្លែងទីបន្ទាល់របស់អ្នក ហើយអ្នកគិតថាវាជាការប្រជុំដ៏ល្អបំផុតនៅក្នុងខែនោះ ប៉ុន្តែប្រសិនបើអង្គុយនៅទីនោះ រាប់កំហុសនៃវេយ្យាករណ៍ ហើយសើចចំអកដល់អ្នកដែលនិយាយមិនបានល្អ នោះអ្នកនឹងពិតជាធុញទ្រាន់ហើយការធុញទ្រាន់នោះធ្វើឲ្យអ្នករអិលជើងចេញពីនរគរបស់ព្រះ ។ . . .

រាល់ខែគណៈប្រធានទីមួយ និង ពួកសាវក ដប់ពីនាក់ និង ពួកអ្នកមានសិទ្ធិអំណាចទូទៅទាំងអស់ជួបជុំគ្នានៅក្នុងព្រះវិហារបរិសុទ្ធ ។ ពួកគេថ្លែងទីបន្ទាល់ ហើយពួកគេប្រាប់គ្នាទៅវិញទៅមកពីរបៀបដែលពួកគេស្រឡាញ់គ្នាគឺដូចជាអ្នកគ្រប់គ្នាធ្វើដែរ ។ ហេតុអ្វីពួកអ្នកមានសិទ្ធិអំណាចទូទៅ ត្រូវការការប្រជុំថ្លែងទីបន្ទាល់ ? វាជាមូលហេតុដូចគ្នាថាអ្នកត្រូវការការប្រជុំថ្លែងទីបន្ទាល់ផងដែរ ។ តើអ្នកគិតថាអ្នកអាចមិនថ្លែងទីបន្ទាល់របស់អ្នកបី ប្រាំមួយ ប្រាំបួន និង ដប់ពីរខែ ហើយបន្តរក្សាតម្លៃដ៏ពោរពេញរបស់ទីបន្ទាល់នោះឬ ?

សមាជិកល្អមួយចំនួនភ័យខ្លាចយ៉ាងខ្លាំងក្នុងការថ្លែងទីបន្ទាល់ដដែលៗរហូតដល់ពួកគេព្យាយាមនិយាយអ្វីផ្សេងទៀតដែលមិនទាក់ទងនឹងដំណឹងល្អ ។ ចូរកុំបារម្ភពីការថ្លែងទីបន្ទាល់ដដែលនោះឡើយ ។ នៅពេលប្រធានសាសនាចក្រថ្លែងទីបន្ទាល់របស់លោក លោកមានប្រសាសន៍ « ខ្ញុំដឹងថា យ៉ូសែប ស្ម៊ីធ ត្រូវបានហៅដោយព្រះ ជាអ្នកតំណាងព្រះ ។ ខ្ញុំដឹងថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ » ។ អ្នកឃើញហើយថា វាគឺជាទីបន្ទាល់ដូចទៅនឹងទីបន្ទាល់ដែលអ្នកទាំងអស់គ្នាថ្លែងដែរ ។ នោះគឺជាទីបន្ទាល់ ។ . . .

ទីបន្ទាល់គឺពុំមែនជាដំបូន្មាន ទីបន្ទាល់ពុំមែនជាការបង្រៀនឡើយ ( គ្មាននរណាម្នាក់នៅទីនោះទូន្មានដល់មនុស្សទាំងអស់ឡើយ ) វាមិនដូចជាការធ្វើដំណើរមួយឡើយ ។ អ្នកនៅទីនោះថ្លែងទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នក ។ ប្រសិនបើអ្នកអាចថ្លែងទីបន្ទាល់របស់ខ្លួនក្នុងរយៈពេល ១ នាទី ឬ ២ ឬ ៤ នាទី ឬ រយៈពេលប៉ុណ្ណាដែលគេផ្តល់ឲ្យអ្នក នោះវាជាការណ៍ដ៏អស្ចារ្យ ។ យើងចង់ដឹងថាតើអ្នកមានអារម្មណ៍បែបណា ។ តើអ្នកពិតជាស្រឡាញ់ការងារឬទេ ? តើអ្នករីករាយក្នុងការងាររបស់អ្នកទេ ? តើអ្នកស្រឡាញ់ព្រះអម្ចាស់ទេ ? តើអ្នកសប្បាយចិត្តទេដែលអ្នកក្លាយជាសមាជិកសាសនាចក្រ ?

. . . ចូរកុំអង្គុយនៅក្នុងការប្រជុំតមអាហាររបស់អ្នក ហើយរារាំងខ្លួនអ្នកពីពរជ័យឡើយ ហើយនិយាយថា « ខ្ញុំគិតថា ខ្ញុំនឹងមិនថ្លែងទីបន្ទាល់ខ្ញុំទេថ្ងៃនេះ ។ ខ្ញុំគិតថាវាមិនយុត្តិធម៌ទេ ចំពោះសមាជិកដទៃទៀត ដោយសារខ្ញុំមានឱកាសច្រើនណាស់ដើម្បីថ្លែងទីបន្ទាល់ » ។ អ្នកថ្លែងទីបន្ទាល់របស់អ្នក ។ ហើយរយៈពេលមួយនាទីជាពេលវេលាគ្រប់គ្រាន់ដើម្បីថ្លែងទីបន្ទាល់ហើយ ។

អ្នកមានទីបន្ទាល់ ! ពិតណាស់ វាត្រូវការស្ថាបនា និង ការលើកស្ទួយ ព្រមទាំងការពង្រីកវា ហើយនោះជាអ្វីដែលអ្នកកំពុងធ្វើ ។ គ្រប់ពេលដែលអ្នកថ្លែងទីបន្ទាល់របស់ខ្លួន នោះវាកាន់តែរឹងមាំ ។ ■

*ដកស្រង់ចេញពី « President Kimball Speaks Out on Testimony »* New Era *ខែ សីហា ឆ្នាំ ១៩៨១ ៤–៧ capitalization standardized ។*

# ការយល់ដឹង



**តើយើងអាចទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ដែលព្រះវរបិតាសួគ៌ មានចំពោះកូនចៅរបស់ទ្រង់ទាំងអស់តាមរបៀបណា ?**

« ដើម្បីបម្រើមនុស្សដទៃឲ្យមានប្រសិទ្ធភាព យើងត្រូវមើលពួកគេតាមរយៈកែវភ្នែករបស់ឪពុក ឬ ម្ដាយម្នាក់ គឺតាមរយៈព្រះនេត្ររបស់ព្រះវរបិតាសួគ៌ ។ នៅពេលនោះហើយទើបយើងអាចចាប់ផ្ដើមយល់ពីតម្លៃដ៏ពិតនៃព្រលឹងមួយ ។ នៅពេលនោះហើយទើបយើងទទួលអារម្មណ៍ពីសេចក្ដីស្រឡាញ់ ដែលព្រះវរបិតាសួគ៌មានចំពោះកូនចៅរបស់ទ្រង់ទាំងអស់ ។ នៅពេលនោះហើយទើបយើងទទួលអារម្មណ៍ពីការព្រួយព្រះទ័យរបស់ព្រះអង្គសង្គ្រោះចំពោះពួកគេ ។ យើងមិនអាចបំពេញកាតព្វកិច្ចនៃសេចក្ដីសញ្ញារបស់យើង ដើម្បីទួញយំនឹងអ្នកណាដែលទួញយំ កម្សាន្តទុក្ខដល់អស់អ្នកណា ដែលកំពុងត្រូវការកម្សាន្តទុក្ខបានឡើយ ដរាបណាយើងមើលឃើញពួកគេ តាមរយៈព្រះនេត្ររបស់ព្រះ » ។

**អែលឌើរ ឌេល ជី រេនឡាន់** ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Through God's Eyes » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ទំព័រ ៩៤ ។

# មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ



### ជើងឯកនៃ ថ្ងៃឈប់សម្រាក

ទំព័រ ៥០

យើងត្រូវតែសម្រេចចិត្តរវាងការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ និងការព្យាយាមយកជ័យជំនះជាជើងឯកជម្រើសជាតិកីឡាបាល់ឱបលើគូប្រកួតរបស់យើង ។ នៅទីបំផុត យើងបានឈ្នះជាងអ្វីដែលយើងបានរំពឹងទុក ។

## សម្រាប់យុវវ័យ

### ផ្នែកដ៏លំបាកបំផុត នៃការធ្វើជា អ្នកផ្សព្វផ្សាយសាសនា

ទំព័រ ៥២

ការរៀបចំខ្លួនសម្រាប់បេសកកម្មគឺមានន័យលើសពីការគ្រាន់តែសិក្សាព្រះគម្ពីរទៅទៀត ។ វាក៏មានន័យថា ជាការរៀនពីរបៀបធ្វើការជាមួយដៃគូប្រឈមមុខនឹងការបដិសេធ ហើយដឹងថាវាមិនល្អឡើយ ដែលបរិភោគការ៉េមសម្រាប់ទាំងអាហារពេលព្រឹក ថ្ងៃត្រង់ និង ពេលល្ងាចនោះ ។



## សម្រាប់កុមារ



### ដៃគូសិក្សារបស់ យ៉័រដាន់

ទំព័រ ៦៨

យ៉័រដាន់ពេញចិត្តដែលបានធ្វើជាដៃគូសិក្សារបស់បងស្រីខ្លួនរយៈពេលពីរបីថ្ងៃ ។ ប៉ុន្តែតើគាត់បានធ្វើដូចម្ដេចនៅពេលបងស្រីរបស់គាត់ត្រឡប់ទៅបេសកកម្មវិញ ?

CAMBODIAN
4 02132 86258 5

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ